សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មិថុនា ឆ្នាំ ២០១៥

លីអាហូណា

ថ្ងៃដ៏រុងរឿងដែលត្រូវចងចាំ ទំព័រ ២៤

រៀបចំបង្រៀនអំពីព្រះអង្គសង្គ្រោះនៅគេហដ្ឋាន ទំព័រ ១០

ត្រូវបានដឹកនាំដោយព្រះអម្ចាស់ ៖ ផ្ទះទៅកាន់ប៉ាលម៉ៃរបស់យ៉ូសែប ទំព័រ ១៤

ការក្លាយជាសិស្សកាន់តែល្អប្រសើរ ៖ មេរៀនទាំងឡាយចេញពីគម្ពីរលូកា ទំព័រ ២៨

« ក្នុងពួកអ្នករាល់គ្នា មើកូនសុំនំប៉័ង តើមានអ្នកណានឹងឲ្យថ្មដល់វា ?
« ឬមើវាសុំត្រី តើនឹងឲ្យពស់វិញឬអី ?
« ចុះមើអ្នករាល់គ្នាដែលអាក្រក់ អ្នកចេះឲ្យរបស់ល្អដល់កូនខ្លួនដូច្នេះ នោះចំណង់មើព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅស្ថានសួគ៌ ទ្រង់នឹងប្រទានរបស់ល្អមកអស់អ្នកដែលសុំ តើជាងអម្បាលម៉ានទៅទៀត ? »

ម៉ាថាយ ៧:៩-១១

លីអាហូណា ខែ មិថុនា ឆ្នាំ ២០១៥

សារលិខិត

4 **សារលិខិតគណៈប្រធានទីមួយ: ក្រុមគ្រួសារអាចរស់នៅជាមួយគ្នាជានិរន្តរ៍**
ដោយ ប្រធាន ហិនរី ប៊ី អាវរិង

7 **សារលិខិតបង្រៀនសួរសុខទុក្ខ: លក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ—ប្រកបដោយគុណធម៌**

អត្ថបទពិសេសៗ

10 **របៀបដែលយើង « ផ្សាយអំពីព្រះគ្រីស្ទ » នៅក្នុងគេហដ្ឋានរបស់យើង**
ដោយ ដារិន អ៊ី ស្នីដច៍
គំនិតស្តីពីការបង្កើតគេហដ្ឋានមួយដែលកាន់តែផ្តោតលើព្រះគ្រីស្ទ ។

14 **ឆ្ពោះទៅកាន់ច័ាលម៉ែរ៉ា**
ដោយ ម៉ាថាយ អេស ហូឡិន
ឆ្ពោះទៅកាន់ច័ាលម៉ែរ៉ា—ជាកន្លែងនៃការនិមិត្តដំបូង និង ជាកន្លែងដែលផ្នាំងមាសត្រូវបានលាក់ទុក—ជាកន្លែងដ៏សុខសាន្តសម្រាប់យ៉ូសែប ស៊្មីធ និង ក្រុមគ្រួសារលោក ។

20 **ការស្វែងរកការសង្គ្រោះ**
ដោយ ខននី ហ្គលឌីង
ប្រសិនបើអ្នកមានអារម្មណ៍ថាត្រូវជាប់អន្ទាក់—ដោយការសាកល្បងផ្ទាល់ខ្លួន ភាពទន់ខ្សោយ ឬ ស្ថានភាពលំបាកនានា—នោះមានន័យថាសេចក្តីសង្ឃឹមនៃការសង្គ្រោះ ។

24 **ថ្ងៃដ៏រុងរឿងនៃការស្តារឡើងវិញនៃបព្វជិតភាព**
ដោយ អែលឌើរ អិល ថម ភែរី
យើងមានអំណរគុណខ្លាំងណាស់ ដែលព្រះអម្ចាស់បានស្តារឡើងវិញនូវសាសនាចក្រ និង បព្វជិតភាពរបស់ទ្រង់មកដល់ផែនដីនេះ ។

28 **ការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីភាពជាសិស្ស**
ដោយ ខេសឺ ដាប់ប៊ីលយូ អូលសិន
ព្រឹត្តិការណ៍ទាំងបួនពីការយាងធ្វើដំណើរចុងក្រោយរបស់ព្រះគ្រីស្ទទៅកាន់ក្រុងយេរូសាឡិម បង្រៀនយើងពីរបៀបធ្វើជាសិស្សឲ្យកាន់តែប្រសើរឡើង ។

34 **អ្នកនេសាទមនុស្ស**
ដោយ អែលឌើរ ស្តត់ ឌី រីតធីង
សម្រាប់ប្តូដមួយ ក្រុមប្រឹក្សាប្តូដមួយដែលមានដំណើរការយ៉ាងត្រឹមត្រូវ ធ្វើឲ្យគ្រប់ការណ៍ទាំងអស់ផ្លាស់ប្តូរ ។

ផ្នែកទាំងឡាយ

8 **ការបម្រើនៅក្នុងសាសនាចក្រ: មេរៀនរបស់ខ្ញុំស្តីពីសេចក្តីស្រឡាញ់**
ដោយ ជេនីស ចេត

9 **ការចាំងត្រឡប់: ការសង្គ្រោះសត្វបក្សី**
ដោយ វីលាម ហូកហ្គាន

38 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាយើងជួបទៀត: ទុកវាចោលមួយឡែកទៅ**
ដោយ ប្រធាន ឌីយដ៏ ឃេ ជាកគី

នៅលើគ្របមុខ
ខាងមុខ ៖ រូបថតដោយ ឡេសលី និលសុន ។ ខាងក្នុងគ្របមុខ ៖ រូបថតដោយ RidvanCelik/iStock/Thinkstock ។ ខាងក្នុងគ្របខាងក្រោយ ៖ រូបថតដោយ ឌូឌី ប៊ែល ។

យុវមជ្ឈិមវ័យ

46

42 **ការទុកចិត្តលើការអះអាងទាំងឡាយរបស់ព្រះអម្ចាស់**
ដោយ អេមី ជេន ឡឺរិត
ជាជាងការរំដោះភ្លាមៗ ព្រះអម្ចាស់អាចនឹងប្រទានពរយើងជាមួយនឹងគ្រានៃការអះអាងទាំងឡាយដែលមិនអាចកាត់ថ្លៃបាន ក្នុងអំឡុងនៃការសាកល្បងរបស់យើង ។

46 **គ្មានការប្តូរតំបន់ទេ**
ដោយ ស៊ីនយៅ ធូ
ខ្ញុំមិនជឿត្រចៀកខ្ញុំទេ ពេលខ្ញុំបានឮថា ខ្ញុំត្រូវបានចាត់ឲ្យនៅតំបន់ដដែលនេះប្រាំមួយសប្តាហ៍ទៀត ។

យុវវ័យ

48 **ការរស់នៅក្នុងពិភពលោកដែលពោពេញដោយការឆ្លាស់ប្តូរ**
ដោយ ប្រធាន ឌៀថើរ អេស្ក អុជដូហ្វ
ធ្វើឲ្យជីវិតអ្នកសាមញ្ញ ដោយការផ្តោតលើទំនាក់ទំនងទាំងបួននេះ ។

52 **ទីកន្លែងរបស់យើង**

54 **ការចែកចាយដំណឹងល្អដូចជាយ៉ូហាន បាទីស្ទ**
ដោយ រ៉ាយអិន ខារ

56 **ប៉ុន្តែ ចុះបើ . . . ? សំណួរអំពីការបម្រើបេសកកម្ម**
រសាប់រសល់ចង់ដឹងថាអ្នករៀបចំរួចរាល់ដើម្បីបម្រើបេសកកម្មហើយឬនៅ ? សំណួរ និងចម្លើយដែលត្រូវបានសួរឆ្លើយជាញឹកញាប់ទាំងនេះអាចមានអត្ថប្រយោជន៍ ?

60 **សំណួរ និង ចម្លើយទាំងឡាយ**
មិត្តម្នាក់របស់ខ្ញុំចង់សាកល្បងអ្វីដែលមិនល្អគ្រាន់តែម្តងប៉ុណ្ណោះ ដើម្បីនាងអាចយល់ពីរឿងនោះ ពេលមនុស្សនិយាយពីវា ។ តើខ្ញុំអាចជួយនាងយ៉ាងដូចម្តេច ដើម្បីឲ្យនាងយល់ថា វាមិនមែនជាគំនិតល្អទេ ?

62 **ល្បែងផ្គុំរូបពេលសិក្សាព្រះគម្ពីរ**
ដោយ ខូឌី ហ្វីលីព
ជាមួយនឹងល្បែងផ្គុំរូប និង ការសិក្សាព្រះគម្ពីរ អ្នកកាន់តែខំធ្វើវាយ៉ាងណា អ្នកអាចឃើញរូបភាពកាន់តែធំយ៉ាងនោះដែរ ។

65 **បងប្អូនស្រីក្នុងដំណឹងល្អ**
ដោយ ផៅឡា សាវ៉ាហ្គី ហើនឌិនដេហ្ស ឃ្លូស
មិត្តរបស់ផៅឡាមានភាពឯកា ដូច្នេះ ផៅឡាចង់ចែកចាយពរជ័យនៃដំណឹងល្អជាមួយនាង ។

កុមារ

72

66 **សាក្សីពិសេស៖ តើខ្ញុំអាចទទួលការដឹកនាំពីព្រះវិញ្ញាណយ៉ាងដូចម្តេច ?**
ដោយ អែលឌើរ អិល ថម គែរី

67 **តន្ត្រី៖ ព្រះវិញ្ញាណបរិសុទ្ធ**
ដោយ ជេនី ភី ឡយី

68 **ពេលវេលាសម្រាប់ព្រះគម្ពីរ៖ អ្នកតង្វាលល្អ**
ដោយ អេរិន ស៊ែនឌើរសិន

70 **ទំព័ររបស់យើង**

71 **តួអង្គទាំងឡាយក្នុងព្រះគម្ពីរសញ្ញាថ្មី៖ អ្នកតង្វាលល្អ**

72 **ថ្ងៃបុណ្យអនាគតឪពុកលើកទីមួយរបស់ស្ទ្រីន**
ដោយ ឃេលី ចច ភូសឺល
ម្តាយរបស់ស្ទ្រីនបានមានគំនិតមួយ ដើម្បីជួយគាត់កុំឲ្យសោកសៅនៅថ្ងៃបុណ្យឪពុក ។

74 **ទីបន្ទាល់របស់ម៉ែ**
ដោយ អាមេលា ហាឃិន
ម៉ែចង់មានទីបន្ទាល់មួយ ប៉ុន្តែតើនាងអាចទទួលបានវាដោយរបៀបណា ?

76 **សម្រាប់កុមារតូចៗ៖ គេហស្ថានដែលដង្វាយមួយភាគក្នុងដប់ត្រូវបានស្ថាបនាឡើង**
ដោយ ចានែល វិលាម

ចាំមើលថា តើអ្នកអាចរកឃើញរូបលើអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ គន្លឹះ ៖ ក្រៅពីឡាន តើអ្វីដែលអ្នកអាចបើកបរបាន ?

48

ខែ មិថុនា ឆ្នាំ ២០១៤ រ៉ែល ១៤ លេខ ៣
លីអាហូណា ១២៥៦ ២៤៨
ទស្សនាវដ្តីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
គណៈប្រធានទីមួយ ៖ ចូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេស្. អុជដូហ្វ
ក្លុំមនៃពួកសាវកដប់ពីរនាក់ ៖ ឱយដ៍ ខេ. ធាកគឺ, អិល. ថម ក្រៃ, រ៉ាសុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ៉ាសុល បាឡឺដ, រ៉ឺឆាដ ជី. ស្កុត, រ៉ូប៊ឺត ឌី. ហ៊ែល, ដែហ្វ្រី អ៊ី. ហ្គូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. ត្រីស្ទូហ្វ៊ីសិន, នែល អិល. អាន់ឌើរសិន
អ្នកតែសម្រួល ៖ ក្រេក អេ. ខាវដុន
អ្នកប្រឹក្សា ៖ សមើវ័ន ប៊ី អាណុល, ឡារ៉ី អ័រ ឡ៊ីរ៉ាន, ដេមស៍ ប៊ី ម៉ាទីណូ, យ៉ូសែប ដបុលយូ ស៊ីតាទី ត្រីស្ទូហ្វែល ហ្គូលឌិន
នាយកគ្រប់គ្រង ៖ ដេវីឌ ជី. រ៉ែនឺ
នាយកគរិះគ្រួសារ និង សមាជិក ៖ វ៊ែនសេនត៍ អេ. វ៉ែញ
នាយកទស្សនាវដ្តីសាសនាចក្រ ៖ អាលែន អ៊ែរ. ឡយបិច
អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖ ហ្គាស្ទូ ខាណុន
អ្នកគ្រប់គ្រងផ្នែកតែសម្រួល ៖ អ៊ែ. ភីល ចនសុន
ជំនួយការអ្នកគ្រប់គ្រងផ្នែកតែសម្រួល ៖ ឡៃអិន ខាវ
ជំនួយការផ្នែកចោះពុម្ព ៖ លីស្សា ស៊ី ឡូម៉ែស្ស
និពន្ធ និងតែសម្រួល ៖ ប្រ៊ីតចាន ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. ឡៃដវ័ដ, ម៉ាថាយ ឌី. ហ្វលីតកូន, ឡូរ៉ា ហ្គូលឡើរ ហ្គ្លៅ អេច. ហ្គាហ្វ, ឡូរិនេ ធតធើ ហ្គូន, មីនឌី អាន់ ឡេវ៉ែក ម៉ៃឃើល អ៊ែ. ម៉ឺរ៉ែស, សាលី ចនសុន អ្នឌេឃីក, យ៉ូស្វេ ដេ ភីគី, ដេន ភីនប៊ូរ៉ាហ្វ, រ៉ាដាជ អិម. ប៉ម៉ឺ, ប៊ុល ប៊ឺនឌិនប៊ើជ, ម៉ាស្សា វ៊ីឌីសុន
នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖ ដេ. ស្កុត ឌួដសិន
នាយកផ្នែកសិល្បៈ ៖ ចាត អ៊ែ. ភីធើរសុន
រចនាម៉ូត ៖ ជីនិត អាន់ន្រូ, ហ្វេ ភី. អាន់ត្រូស, មែនឌី អ៊ែម. ប៊ែនលី, ស៊ឺ. ឃីមម៊ែល បុត, ចូម៉ាស ឆាល, ណាត ហ៊ូនេស, ឌូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស៊ូសាន ឡ ហ្គ្រីន, ស្កុត អិម. ម៊ូយ, ម៉ាក ដបុលយូ. រ៉ូប៊ឺសុន, ប្រាត ផ្សៀ, ឃេ. ឌីកូល រ៉កឃិនហ៊ូស
អ្នកតែសម្រួលកម្មសិទ្ធបញ្ញា ៖ ឌូលែត នែមេឃើ អាន
អ្នកគ្រប់គ្រងផ្នែកជលិតកម្ម ៖ ជេន អាន ភិធើរស៍
ជលិតកម្ម ៖ ខនធី ប៊ីត្រូម ប្រ៊ីជ, ជូលី ប៊ើដែត, កាធ៊ ដន់ខេន, ប្រាយ់អែន ដបុលយូ. ជីគី, ដេនីស តើម៉ៃ, ជីន្នី ហ៊ូនធ៍ ដេ. នីលសុន, ហ្គេលី ចេត វ៉ាហ៊ូធ
អ្នកពិនិត្យមុនការចោះពុម្ព ៖ ដេហ្វ អិល. ម៉ាទីន
នាយកផ្នែកចោះពុម្ព ៖ ក្រេហ្គ ខេ. សៃតវ័ត
នាយកផ្នែកចែកចាយ ៖ ស្តេហ្វិន អ៊ែ ត្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

លីអាហូណា (ពាក្យក្នុងព្រះគម្ពីរមានមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ ») ត្រូវបានចោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ឺស្ការមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន (ងាយស្រួល), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បាភាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អាយឡែនឌិក, តណ្ហ៊ូនេសី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាសី, ម៉ាល្លែយ, ម៉ុងហ្គោលី,នរវ៉ែ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លាវ៉ែនី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយគ្រែន, អ៊ឺឌូ និង វៀតណាម ។ (ការចេញញឹកញាប់ប៉ុន៎ណា គឺប្រែប្រួលទៅតាមភាសា) ។

© 2015 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ ចោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារៈដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចចតចម្លងយកទៅប្រើប្រាស់ជាមគ្គុទ្ទេសក៍ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារៈដែលមើលឃើញ មិនអាចចតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

For Readers in the United States and Canada:
June 2015 Vol. 14 No. 3. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store .lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ នៅខាងក្រោមជាគំនិតចំនួនពីរ ។

« ថ្ងៃដ៏រុងរឿងនៃការស្តារឡើងវិញនៃបព្វជិតភាព » ទំព័រ ២៤ ៖ សូមពិចារណាក្នុងការពន្យល់ពីរបៀបដែលបព្វជិតភាពត្រូវបានប្រគល់បន្ត ដោយគូរបន្ទាត់សាមញ្ញមួយចេញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយចាប់ផ្តើមពីលោកអ័ដាម ហើយបន្តទៅព្យាការីទាំងឡាយក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយបន្ទាប់មកចាប់ពីព្រះយេស៊ូវគ្រីស្ទ និង ពួកសាវករបស់ទ្រង់ទៅដល់យ៉ូសែប ស្ម៊ីធ ។ អ្នកអាចព្យាយាមទន្ទេញពាក្យទាំងឡាយ ដែលយ៉ូហាន បាទីស្ទ បានមានប្រសាសន៍នៅពេលប្រគល់បព្វជិតភាពអ៊ើរ៉ុនទៅដល់យ៉ូសែប ស្ម៊ីធ និង អូលីវ៉ើ ខៅឌ៊ើ ដូចមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣:១ ហើយពិភាក្សាពីភាពសំខាន់នៃព្រឹត្តិការណ៍នោះ ។

« ទីបន្ទាល់របស់ម៉ែ » ទំព័រ ៧៤ ៖ បន្ទាប់ពីអានអត្ថបទជាមួយគ្នារួចហើយ អ្នកអាចពិភាក្សាពី « របៀប » ដើម្បីទទួលបានទីបន្ទាល់មួយ ៖ អធិស្ឋាន អានព្រះគម្ពីរ ស្តាប់ពួកព្យាការី និង សាវក ស្តាប់ទីបន្ទាល់របស់អ្នកផ្សេងទៀត ថ្លែងទីបន្ទាល់ផ្ទាល់ខ្លួន ជាដើម ។ សូមនិយាយអំពីរបៀបដែលទីបន្ទាល់អាចដូចជាពន្លឺ ។ បន្ទាប់មក ឪពុកម្តាយអាចថ្លែងទីបន្ទាល់របស់ពួកគាត់ ហើយអញ្ជើញកូន។ឲ្យចែកចាយទីបន្ទាល់ ឬ អារម្មណ៍របស់ពួកគេ បើពួកគេចង់ ។

ជាភាសារបស់អ្នក

លីអាហូណា និងធនធានផ្សេងទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org** ។

ប្រធានបទទាំងឡាយក្នុងច្បាប់នេះ
លេខទាំងឡាយគឺតំណាងឲ្យទំព័រមួយនៃអត្ថបទនោះ ។

ការងារ, *៣៩, ៥២*
ការចាត់ចែង/ការបម្រើ, *៩, ២៨, ៣៤*
ការធ្វើឲ្យសកម្ម, *៩*
ការបង្រៀន, *១០*
ការបម្រើ, *៨, ២៤, ៣៤, ៤១, ៤៨*
ការព្រៃចិត្ត, *៥៦*
ការមិនគិតពីខ្លួនឯង, *២៨*
ការយាងមកជាលើកទីពីរ, *៥៤*
ការសង្គ្រោះ, *៩, ២០*
ការសាកល្បង, *២០, ៤២, ៥២*
ការស្តារឡើងវិញ, *១៤, ២៤*
ការអធិស្ឋាន, *១០, ៧៤*
ការអភ័យទោស, *៨០*
កិច្ចការផ្សព្វផ្សាយសាសនា, *៥៤, ៦៥*
កិច្ចការព្រះវិហារបរិសុទ្ធ, *៤, ៦, ៧០*
ក្រុមគ្រួសារ, *៤, ១០, ៤៨, ៧២*
ក្រុមប្រឹក្សាភូរិ, *៣៤*
គុណធម៌, *៧*
ជង្វាយធួន, *២០, ៤២*
ជង្វាយមួយភាគក្នុងដប់, *៧៦*
តន្ត្រី, *៨, ៥៣, ៦៧*
ទីបន្ទាល់, *៥៦, ៧៤*
បព្វជិតភាព, *៤, ២៤*
បេសកកម្ម, *៤០, ៤២, ៤៦, ៥៤, ៥៦*
ពង្សប្រវត្តិ, *៤*
ពិធីមុណ្យត្រមុជទឹក, *៦៥, ៧០*
ព្រះគម្ពីរ, *៦២, ៦៨, ៧១*
ព្រះគម្ពីរមរមន, *១០*
ព្រះយេស៊ូវគ្រីស្ទ, *៧, ១០, ២០, ២៨, ៤២, ៤៨, ៥៤, ៦៦*
ព្រះវរបិតាសួគ៌, *៤៨*
ព្រះវិញ្ញាណបរិសុទ្ធ, *៦២, ៦៦, ៦៧, ៧៤*
ភាពជាសិស្ស, *២៨*
ភាពជាអ្នកដឹកនាំ, *៣៤, ៤៦, ៨០*
ភាពអត់ធ្មត់, *៣៨*
សេចក្តីសង្ឃឹម, *៤២*
សេចក្តីស្រឡាញ់, *៨, ៤០*
ស្ម៊ីធ, យ៉ូសែប, *១៤*
ឪពុកទាំងឡាយ, *៧២*

ដោយ ប្រធាន ហិនរ៍ ប៊ី អារ៉ីង
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

ក្រុមគ្រួសារអាចរស់នៅជាមួយគ្នា

ជានិរន្តរ៍

អំណោយទានមួយក្នុងចំណោមអំណោយទានដ៏មហិមាបំផុតនានារបស់ព្រះ ។ មនុស្សគ្រប់គ្នាដែលយល់ពីផែនការនៃសេចក្តីសង្គ្រោះ ចង់បានយ៉ាងខ្លាំងនូវពរជ័យដ៏និរន្តរ៍នោះ ។ មានតែនៅក្នុងពិធីផ្សារភ្ជាប់ ដែលធ្វើឡើងក្នុងព្រះវិហារបរិសុទ្ធដែលបានឧទ្ទិសហើយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយប៉ុណ្ណោះ ទើបព្រះប្រទាននូវការសន្យាថា ក្រុមគ្រួសារអាចត្រូវបានចងភ្ជាប់ជាមួយគ្នាជានិរន្តរ៍ ។

កូនសោបព្វជិតភាពដែលធ្វើឲ្យការណ៍នោះអាចកើតឡើងបាន ត្រូវបានស្តារឡើងវិញដល់ផែនដី ដោយព្យាការី អេលីយ៉ា ដល់ យ៉ូសែប ស្ម៊ីធ នៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ។ កូនសោបព្វជិតភាពទាំងនោះ ត្រូវបានប្រគល់បន្តមកតាមខ្សែបន្ទាត់ដ៏តតាំងមួយ តាមរយៈពួកព្យាការីនៅរស់ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ រហូតដល់ថ្ងៃបច្ចុប្បន្ន ។

ក្នុងការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលទៅកាន់ពេត្រុស ជាប្រធានសាវ័ករបស់ទ្រង់ អំពីអំណាចនៃការផ្សារភ្ជាប់ក្រុមគ្រួសារ ទ្រង់បានមានបន្ទូលថា « ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើស្រាយអ្វីៗនៅផែនដី នោះក៏នឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ » (ម៉ាថាយ ១៨:១៨) ។

មានតែនៅក្នុងនគរសេឡេស្ទាលប៉ុណ្ណោះ ទើបយើងអាចរស់នៅជាក្រុមគ្រួសារជានិរន្តរ៍ ។ នៅទីនោះ យើងអាចនៅជាក្រុមគ្រួសារក្នុងវត្តមាននៃព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះរបស់យើង ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានពិពណ៌នាពីបទពិសោធន៍ដ៏ប្រពៃនោះនៅក្នុងគោលលទ្ធិ និង សេចក្តីសញ្ញា តាមរបៀបនេះថា ៖

« កាលព្រះអង្គសង្គ្រោះទ្រង់លេចមក នោះយើងនឹងឃើញទ្រង់ដូចជាទ្រង់យ៉ាងនេះឯង ។ យើងនឹងឃើញថា ព្រះអង្គជាមនុស្សដូចរូបយើងរាល់គ្នា ។

« ហើយទំនាក់ទំនងដែលមាននៅក្នុងចំណោមពួកយើងនៅទីនេះយ៉ាងណា នោះក៏នឹងមាននៅក្នុងចំណោមយើងនៅទីនោះយ៉ាងនោះដែរ គ្រាន់តែរួមបញ្ចូលដោយសិរីល្អដ៏នៅអស់កល្បជានិច្ច គឺជាសិរីល្អដែលយើងពុំមានការពិសោធន៍នៅពេលឥឡូវនេះប៉ុណ្ណោះ ។ » (គ. និង ស. ១៣០:១–២) ។

បទគម្ពីរនេះប្រាប់ថា យើងអាចសម្រេចបានដោយមានទំនុកចិត្តនូវបទដ្ឋានស្ថានសួគ៌នៅក្នុងទំនាក់ទំនងក្នុងក្រុមគ្រួសាររបស់យើង ។ យើងអាចខ្វល់ខ្វាយពីសមាជិកគ្រួសារយើង ទាំងនៅរស់ និង ស្លាប់ទៅហើយ ខ្លាំងរហូតដល់ធ្វើអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន ដើម្បីផ្តល់ដល់ពួកគេនូវពិធីបរិសុទ្ធនៃបព្វជិតភាព ដែលនឹងចងភ្ជាប់យើងនៅស្ថានសួគ៌ ។

អ្នករាល់គ្នាជាច្រើន ទាំងក្មេង ទាំងចាស់ កំពុងតែធ្វើការណ៍នោះ ។ អ្នកបានរកមើលឈ្មោះរបស់បុព្វការីជនដែលពុំទាន់បានទទួលពិធីបរិសុទ្ធដែលអាចផ្សារភ្ជាប់អ្នកជាមួយគ្នា ។

អ្នកទាំងអស់គ្នាស្ទើរតែទាំងអស់ មានសាច់ញាតិដែលនៅរស់ដែលពុំទាន់បានផ្សារភ្ជាប់ក្នុងក្រុមគ្រួសារដោយអំណាចបព្វជិតភាព ។ មនុស្សជាច្រើនមានសាច់ញាតិដែលនៅរស់ដែលបានទទួលពិធីបរិសុទ្ធនៃបព្វជិតភាពហើយ ប៉ុន្តែពុំរក្សាសេចក្តីសញ្ញាដែលពួកគេបានធ្វើនឹងព្រះ ។ ព្រះនឹងប្រទានពរអ្នក ថាអ្នកនឹងអាចឈោងជួយដល់សាច់ញាតិទាំងអស់នោះ នៅក្នុងសេចក្តីជំនឿ ។ អ្នកមាននូវការសន្យាមួយ ដែលព្រះអម្ចាស់សន្យាដល់ពួកសិស្សទ្រង់ដែលនាំអ្នកផ្សេងទៀតមករកទ្រង់ ៖

« ហើយអស់អ្នកណាដែលទទួលអ្នក នោះយើងក៏នឹងនៅទីនោះដែរ ដ្បិតយើងនឹងទៅពីមុខអ្នក ។ យើងនឹងនៅខាងស្តាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួក



ទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នក ដើម្បីទ្រអ្នកឡើង » (គ. និង ស. ៨៤:៨៨) ។

ពីបង្អួចបន្ទប់ការិយាល័យរបស់ខ្ញុំ ខ្ញុំមើលឃើញកូនក្រមុំ និង កូនកំឡោះទាំងឡាយជារៀងរាល់ថ្ងៃ ថតរូបជាមួយផ្កាដ៏ស្រស់ស្អាត និង ទឹកដែលបាញ់ឡើង ។ ជាញឹកញាប់ កូនកំឡោះបីកូនក្រមុំក្នុងដៃគាត់ យ៉ាងហោចណាស់ក៏ដើរពីរបីជំហានដែរ ពេលដែលជាងថតរូបអាពាហ៍ពិពាហ៍ ។ រាល់ពេលខ្ញុំឃើញបែបនោះ ខ្ញុំនឹកឃើញពីគូស្វាមីភរិយាមួយគូដែលខ្ញុំបានស្គាល់ ដែលត្រូវតែបីត្រកងគ្នាទៅវិញទៅមកក្នុងរបៀបផ្សេងទៀត ពេលជីវិតជួបការលំបាក — ជួនកាល គឺនៅមិនយូរប៉ុន្មានសោះពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ។ ការងារអាចបាត់បង់ ។ កូនៗអាចកើតមកជាមួយនឹងឧបសគ្គយ៉ាងធំ ។ អាចកើតមានជំងឺ ។ បន្ទាប់មក ទម្លាប់នៃការប្រព្រឹត្តចំពោះអ្នកដទៃ ដូចដែលយើងចង់ឲ្យគេប្រព្រឹត្តចំពោះយើង — វាងាយស្រួលនឹងធ្វើដូច្នោះ — នឹងធ្វើឲ្យយើងក្លាយជាវីរបុរស និង វីរនារីក្នុងអំឡុងពេលដ៏លំបាកទាំងនោះ ដែលការប្រព្រឹត្តល្អចំពោះអ្នកដទៃតម្រូវឲ្យមានការខិតខំខ្លាំងជាងដែលយើងគិតថាយើងមានក្នុងខ្លួនយើង ។

យើងជំពាក់ក្រុមគ្រួសារយើងនូវទំនាក់ទំនងបែបនោះ ជាទំនាក់ទំនងដែលយើងអាចយកទៅក្នុងវត្តមាននៃព្រះ ។ យើងត្រូវតែព្យាយាម កុំធ្វើឲ្យមានការអាក់អន់ចិត្ត ឬ កុំអាក់អន់ចិត្ត ។ យើងអាចប្តេជ្ញាអត់ទោសឆាប់ៗ និង ទាំងស្រុង ។ យើងអាចព្យាយាមស្វែងរកសុភមង្គលរបស់អ្នកដទៃពីមុនសុភមង្គលផ្ទាល់ខ្លួនយើង ។ យើងអាចមានចិត្តល្អក្នុងការនិយាយរបស់យើង ។ នៅពេលយើងព្យាយាមធ្វើការណ៍ទាំងអស់នេះ យើងនឹងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យចូលក្នុងក្រុមគ្រួសារ និង ជីវិតរបស់យើង ។

ការអះអាងរបស់ខ្ញុំចំពោះអ្នកគឺថា ដោយមានជំនួយពីព្រះអម្ចាស់ និង ដួងចិត្តដែលមានការកែប្រែនោះយើងអាចស្រមៃឃើញពីជីវិតបែបនេះ ជាជីវិតដែលយើងចង់បានជារៀងរហូត ។ ព្រះវរបិតាសួគ៌ស្រឡាញ់យើង ។ ទ្រង់ចង់ឲ្យយើងត្រឡប់ទៅនៅជាមួយទ្រង់វិញ ។ តាមរយៈដង្វាយធួនរបស់ទ្រង់ ព្រះអង្គសង្គ្រោះធ្វើឲ្យមានឡើងនូវការផ្លាស់ប្តូរក្នុងដួងចិត្តយើង ជាការផ្លាស់ប្តូរដែលយើងត្រូវការធ្វើដើម្បីបានចូលក្នុងព្រះវិហារបរិសុទ្ធ ធ្វើសេចក្តីសញ្ញាដែលយើងអាចរក្សាបានក្រោយពីនោះ ហើយនៅទីបំផុត បានរស់នៅជាក្រុមគ្រួសារជានិរន្តរ៍ក្នុងសិរីល្អសេឡេស្ទាល — ជាគេហដ្ឋាននោះម្តងទៀត ។ ■

ការបង្រៀនចេញពីសារលិខិតនេះ

កាលណាអ្នកចែកចាយគោលលទ្ធិអំពីក្រុមគ្រួសារដ៏អស់កល្បជានិច្ច នោះសូមពិចារណាពីអ្វីដែលអែលឌើរ រីឆាដ ជី ស្កត ក្នុងក្លឹមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ ៖ « ចូរព្យាយាមពង្រឹងក្រុមគ្រួសារជានិច្ច ។ ចូរបង្រៀនដោយមានទស្សនវិស័យមួយអំពីសេចក្តីសំខាន់នៃក្រុមគ្រួសារដែលបានផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ។ . . . ពេលអ្នកមានទស្សនវិស័យមួយអំពីពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ នោះអ្នកនឹងជួយស្ថាបនាន្តរនៃព្រះនៅលើផែនដីនេះ » (“I Have Given You an Example,” *លីអាហូណា ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៣៤*) ។ តើអ្នកអាចជួយដល់ពួកអ្នកដែលអ្នកបង្រៀន បង្កើតនូវទស្សនវិស័យមួយអំពីភាពសំខាន់នៃការផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធដោយរបៀបណា ? សូមអញ្ជើញពួកអ្នកដែលពុំទាន់បានផ្សារភ្ជាប់ ឲ្យពិភាក្សាជំហានទាំងឡាយដែលពួកគេត្រូវធ្វើដើម្បីបានទទួលពិធីបរិសុទ្ធនោះ ។ សូមអញ្ជើញពួកអ្នកដែលបានផ្សារភ្ជាប់ហើយ ឲ្យពិភាក្សាពីរបៀបដែលពួកគេអាចរក្សាបាននូវទស្សនវិស័យអំពីក្រុមគ្រួសារដ៏អស់កល្បជានិច្ចរបស់ពួកគេ ហើយខិតខំធ្វើឲ្យទំនាក់ទំនងរបស់ពួកគេកាន់តែប្រសើរឡើង ។

ត្រូវបានភ្ជាប់ជាមួយក្រុមគ្រួសាររបស់ខ្ញុំអស់កល្បជានិច្ច

ដោយ ឡូរ៉ា ប៊ីតចុន

ពេលខ្ញុំត្រូវបានយកមកចិញ្ចឹមនៅអាយុបីឆ្នាំ ម្តាយបង្កើតរបស់ខ្ញុំបានអនុញ្ញាតឲ្យការចិញ្ចឹមនោះសម្រេចបាន លើកលែងតែឪពុកម្តាយខ្ញុំយល់ព្រមឲ្យខ្ញុំទទួលពិធីបរិសុទ្ធទាំងឡាយនៃសាសនាចក្របន្ទាប់ពីខ្ញុំចូលដល់អាយុ ១២ ឆ្នាំ ហើយប៉ុណ្ណោះ ។ គាត់បានគិតថា ខ្ញុំត្រូវតែមានអាយុធំល្មមដើម្បីធ្វើការសម្រេចចិត្តសម្រាប់ខ្លួនឯងសិនប៉ុន្តែ ភាពិបាកនឹងចាំណាស់ ។

មែនហើយ ភាពិបាកដែលឃើញមិត្តភក្តិខ្ញុំជាច្រើនទទួលបុណ្យជ្រមុជទឹកនៅពេលពួកគេមានអាយុប្រាំបីឆ្នាំ ប៉ុន្តែអ្វីដែលពិបាកជាងនោះទៅទៀតគឺការដឹងថា ខ្ញុំពុំអាចផ្សារភ្ជាប់ជាមួយឪពុកម្តាយចិញ្ចឹម និង បងៗចិញ្ចឹមប្រាំនាក់របស់ខ្ញុំបាន ទាល់តែខ្ញុំមានអាយុ ១២ ឆ្នាំ ។ ខ្ញុំខ្លាចថា បើមានអ្វីកើតឡើងចំពោះខ្ញុំ នោះខ្ញុំនឹងពុំអាចផ្សារភ្ជាប់ជាមួយនឹងពួកគាត់បាន ។

កាលដែលខ្ញុំជិតចូលដល់អាយុ ១២ ឆ្នាំ នោះយើងបានចាប់ផ្តើមដាក់ផែនការសម្រាប់បុណ្យជ្រមុជទឹក និង ការផ្សារភ្ជាប់ជាមួយក្រុមគ្រួសារខ្ញុំ ។ ឪពុកម្តាយខ្ញុំបានអនុញ្ញាតឲ្យខ្ញុំជ្រើសរើសព្រះវិហារបរិសុទ្ធដែលយើងនឹងទៅផ្សារភ្ជាប់ ។ ខ្ញុំតែងតែគិតថា ព្រះវិហារបរិសុទ្ធ សាន់ឌីអាហ្គូ កាលីហ្វ័រ្ញ៉ា ជាព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតបំផុត ដូច្នេះក្រុមគ្រួសារខ្ញុំទាំងមូលបានយល់ស្របបើកឡានទៅកាលីហ្វ័រ្ញ៉ា សម្រាប់ការផ្សារភ្ជាប់ ។

ខ្ញុំពុំអាចរង់ចាំដើម្បីក្លាយជាក្រុមគ្រួសារដ៏អស់កល្បជានិច្ចជាមួយនឹងឪពុកម្តាយ និង បងៗខ្ញុំនោះទេ ។ អំឡុងពេលនៃការផ្សារភ្ជាប់របស់ខ្ញុំ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងខ្លាំង ដែលពិបាកនឹងពន្យល់ ។ តឡូវនេះ ដោយខ្ញុំបានផ្សារភ្ជាប់ជាមួយនឹងក្រុមគ្រួសារខ្ញុំនៅទីបំផុត នោះអារម្មណ៍ជ្រួយបារម្ភដែលខ្ញុំបានមាន ត្រូវបានជំនួសដោយការលួងលោម និង អារម្មណ៍សុខសាន្ត ដោយដឹងថា តឡូវនេះ ខ្ញុំត្រូវបានភ្ជាប់នឹងពួកគាត់អស់កល្បជានិច្ច ។

អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។

ការសំឡឹងទៅឯព្រះវិហារបរិសុទ្ធ

ប្រធាន អាវរិង ពន្យល់ថា ដោយសារអំណាចបព្វជិតភាព នោះយើងមានឱកាសដើម្បីទៅព្រះវិហារបរិសុទ្ធដើម្បីផ្សារភ្ជាប់ជាមួយនឹងក្រុមគ្រួសាររបស់យើងសម្រាប់ភាពអស់កល្បជានិច្ច ។ សូមគូរ ឬ ស្វែងរករូបភាពនៃព្រះវិហារបរិសុទ្ធដែលអ្នកចូលចិត្ត ហើយដាក់វានៅកន្លែងដែលអ្នកអាចមើលឃើញជារៀងរាល់ថ្ងៃ ។ សូមធ្វើបញ្ជីមួយអំពីរបៀបដែលអ្នកនឹងរៀបចំខ្លួនដើម្បីទៅកាន់ព្រះវិហារបរិសុទ្ធនៅថ្ងៃណាមួយ ។

សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន ហើយព្យាយាមដើម្បីដឹងថាត្រូវចែកចាយអ្វីខ្លះ ។ តើការយល់ពីលក្ខណៈសម្បត្តិដ៏ទេវភាពរបស់ព្រះអង្គសង្គ្រោះ នឹងពង្រីកជំនឿរបស់អ្នកចំពោះទ្រង់ ហើយនិងផ្តល់ពរជ័យដល់អ្នកទាំងឡាយដែលអ្នកថែទាំតាមរយៈការបង្រៀនសួរសុខទុក្ខដោយរបៀបណា ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅគេហទំព័រ reliefsociety.lds.org ។

លក្ខណៈសម្បត្តិដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ ៖ គុណធម៌

នេះជាផ្នែកនៃការគិតគូរមួយអំពីសារលិខិតបង្រៀនសួរសុខទុក្ខដែលឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិរបស់ព្រះអង្គសង្គ្រោះ ។

« សូមឲ្យគុណធម៌តុមតែងគំនិតអ្នកដោយឥតឈប់ឈរឡើយ ខណៈនោះអ្នកនឹងមានចិត្តក្លាហានឡើងនៅចំពោះវត្តមាននៃព្រះ ហើយគោលលទ្ធិអំពីបព្វជិតភាពនឹងចុះមកលើព្រលឹងរបស់អ្នកដូចជាទឹកសន្សើមចុះពីលើមេឃ » (គ. និង ស ១២១:៤៥) ។

តើគុណធម៌គឺជាអ្វី ? ប្រធានជេម អ៊ី ហ្វោស្ត (ឆ្នាំ ១៩២០–២០០៧) បានមានប្រសាសន៍ថា « នៅក្នុងន័យពេញលេញរបស់វា ពាក្យគុណធម៌រួមបញ្ចូលនូវលក្ខណៈទាំងអស់នៃសេចក្តីសុចរិតដែលជួយឱ្យយើងបង្កើតជាអត្តចរិតរបស់យើង »[1] ប្រធានហ្គរដុន ប៊ី ហិងគ្លី (១៩១០–២០០៨) បានបន្ថែមថា ៖ « សេចក្តីស្រឡាញ់នៃព្រះគឺជាឫសគល់នៃអស់ទាំងគុណធម៌ នៃគ្រប់អស់ទាំងកិច្ចការល្អៗ នៃគ្រប់អស់ទាំងកម្លាំងនៃអត្តចរិត » ។[2]

ស្តីអំពីទំនាក់ទំនងរវាងស្ត្រី និង គុណធម៌ នោះអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ៖« ស្ត្រីកើតមកក្នុងលោកីយ៍ ជាមួយនឹងគុណធម៌ ជាអំណោយទានដ៏ទេវភាព ដែលធ្វើឲ្យពួកគាត់អាចដាក់បញ្ចូលគុណសម្បត្តិដូចជា សេចក្តីជំនឿ សេចក្តីក្លាហាន មេត្តាធម៌ និង ធ្វើឲ្យមានភាពប្រសើរឡើងក្នុងទំនាក់ទំនង និងក្នុងរបៀបធម៌ ។ . . .

« បងប្អូនស្ត្រីអើយ គ្រប់ទាំងទំនាក់ទំនងរបស់អ្នក គឺរវាងអ្នក និងព្រះ ជាព្រះវរបិតាសួគ៌របស់

អ្នក ទ្រង់ជាប្រភពនៃអំណាចខាងសីលធម៌របស់អ្នក ដែលអ្នកត្រូវតែឱបក្រសោបជាបឋមក្នុងជីវិត ។ សូមចាំថា អំណាចរបស់ព្រះយេស៊ូវបានមកតាមការបូជាព្រះទ័យដ៏ស្មោះរបស់ទ្រង់ចំពោះព្រះឆន្ទៈព្រះវរបិតា ។ . . . សូមខំប្រឹងប្រែងធ្វើជាសិស្សបែបនោះរបស់ព្រះវរបិតា និងព្រះរាជបុត្រា នោះអានុភាពអ្នកនឹងមិនរសាយឡើយ » ។[3]

បទគម្ពីរបន្ថែម

ទំនុកដំកើង ២៤:៣–៥; ភីលីព ៤:៨; ពេត្រុសទី ២ ១:៣–៥; អាលម៉ា ៣១:៥; គោលលទ្ធិ និង សេចក្តីសញ្ញា ៣៨:២៣–២៤

កំណត់ចំណាំ

1. ជែមស៍ អ៊ី ហ្វោស្ត “The Virtues of Righteous Daughters of God” *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៣ ទំព័រ ១០៨ ។
2. ហ្គរដុន ប៊ី ហិងគ្លី “Excerpts from Recent Addresses of President Gordon B. Hinckley,” *Ensign,* ខែ មេសា ឆ្នាំ ១៩៩៦ ទំព័រ ៧៣ ។
3. ឌី ថត គ្រីស្តូហ្វឺសិន « កម្លាំងសីលធម៌របស់ស្ត្រី » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ២៩, ៣១ ។
4. គុណធម៌មានព្រះចេស្តា (សូមមើល ម៉ាកុស ៥:៣០)
5. នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ពាក្យថា « បព្វជិតភាព » ត្រូវបានឲ្យនិយមន័យថា ជា « សិទ្ធិអំណាច និង អំណាចដែលព្រះប្រទានដល់បុរសដើម្បីធ្វើគ្រប់កិច្ចការទាំងអស់សម្រាប់សេចក្តីសង្គ្រោះនៃមនុស្ស » (គ. និង ស ៥០:២៦–២៧) ។

សូមពិចារណាពីសំណួរនេះ

តើគុណធម៌ផ្តល់អំណាច និង ពង្រឹងយើងយ៉ាងដូចម្តេច ?

សេចក្តីជំនឿ ត្រួមត្រួសារ តារាសង្គ្រោះ

ចេញពីព្រះគម្ពីរ

សព្វថ្ងៃនេះ គុណធម៌ស្ត្រី គឺពោរពេញដោយសេចក្តីជំនឿ បានជួយដល់ព្រះអង្គសង្គ្រោះ ។ នៅក្នុង លូកា ៨ យើងអានអំពីស្ត្រីម្នាក់ដែលមានជំងឺឆ្លាក់ឈាមអស់រយៈពេល ១២ ឆ្នាំ ដែលមិនអាចព្យាបាលជាឡើយ ។ នាងបានជាសះស្បើយនៅពេលនាង« បានមកពីក្រោយ [ព្រះគ្រីស្ទ] ហើយបានពាល់ជាយព្រះពស្ត្រទ្រង់ ៖ ហើយភ្លាមនោះ ជំងឺឆ្លាក់ឈាមរបស់គាត់បាន [ជា] មួយរំពេច ។ . . . ព្រះយេស៊ូវមានព្រះបន្ទូលសួរថាអ្នកណាពាល់ខ្ញុំ ៖ ដ្បិតខ្ញុំដឹងថាមានឫទ្ធិ[4] ផ្សាយចេញពីខ្ញុំទៅហើយ » ។ ស្ត្រីដ៏មានគុណធម៌ស្មោះត្រង់នោះបាន ផ្តួលខ្លួននៅចំពោះទ្រង់ ទូលទៅ កាន់ទ្រង់« នៅមុខមនុស្សទាំងអស់ » ពីហេតុដែល« នាងពាល់ទ្រង់ » ហើយ« ពីរបៀបដែលនាងបានជាភ្លាមៗរំពេចផង ។ ហើយទ្រង់មានព្រះបន្ទូលទៅនាងថា ចូរសង្ឃឹមឡើង កូនស្រីអើយ ៖ ដ្បិតសេចក្តីជំនឿនាងបានសង្គ្រោះនាងហើយ » (សូមមើល លូកា ៨:៤៣-៤៨សូមមើលផងដែរ ៦:១៧–១៩) ។

តាមរយៈគុណធម៌របស់ទ្រង់[5] នោះព្រះគ្រីស្ទអាចព្យាបាល អាចធ្វើកិច្ចការបានពង្រឹង លួងលោម និង រីករាយនៅពេលយើងជ្រើសរើសដោយសេចក្តីក្លាហាន និង សេចក្តីជំនឿដើម្បីជួយទ្រង់ ។

មេរៀនរបស់ខ្ញុំស្ដីពីសេចក្ដីស្រឡាញ់

ដោយ ចេនីស ចេត

ខ្ញុំមិនរំពឹងទេថា គម្រោងនៃការបម្រើដ៏សាមញ្ញ បង្រៀនខ្ញុំយ៉ាងច្រើនអំពីសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះបុត្រាបុត្រីទ្រង់ ។

ស្ដាប់ទៅវាដូចជាគម្រោងនៃការបម្រើធម្មតា ៖ ប្រមូលផ្ដុំបងប្អូនស្រ្ដីក្នុងសមាគមន៍សង្គ្រោះដើម្បីរៀបចំកម្មវិធីចម្រៀងខ្លីមួយនៅមជ្ឈមណ្ឌលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យមួយក្នុងមូលដ្ឋាន ទោះជាពុំមាននរណាម្នាក់ពីវួដរបស់យើងសម្រាកព្យាបាលនៅទីនោះក៏ដោយ ។

យើងបានឃើញថា ពួកយើងប្រជ្រៀតគ្នាក្នុងបន្ទប់តូចមួយ ដែលមានអ្នកជំងឺចាស់ៗប្រាំបួននាក់អង្គុយក្នុងរទេះរុញរបស់ពួកគាត់នៅទល់មុខយើង ។ ទឹកមុខរបស់ពួកគាត់ហាក់គ្មានចំណាប់អារម្មណ៍អ្វីសោះ ។ វាក្ដៅ ហើយស្អុះស្អាប់ ហើយខ្ញុំគិតថា « សូមធ្វើកិច្ចការនេះឲ្យចប់ចុះ » ។

ខ្ញុំត្រូវដឹកនាំតន្ត្រី ដូច្នេះខ្ញុំបានបែរខ្នងរបស់ខ្ញុំទៅអ្នកជំងឺ ហើយផ្ដោតទៅលើកម្មវិធី ។ ពេលយើងបានចាប់ផ្ដើម ខ្ញុំបានឮអ្នកជំងឺម្នាក់ហៅ « ម៉ាម៉ា ម៉ាម៉ា » ខណៈអ្នកជំងឺម្នាក់ទៀតទះដៃ ហើយធ្វើសំឡេង ។ ខ្ញុំមានអារម្មណ៍មិនស្រួលក្នុងចិត្ត ប៉ុន្តែពីរបីនាទីទៀត ប៉ុណ្ណោះ យើងនឹងបញ្ចប់ ហើយបានទៅផ្ទះហើយ ។

កាលដែលយើងបានរៀបចំច្រៀងទំនុកតម្កើងចុងក្រោយរបស់យើង គឺបទ « ទ្រង់ធំណាស់ណា ! » (*ទំនុកតម្កើង* លេខ ៣៨) នោះយើងបានអញ្ជើញអ្នកជំងឺ និង បុគ្គលិកនៅមន្ទីរពេទ្យឲ្យចូលរួមច្រៀងជាមួយយើង ។ ខ្ញុំបែរខ្លួនទៅដឹកនាំចម្រៀងសម្រាប់អ្នកគ្រប់គ្នា ហើយនៅពេលនោះហើយដែលខ្ញុំបានឃើញគាត់ — ជាស្រ្ដីម្នាក់ដ៏តូចមានសក់ស មុខជ្រីវជ្រួញ មានក្រដាសជូតមុខសើមជោកដោយទឹកភ្នែកនៅលើភ្លៅរបស់គាត់ ។

គាត់បានហៅខ្ញុំឲ្យទៅរកគាត់ ។ ខ្ញុំបានធ្វើដូច្នោះ ហើយពេលខ្ញុំឱនក្បាលទៅស្ដាប់ គាត់បានចាប់ដៃខ្ញុំ ។ ខ្លួនគាត់ទាំងមូលញ័រចំប្រប់ ពេលដែលគាត់ខ្សឹបថា « ខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ វាអស្ចារ្យណាស់ដែលមានបងប្អូនស្រ្ដីរបស់ខ្ញុំមកទីនេះ » ។

ព្រលឹងខ្ញុំពោរពេញដោយព្រះវិញ្ញាណ ហើយខ្ញុំបានលត់ជង្គង់ចុះក្បែរគាត់ ទាំងហូរទឹកភ្នែកជោកថ្ពាល់ ។ គាត់ដាក់ដៃដ៏ទន់ខ្សោយរបស់គាត់អោបខ្ញុំ ហើយបានទះខ្នងខ្ញុំ ដោយគាត់យល់ពីអារម្មណ៍ខ្ញុំ ។ អ្នកគ្រប់គ្នាបានចាប់ផ្ដើមច្រៀងទំនុកតម្កើង ប៉ុន្តែខ្ញុំមិនអាចទាំងច្រៀងវគ្គទីមួយចេញផង ។

ខណៈដែលពួកអ្នកជំងឺ និង បុគ្គលិកច្រៀងពីភាពអស្ចារ្យរបស់ព្រះ នោះព្រះវិញ្ញាណបានមកសណ្ឋិតក្នុងបន្ទប់នោះ ហើយអ្នកទាំងអស់គ្នាបានរំជួលចិត្ត ។ ទីបំផុតខ្ញុំបានប្រមូលការគ្រប់គ្រងអារម្មណ៍ឡើងវិញ ហើយបានចូលរួមច្រៀងជាមួយអ្នកផ្សេងទៀត ៖

លុះដល់ព្រះគ្រីស្ទយាងមកលាន់ឮស្នូរអឺងកង
ទាំងស្រង់ខ្ញុំឡើង ជាមួយទ្រង់ជាវិសុទ្ធ
នោះចិត្តខ្ញុំអរ និង ក្រាបថ្វាយបង្គំព្រះអង្គ
ទាំងថ្លែងទៅថា « ព្រះខ្ញុំទ្រង់ធំបំផុត ! »

បន្ទាប់ពីកម្មវិធីនោះ បងប្អូនស្រ្ដីក្នុងសមាគមន៍សង្គ្រោះបាននៅនិយាយលេងជាមួយនឹងអ្នកជំងឺ និង បុគ្គលិក ។ បងស្រីសក់សបានប្រាប់យើងថា គាត់បានមានអារម្មណ៍ឯកោ ហើយមានអារម្មណ៍ថាត្រូវបានហ៊ុំព័ទ្ធដោយមនុស្សចម្លែករហូតដល់ពួកយើងបានមកទីនោះ ។ យើងពុំបានដឹងថា គាត់នៅទីនោះទេ ប៉ុន្តែព្រះវរបិតាទ្រង់ត្រាស់ដឹង ។

ខ្ញុំត្រូវបានរំឭកថា មនុស្សទាំងអស់នេះជាបងប្អូនប្រុសស្រីរបស់យើង ថាពួកគាត់ត្រូវការសេចក្ដីស្រឡាញ់ និង ការលួងលោម ហើយថាថ្ងៃមួយខ្ញុំអាចនឹងនៅកន្លែងនេះដែរ ។ ខ្ញុំមានការរំជួលចិត្ត ដែលយើងអាចធ្វើជាឧបករណ៍នៃព្រះវរបិតាដ៏ពោរពេញដោយក្ដីស្រឡាញ់ ហើយខ្ញុំមានអំណរគុណដែលគម្រោងនៃការបម្រើរបស់យើងបានបង្រៀនខ្ញុំនូវមេរៀនដ៏មានចេស្ដាមួយអំពីសេចក្ដីស្រឡាញ់ ។ ■

អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វូញ៉ា ស.រ.អា ។



សេចក្ដីស្រឡាញ់ក្នុងសកម្មភាព

« មានតម្រូវការដ៏ធំមួយខាងសេចក្ដីសប្បុរស ដែលត្រូវផ្ដល់ការយកចិត្តទុក្ខដាក់ចំពោះពួកអ្នកដែលមិនត្រូវបានគេចាប់អារម្មណ៍ ផ្ដល់សេចក្ដីសង្ឃឹមដល់ពួកអ្នកដែលបាក់ទឹកចិត្ត ផ្ដល់ជំនួយដល់ពួកអ្នកដែលមានទុក្ខ ។ សេចក្ដីសប្បុរសដ៏ពិតគឺជាសេចក្ដីស្រឡាញ់ក្នុងសកម្មភាព ។ តម្រូវការខាងសេចក្ដីសប្បុរសមាននៅគ្រប់ទិសទី » ។

ប្រធាន ថូម៉ាស អេស ម៉នសុន "Charity Never Faileth," *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៤ ។

ការសង្គ្រោះសត្វបក្សី

ដោយ វីលាម ហូកហ្គាន

ក្នុងការសង្គ្រោះសត្វបក្សីមួយ យើងបានរៀនពីរបៀបដើម្បីជួយអ្នកទន់ខ្សោយខាងវិញ្ញាណ ។

នៅឯការចោះជំរុំឃុវ៉ូនារីនៅឯភ្នំនៃរដ្ឋ កាលីហ្វ័ញ៉ា ពួកឃុវ៉ូនារី និង អ្នកដឹកនាំបានរង់ចាំទទួលទានអាហារពេលល្ងាចក្នុងផ្ទះសំណាក់រាងជាអក្សរ A មួយ ។ ពេលយើងរង់ចាំ ឃុវ៉ូនារីមួយចំនួនបានកត់សម្គាល់ថាមានអ្វីមួយនៅក្រោមតុ ។ មិនដឹងថាដោយរបៀបណា តែមានសត្វបក្សីមួយបានហើរចូលមកក្នុងផ្ទះសំណាក់ មិនអាចរកផ្លូវចេញបាន ហើយនៅទីបំផុតក៏បានធ្លាក់ចុះនៅលើឥដ្ឋ ។ ពួកគេបានសូមឲ្យខ្ញុំជួយវា ។

បក្សីនោះ មើលទៅស្ទើរតែនឹងស្លាប់ទៅហើយ ចំពុះវាត្រូវរុំដោយសំបុកពីងពាង ហើយស្លាបវាឡើងរឿច ។ ខ្ញុំបានដាក់វាថ្នមៗទៅក្នុងពែងមួយ ហើយបានយកវាទៅខាងក្រៅ ។ ខ្ញុំសង្ឃឹមថា វានឹងបានជាដោយខ្លួនវា ប៉ុន្តែខ្ញុំជឿភាពជាក់ស្តែង ហើយក៏រំពឹងថា វានឹងស្លាប់ទៅតាមបែបធម្មជាតិ ។ ទោះជាយ៉ាងណា នៅពេលដែលខ្ញុំផ្លៀងពែងថ្នមៗដើម្បីចាក់សត្វបក្សីនោះចេញទៅលើដី ស្រាប់តែសត្វបក្សីដែលកំពុងតែរំកិលខ្លួនចេញមក នោះបែរជាវាតោងមាត់ពែងនោះជាប់ជាមួយនឹងក្រញាំវាទៅវិញ ។ ខ្ញុំបានកាន់ពែងឲ្យត្រង់ឡើងវិញ សត្វបក្សីទុំនៅនឹងមាត់ពែង ហើយភ្នែកវាបិទ ។ ចុះឥឡូវនេះយ៉ាងម៉េចដែរ ?

ដោយបានឃើញសត្វបក្សី នោះអ្នកដឹកនាំម្នាក់បានលាយស្ករ និង ទឹក ហើយយកមកឲ្យខ្ញុំ ។ ដំបូង ខ្ញុំបបោសសំបុកពីងពាងថ្នមៗ ចេញពីចំពុះស្រួចដូចម្ជុល ។ សត្វបក្សីមិនបានកម្រើកឡើយ ។ បន្ទាប់មក ខ្ញុំបានជ្រលក់ម្រាមដៃទៅក្នុងទឹកស្ករ ហើយបន្តក់ទៅចុងចំពុះវា ។ តំណក់ទឹកស្ករបាត់អស់រលីង ទោះជាសត្វបក្សីមិនបានកម្រើកក្តី ។ ប្រហែលទឹកស្ករហូរចូលក្នុងចំពុះ ? ខ្ញុំបានជ្រលក់ម្រាមដៃទៅក្នុងទឹកស្ករម្តងទៀត ហើយដាក់ទៅនឹងចំពុះវា ។ ម្តងនេះ អណ្តាតដ៏តូច ស្តើងជាងសរសៃសក់ បានលិតចុងម្រាមដៃខ្ញុំ ។

សត្វបក្សីបានផឹកទឹកស្ករពីមួយតំណក់ទៅមួយតំណក់ អស់រយៈពេល ១០ ឬ ១៥ នាទី ។ មកដល់ពេលនោះ អ្នកដឹកនាំបួនប្រាំនាក់ទៀតបានប្រមូលគ្នាមកជុំវិញខ្ញុំ ហើយខ្ញុំឲ្យពួកគាត់សាកឲ្យទឹកស្ករវា ។

រំពេចនោះ សត្វបក្សីបានបើកភ្នែកវា ហើយរោមដ៏រញ៉ៅរញ៉ៃរបស់វាបានរៀបរយឡើងវិញ ។ បន្ទាប់ពីផឹកទឹកស្ករពីរបីតំណក់ថែមទៀត វាចាប់ផ្តើមរលាស់ ហើយកម្តៅស្លាបវាមួយភ្លែត ហើយបានហើរឡើងទៅ ។ វាឈប់មួយសន្ទុះនៅពីលើយើង ហើយបានហោះចេញទៅ ។

យើងបានឈរនៅទីនោះ ទាំងស្រឡាំងកាំង ។ ក្រោយពីសត្វបក្សីហើរចេញទៅភ្លាម ក៏មាននូវមេរៀនខាងវិញ្ញាណមួយលេចឡើង ៖

- ជាញឹកញាប់ ពេលយើងឈោងទៅជួយសមាជិកអសកម្ម ការខិតខំរបស់យើងហាក់ដូចជាមិនឃើញធ្វើឲ្យមានការផ្លាស់ប្តូរអ្វីសោះ ។ ប៉ុន្តែ សេចក្តីស្រឡាញ់ដែលយើងផ្តល់ឲ្យពិតជាចូលទៅក្នុងចន្លោះដែលប្រេះស្រាំ — ដូចជាទឹកអម្រិតដែលចូលទៅក្នុងចំពុះដែលមិនកម្រើកនៃសត្វបក្សីនោះដែរ — ជាការផ្តល់នូវការចិញ្ចឹមបីបាច់ខាងវិញ្ញាណ ដែលអាចនឹងបង្កើតជាផលផ្លែនៅថ្ងៃណាមួយ ។
- ពេលខ្លះ យើងពុំអាចទៅបានឆ្ងាយជាងនេះទៀត ដោយខ្លួនឯងទេ យើងត្រូវការដៃដែលខ្វល់ខ្វាយ និង ករុណា ។
- ជួនកាលមនុស្សត្រូវជំពាក់ជាប់ក្នុងសំបុកពីងពាងនៃអំពើបាប ឬ ការញៀន ហើយត្រូវការជំនួយពីមិត្តភក្តិ ឬ អ្នកដឹកនាំបព្វជិតភាពម្នាក់ និង ជំនួយរបស់ព្រះអង្គសង្គ្រោះដើម្បីទទួលបានសេរីភាព ។
- យើងត្រូវការចំណីអាហារចិញ្ចឹមខាងវិញ្ញាណជាប្រចាំ ដើម្បីស៊ូទ្រាំ បើមិនដូច្នោះទេយើងនឹងអស់កម្លាំងខាងវិញ្ញាណ ហើយធ្លាក់ទៅជាជនរងគ្រោះចំពោះឥទ្ធិពលនៃអារក្ស ។
- សត្វបក្សីនោះនៅបន្តតោងជាប់ ។ ពិតណាស់ ។ ការតោងជាប់ធ្វើឲ្យមានការផ្លាស់ប្តូរទាំងអស់ ។ ពេលខ្លះ យើងត្រូវតែស៊ូទ្រាំប៉ុណ្ណោះ គឺស៊ូទ្រាំនៅក្នុងសេចក្តីជំនឿ កាលដែលយើងប្រឈមនឹងឧបសគ្គដ៏ឈឺចាប់ ហើយពេលខ្លះគឺជាឧបសគ្គដ៏គួរឲ្យរន្ធត់ក្នុងជីវិត ។

ព្រះគម្ពីរសញ្ញាថ្មីចែងថា ព្រះអម្ចាស់ទ្រង់ត្រាស់ដឹងសូម្បីតែសត្វចាបមួយធ្លាក់ (សូមមើល ម៉ាថាយ ១០:២៩–៣១) ។ ឥឡូវនេះខ្ញុំដឹងថា ទ្រង់ក៏ត្រាស់ដឹងពីការធ្លាក់របស់សត្វបក្សីនេះដែរ ។ ហើយទ្រង់ត្រាស់ដឹងពីអ្នក ។ ■

អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វ័ញ៉ា ស.រ.អា ។

រូបចំណោម KOJIHIRANO/ISTOCK/THINKSTOCK

របៀបដែលយើង «ផ្សាយអំពីព្រះគ្រីស្ទ» នៅក្នុងគេហដ្ឋានរបស់យើង

រូបភាពផ្តល់ជូនដោយបណ្ណាល័យរូបភាពទាមទារ HEMERA/THINKSTOCK

« យើងនិយាយអំពីព្រះគ្រីស្ទ យើងអរសប្បាយក្នុងព្រះគ្រីស្ទ យើងផ្សាយអំពីព្រះគ្រីស្ទ យើងព្យាករអំពីព្រះគ្រីស្ទ ហើយយើងសរសេរស្របតាមពាក្យព្យាករណ៍ទាំងឡាយរបស់យើង ដើម្បីឲ្យកូនចៅយើងបានដឹងថា តើត្រូវស្វែងរកប្រភពណាមួយដើម្បីឲ្យបានផ្តាច់បាបរបស់ពួកគេ » (*នីហ្វៃទី២ ២៥:២៦*) ។

ដោយ ដារិន អ៊ី ស្មីដថ

អំឡុងពេលបុណ្យអ៊ីស្ទើរនៅឆ្នាំមួយ ភរិយាខ្ញុំបានផ្តល់យោបល់ថា យើងអានជាក្រុមគ្រួសារនូវដំណើររឿងចេញពីព្រះគម្ពីរ អំពីសប្តាហ៍ចុងក្រោយរបស់ព្រះអង្គសង្គ្រោះក្នុងជីវិតរមែងស្លាប់ ។ រៀងរាល់យប់ពេលចូលគេង យើងអានព្រះគម្ពីរសញ្ញាថ្មី ហើយបង្ហាញកូនៗយើងនូវរឿងអូខ្លីមួយ អំពីព្រឹត្តិការណ៍នីមួយៗ ហើយបានពិភាក្សាអំពីសំណួរទាំងឡាយដែលមាន ។ ខ្ញុំមានភាពអស្ចារ្យនឹងសំណួរដែលកូនៗយើងមាន ក៏ដូចជាមានភាពអស្ចារ្យនឹងព្រះវិញ្ញាណដែលយាងចូលក្នុងគេហដ្ឋានរបស់យើង អំឡុងពេលយើងអាន និង ពិភាក្សា ។

នៅចុងបញ្ចប់នៃសប្តាហ៍នោះ ខ្ញុំបានមានអារម្មណ៍នៃការដឹងគុណ និងសេចក្តីស្រឡាញ់ដែលកាន់តែជ្រាលជ្រៅចំពោះព្រះអង្គសង្គ្រោះ ដោយបានឆ្លុះបញ្ចាំងជាច្រើនពីពលិកម្មរបស់ទ្រង់ និង លទ្ធផលដ៏អស់កល្បជានិច្ច ដែលបានមកពីអ្វីៗទាំងអស់ដែលទ្រង់បានឆ្លងកាត់សម្រាប់យើង ។ ជាមួយនឹងអារម្មណ៍ដ៏រំជួលរបស់ខ្ញុំ នោះខ្ញុំបានដឹងថា ភរិយារបស់ខ្ញុំត្រូវបានបំផុសគំនិត ហើយខ្ញុំបានឃើញពីការយល់ដឹង និង សេចក្តីស្រឡាញ់ដែលកាន់តែជ្រាលជ្រៅចំពោះព្រះអង្គសង្គ្រោះនៅក្នុងចិត្តកូនៗយើង ក៏ដូចជាបំណងប្រាថ្នាកាន់តែធំឆេងដើម្បីបង្ហាញអកប្បកិរិយាដូចព្រះគ្រីស្ទចំពោះគ្នាទៅវិញទៅមក ។

តាំងពីពេលនោះមក យើងបានរុករកវិធីផ្សេងៗទៀត ដើម្បីយើងអាច « និយាយអំពីព្រះគ្រីស្ទ » និង « ផ្សាយអំពីព្រះគ្រីស្ទ » ឲ្យបានកាន់តែច្រើនថែមទៀតនៅក្នុងការសន្ទនា និង មេរៀនរបស់យើង ដោយដឹងថា ដោយការស្ថាបនានៅលើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទ នោះយើងត្រូវបានសន្យាថានឹងបាននូវការតទល់យ៉ាងអស្ចារ្យទាស់នឹងព្យុះនៃជីវិត (សូមមើល ហេលេមិន ៥:១២) ។

យកព្រះអង្គសង្គ្រោះធ្វើជាការផ្តោតដ៏សំខាន់ក្នុងការបង្រៀនរបស់អ្នក

អ្វីមួយដែលយើងបានរកឃើញ គឺថា ពេលយើងនាំយកគំរូ និង ការបង្រៀនរបស់ព្រះអង្គសង្គ្រោះចូលក្នុងការពិភាក្សា និង ការប្រាស្រ័យទាក់ទងរបស់ក្រុមគ្រួសារយើង នោះគំរូ និង ការបង្រៀនទាំងនោះកាន់តែមានចេស្តា និង កាន់តែពោរពេញដោយគោលបំណង ។ ដើម្បីប្រើប្រាស់ការប្រៀបធៀបចេញពីព្រះអង្គសង្គ្រោះផ្ទាល់ នោះទ្រង់បានបង្រៀនថា « ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន » (យ៉ូហាន ១៥:៥) ។ បើយើងអនុវត្តការប្រៀបធៀបនេះទៅនឹងការបង្រៀនរបស់យើង នោះយើងបង្រៀនគោលការណ៍ដំណឹងល្អ មិនត្រឹមតែជាគំនិតដែលទាក់ទងទេ តែជាផ្នែកនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដូចជា ព្យាការី យ៉ូសែប ស្ម៊ីធ បានប្រកាសថាវាដូច្នោះ ។[9] នេះជារបៀបដែលយើងយកព្រះអង្គសង្គ្រោះជាការផ្តោតដ៏សំខាន់ក្នុងការណែនាំរបស់យើង មិនមែនគ្រាន់តែជាស្លឹកដែលយើងក្តិចចេញពីគល់ដ៏ពិតរបស់ទ្រង់នោះទេ ។

បើយើងធ្វើឲ្យទ្រង់ជាចំនុចសំខាន់បំផុតនៃការបង្រៀនរបស់យើង នោះយើងត្រូវបានសន្យាថានឹងបាននូវការចិញ្ចឹមបីបាច់ កម្លាំង និង ការលូតលាស់ រួមទាំងមែកសាខាពេញដោយផលផ្លែ — និយាយម្យ៉ាងទៀត គឺថា ការពិភាក្សា និង មេរៀនរបស់យើងនឹងកាន់តែមាននូវចេស្តានៃការប្រែចិត្តជឿ និង ជាលទ្ធផលដ៏យូរអង្វែង ។ របៀបមួយដែលយើងធ្វើ គឺបង្រៀនគោលការណ៍ដំណឹងល្អមួយ រួចហើយសួរកូនៗយើងសំណួរមួយ ដូចជា « តើព្រះយេស៊ូវគ្រីស្ទបង្ហាញពីគោលការណ៍ ឬ ការបង្រៀននេះយ៉ាងដូចម្តេចដែរ ? » ឬ « តើព្រះអម្ចាស់បានបង្រៀនអ្វី អំពីការណ៍នេះ ? »

គំរូមួយពីការបង្រៀនអំពីការអធិស្ឋាន

ឧទាហរណ៍ អ្នកកំពុងបង្រៀនពីសារៈសំខាន់នៃការអធិស្ឋាន ។ អ្នកអាចប្រើ គោលលទ្ធិ និង សេចក្តីសញ្ញា ១០:៥ ដែលយើងត្រូវបានណែនាំឲ្យ « អធិស្ឋានជានិច្ច » ឬ ការទូន្មានរបស់នីហ្វៃដែលថា « អារក្សអសោចិ៍មិនបង្រៀនមនុស្សណាមួយឲ្យអធិស្ឋានទេ ប៉ុន្តែបង្រៀនគេមិនឲ្យអធិស្ឋានវិញ » (នីហ្វៃទី២ ៣២:៨) ។ បទគម្ពីរទាំងនេះបង្រៀនពីគោលលទ្ធិនៃការអធិស្ឋានប្រកបដោយចេស្តា ។ ពេលអ្នកពិភាក្សាពីបទគម្ពីរទាំងនេះ ឧបមាថាអ្នកសួរសំណួរដូចជា « តើព្រះអង្គសង្គ្រោះបានអធិស្ឋានដោយរបៀបណា ? » ឬ « តើការអធិស្ឋានរបស់ព្រះអង្គសង្គ្រោះមានលក្ខណៈយ៉ាងណាដែរ ? » បើអ្នកមានក្មេងតូចៗ អ្នកអាចសួរថា « តើកូន *គិត* ថាការអធិស្ឋានរបស់ព្រះអង្គសង្គ្រោះមានលក្ខណៈយ៉ាងណាដែរ ? »

យកពេលមួយភ្លែតគិតអំពីរបៀបដែលអ្នកអាចនឹងឆ្លើយសំណួរនេះដោយផ្ទាល់ខ្លួន ដោយពិចារណាពីដំណើររឿងក្នុងព្រះគម្ពីរដែលអ្នកនឹកឃើញ ។ ខ្ញុំបានគិតភ្លាមអំពីកាលដែលព្រះអង្គសង្គ្រោះយាងមកទ្វីបអាមេរិក ពេលដែល « ទ្រង់បានអធិស្ឋានទៅព្រះវរបិតា ហើយអ្វីៗដែលទ្រង់បានអធិស្ឋាននោះពុំអាចយកមកសរសេរបានឡើយ ។ . . . ភ្នែកមិនដែលឃើញសោះ ឯត្រចៀកក៏មិនដែលបានឮរឿងដ៏មហិមា និង អស្ចារ្យ ដូចដែលយើងបានឃើញ ហើយបានឮព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅកាន់ព្រះវរបិតាឡើយ » (នីហ្វៃទី៣ ១៧:១៥–១៦) ។

ក្រោយមកនៅក្នុងដំណើររឿងនេះ យើងឃើញថា ប្រជាជនបានព្យាយាមយកគំរូតាមការអធិស្ឋានរបស់ទ្រង់ ហើយជាលទ្ធផល « មិនត្រូវបានបន្ថែមពាក្យច្រើនឡើយ ដ្បិត *ត្រូវបានប្រទានដល់ពួកគេ* នូវអ្វីដែលពួកគេត្រូវអធិស្ឋានហើយ ហើយពួកគេ *បានពោរពេញទៅដោយសេចក្តីប្រាថ្នា* » (នីហ្វៃទី៣ ១៩:២៤ ការសង្កត់ន័យត្រូវបានបន្ថែម) ។ មកដល់ត្រឹមនេះ អ្នកអាចអញ្ជើញកូនៗរបស់អ្នកឲ្យចែកចាយពេលមួយដែលពួកគេបានពោរពេញដោយសេចក្តីប្រាថ្នាដើម្បីអធិស្ឋាន ឬ អ្នកអាចចែកចាយពីពេលមួយដែលអ្នកត្រូវបានប្រទានឲ្យនូវពាក្យទាំងឡាយដើម្បីនិយាយខណៈកំពុងអធិស្ឋាន ។ បន្ទាប់មក អ្នកអាចថ្លែងទីបន្ទាល់ថា ការអធិស្ឋានមានភាពខុសប្លែកគ្នាយ៉ាងណា ពេលយើងអធិស្ឋានតាមរបៀបនេះ គឺដូចជាព្រះអង្គសង្គ្រោះបានបង្រៀន ។

សូមគិតអំពីការផ្លាស់ប្តូរដែលអ្នកអាចមានលើកូនៗអ្នក បើសិនពួកគេត្រូវអនុវត្តលើគោលការណ៍នៃការអធិស្ឋាន ដែលមានក្នុងខទាំងនេះ និង នៅក្នុង

ទីបន្ទាល់ដែលអ្នក និង ពួកគេបានថ្លែង ។ សូមគិតពីរបៀបដែលការណ៍នេះ អាចអភិវឌ្ឍសមត្ថភាពក្នុងការទទួលអារម្មណ៍ និង ស្គាល់ព្រះវិញ្ញាណ លើកតម្កើងការហៅបម្រើរបស់ពួកគេ ផ្តល់ពរជ័យបព្វជិតភាព ហើយក្រោយមកចិញ្ចឹមបីបាច់ក្រុមគ្រួសាររបស់គេផ្ទាល់ ត្រូវបានដឹកនាំដោយព្រះវិញ្ញាណដដែល ដែល « បង្រៀនមនុស្សឲ្យអធិស្ឋាន » (នីហ្វៃទី២ ៣២:៨) ។

បើយើងមិនបានបញ្ចូលគំរូ និង ការបង្រៀនរបស់ព្រះអង្គសង្គ្រោះក្នុងការបង្រៀននេះទេ នោះយើងអាចនៅតែមានការពិភាក្សាដ៏ល្អមួយអំពីការអធិស្ឋាន ប៉ុន្តែការបញ្ចូលគំរូ និង ការបង្រៀនរបស់ទ្រង់ កាន់តែបន្ថែមនូវភាពសិទ្ធជម្រៅ និង ព្រះចេស្តា ។

សិល្បៈដែលផ្តោតលើដំណឹងល្អ

អ្វីមួយទៀតដែលយើងបានព្យាយាមធ្វើ ដើម្បីស្តាបនាគេហដ្ឋានដែលផ្តោតលើព្រះគ្រីស្ទ គឺការមានរូបភាពព្រះគ្រីស្ទ ព្រះវិហារបរិសុទ្ធ និង អ្វីៗដែលទាក់ទងនឹងដំណឹងល្អ នៅកន្លែងដែលអាចងាយនឹងមើលឃើញ ហើយដែលកូនៗយើងអាចដឹងថា អ្វីដែលពិតជាសំខាន់សម្រាប់យើង ។

ពីរបីឆ្នាំកន្លងទៅហើយ ខណៈកំពុងអង្គុយជាមួយកូនៗយើងពេលទូទាត់ដង្វាយមួយភាគក្នុងដប់ នោះប៊ីស្សពរបស់យើងបានអញ្ជើញកូនប្រុសអាយុ ១០ ឆ្នាំ របស់យើង ឲ្យយករូបព្រះអង្គសង្គ្រោះដ៏តូចមួយ ហើយឲ្យគាត់សម្រេចចិត្តថាត្រូវដាក់វានៅកន្លែងណានៅផ្ទះរបស់យើង ជាកន្លែងដែលវានឹងក្លាយជាការរំឭកអំពីការតាំងចិត្តរបស់ក្រុមគ្រួសារយើងដើម្បីធ្វើតាមទ្រង់ ។ បន្ទាប់ពីត្រឡប់មកផ្ទះវិញ គាត់បានដាក់រូបនៅទ្វារខាងមុខ ជាកន្លែងដែលកូនប្រុសយើងនិយាយថា « យើងម្នាក់ៗនឹងឃើញវាច្រើនបំផុត » ។ វាជាពរជ័យមួយដ៏មហិមា និង ជាការរំឭកដ៏ខ្ជាប់ខ្ជួនដល់យើងទាំងអស់គ្នារៀងរាល់ថ្ងៃ នៅក្នុងរបៀបតូចមួយ ប៉ុន្តែប្រកបដោយចេស្តា អំពីការសន្យារបស់យើងក្នុងការធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។

ដោយមិនគិតពីទីកន្លែងដែលដាក់រូបភាពក្នុងគេហដ្ឋានរបស់អ្នក នោះវាសមនឹងតម្លៃនៃការខំយកចិត្តទុកដាក់លើរូបភាពទាំងឡាយដែលនៅលើជញ្ជាំង និង សារលិខិតដែលអ្នកនឹងផ្តល់ដល់កូនៗអ្នក ។ តើរូបភាពសិល្បៈនៅក្នុងគេហដ្ឋានរបស់អ្នក បង្ហាញពីសារដែលថា អ្នកមានការតាំងចិត្តក្នុងការធ្វើតាមព្រះគ្រីស្ទដែរឬទេ ?

របៀបផ្សេងៗទៀតក្នុងការបង្រៀនពីព្រះគ្រីស្ទ

ខ្ញុំទទួលស្គាល់ថា ខ្ញុំបានសើចច្រើនជាងម្តង ពេលកូនរបស់ខ្ញុំម្នាក់បានសួរខ្ញុំ បើសិនជាព្រះយេស៊ូវរាំងមាំជាងវីរបុរសក្នុងរឿងតុក្កតា ទោះយ៉ាងណាខ្ញុំបានឃើញថា សំណួររបស់កូនខ្ញុំតែងតែបង្កើតនូវការពិភាក្សាដ៏ប្រសើរអំពីអ្វីដែលធ្វើឲ្យព្រះអង្គសង្គ្រោះខ្ពង់ខ្ពស់ឧត្តុង្គឧត្តមជាងវីរបុរសនោះ ។ ទន្ទឹមនឹងការសន្ទនាប្រចាំថ្ងៃបែបនេះ នេះជាគំនិតមួយចំនួនបន្ថែមទៀត ដែលអ្នកអាចពិចារណាដើម្បីធ្វើឲ្យគេហដ្ឋានរបស់អ្នកកាន់តែផ្តោតលើព្រះគ្រីស្ទ ។

- ប្រើព្រះគម្ពីរមរមនដើម្បីបង្រៀនកូនៗអ្នកអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ពាក្យ *ដង្វាយធួន* ឬ *ធួន* មានលេចឡើង ៣៩ ដងក្នុងព្រះគម្ពីរមរមន ។
- ប្រើវីដេអូ Mormon Messages វីដេអូព្រះគម្ពីរប៊ីប និង ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតរបស់សាសនាចក្រ ដែលបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ដើម្បីធ្វើឲ្យមេរៀនរាត្រីជួបជុំក្រុមគ្រួសារ និង ការសិក្សាព្រះគម្ពីររបស់អ្នកកាន់តែប្រសើរឡើង ។
- រៀន និង ច្រៀងទំនុកតម្កើងអំពីព្រះអង្គសង្គ្រោះជាមួយគ្នា ហើយពិភាក្សាការបង្រៀន និង អត្ថន័យនៃទំនុកតម្កើងនោះ ។
- ស្វែងរកវិធីដើម្បីសង្កត់ន័យថា ពួកព្យាការីគឺជាពួកសាក្សីរបស់ព្រះយេស៊ូវគ្រីស្ទដែលប្រកបដោយព្រះចេស្តា ។
- ព្យាយាមជានិច្ចដើម្បីអភិវឌ្ឍទំនាក់ទំនងរបស់អ្នកផ្ទាល់ជាមួយនឹងព្រះអង្គសង្គ្រោះ ។

ខ្ញុំបានដឹងតាមរយៈការសិក្សាដ៏យកចិត្តទុកដាក់ និង ការអធិស្ឋានដ៏ភ្លៀវភ្លាថា ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយថាអំណោយដ៏ធំធេងរបស់ទ្រង់ គឺដង្វាយធួន គឺមានពិតមែន ហើយផ្តល់ជីវិតដល់យើង និង ជីវិតរបស់ពួកអ្នកទាំងឡាយដែលយើងស្រឡាញ់ ផ្តល់នូវអត្ថន័យ និង គោលបំណងជាមួយនឹងសេចក្តីសង្ឃឹមដ៏រុងរឿង និង ធំមហិមា ដែលក្រុមគ្រួសារយើងអាចបាន ហើយនឹងក្លាយជារបស់យើងអស់កល្បជានិច្ច ។ សូមឲ្យយើងម្នាក់ៗបានដឹងពីសារៈសំខាន់ដ៏ធំធេងនៃការស្តាបនាគេហដ្ឋានដែលផ្តោតលើព្រះគ្រីស្ទ និង ទទួលស្គាល់ថា « គ្មានផ្លូវ ឬ មធ្យោបាយឯណាផ្សេងទៀតទេ ដែលនាំឲ្យមនុស្សបានសង្គ្រោះ មានតែដោយ និង តាមរយៈព្រះគ្រីស្ទមួយប៉ុណ្ណោះ » (អាលម៉ា ៣៨:៩) ។ ■

អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។

កំណត់ចំណាំ

១. សូមមើល *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស៊្មីធ* (ឆ្នាំ ២០០៧) ទំព័រ ៤៩-៥០ ។

ផ្លូវទៅកាន់

ប៉ាលម៉ែរ៉ា



រូបចម្លាយ ចេ ម៉ែនឌែលសិន ដោយការអនុញ្ញាតពីសារមន្ទីរប្រតិបត្តិសិល្បៈផ្នែកសិទ្ធិ

ផ្លូវទៅកាន់ប៉ាលម៉ែរ៉ា — ជាកន្លែងនៃទស្សនិមិត្តដំបូង និង ជាកន្លែងដែលផ្នាំងមាសត្រូវបានលាក់ទុក — ជាផ្លូវនៃសេចក្តីផ្អែមល្ហែម និង ពន្លឺសម្រាប់យ៉ូសែប ស្ម៊ីធ និង ក្រុមគ្រួសារលោក ។

ដោយ ម៉ាថាយ អេស ហូឡិន

នេះគឺជាអត្ថបទទីមួយក្នុងអត្ថបទដែលមានពីរអំពីព្យាការី យ៉ូសែប ស្ម៊ីធ ។ អត្ថបទទីពីរ « ការលេចចេញមកនៃព្រះគម្ពីរមរមន » នឹងមាននៅក្នុងចុងខែក្រោយនៃទស្សនាវដ្តី លីអាហូណា ។

ស្ងួមកុំយល់ច្រឡំឲ្យសោះ ។ ទោះបីជាអ្នកមិនមែនជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងក៏ដោយ ពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងអស់ត្រូវបានហៅឲ្យទទួលយកសារលិខិតនៃដំណឹងល្អរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទទៅកាន់ « គ្រប់ក្នុងលោកីយ៍ » (ម៉ាថាយ ២៤:១៤) ។ យើងត្រូវបានហៅឲ្យចែកចាយគោលការណ៍បរិសុទ្ធ ហើយរៀបចំអនុវត្តដំណឹងល្អ *របស់ទ្រង់* នៅក្នុងព្រះនាម *របស់ទ្រង់* ។ ដើម្បីធ្វើដូច្នេះបាន អ្នកត្រូវតែចាំផងដែរថា វាជាការចាំបាច់ដើម្បីបង្រៀន និង ថ្លែងទីបន្ទាល់ថា យ៉ូសែប ស្ម៊ីធ ជាឧបករណ៍របស់ទ្រង់នៅក្នុងការស្តារឡើងវិញនូវគោលការណ៍ដ៏បរិសុទ្ធទាំងនោះ និង រៀបចំនូវការអនុវត្តន៍ទាំងឡាយចំពោះផែនដីនេះ ។

ដោយព្រោះតែមាននូវអ្វីៗជាច្រើនស្ថិតនៅក្នុងភាពប្រថុយប្រថាន នោះអ្នកអាចឆ្លៀតវេលាដើម្បី សួរខ្លួនឯងថា តើអ្នកត្រៀមរួចរាល់ហើយឬនៅ ដើម្បីឈានទៅមុខ ហើយប្រកាសដោយការជឿជាក់ច្បាស់ និង ម៉ឺងម៉ាត់ថា « នៅព្រឹកព្រលឹមនៃថ្ងៃដ៏ល្អភ្លឺស្វាង គឺនៅដើមនិទាឃរដូវក្នុងឆ្នាំមួយពាន់ប្រាំបីរយម្ភៃ »[1] យ៉ូសែប ស្ម៊ីធ បានដើរចូលទៅក្នុងព្រៃដាច់ស្រយាលមួយ លុតជង្គង់ចុះអធិស្ឋាន នោះពិភពលោកនេះបានផ្លាស់មិនដូចមុនទៀតឡើយ ។ ប្រសិនបើអ្នកចង់ធ្វើជាអ្នកបម្រើរបស់ព្រះ នោះអ្នកត្រូវបានហៅឲ្យធ្វើដូច្នោះ នោះអ្នកត្រូវតែរៀបចំរួចជាស្រេចដើម្បីធ្វើដូច្នោះ ។

សូមសម្រេចចិត្តពីឥឡូវនេះ ដើម្បីសិក្សាដោយយកចិត្តទុកដាក់អំពីជីវិតរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។ មាននូវអំណាច និង ប្រាជ្ញាក្នុងជីវិតរបស់លោក ដែលមនុស្សផ្សេងទៀតគ្មានឡើយ លើកលែងតែព្រះជន្ម របស់ព្រះអង្គសង្គ្រោះផ្ទាល់ប៉ុណ្ណោះ ។ នៅពេលដែលអ្នករៀនដោយស្មោះអស់ពីចិត្ត និង ប្រកបដោយការអធិស្ឋាន អំពីព័ត៌មានពិស្តារអំពីជីវិតយ៉ូសែប នោះខ្ញុំសន្យាថា អ្នកនឹងឃើញថា សេចក្តីស្រឡាញ់ និង ការកោតសរសើររបស់អ្នកចំពោះលោកីរកលូតលាស់ឡើង អ្នកនឹងទទួលបានការលួងលោម និង ការលើកទឹកចិត្ត ជាពិសេសគឺសម្រាប់ថ្ងៃ និង ការបម្រើដ៏លំបាកទាំងឡាយ ហើយអ្នកនឹងបង្កើនការយល់ដឹងរបស់អ្នក ជំទាស់នឹងអ្នកិះគន់មើលងាយក្នុងសម័យទំនើបនេះ ដែលពួកគេប្រាកដណាស់ថា ភស្តុតាងខាងលោកិយបង្ហាញថា យ៉ូសែបមិនអាចជាអ្វីដែលលោកបានប្រកាសអះអាងនោះទេ ។ ដើម្បីសម្រេចវាបាន សូមពិចារណាលើព័ត៌មានសង្ខេបមួយចំនួនអំពីបុរសដ៏ឆ្នើមអស្ចារ្យបំផុតនេះ ។

បន្ទាប់ពីមរណភាពក្នុងការដាំដំណាំអស់រយៈពេលមួយឆ្នាំ នៅទីក្រុង រ៉ាម៉ិន្ត មក យ៉ូសែប ស្ម៊ីធ សឺញ៉ា បាននាំគ្រួសារលោកធ្វើដំណើរយ៉ាងលំបាកចម្ងាយ ៤៨២ គីឡូម៉ែត្រ ទៅទិសនិរតី ទៅកាន់ទីក្រុងប៉ាលម៉ៃរ៉ានៅ ប៉ែកខាងលើនៃរដ្ឋ នូវ យ៉ក ។

ដោយសំណាងអាក្រក់ ឬក៏ជាផែនការកំណាចអប្រិយ នោះទំនិញរបស់ យ៉ូសែប សឺញ៉ារ បានស្ថិតនៅលើកប៉ាល់ដែលកូនប្រុសរបស់ឈ្មួញកណ្តាល ដែលលោកបានបដិសេធមិនធ្វើជំនួញជាមួយនោះ ។ ដោយឆ្លៀតយកប្រៀបលើស្ថានការណ៍នេះ កូនប្រុសនោះបានលក់យិនសិនរបស់គ្រួសារស្ម៊ីធ ក្នុងប្រទេសចិន « ក្នុងតម្លៃយ៉ាងខ្ពស់ » ហើយទុកប្រាក់ចំណេញសម្រាប់ខ្លួនឯង ហើយបានកុហកថា ការខិតខំលក់ជិនសិននោះមិនបានជោគជ័យទេ តែទទួលបានមកវិញត្រឹមតែស្លឹកតែមួយហិបប៉ុណ្ណោះ។[៥]

ខណៈដែលលោកត្រូវបានគេបោក នោះក៏ត្រូវដល់ពេលសងលុយសម្រាប់ទំនិញក្នុងហាងស្ម៊ីធទៀត ។ ដោយត្រូវប្រឈមនឹងម្ចាស់បំណុលដែលតម្រូវឲ្យ

សងលុយ នោះក្រុមគ្រួសារស្ម៊ីធបានធ្លាក់ក្នុងស្ថានភាពដ៏អស់សង្ឃឹម ។ ដើម្បីសងបំណុល លូស៊ីបានលះបង់អំណោយអាពាហ៍ពិពាហ៍ដែលនាងបានរក្សាទុកមកជាយូរ ដោយបានលុយមកវិញចំនួន ១000 ដុល្លារ ចំណែកយ៉ូសែប សុខចិត្តលក់ចម្ការរបស់ក្រុមគ្រួសារនៅភូមិថុនប្រិជន៍ ក្នុងតម្លៃ ៨00 ដុល្លារ ។[៦] ចម្ការគឺជារបស់តែមួយគត់ដែលយ៉ាងហោចណាស់អាចធានាបាននូវស្ថេរភាព សេដ្ឋកិច្ចបន្តិចបន្តួច និង ផ្តល់ជាសន្តិសុខខាងរាងកាយបានយូរអង្វែង ក្នុងពិភពដ៏ឃោរឃៅនៃដែនដីអាមេរិកដែលមិនទាន់មានស្ថេរភាពនោះ ។ ឥឡូវនេះ ដោយគ្មានប្រាក់ ហើយគ្មានដី នោះក្រុមគ្រួសារស្ម៊ីធត្រូវបង្ខំឲ្យផ្លាស់ប្តូរទីលំនៅ ៨ ដង ក្នុងរយៈពេល ១៤ ឆ្នាំ ដោយតែងតែព្យាយាមរកមធ្យោបាយនានាដើម្បីផ្គត់ផ្គង់គ្រួសារ ។

យ៉ាងហោចណាស់មានការផ្លាស់ប្តូរទីលំនៅមួយក្នុងចំណោមការផ្លាស់ប្តូរទាំងនោះ ដែលបណ្តុះបណ្តាលមកពីការលំបាកផ្នែកហិរញ្ញវត្ថុ ដោយត្រូវបង់ថ្លៃថ្នាំដោយសារតែជំងឺគ្រុនសណ្តាំដែលរាតត្បាតយ៉ាងខ្លាំងក្នុងឆ្នាំ ១៨១៣ ដែលបានឆ្លងយ៉ាងធ្ងន់ធ្ងរដល់កូនៗទាំងអស់របស់ក្រុមគ្រួសារស្ម៊ីធ ។ ពីរបីសប្តាហ៍

ផ្លូវដ៏ឈឺចាប់មួយ

មានមូលហេតុដ៏ជាក់មួយ ដើម្បីជឿថា ព្រឹកព្រលឹមនៃការនិមិត្តដំបូងគឺរុងរឿង ហើយក៏សូប់ស្ងាត់ដូចជាទំនុកតម្កើង « ការអធិស្ឋានដំបូងរបស់យ៉ូសែប ស្ម៊ីធ »[២] បានប្រាប់ ។ ប៉ុន្តែ ខណៈដែលយើងកំពុងរីករាយនឹងរូបភាពដ៏ស្រស់ស្អាតនេះ នៅក្នុងគំនិត នោះយើងមិនត្រូវភ្លេចពីព្រឹត្តិការណ៍ទាំងឡាយដែលនាំទៅដល់ព្រឹកនោះឡើយ ។ ផ្លូវទៅកាន់ប៉ាលម៉ៃរ៉ា — ជាកន្លែងសាមញ្ញនៃគ្រាដ៏ពិសិដ្ឋ និង គ្មានពីរ — ជាផ្លូវនៃភាពដ៏ផ្អែមល្ហែម និង ពន្លឺសម្រាប់ក្មេងប្រុសជាព្យាការីនេះ និង ក្រុមគ្រួសារលោក ។

ឪពុកម្តាយរបស់ព្យាការី យ៉ូសែប ស្ម៊ីធ សឺញ៉ារ និង លូស៊ី ម៉ាក ស្ម៊ីធ បានរៀបការក្នុងភូមិ ថុនប្រិដច៍ រដ្ឋ វ៉ឺម៉ន្ត ស.រ.អា ក្នុងឆ្នាំ ១៧៩៦ ។ ប្រាំមួយឆ្នាំក្រោយពីការធ្វើចម្ការមិនសូវទទួលបានផល នោះក្រុមគ្រួសារស្ម៊ីធ បានប្តូរមកនៅជិតភូមិរេនដូល ដើម្បីសាកបើកហាងរកស៊ីវិញ ។[៣]

ទំនិញដែលយ៉ូសែប សឺញ៉ារ បានទទួល ដោយមកពីជំនួយរបស់អ្នកឲ្យខ្ចីប្រាក់នៅទីក្រុងបោស្តុន លក់ដាច់យ៉ាងខ្លាំងទៅដល់អតិថិជនថ្មីថ្មោងដែលចង់បាន — មិនបានជាលុយទេ តែបានជាការសន្យាថានឹងសងវិញពេលប្រមូលផលនៅចុងរដូវ ។ ខណៈដែលលោករង់ចាំការសងមកវិញដែលគេសន្យា ដើម្បីលោកអាចយកទៅសងម្ចាស់បំណុលវិញ នោះលោកបានឈោងចាប់យកឱកាសបណ្តាក់ទុនថ្មីមួយទៀត ។

នៅសម័យនោះ ទីផ្សារចិនកំពុងត្រូវការរកទិញឫសយិនសិន ។ ថ្វីបើឈ្មួញកណ្តាលបានសុខចិត្តផ្តល់លុយ ៣000 ដុល្លារ ដល់យ៉ូសែប សឺញ៉ារ សម្រាប់ឫសយិនសិនដែលលោកបានប្រមូលបាន និង បានរៀបចំបញ្ជូនទៅក្តី ក៏លោកបានសម្រេចចិត្តប្រើយុទ្ធសាស្ត្រដែលមានហានិភ័យខ្ពស់ជាង ប៉ុន្តែអាចជាយុទ្ធសាស្ត្រដែលផ្តល់កម្រៃចំណេញច្រើនជាង ដោយលោកបានយកទំនិញទៅនូវយ៉ោកដោយខ្លួនឯង ហើយចុះកិច្ចសន្យាជាមួយមេកប៉ាល់ ដើម្បីឲ្យមេកប៉ាល់នោះលក់ទំនិញនៅស្រុកចិនជំនួសលោក ។ ដោយការកាត់ចោលឈ្មួញកណ្តាល នោះលោកអាចនឹងទទួលកម្រៃបាន ៤៥00 ដុល្លារ — ជាចំនួនដ៏ច្រើនក្រៃលែងនៅជំនាន់នោះ ។[៤]

ពេលយ៉ូសែបបានមកដល់ប៉ាល់ម៉ៃរ៉ា ព្រះអម្ចាស់បាននាំមកនូវព្យាការីរបស់ទ្រង់ដែលត្រូវបានតែងតាំងតាំងពីមុនកំណើតផែនដីមក មកដល់កន្លែង — ភ្នំមួយនៅជិតនោះ — ដែលលាក់ទុករតនៈសម្បត្តិដែលមានតម្លៃឥតគណនា ។

បន្ទាប់ពីបានជាពីជំងឺគ្រុនសណ្ដំ យ៉ូសែបបានមានការឈឺចាប់យ៉ាងក្រៃលែងនៅត្រង់ស្មារបស់លោក ។ គ្រូពេទ្យក្នុងភូមិបានធ្វើពាគវិនិច្ឆ័យខុស ដោយថា ការឈឺចាប់នោះគឺដោយសារការគ្រេច ។ ពីរសប្ដាហ៍ក្រោយមក ពេលដែលការឈឺចាប់នោះរឹតតែឈឺខ្លាំងឡើងហួសប្រមាណ នោះគ្រូពេទ្យបានត្រឡប់មកវិញ ហើយបានរកឃើញថា មេរោគឆ្លងនោះគឺជាប់ទាក់ទងនឹងគ្រុនសណ្ដំដែលសអូសបន្លាយរបស់ យ៉ូសែបប ។[7]

គេវះបង្ហូរយកបាននូវខ្ទុះមេរោគនោះប្រហែលមួយលីត្រ ប៉ុន្តែទម្រង់ការនោះមិនបានសម្រេចឡើយ ហើយមេរោគថ្មីបានឆ្លងទៅដល់ផ្នែកខាងក្រោមនៃជើងឆ្វេងរបស់យ៉ូសែប ។ ដូច្នេះ គេក៏បានហៅគ្រូពេទ្យវះកាត់មក ។ គ្រូពេទ្យបានបដិសេធជម្រើសទាំងពីរនោះ ។ តែលោកបានដាក់សំណើពីរវិញ—គឺថា សូមឲ្យឪពុកលោកក្រកងបីលោក និង សូមឲ្យម្ដាយលោកចេញពីបន្ទប់ ។[10]

ពេលយ៉ូសែបយំស្រែកខ្លាំងពេកហួតឮដល់ម្ដាយលោក ធ្វើឲ្យគាត់ពុំអាចឈរនៅឆ្ងាយពីបន្ទប់បាន នោះគាត់បានចូលមកក្នុងបន្ទប់ពីរដង ទោះមានការប្រកែកអង្វររបស់លោកក្ដី ។ អ្វីដែលគាត់បានឃើញនោះធ្វើឲ្យដក់ជាប់នូវអនុស្សាវរីយ៍ដែលមិនអាចលុបបានឡើយ ។ គឺឃើញយ៉ូសែបដេកស្ដូកស្ដឹងនៅក្នុងថ្លុកឈាមលើគ្រែ « ស្លាំងដូចសាកសព [ដោយមាន] តំណក់ញើសធំៗ . . . ហូរចុះលើមុខគាត់ ខណៈដែលទឹកមុខគាត់បង្ហាញពីការឈឺចាប់វេទនាខ្លាំងបំផុត » ។[11] សំណាងល្អ ការវះកាត់នោះបានទទួលជោគជ័យ

វះ អស់ប្រវែង ២០ សង់ទីម៉ែត្រ គឺចាប់ពីក្បាលជង្គង់ដល់កែងជើង ដែលជួយសម្រាលនូវការឈឺចាប់ ។ ជាអកុសល មេរោគនោះបានចូលទៅក្នុងឆ្អឹង ។[8]

មកដល់ត្រឹមនេះ ក្រុមគ្រួសារបានស្វែងរកជំនួយពីផ្នែកវេជ្ជសាស្ត្រចុងក្រោយបំផុតពីអ្នកជំនាញខាងវេជ្ជសាស្ត្រនៅមហាវិទ្យាល័យវេជ្ជសាស្ត្រដាតម៉ោស៍ ។ លូស៊ីបានទទូច *កុំ* ឲ្យគេប្រើទម្រង់ការព្យាបាលដោយកាត់ជើងតាមបែបបុរាណ និង ដែលគេធ្វើច្រើនបំផុតនាពេលនោះ ។ ផ្ទុយទៅវិញ ក្រុមគ្រួសារស្មីធ នឹងសាកល្បងទម្រង់ការថ្មី និង ដ៏ឈឺចាប់មួយ — ជាទម្រង់ការមួយដែលគេពុំបានសន្យាថានឹងមានជោគជ័យនោះទេ ។ គ្រូពេទ្យនឹងកាត់បើកជើងរបស់យ៉ូសែប ហើយចោះរន្ធពីរនៅសងខាងឆ្អឹង ។ បន្ទាប់មក គេនឹងច្រឹបឆ្អឹងបីកន្លែងដើម្បីយកមេរោគចេញឲ្យអស់ ។[9]

ទម្រង់ការទាំងអស់នេះធ្វើឡើងដោយគ្មានថ្នាំស្ពឹកដូចយើងសព្វថ្ងៃនេះទេ ។ ជាលទ្ធផល ក្រុមគ្រួសារត្រូវបានគេជម្រុញឲ្យផ្ដល់ស្រាដល់យ៉ូសែប ឬ ចងលោកទៅនឹងគ្រែ ដើម្បីកុំឲ្យលោកកន្ត្រាក់ដោយឈឺចាប់ក្នុងអំឡុងពេលនៃការធ្វើទម្រង់ការដ៏ឈឺចាប់នោះ ។ ទើបនឹងមានអាយុប្រាំពីរឆ្នាំប៉ុណ្ណោះ តែយ៉ូសែបបានប៉ុន្តែ យ៉ូសែបបានប្រើឈើច្រត់រយៈពេលបីឆ្នាំក្រោយពីការវះកាត់នោះ ។

បន្ទាប់ពីបទពិសោធន៍ដ៏លំបាកនេះ ក្រុមគ្រួសារបានសង្ឃឹមថា ការចាប់ផ្ដើមជាថ្មីនៅភូមិ ណូវិច រដ្ឋ វ៉ែម៉ុន្ត នឹងនាំមកនូវស្ថេរភាពពិង ភាពចំរុងចម្រើនដែលពួកគេខំស្វែងរកជាបន្ទាន់នោះ ។ ប៉ុន្តែជាថ្មីម្ដងទៀតក្ដីសង្ឃឹមរបស់ពួកគេត្រូវរលាយសាបសូន្យ ។ នៅឆ្នាំដំបូងដែលពួកគេបានព្យាយាមធ្វើស្រែចម្ការនៅលើដីជួយ នោះដំណាំរបស់ពួកគេមិនបានផលទេ ។ នៅឆ្នាំទីពីរក៏មិនបានផលទៀត ។ ក្នុងឆ្នាំទីបី គឺឆ្នាំ ១៨១៦ យ៉ូសែប ស្មីធ ស៊ីញ៉ រ បានតាំងចិត្តសាកល្បងម្ដងទៀត ដោយជឿថា អ្វីៗនឹងប្រសើរឡើង ។[12]

នៅឯម្ខាងទៀតនៃផែនដី ក្នុងឆ្នាំ ១៨១៥ នោះភ្នំថេមបូរ៉ាក្នុងប្រទេសឥណ្ឌូនេស៊ី បានផ្ទុះ ហើយបានព្រួសចេញនូវផេះជាច្រើនទៅក្នុងបរិយាកាសផែនដី ដែលបានធ្វើឲ្យបង្កាក់ដល់ដំណើរវិវឌ្ឍន៍ជាធម្មតារបស់អាកាសធាតុ ។ តាំងពីខែ មិថុនា រហូតដល់ខែ សីហា ឆ្នាំ ១៨១៦ — ត្រូវបានគេហៅថា « ឆ្នាំដែលគ្មានរដូវក្ដៅ » — នោះមានកំណកទឹកកកកកឡើងនៅតំបន់ នូវ អង់គ្លេស បំផ្លាញអស់ដំណាំដែលដាំនៅរដូវក្ដៅនោះទៀត ។[13]

រូបថតនៃភ្នំកូមូរ៉ា បានទទួលការអនុញ្ញាតពី បណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ

ដោយមានគ្រោះមហន្តរាយ ហើយប្រជាជនរាប់ពាន់នាក់បាននាំក្រុមគ្រួសារចាកចេញពីរដ្ឋ វីរម៉ុន្ត នោះយ៉ូសែប ស៊ីញ្ញ័រ បានធ្វើអ្វីដែលចាំបាច់បំផុតដែលលោកអាចធ្វើបាន ។ លោកបានសម្រេចចិត្តចាកចេញពីទឹកដីដែលមានប្រវែងប្រមាណ ៣២ គីឡូម៉ែត្រ ជាទឹកដីដែលមានក្រុមគ្រួសារ មិត្តភក្តិ និង ដីចម្ការដែលលោកបានស្គាល់អស់មួយជីវិតមជ្ឈិមវ័យរបស់លោក ហើយបានធ្វើដំណើរ ៤៨២ គីឡូម៉ែត្រ ទៅទិសនិរតី ទៅកាន់ទីក្រុងប៉ាលម៉ៃរ៉ានៅប៉ែកខាងលើនៃរដ្ឋ នូវ យ៉ោក ។ នៅទីនោះ ត្រូវបានគេផ្តល់ដំណឹងថា ដីមានជីជាតិ ហើយក៏មានការផ្តល់ឥណទានក្នុងរយៈពេលយូរអង្វែងផងដែរ ។ ដោយមានភាពចាំបាច់ នោះយ៉ូសែប ស៊ីញ្ញ័រ បានចាកចេញទៅមុន ដោយទុកលូស៊ី និង កូនៗទាំងប្រាំបីនាក់ ឲ្យរៀបចំឥវ៉ាន់ និង ផ្ទះសម្បែង ហើយទៅតាមលោក ។[១៤]

វាជារដូវរងា នៅពេលលូស៊ី និង កូនៗដ៏ក្លាហានរបស់នាងបានដាក់របស់របរគ្រប់យ៉ាងដែលពួកគេមានទៅលើគារទឹកកក ហើយបន្ទាប់មកទៅក្នុងរទេះ ។ បន្ទាប់ពីបានសងលុយទៅកាន់ម្ចាស់បំណុលមួយចំនួនហើយ លូស៊ីមានលុយតែបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ការធ្វើដំណើរ ។ ទម្រាំការធ្វើដំណើរ

ចប់ នាងបានឲ្យសំលៀកបំពាក់ និង ថ្នាំសង្កូវជាថ្នូរនឹងថ្លៃឈ្នួលផ្ទះសំណាក់ ។ នាងបានរំឭកពីការមកដល់ប៉ាលម៉ៃរ៉ា ដោយមានសល់ « លុយតែពីរសេនប៉ុណ្ណោះ » ។[១៥]

នៅតាមផ្លូវ បុរសដែលត្រូវបានជួលឲ្យបរគារទឹកកក បានបង្ខំឲ្យយ៉ូសែបដ៏ក្មេងខ្ចីចុះ ដើម្បីទុកកន្លែងឲ្យកូនស្រីស្រស់ស្អាតរបស់ក្រុមគ្រួសារហ្គេត ដែលពួកគេបានជួបក្នុងការធ្វើដំណើរទៅតាមផ្លូវដូចគ្នា ។ យ៉ូសែប — មិនទាន់ទាំងបានជាស្រួលបួលផង — ត្រូវបានបង្ខំឲ្យដើរខ្ចីចៗ « កាត់ព្រំល ៦៤ គីឡូម៉ែត្រក្នុងមួយថ្ងៃ អស់រយៈពេលបួនប្រាំថ្ងៃ » ជាបទពិសោធន៍ដែលលោកហៅថា « ការអស់កម្លាំង និង ការឈឺចាប់ដ៏ទារុណបំផុត » ។[១៦]

ពេលបងប្រុសដ៏មានភក្តីភាពរបស់យ៉ូសែប គឺហៃរុម និង អាលវិន បានអង្វរដល់បុរសនោះឲ្យបន្ធន់ចិត្ត នោះគាត់បានវាយពួកលោកដោយហឹង្សាដួលទៅលើដី ។ ពេលទៅដល់ទីក្រុងយូធីកា ពេលដែលមើលទៅឃើញថា លូស៊ីមិនមានប្រាក់ទៀត បុរសនោះបានបោះបង់ចោលគ្រួសារស្មើធ — ប៉ុន្តែមិនចាកចេញភ្លាមទេ វាបានព្យាយាមលួចរទេះរបស់ពួកគាត់ ប៉ុន្តែត្រូវពួកគាត់តាមទាន់ពេលកំពុងបោះតវ៉ាន់ចោលទៅលើដី ។[១៧] ទោះយ៉ាងណា ពួកគាត់បានបន្តទៅមុខរហូតមកដល់ប៉ាលម៉ៃរ៉ាដោយសុវត្ថិភាព ដោយរត់ទៅក្នុងរង្វង់ដៃយ៉ូសែប ស៊ីញ្ញ័រ ទាំងទឹកភ្នែករហាម ។

ប្រហែលរឿងពិស្តារនៃការធ្វើដំណើរដ៏រន្ធត់ចិត្តបំផុតនេះ គឺមាននៅក្នុងបច្ឆាលិខិតដែលមិនត្រូវបានឲ្យតម្លៃ ដែលក្រោយមកយ៉ូសែបបានបន្ថែមទៅក្នុងដំណើររឿងដើមនៃការធ្វើដំណើររបស់ក្រុមគ្រួសារលោក ៖ « នៅតាមផ្លូវពីទីក្រុងយូធីកា ខ្ញុំត្រូវបានទុកឲ្យនៅជិះលើគារទឹកកកក្រោយគេបំផុតក្នុងក្រុម ប៉ុន្តែពេលគារនោះមកដល់ អ្នកបរដែលជាកូនប្រុសម្ចាស់របស់ក្រុមគ្រួសារហ្គេត បានវាយខ្ញុំ ហើយទុកឲ្យខ្ញុំដេកស្កុកស្តឹងក្នុងថ្ពក់ឈាមរបស់ខ្ញុំ រហូតទាល់តែមានមនុស្សមិនស្គាល់គ្នាម្នាក់បានមកត្រកងខ្ញុំឡើង ហើយលើខ្ញុំទៅកាន់ទីក្រុងប៉ាលម៉ៃរ៉ា » ។[១៨] សារៈសំខាន់នៃរឿងនេះមិនគួរត្រូវបានមើលរំលងនោះទេ ។

រតនៈសម្បត្តិដែលមានតម្លៃលើសលុបមិនអាចកាត់ថ្លៃបាន

តែបីគីឡូម៉ែត្រនៅខាងត្បូងពីកណ្តាលក្រុងប៉ាលម៉ៃរ៉ាប៉ុណ្ណោះ មានព្រៃមួយដែលនឹងក្លាយជាទីកន្លែងនៃទស្សនៈនិមិត្តដ៏អស្ចារ្យបំផុតមួយក្នុងប្រវត្តិសាស្ត្រមនុស្សលោក ។ ប្រាំគីឡូម៉ែត្រពីកន្លែងនោះ គឺភ្នំគូម៉ូរ៉ា ជាកន្លែងទុកផ្ទាំងចំណារមាសដែលពុំមាននរណាដឹងនៅពេលនោះទេ ។

ពេលយ៉ូសែបបានមកដល់ប៉ាលម៉ៃរ៉ា ព្រះអម្ចាស់បាននាំមកនូវព្យាការីរបស់ទ្រង់ដែលត្រូវបានតែងតាំងតាំងពីមុនកំណើតផែនដីមក មកដល់កន្លែងដែលលាក់ទុករតនៈសម្បត្តិដែលមានតម្លៃតតណានា ។ រតនៈសម្បត្តិនេះនឹងផ្តល់ជាសញ្ញាថា បន្ទាប់ពីភាពងងឹង និង ការភ័ន្តច្រឡំខាងវិញ្ញាណជាទូទៅអស់ជាច្រើនសតវត្សមក នោះស្ថានសួគ៌បានបើកទ្វារម្តងទៀត ។ រតនៈសម្បត្តិនេះនឹងបង្ហាញថា ការបម្រើរបស់ព្រះយេស៊ូវគឺមានភាពទូលំទូលាយទាំងខាងគោលលទ្ធិ និង ខាងភូមិសាស្ត្រជាងដែលសាសនាចក្រគ្រីស្ទានទាំងឡាយនៅជំនាន់នោះអាចដឹង ។ រតនៈសម្បត្តិនេះនឹងបញ្ជាក់នៅក្នុងរបៀបដ៏អស្ចារ្យក្រៃលែងថា ព្រះពិតជាសកម្មពេញលេញតតចន្លោះក្នុងកិច្ចការរបស់មនុស្សគ្រប់ពេលវេលា ភាសា និង ទ្វីប ។ ហើយរតនៈសម្បត្តិនេះនឹងសន្យានូវការបង្រៀនដ៏សច្ចៈ និង ពោរពេញដោយព្រះចេស្តា ដែលថាបើសិនជាអ្នកដាំវាចូលយ៉ាងជ្រៅទៅក្នុងព្រលឹងអ្នក នោះអ្នកអាចត្រូវបានប្រែរូប បានភ្លក់នូវអ្វីដែលឆ្ងាញ់បំផុត ដូចជាមាននូវពិធីជប់លៀងមួយដែលមិនអាចប្រៀបផ្ទឹមបាន និង ដ៏ខ្ពង់ខ្ពស់បំផុតតាមការប្រាថ្នាចង់បានរបស់អ្នក ។

ជាមួយនឹងភ្នែកខាងជីវិតរមែងស្លាប់ យើងអាចនឹងត្រូវបានល្បួងឲ្យស្រមៃឃើញថា មានផ្លូវដ៏សក្តិសមសម្រាប់បុរសម្នាក់ដូចនេះ និង សម្រាប់គ្រាបែបនេះ គួរជាផ្លូវមួយដែលងាយស្រួលជាង ល្អជាង និង រីករាយសាទរជាងនេះ ។ ក្នុងការទទួលស្គាល់នូវព្រឹត្តិការណ៍ដែលរន្ធឺដល់ផែនដី ដែលហៀបនឹងកើតឡើង ដែលជាលទ្ធផលនៃការចូលមកដល់ក្នុងទីក្រុងនេះរបស់ក្មេងប្រុសនេះនៅពេលនេះ តើព្រះអម្ចាស់ ជាអង្គដែលបានរៀបគម្រោងដ៏ប្រុងប្រយ័ត្នក្នុងការដាក់ទុកនូវផ្ទាំងចំណារមាស អស់ជាងមួយពាន់ឆ្នាំមកហើយនោះ មិនអាចផ្តល់នូវផ្លូវដែលត្រង់ជាង ងាយស្រួលជាង និង ឲ្យបានដឹងជាមុនទេឬអី ?

មែនហើយ ទ្រង់ពិតជាអាចធ្វើបាន ប៉ុន្តែទ្រង់មិនបានធ្វើដូច្នោះទេ ។

ពុំមាននូវការចាក់ប្រេងតាំងពេលលោកនៅវ័យក្មេងនោះទេ (សាំយូអែល

មិនឆ្ងាយប៉ុន្មាននៅខាងត្បូងក្រុងប៉ាលម៉ៃរ៉ា មានព្រៃមួយដែលនឹងក្លាយជាទីកន្លែងនៃការនិមិត្តដ៏ធំបំផុតមួយក្នុងប្រវត្តិសាស្ត្រមនុស្សលោក ។

ទី១ ១៦:១១–១៣) ។ ពុំមាននូវការសុបិន្តចំៗ ចង្អុលគាត់ឲ្យទៅដែនដីសន្យានោះទេ ។ (សូមមើល នីហ្វៃទី ១ ១ ៥:៤–៥) ។ ពុំមានលើអាហារណាដើម្បីជួយក្រុមគ្រួសារលោកឲ្យចៀសផុតពីការដើរខុសនៅតាមផ្លូវនោះដែរ (សូមមើល នីហ្វៃទី១ ១៦:១០; អាលម៉ា ៣៧:៣៨) ។ ហើយប្រាកដណាស់ថាគ្មានយានយន្តបើកដំបូលទំនើបដឹកលោកកាត់ភ្លូនព្យុះហយាគ្រាក្រោមថ្ងៃចែងចាំងដែលមានហ្វូងមនុស្សកុះករអបអរសាទរនោះដែរ ។

ផ្ទុយពីនោះ សម្រាប់យ៉ូសែប និង ក្រុមគ្រួសារ មាននូវការសាកល្បងទុក្ខវេទនាដ៏ជូរចត់ ដែលមានដូចជាសំណាងអាក្រក់ ជំងឺ ការរិនិច្ឆ័យខុស គ្រោះធម្មជាតិ ការឈឺចាប់ហួសប្រមាណ ភាពអយុត្តិធម៌ឥតមេត្តា ភាពងងឹតជាបន្តបន្ទាប់ និង ភាពក្រីក្រឥតស្រាកស្រាន្ត ។ ការណ៍នេះមិនបាននិយាយថាក្រុមគ្រួសារស្មីធបានរស់នៅក្នុងវដ្តនៃសេចក្តីវេទនាតែមួយរហូតនោះទេ ។ ប៉ុន្តែផ្លូវទៅកាន់ប៉ាលម៉ៃរ៉ាពុំមែនជាផ្លូវត្រង់ ចម្រុងចម្រើន និង ដែលគួរឲ្យកត់សម្គាល់ជាសារធាណៈនោះទេ ។ ដោយដើរខ្ចៃចៗ យឺតៗ និង ដោយហូរចេញឈាមនោះព្យាការីត្រូវបានលីសែងដោយមនុស្សមិនស្គាល់ឈ្មោះម្នាក់ ទៅកាន់ជោគវាសនាមួយដែលពិសេសគ្មានពីរ ។

សូមចងចាំថា នោះប្រហែលជាមេរៀនដំបូងបំផុតនៃជីវិតរបស់យ៉ូសែប និងការលេចចេញមកនៃព្រះគម្ពីរមរមន ។ ថ្វីបើមានការបរាជ័យ គ្រោះអកុសល និងស្ថានភាពល្ងីងជូរចត់ក្តី — ហើយក្នុងករណីជាច្រើនគឺប្រាកដជា *ដោយសារ* រឿងអាក្រក់ទាំងនោះ — ក៏យ៉ូសែប ស្មីធ បានទៅដល់កន្លែងដែលលោកត្រូវការដើម្បីបំពេញបេសកកម្មរបស់លោក ។ ដូច្នេះ បើតឡូវនេះ ឬ ក្នុងថ្ងៃអនាគតណាមួយ អ្នកមើលជុំវិញខ្លួនអ្នក ហើយឃើញថា មនុស្សជទៃទៀតហាក់ដូចជាពុំសូវលះបង់កំពុងជោគជ័យក្នុងការងារខ្លួន ខណៈដែលអ្នកបរាជ័យបើសិនជាអ្នកមានជំងឺកាចសាហាវមានលើរូបអ្នកនៅចំពេលដែលមានការហៅបម្រើសំខាន់បានមកដល់ឬ បើសិនជាអ្នកត្រូវបានហៅបម្រើក្នុងតំណែងដែលមានហាន:មុខមាត់ខ្ពស់ ត្រូវផ្តល់ទៅឲ្យនរណាម្នាក់ផ្សេងទៀត បើសិនដៃគូផ្សព្វផ្សាយសាសនារបស់អ្នកហាក់បីដូចជារៀនភាសាបានលឿនជាងអ្នកបើសិនសកម្មភាពដោយចេតនានានាំទៅរកភាពមហន្តរាយជាមួយនឹងដៃគូ សមាជិកវួដ អ្នកជិតខាង ឬសាសនាគន់ការ បើសិនមានជំណឹងពីផ្ទះពីការលំបាកផ្នែកហិរញ្ញវត្ថុ ឬ សោកនាដកម្មខាងជីវិតរមែងស្លាប់ដែលអ្នកពុំអាចធ្វើអ្វីបាន ឬ ប្រសិនបើ ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកមានអារម្មណ៍ដូចជាមនុស្សធម្មតា និង គ្រាន់តែជាអ្នកសម្តែងដំណឹងល្អនៅក្នុងរឿងល្ខោនបេសកកម្មមួយដែលគ្រាន់តែសម្រាប់ភាពសប្បាយរបស់អ្នកដទៃ *នោះសូមដឹងដូចនេះថា ៖* មានរឿងរ៉ាវជាច្រើន ដែលយ៉ូសែប ស្មីធ បានទ្រាំទ្រដោយខ្លួនលោកផ្ទាល់ គឺនៅគ្រានោះតែម្តង ជាគ្រាដែលលោកត្រូវបានដឹកនាំទៅកាន់ឆាកនៃរឿងមួយដែលវិសេសវិសាលបំផុត ដែលនឹងកើតឡើងនៅលើផែនដីនេះ តាំងពីព្រឹត្តិការណ៍នៅគាល់កូថាដែលស្រាយថាភ្នំរលាក្បាលនិង សួនផ្សរ ជិត ២០០០ ឆ្នាំមុន ។

« ប៉ុន្តែ » អ្នកអាចនិយាយថា « ជីវិត និង ជោគវាសនាខាងលោកិយរបស់ខ្ញុំនឹងមិនដូចជាឆាកជីវិតរបស់ព្យាការី យ៉ូសែប ឡើយ » ។

នោះប្រហែលជាការពិត ។ ប៉ុន្តែ វាជាការពិតថា ជីវិតរបស់អ្នកពិតជាសំខាន់ណាស់ចំពោះព្រះ ហើយសក្តានុពលភាពដ៏អស់កល្បរបស់អ្នក និង គ្រប់ព្រលឹងទាំងអស់ដែលអ្នកនឹងជួប គឺពុំមែនមានភាពសំខាន់តិចជាងព្យាការី យ៉ូសែប នោះឡើយ ។ ហេតុដូច្នេះហើយ គឺដូចជាយ៉ូសែប ជាទីស្រឡាញ់របស់យើងដែរ អ្នកមិនត្រូវបោះបង់ចោល មិនត្រូវចុះចាញ់ឡើយ នៅក្នុងជីវិតទូទៅ ឬ ជាពិសេសកិច្ចការផ្សព្វផ្សាយសាសនាទទួលការឈឺចាប់ ការភ័ន្តច្រឡំ ឬ ធុញទ្រាន់ពេញទំហឹងនោះ ។ ផ្ទុយទៅវិញ ដូចជាប៉ុលបង្រៀន អ្នកត្រូវតែឃើញថា « *គ្រប់* ការណ៍ទាំងអស់ផ្សំគ្នាសម្រាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមកតាមព្រះតំរិះទ្រង់ » (រ៉ូម ៨:២៨ ការសង្កត់ន័យត្រូវបានបន្ថែម) ។

ដូចជាទ្រង់បានធ្វើជាមួយនឹងយ៉ូសែប ស្មីធ ក្មេងខ្ចីដែរ ព្រះកំពុងតែដុសខាត់ និង តម្រែតម្រង់អ្នកជារៀងរាល់ថ្ងៃសម្រាប់គោលបំណងទាំងឡាយដែលរុងរឿងជាងដែលអ្នកអាចដឹង ! ■

ចេញពីការប្រជុំជម្រុនិដ្ឋាន « ការបង្កើតព្រះគម្ពីរមរមន យ៉ូសែប ស្មីធ និង អ្នក » ដែលត្រូវបានផ្តល់នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកផ្សព្វផ្សាយសាសនា ទីក្រុង ប្រ៊ូរ រដ្ឋ យូថាហ៍ នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ ។ ម៉ាថាយ អេស ហូឡិន ជានាយកសាកលវិទ្យាល័យយូថាហ៍វែលលី ។

កំណាត់ចំណាំ

១. យ៉ូសែប ស្មីធ — ប្រវត្តិ ១:១៤ ។

២. *ទំនុកតម្កើង* លេខ ២៦ ។

៣. សូមមើល Lucy Mack Smith, *Biographical Sketches of Joseph Smith, the Prophet, and His Progenitors for Many Generations* (ឆ្នាំ ១៨៥៣) ទំព័រ ៣៧, ៤៥ ។ សម្រាប់ការសង្ខេបខ្លីនៃព្រឹត្តិការណ៍ទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅរបស់ក្រុមគ្រួសារស្មីធទៅកាន់ប៉ាលម៉ៃរ៉ា សូមមើ Richard Lyman Bushman, *Joseph Smith: Rough Stone Rolling* (ឆ្នាំ ២០០៥) ទំព័រ ១៧–២៩ ។

៤. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ ៤៩ ។

៥. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ ៤៩–៥០ ។

៦. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ ៥១ ។

៧. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ ៦០, ៦២ ។

៨. សូមមើល Lucy Mack Smith, Biographical Sketches, ទំព័រ ៦២–៦៣ ។

៩. សូមមើល LeRoy S. Wirthlin, "Joseph Smith's Boyhood Operation: An 1813 Surgical Success," BYU Studies ២១, លេខ ២ (ឆ្នាំ ១៩៨១): ១៤៦–៥៤ ។

១០. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ ៦៤ ។

១១. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ ៦៥ ។

១២. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ ៦៦ ។

១៣. សូមមើល *Church History in the Fulness of Times,* 2nd ed. (ឆ្នាំ ២០០៣) ទំព័រ ២៤ ។

១៤. សូមមើល Lucy Mack Smith, *Biographical Sketches,* ទំព័រ 67 ។

១៥. Lucy Mack Smith, *Biographical Sketches,* ទំព័រ ៦៨, ៧០ ។

១៦. Joseph Smith, នៅក្នុង *The Papers of Joseph Smith,* ed. Dean C. Jessee, រំលុ ២ (ឆ្នាំ ១៩៨៩), ១:២៦៨ ។

១៧. សូមមើល *The Papers of Joseph Smith,* ១:២៦៨ ។

១៨. Joseph Smith, នៅក្នុង *The Papers of Joseph Smith,* ១:២៦៨–៦៩ ។

ការស្វែងរក

ការសង្គ្រោះ

ដោយ ខននី ហ្គូលឌីង

នៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១០ អ្នករុករករ៉ែជនជាតិឈីលី ៣៣ នាក់ ត្រូវបានជាប់ដោយការបាក់រលំភ្លាមៗយ៉ាងសម្បើម បន្ទាប់ពីថ្មនៅខាងក្នុងអណ្តូងរ៉ែនោះត្រូវបាក់ ។ ពួកគេបានជាប់នៅនឹងកន្លែងសុវត្ថិភាពតូចមួយ តាមផ្លូវចុះទៅអណ្តូងរ៉ែដែលនៅពីក្រោមចំនុចបាក់រលំនោះ ដែលមានជម្រៅប្រមាណ ៧០០ ម៉ែត្រ ទៅក្រោមដី ។

វាជាស្ថានភាពដ៏គួរឲ្យអស់សង្ឃឹម ។ ពួកគេត្រូវបានបំបែកចេញពីផ្ទះ និងក្រុមគ្រួសារ ដោយមានថ្មដែលមិនអាចរំកិលបានកំពស់ប្រមាណជិតមួយគីឡូម៉ែត្រនៅពីលើក្បាល ហើយពួកគេមានម្ហូបអាហារ និង ទឹកតែបន្តិចបន្តួចប៉ុណ្ណោះ ។ ថ្វីបើពួកគេមានឧបករណ៍ និង ចំណេះដឹងក៏ដោយ តែដោយសារតែអណ្តូងរ៉ែនោះពុំមានលំនឹង ពួកគេពុំអាចសង្គ្រោះខ្លួនឯងបានទេ ។ ឱកាសតែមួយគត់របស់ពួកគេ គឺត្រូវបានគេរកឃើញ ហើយត្រូវគេសង្គ្រោះ ។

ថ្វីបើដូច្នោះក៏ដោយ ក៏ពួកគេបានជ្រើសរើសដើម្បីមានសង្ឃឹម ។ ពួកគេបានរៀបចំខ្លួន ចែកចំណែកម្ហូប និង ទឹក ហើយបានរង់ចាំ ។ ពួកគេបានមានសេចក្តីជំនឿថា ពួកអ្នកដែលនៅខាងលើកំពុងតែធ្វើអ្វីៗដែលពួកគេអាចធ្វើ ដើម្បីសង្គ្រោះពួកគេ ។ ទោះបីដូច្នោះក៏ដោយ វាពិតជាពិបាកណាស់ ដែលត្រូវតោងជាប់ទៅនឹងសេចក្តីសង្ឃឹមនោះ ពេលដែលពួកគេបានរង់ចាំនៅក្នុងទីងងឹត ។ ពីមួយថ្ងៃទៅមួយថ្ងៃចេះតែកន្លងទៅ រហូតដល់រាប់សប្តាហ៍ ។ អាហារដែលគេចែកចំណែកដោយប្រុងប្រយ័ត្ននោះក៏អស់ទៅ ។

ខ្ញុំបានរងនូវការលំបាកយ៉ាងធំសម្បើម ក្នុងជីវិតខ្ញុំផ្ទាល់ ។ កូនប្រុសរបស់ខ្ញុំអាយុប្រាំបីឆ្នាំដែលពោរពេញដោយថាមពល កំប្លុកកំប្លែង ហើយស្រស់ស្អាតបានស្លាប់ក្នុងគ្រោះថ្នាក់រថយន្តមួយ នៅពីមុខភ្នែកខ្ញុំ ។ ខ្ញុំបានបីត្រកងរូបកាយគាត់ ពេលដែលឈាមរបស់គាត់ហូរស្រក់ទៅលើផ្លូវ ហើយវិញ្ញាណរបស់គាត់ត្រូវបានបំបែកចេញទៅ ហើយត្រឡប់ទៅផ្ទះនៅស្ថានសួគ៌របស់គាត់វិញ ។ ខ្ញុំបានទូលអង្វរដល់ព្រះវរបិតាសួគ៌ ដើម្បីទុកឲ្យគាត់រស់នៅ ប៉ុន្តែការណ៍នោះមិននៅក្នុងផែនការជីវិតរបស់កូនប្រុសខ្ញុំទេ ។

ខ្ញុំបានវង្វេងនៅក្នុងភាពងងឹត ត្រូវបានសន្ធប់ដោយបន្ទុកនៃទុក្ខព្រួយរបស់ខ្ញុំ ។ ខ្ញុំគ្មានកម្លាំងពលំ មិនអាចសម្រាកបាន ខណៈដែលបញ្ហានៃភាពមែងស្លាប់បាំងគ្របភ្នែកខ្ញុំ ។ ខ្ញុំបានដឹងថា ដួងចិត្តសង្រែងគឺជាអារម្មណ៍ខាងសាច់ឈាមដ៏ពិត ។ ខ្ញុំធ្លាប់តែមានដួងចិត្ត ឥឡូវនេះមានតែភាពទទេស្អាតដែលពោរពេញដោយភាពឈឺចាប់ ។

ដូចជាបុរស ៣៣ នាក់ ដែលត្រូវជាប់ក្នុងការបាក់រលំអណ្តូងរ៉ែនៅប្រទេសឈីលីដែរ យើងអាចមានអារម្មណ៍ថាត្រូវជាប់ដោយការសោកល្វង និង ភាពទន់ខ្សោយរបស់យើង ទោះយ៉ាងណា តាមរយៈផែនការនៃសេចក្តីសង្គ្រោះ នោះយើងអាចរកឃើញសេចក្តីសង្ឃឹមនៃការសង្គ្រោះ ។

ខ្ញុំបានជឿថា ខ្ញុំរឹងមាំគ្រប់គ្រាន់ដើម្បីយកឈ្នះវា ។ មនុស្សជាច្រើនរងទុក្ខច្រើនជាងនោះទៀត ។ ប៉ុន្តែ ដូចជាពួកអ្នករុករករ៉ែ ដែលត្រូវជាប់ដោយថ្មដែលមិនអាចរំកិលចេញបានដែរ ខ្ញុំពុំអាចដកចេញនូវបន្ទុកនៃទុក្ខព្រួយរបស់ខ្ញុំបានឡើយ ។

យើងទាំងអស់គ្នាអាចមានអារម្មណ៍ថាត្រូវជាប់នៅក្នុងរបៀបជាច្រើន ។ មនុស្សខ្លះអាចមានអារម្មណ៍ថាត្រូវជាប់ ដោយការសោកល្វងផ្ទាល់ខ្លួន ភាពទន់ខ្សោយ ឬ កាលៈទេសៈលំបាកនានាក្នុងជីវិត ។ យ៉ាងណាក៏ដោយ មាននូវការលួងលោមក្នុងការដែលដឹងថា ជីវិតរមែងស្លាប់គឺជាពេលមួយដែលយើងត្រូវលូតលាស់ឲ្យកាន់តែរឹងមាំឡើង កាលដែលយើងប្រឈមនឹងទុកព្រួយ និង ភាពសោកសៅរបស់យើង ។ យើងរកឃើញសេចក្តីសង្ឃឹមក្នុងព្រះយេស៊ូវគ្រីស្ទ ។

រស្មីនៃសេចក្តីសង្ឃឹម

នៅថ្ងៃទី ១៧ នៃការលំបាករបស់ពួកគេ នោះចាប់ផ្តើមមានសេចក្តីសង្ឃឹមឡើងវិញសម្រាប់ពួកអ្នករុករករ៉ែ ពេលដែលពួកគេបានប្រើដែកខួងដើម្បីខួងបំបែកថ្មដែលចាំងគេនោះដើម្បីធ្វើជារន្ធបញ្ឆេរតូចមួយ ។

ដោយចង់ឲ្យពួកអ្នកនៅខាងលើបានដឹងថាពួកគេនៅរស់នៅឡើយ នោះពួកបុរសដែលជាប់ក្នុងអណ្តូងរ៉ែបានគោះផ្លែដែកខួង ហើយបានចងក្រណាត់ដែលមានសរសេរពណ៌ក្រហមនៅចុង ។ ក្រណាត់នោះសរសេរថា “Estamos bien en el refugio, los 33” (« ពួកយើងសុខសប្បាយទេនៅក្នុងជម្រកនេះ ពីពួកយើងទាំង ៣៣ នាក់ ») ។ សេចក្តីសង្ឃឹមបានមានឡើងវិញ ។ ពួកគេត្រូវបានរកឃើញ ។

រូបភាពចង្អៀត ISTOCKPHOTO/THINKSTOCK

យើងម្នាក់ៗត្រូវតែជ្រើសរើសប្រគល់ឆន្ទៈរបស់យើងដើម្បីទុកចិត្តលើព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។ សម្រាប់យើងមានផែនការនៃការសង្គ្រោះតែមួយគត់ វាគឺនៅក្នុង និង តាមរយៈការលះបង់ដ៏ធួនរបស់ទ្រង់ ។ ទ្រង់បានយាងចុះមកក្រោមអ្វីៗទាំងអស់ដើម្បីសង្គ្រោះយើង ។

តាមរយៈប្រហោងតូចមួយ ដែលមានរង្វង់ប្រហែលប៉ុនផ្លែទំពាំងបាយជូរមួយប៉ុណ្ណោះ នោះទំនាក់ទំនងមួយត្រូវបានបង្កើតឡើងជាមួយអ្នកនៅខាងលើ ។ ពួកអ្នកជាទីស្រឡាញ់របស់អ្នករ៉ែទាំងនោះបានបញ្ជូនម្ហូបអាហារ ទឹក ថ្នាំសង្កូវ និង សំបុត្រ ទៅក្នុងអណ្តូងរ៉ែនោះ ។

វាប្រកដជាមានអារម្មណ៍លាយឡំគ្នា ដែលពួកអ្នករុករ៉ែបានដឹងពីស្ថានភាពរបស់ខ្លួន ។ ទោះបីពួកគេបានមានសេចក្តីអំណរដ៏លើសលប់ និង បានធូរចិត្ត ដែលពួកគេត្រូវបានរកឃើញក្តី ប៉ុន្តែស្ថានភាពរបស់ពួកគេគឺស្ថិតក្នុងគ្រោះថ្នាក់នៅឡើយ ។ ថ្វីបើពួកអ្នកនៅខាងលើបានដឹងថាពួកគេនៅកន្លែងណាក៏ដោយ ក៏វាត្រូវការពេលវេលាដើម្បីដាក់ផែនការសង្គ្រោះ ហើយពួកគេគ្រាន់តែអាចសង្ឃឹមថា ផែនការនោះនឹងបានសម្រេចប៉ុណ្ណោះ ។

ពួកអ្នកសង្គ្រោះស្ទាក់ស្ទើរនឹងប្រាប់ដល់ពួកអ្នករុករ៉ែថា វានឹងត្រូវចំណាយពេលរាប់ខែ ទើបអាចយកពួកគេមកខាងលើវិញបាន ។ ពួកគេសង្ឃឹមថានឹងយកពួកអ្នករុករ៉ែមកជួបនឹងក្រុមគ្រួសារពួកគេវិញនៅពេលបុណ្យគ្រីស្ទម៉ាស មានន័យថា ពួកអ្នករុករ៉ែត្រូវប្រឈមនឹងថ្មកប់នោះរយៈពេលបួនខែបន្ថែមទៀត ។ ទោះជាយ៉ាងណាក៏ឥឡូវនេះពួកគេបានរង់ចាំជាមួយនឹងក្តីសង្ឃឹម ។

យើងក៏មានស្មើនៃសេចក្តីសង្ឃឹមដែរ ។ តាំងពីមុនផែនដីត្រូវបានបង្កើត មានផែនការមួយត្រូវបានធ្វើឡើង ដើម្បីសង្គ្រោះយើង ។ ព្រះវរបិតាសួគ៌បានប្រទានដល់យើងនូវព្រះអង្គសង្គ្រោះមួយអង្គ ដែលនឹងសង្គ្រោះយើងចេញពីភាពរមែងស្លាប់របស់យើង ពីអំពើបាបរបស់យើង ពីភាពទន់ខ្សោយរបស់យើង និង ពីអ្វីៗទាំងអស់ដែលយើងរងទុក្ខក្នុងជីវិតនេះ ។ ទ្រង់គឺជាអង្គប្រទាននូវសេចក្តីសង្ឃឹម និង ជីវិត ។ ទ្រង់ត្រាយផ្លូវសម្រាប់យើងដើម្បីត្រឡប់ទៅព្រះវរបិតាសួគ៌យើងវិញ និង ដើម្បីបានជួបជុំនឹងមនុស្សជាទីស្រឡាញ់របស់យើងដែលបានស្លាប់ទៅមុនយើង ។ ទ្រង់គង់នៅក្បែរយើង ដើម្បីយកទម្ងន់នៃបន្ទុកដែលយើងរ៉ែក ដើម្បីជូតទឹកភ្នែកយើង និង ដើម្បីប្រទានសេចក្តីសុខសាន្តដល់យើង ។ ទ្រង់បានយាងមកដើម្បីនាំយើងត្រឡប់ទៅផ្ទះវិញ ប្រសិនបើយើងធ្វើតាមផែនការដែលទ្រង់បានដាក់ឲ្យ ។

ការសង្គ្រោះ

ថ្វីបើមានការព្យាយាមខុសៗគ្នាត្រូវបានធ្វើឡើង ដើម្បីសង្គ្រោះដល់ពួកអ្នករុករ៉ែ ប៉ុន្តែមានតែដែកខួងមួយប៉ុណ្ណោះដែលបានខួងតាមផ្លូវត្រង់ តាមរន្ធគំរូតូចមួយដែលត្រូវបានគេខួងពីមុនមកដើម្បីរកមើលកន្លែងដែលពួកអ្នករុករ៉ែនៅ ។

ពួកអ្នករុករ៉ែពុំមែនមិនធ្វើអ្វីសោះនៅក្នុងការសង្គ្រោះនោះទេ ។ ពេលដែលដែកខួងខួងថ្មដើម្បីសង្គ្រោះ នោះមានថ្មធ្លាក់តាមរន្ធតូចៗ ហើយគរជាគំនរនៅក្នុងរូងថ្មដែលពួកអ្នករុករ៉ែទាំងនោះនៅជាប់ ។ ពួកគេបានយកថ្មចេញពេលថ្មធ្លាក់មក ដើម្បីទុកកន្លែងសម្រាប់ដែកខួងធំ ។

ពួកអ្នកសង្គ្រោះបានធ្វើឡាំងមួយដើម្បីសម្រុតចុះទៅក្រោមតាមរន្ធអណ្តូងតូចនោះដោយប្រើខ្សែពួរ ។ ឡាំងសង្គ្រោះនោះគឺគ្រាន់តែធំល្មមសម្រាប់ដាក់មនុស្សម្នាក់ប៉ុណ្ណោះ ។ ឡាំងនោះមានទំហំតូចជាងរន្ធអណ្តូងតែ ១០ សង់ទីម៉ែត្រប៉ុណ្ណោះ ដែលត្រូវសម្រុតចុះទៅក្រោមប្រមាណ ៧០០ ម៉ែត្រ ឆ្លងកាត់ថ្មដ៏តាន់នៅជុំវិញ ។

នៅពេលដែលពេលវេលាមកដល់ដើម្បីសង្គ្រោះពួកអ្នករុករ៉ែទាំងនោះ នោះពួកគេម្នាក់ៗត្រូវប្រឈមនឹងជម្រើសមួយ ។ មនុស្សម្នាក់ម្តងៗចូលក្នុងឡាំង

នោះ ហើយនឹងត្រូវលើកឡើងមកលើតែម្នាក់ឯង ។ ខណៈដែលមនុស្សម្នាក់ៗជ្រើសរើសទុកចិត្តផែនការនោះ នោះគាត់ត្រូវតែមានសេចក្តីសង្ឃឹមថា ឡាំងនោះនឹងត្រូវបានលើកឡើងតាមរន្ធអណ្តូងដ៏ចង្អៀតដោយត្រង់ និង មិនផ្អៀង ហើយជាប់គាំងនឹងថ្ម ។ ផែនការនោះត្រូវតែបានសម្រេច ឬ ត្រូវបាត់បង់សេចក្តីសង្ឃឹមទាំងអស់តែម្តង ។ ពួកអ្នករុករករ៉ែម្នាក់ៗបានចូលក្នុងឡាំង ហើយប្រគល់ការតាំងចិត្តរបស់គាត់ទៅលើផែនការ និង ទៅលើពួកអ្នកសង្គ្រោះ ។

ម្នាក់ម្តងៗ ពួកអ្នករុករករ៉ែបានធ្វើដំណើរតែម្នាក់ឯងមកខាងលើ ចេញពីទីងងឹតមកកាន់ពន្លឺ ។ ពួកគេត្រូវបានស្វាគមន៍ដោយមនុស្សជាទីស្រឡាញ់របស់ពួកគេ ខណៈដែលពិភពលោកទាំងមូលបានមើល និង សាទរ ។

ផែនការសង្គ្រោះបានជោគជ័យ មិនមានបុរសណាម្នាក់ត្រូវបាត់បង់ឡើយ ។ ពួកគេត្រូវបានសង្គ្រោះនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១០ — គឺ ៦៩ ថ្ងៃ បន្ទាប់ពីការបាក់រលំអណ្តូងរ៉ែ និង ៥២ ថ្ងៃ បន្ទាប់ពីពួកគេត្រូវបានរកឃើញថានៅរស់រានមានជីវិត ។

ទុកចិត្តលើជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

ដូចជាពួកអ្នករុករករ៉ែទាំងនោះដែរ ការសង្គ្រោះរបស់យើងគឺជាការសង្គ្រោះម្នាក់ៗ ។ ទោះជាសេចក្តីសង្គ្រោះមានដល់មនុស្សគ្រប់គ្នាក្តី ក៏ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះអង្គសង្គ្រោះ គឺជាទំនាក់ទំនងផ្ទាល់ខ្លួនដ៏ជ្រាលជ្រៅ ។ យើងម្នាក់ៗត្រូវតែជ្រើសរើសប្រគល់ឆន្ទៈរបស់យើងដើម្បីទុកចិត្តលើព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។

ដោយសារតែភាពស័ក្តិសិទ្ធិនៃសិទ្ធិជ្រើសរើសរបស់មនុស្សដែលជីវិតរមែងស្លាប់នេះមាន នោះព្រះអង្គសង្គ្រោះពុំអាចដកយកឆន្ទៈរបស់យើងបានឡើយ ។ យើងមានសេរីភាពដើម្បីជ្រើសរើស ។ ព្រះអង្គសង្គ្រោះទ្រង់គង់នៅក្បែរយើង រង់ចាំព្យាបាលរបួសយើង និង លើកយើងទៅឯសេចក្តីសង្គ្រោះដ៏អស់កល្បជានិច្ច ប៉ុន្តែទ្រង់អាចធ្វើដូច្នោះបាន មានតែដោយការអញ្ជើញរបស់យើងប៉ុណ្ណោះ ។ យើងត្រូវតែជ្រើសរើសយកទ្រង់ ។ សម្រាប់យើង មានផែនការនៃការសង្គ្រោះតែមួយគត់ វាគឺនៅក្នុង និង តាមរយៈការលះបង់ដ៏ធួនរបស់ទ្រង់ ។ ទ្រង់បានយាងចុះមកក្រោមអ្វីៗទាំងអស់ដើម្បីសង្គ្រោះយើង ។

ការសង្គ្រោះរបស់ខ្ញុំបានមានដល់ខ្ញុំ ពេលខ្ញុំបានលុតជង្គង់ចុះក្នុងជម្រៅនៃទុក្ខព្រួយចំពោះការស្លាប់របស់កូនប្រុសខ្ញុំ ។ ដូចជាពួកអ្នករុករករ៉ែពេលដែលពួកគេចូលក្នុងឡាំងសង្គ្រោះដែរ ខ្ញុំបានស្ថិតនៅក្នុងចំនុចស្នូលមួយ ៖ តើខ្ញុំគួរតែព្យាយាមយកឈ្នះឧបសគ្គរបស់ខ្ញុំ ដោយកម្លាំង និង ការចេះដឹងរបស់ខ្ញុំផ្ទាល់ ឬ ខ្ញុំគួរតែឈោងទៅឯព្រះវរបិតាសួគ៌ ហើយសូមជំនួយ ?

ដោយត្រូវបានសង្កត់សង្កិនដោយទម្ងន់នៃទុក្ខព្រួយរបស់ខ្ញុំ នោះខ្ញុំបានសម្រេចចិត្តបែរទៅរកព្រះ ។ កាលដែលខ្ញុំអំពាវនាវដល់ព្រះវរបិតារបស់ខ្ញុំដែលគង់នៅស្ថានសួគ៌ នោះខ្ញុំបានទូលទ្រង់ថា ខ្ញុំទន់ខ្សោយយ៉ាងណា ហើយខ្ញុំបានសូមទ្រង់មេត្តាលើកបន្ទុកនៃទុក្ខព្រួយរបស់ខ្ញុំចេញ ។ មុនពេលដែលខ្ញុំបានក្រោកឈរម្តងទៀត នោះទម្ងន់នៃទុក្ខព្រួយរបស់ខ្ញុំត្រូវបានលើកចេញពីស្មារបស់ខ្ញុំ ។ ខ្ញុំនៅតែត្រូវខំចេញឲ្យផុតពីការឈឺចាប់ និង ការបាត់បង់នោះ ប៉ុន្តែបន្ទុកដែលមិនអាចទ្រាំទ្របាននោះត្រូវបានយកចេញពីខ្ញុំ ។

នៅពេលនោះហើយ ដែលខ្ញុំបានដឹងថា ព្រះអង្គសង្គ្រោះទ្រង់គង់នៅក្បែរយើង រង់ចាំលើកយើងឡើង រង់ចាំឲ្យយើងគ្រាន់តែសូមដល់ទ្រង់ រង់ចាំឲ្យយើងដាក់បន្ទុករបស់យើងលើស្មាទ្រង់ រង់ចាំយើងឲ្យដាក់ដៃយើងក្នុងព្រះហស្តទ្រង់ ដើម្បីទ្រង់អាចសង្គ្រោះយើង ។

យើង — ដូចជាពួកអ្នករុករករ៉ែ ដែលត្រូវតែទាញទ្វារឡាំងបិទ ហើយទុកចិត្តលើពួកអ្នកសង្គ្រោះរបស់ពួកគេដែរ — ត្រូវតែដាក់ចុះនូវឆន្ទៈរបស់យើងចំពោះព្រះអង្គសង្គ្រោះ ហើយទុកចិត្តលើផែនការសង្គ្រោះរបស់ទ្រង់សម្រាប់យើង ។

វាជាសេចក្តីសង្ឃឹមរបស់ខ្ញុំថា ពេលខ្ញុំធ្វើដំណើរតែម្នាក់ឯងចេញពីជីវិតនេះទៅឯជីវិតបន្ទាប់ទៀត នោះនឹងមាននូវសេចក្តីអំណរ កាលដែលខ្ញុំបានជួបជុំគ្នាវិញជាមួយពួកអ្នកដែលបានធ្វើដំណើរទៅមុនខ្ញុំ ! នៅចន្លោះពីពេលនេះទៅពេលនោះ នោះខ្ញុំដឹងថា ព្រះអង្គសង្គ្រោះរបស់ខ្ញុំមានព្រះជន្មរស់នៅ ហើយស្រឡាញ់ខ្ញុំ ហើយគង់នៅក្បែរខ្ញុំ ។ ■

អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។

ជង្វាយធួនរបស់ព្រះអង្គសង្គ្រោះអាចលើកអ្នកឡើងបាន

« យើងទទួលស្គាល់ថា ពេលខ្លះឆ្នូរបស់អ្នកមានការលំបាក ។ តែខ្ញុំផ្តល់ការសន្យានេះដល់អ្នកក្នុងព្រះនាមព្រះអម្ចាស់ថា ៖ ប្រើអ្នកក្រោកឈរឡើង ហើយដើរតាមដានព្រះបាទានៃព្រះគ្រោះលោះយើង ហើយនៅថ្ងៃមួយពេលអ្នកនឹងក្រឡេកមើលមកក្រោយវិញ នោះអ្នកពោរពេញដោយអំណរគុណដ៏អស់កល្បដែលអ្នកបានជ្រើសយកការទុកចិត្តលើជង្វាយធួន និងអំណាចនៃជង្វាយធួន ដើម្បីលើកហើយពង្រឹងដល់អ្នក » ។

ប្រធាន ឌៀថើ អេស្ក អ៊ុចដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ « អ្នកអាចធ្វើកន្សែងនេះបាន ! » *លេអាហ្គូណា* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៥៧ ។

ដោយ អែលឌើរ អិល ថម គែរី
នៃក្លុំមនៃពួកសាវកដប់ពីរនាក់

ថ្ងៃដ៏រុងរឿងនៃ ការស្ដារឡើងវិញ នៃបព្វជិតភាព

យើងគួរតែមានអំណរគុណយ៉ាងខ្លាំង ដែលព្រះអម្ចាស់បានស្ដារសាសនាចក្រ និងអំណាចបព្វជិតភាពរបស់ទ្រង់នៅលើផែនដីឡើងវិញ។

ពេលដែលព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទបានយាងមកផែនដី កិច្ចការដំបូងបំផុតមួយដែលទ្រង់បានធ្វើ គឺស្ថាបនាសាសនាចក្ររបស់ទ្រង់ ។ ព្រះគម្ពីរសញ្ញាថ្មីប្រាប់យើងថា ទ្រង់ « ចេញទៅឯភ្នំដើម្បីនឹងអធិស្ឋាន រួចទ្រង់អធិស្ឋានដល់ព្រះដរាបទាល់ភ្លឺ » ។ ពេលទ្រង់យាងចុះមកនៅថ្ងៃបន្ទាប់ ទ្រង់បានហៅពួកសិស្សមកជុំគ្នា ។ « ក៏រើសយក ១២ នាក់ ដែលទ្រង់ហៅថា សាវក » (លូកា ៦:១២–១៣) ។

ក្រោយមកទៀតទ្រង់បានយកពេត្រុស យ៉ាកុប និង យ៉ូហាន ទៅលើភ្នំ ហើយនៅទីនោះ ពេត្រុសបានទទួលកូនសោទាំងឡាយនៃបព្វជិតភាព (សូមមើល ម៉ាថាយ ១៧:១–៩; សូមមើលផងដែរ ១៦:១៨–១៩) ។ ពេត្រុសបានក្លាយទៅជាសាវកម្នាក់ដែលទទួលឧសត្រូវក្នុងការកាន់កូនសោទាំងអស់នៅលើផែនដី ដើម្បីដឹកនាំសាសនាចក្របន្ទាប់ពីការយាងចេញរបស់ព្រះអង្គសង្គ្រោះ ។

ដោយគោរពតាមព្រះបង្គាប់របស់ព្រះអង្គសង្គ្រោះ (សូមមើល ម៉ាកុស ១៦:១៥) នោះពួកសាវកបានផ្សព្វផ្សាយដំណឹងល្អ ហើយបានស្ថាបនាសាខាទាំងឡាយនៃសាសនាចក្រ ។ ក្នុងករណីជាច្រើន ពួកលោកបានមានឱកាសសួរសុខទុក្ខដល់សាខាទាំងឡាយបានតែម្ដងប៉ុណ្ណោះ ដែលវាផ្ដល់ឱកាសតិចតួចណាស់សម្រាប់ឲ្យពួកលោកបង្រៀន និង ហ្វឹកហ្វឺន ។ គំនិតរបស់អ្នកមិនជឿលើព្រះគ្រីស្ទក៏ជ្រៀតចូលមកយ៉ាងឆាប់រហ័ស ហើយគំនិតផ្សេងៗនៃគោលលទ្ធិរបស់ព្រះអង្គសង្គ្រោះត្រូវបានផ្លាស់ប្ដូរ ឬ កែសម្រួល (សូមមើល អេសាយ ២៤:៥) ។ ពេលដែលការក្បត់សាសនាបានរីករាលដាល នោះវាចាំបាច់ដែលព្រះអម្ចាស់ត្រូវដកយកបព្វជិតភាពពីផែនដីទៅ ។ ជាលទ្ធផល ផែនដីពុំបានមានពរជ័យនៃបព្វជិតភាពអស់មួយរយៈវែង ។

ដើម្បីស្ថាបនាគររបស់ទ្រង់នៅលើផែនដីម្ដងទៀត ជាមួយនឹងអំណាចទាំងឡាយនៃបព្វជិតភាព នោះព្រះអម្ចាស់បានស្ដារដំណឹងល្អឡើងវិញ ។

សេចក្ដីស្លាយពី ការស្ដារឡើងវិញនៃបព្វជិតភាពវិញ ដោយ អែល ពាលិន

សូមចងចាំពីការស្តារឡើងវិញ

ពេលយ៉ូសែប ស្ម៊ីធ កំពុងបកប្រែព្រះគម្ពីរមរមន ហើយអូលីវើរ ខៅឌើរី បានបម្រើជាស្មៀនរបស់លោក នោះពួកលោកបានប្រទះនឹងរឿងមួយក្នុងនីហ្វៃទី៣ អំពីព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ បានយាងមកឯអឌ្ឍគោលប៉ែកខាងលិច ។ ពេលពួកលោកបានរៀនអំពីការបង្រៀនរបស់ទ្រង់ពីបុណ្យជ្រមុជទឹក (សូមមើល នីហ្វៃទី៣ ១១:២៣–២៨) ពួកលោកបានឆ្ងល់អំពីទម្រង់ជាច្រើននៃបុណ្យជ្រមុជទឹក ដែលកំពុងត្រូវបានធ្វើឡើងក្នុងជំនាន់របស់ពួកលោក និង អំពីថានរណាដែលមានសិទ្ធិអំណាចដើម្បីធ្វើបុណ្យជ្រមុជទឹក ។

យ៉ូសែប និង អូលីវើរ បានសម្រេចចិត្តអំពាវនាវដល់ព្រះអម្ចាស់ ដោយអធិស្ឋាននៅក្នុងព្រៃជិតផ្ទះរបស់យ៉ូសែប និង អិមម៉ា ។ នៅទីនោះ វិវរណៈដ៏អស្ចារ្យបំផុតបានកើតឡើង កាលដែលយ៉ូហាន បាទីស្ទ បានលេចចេញមក បានដាក់ដៃលើក្បាលពួកលោក ហើយបានមានប្រសាសន៍ថា ៖ « នៅលើអ្នក ជាពួកអ្នកបម្រើដូចរូបខ្ញុំអើយ ដោយនូវព្រះនាមនៃព្រះមែស៊ី ខ្ញុំសូមប្រគល់បព្វជិតភាពអើរ៉ុនដែលកាន់កូនសោទាំងឡាយអំពីការបម្រើនៃពួកទេវតា និង អំពីដំណឹងល្អនៃការប្រែចិត្ត និង អំពីបុណ្យជ្រមុជទឹកដោយការពន្លិចសម្រាប់ការផ្តាច់បាប ហើយបព្វជិតភាពនេះនឹងមិនត្រូវបានដកចេញពីផែនដីទៀតឡើយ រហូតដល់ពេលកូនប្រុសទាំងឡាយនៃលោកលេវីថ្វាយដង្វាយម្តងទៀតដល់ព្រះអម្ចាស់ដោយសេចក្តីសុចរិត » (គ. និង ស. ១៣:១) ។

នោះគឺជាព្រឹត្តិការណ៍ដ៏រុងរឿង ។ ខ្ញុំសង្ឃឹមថា អ្នកកាន់បព្វជិតទាំងអស់ចងចាំថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៨២៩ ទុកជាព្រឹត្តិការណ៍ដ៏ពិសិដ្ឋមួយនៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រ និង ជាព្រឹត្តិការណ៍ពិសេសនៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។

មាត្រានៃសេចក្តីជំនឿ ប្រាប់យើងថា « យើងខ្ញុំជឿថា មនុស្សត្រូវតែបានហៅពីព្រះ ដោយការព្យាករណ៍ និង ដោយការដាក់ដៃលើ ដោយអស់អ្នកណាដែលមានសិទ្ធិអំណាច ដើម្បីនឹងផ្សាយដំណឹងល្អ ហើយប្រព្រឹត្តពិធីការទាំងឡាយនៃដំណឹងល្អ » (មាត្រានៃសេចក្តីជំនឿ ១:៥) ។

មនុស្សទាំងឡាយមិនមែនត្រូវបានហៅដោយព្រៀវៗនោះទេ ពួកគេត្រូវបានហៅដោយការបំផុសគំនិត និង ការព្យាករណ៍ ។ មាននូវខ្សែរយៈនៃការបំផុតគំនិតដោយផ្ទាល់ពីព្រះអម្ចាស់ ដល់ពួកអ្នកដែលត្រូវបានហៅឲ្យកាន់បព្វជិតភាព ។ នោះគឺជារបៀបដែលព្រះអម្ចាស់គ្រប់គ្រងសាសនាចក្ររបស់ទ្រង់ ហើយនោះគឺជារបៀបដែលទ្រង់បានហៅព្យាការី យ៉ូសែប ស្ម៊ីធ ។

សូមមានភាពសក្តិសមដើម្បីកាន់បព្វជិតភាព

ការទទួលបព្វជិតភាពពុំមែនជាទង្វើដែលជានិមិត្តរូបអំពីការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងជីវិត ដែលបានមកដោយស្ងួយប្រវត្តិស្របទៅតាមអាយុនោះទេ ។ យើងត្រូវតែមានភាពសក្តិសម ហើយ « ស្មោះត្រង់ក្នុងកាលបានបព្វជិតភាពទាំងពីរនេះ » (គ. និង ស. ៨៤:៣៣) ។ យើងគប្បីអានដោយប្រុងប្រយ័ត្ននូវពាក្យសម្បថ និង សេចក្តីសញ្ញានៃបព្វជិតភាពមិលគីស្សាដែក ដែលចង្អុលបង្ហាញយ៉ាងពិសេសពីលក្ខខណ្ឌដែលយើងត្រូវតែយល់ និង យល់ព្រម ដើម្បីទទួលយកបព្វជិតភាពនេះ ៖

« ប៉ុន្តែអស់អ្នកទាំងនោះដែលទទួលបព្វជិតភាព ឈ្មោះថាទទួលសម្បថ និង សេចក្តីសញ្ញានេះពីព្រះវរបិតាយើង ដែលទ្រង់ពុំអាចបណ្តាច់ ឬ អាចរើបានឡើយ ។

« ប៉ុន្តែអស់អ្នកណាដែលបណ្តាច់សេចក្តីសញ្ញានេះ បន្ទាប់ពីអ្នកនោះបានទទួលរួចស្រេច ហើយបែរចេញព្រងើយ នោះនឹងមិនត្រូវបានអត់ទោសឲ្យឡើយ ទោះជានៅលោកិយនេះ ឬក៏នៅបរលោកក្តី » (គ. និង ស. ៨៤:៤០–៤១) ។

វាមធ្យ័តណាស់ ។ អ្នកអាចនឹងគិតថា បុរសទាំងឡាយនឹងព្យាយាមចៀសវាងពីការទទួលបព្វជិតភាពអើរ៉ុន និង មិលគីស្សាដែក ប៉ុន្តែខបន្ទាប់ទៀតចែងថា « វេទនាដល់អស់អ្នកណា ដែល *ពុំ* ចូលមកក្នុងបព្វជិតភាពនេះ (គ. និង ស. ៨៤:៤២; ការសង្កត់ន័យត្រូវបានបន្ថែម) ។

ប្រសិនបើយើងទទួលបព្វជិតភាព ហើយរស់នៅឲ្យសក្តិសមនឹងវា នោះយើងទទួលបាននូវពរជ័យពីព្រះអម្ចាស់ ។ ប៉ុន្តែបើយើងបំបាក់សេចក្តីសញ្ញារបស់យើង ហើយបែរចេញពីបព្វជិតភាពរបស់យើង នោះយើងនឹងមិនទទួលពរជ័យរបស់ព្រះអម្ចាស់ ឬ ក្លាយជា « ពួកធើសតាំងនៃព្រះ » ឡើយ (គ. និង ស. ៨៤:៣៤) ។

បព្វជិតភាពអើរ៉ុន ដែលត្រូវទទួលដោយសេចក្តីសញ្ញា ជួយរៀបចំពួកយុវជនឲ្យទទួលបព្វជិតភាពមិលគីស្សាដែក ដែលជាបព្វជិតភាពខ្ពស់ជាង ដែលត្រូវទទួលដោយសម្បថ *និង* សេចក្តីសញ្ញា ។

ស្វែងរកឱកាសបម្រើ

បព្វជិតភាពគឺជាអង្គភាពនៃបងប្អូនប្រុសដ៏ធំអស្ចារ្យ — ប្រហែលជាអង្គភាពនៃបងប្អូនប្រុសដ៏ធំអស្ចារ្យបំផុតនៅលើផែនដី ។ ទំនាក់ទំនងក្នុងចំណោម

បងប្អូនប្រុសអ្នកកាន់បព្វជិតភាពរបស់យើង គប្បីជាទំនាក់ទំនងដែលធំធេងជាងទំនាក់ទំនងណាណាផ្សេងទៀត លើកលែងតែទំនាក់ទំនងក្រុមគ្រួសារយើងប៉ុណ្ណោះ ។ បន្ថែមលើការដែលជាអង្គភាពនៃបងប្អូនប្រុស បព្វជិតភាពគឺជាអង្គភាពបម្រើមួយ ដែលយើងលះបង់ខ្លួនយើងដើម្បីជួយអ្នកដទៃទៀត និងធ្វើឲ្យអ្វីៗបានប្រសើរឡើង ។

តាំងពីពេលដែលយុវជនម្នាក់ទទួលបព្វជិតភាពអើរ៉ុន ហើយត្រូវបានតែងតាំងជាឪកុន ឬ គ្រូ ឬ សង្ឃ នោះគាត់ជាកម្មសិទ្ធិរបស់ក្លុំមួយ ។ ភាពជាបងប្អូនប្រុសក្នុងក្លុំមនោះបន្ត ពេលដែលគាត់ទទួលបព្វជិតភាពមិលគីស្សាដែក ហើយត្រូវបានតែងតាំងជាអែលឌើរម្នាក់ ។ ក្លុំមទាំងឡាយនៅក្នុងបព្វជិតភាពគឺសំខាន់ខ្លាំងណាស់ ។

ថ្មីៗនេះ មានយុវជនម្នាក់ដែលនឹងទៅបម្រើបេសកកម្ម បាននិយាយក្នុងការប្រជុំសាក្រាម៉ង់ ។ ក្នុងការនិយាយរបស់គាត់ គាត់បានពន្យល់ថា គាត់ និងមិត្តភក្តិបួននាក់បានចាប់ផ្តើមជាមួយគ្នានៅក្នុងក្លុំមឪកុន ។ គាត់បាននិយាយថា មិត្តភាព និង ការគាំទ្រដែលពួកគេបានផ្តល់ដល់គ្នាទៅវិញទៅមក ពេលដែលពួកគេប្រឈមនឹងឧបសគ្គនានា និង ពេលឆ្លងកាត់ពីមុខតំណែងទាំងឡាយក្នុងបព្វជិតភាពអើរ៉ុន បានជួយពួកគេឲ្យទៅដល់គោលដៅរបស់ពួកគេគឺបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។

ខ្ញុំជាកម្មសិទ្ធិរបស់ក្លុំមួយ ។ វាជាក្លុំមដ៏ពិសេសមួយ ។ វាត្រូវបានបង្កើតឡើងដោយបុរសទាំងឡាយចេញពីគ្រប់ប្រភេទអាជីព និង វិជ្ជាជីវៈទាំងអស់ ។ ប៉ុន្តែពេលយើងប្រព្រឹត្តក្នុងនាមជាក្លុំម យើងរួបរួមគ្នាក្នុងគោលបំណងមួយ ។

ពេលសមាជិកក្លុំមយល់ស្របជាឯកច្ឆន្ទទៅលើដំណើរការមួយថាត្រូវធ្វើតាម ហើយធ្វើជាមួយគ្នាក្រោមឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ នោះពួកលោកប្រព្រឹត្តស្របនឹងព្រះឆន្ទៈរបស់ព្រះ ។ លើកលែងតែអ្នកមានការយល់ស្របទាំងស្រុងពីសមាជិកនៃក្លុំម បើមិនដូច្នោះអ្នកមិនប្រព្រឹត្តឡើយ ។ សូមគិតថាតើការណ៍នោះអាចការពារអ្នកអស់មួយជីវិតអ្នកយ៉ាងណាដែរ ។

បព្វជិតភាពគឺជាអង្គភាពនៃបងប្អូនប្រុសដ៏ធំអស្ចារ្យ — ប្រហែលជាអង្គភាពនៃបងប្អូនប្រុសដ៏ធំអស្ចារ្យបំផុតនៅលើផែនដី ។

គ្រប់អ្នកដឹកនាំក្លុំមគួរតែមានបញ្ជីសមាជិកក្នុងក្លុំម ហើយគាត់គួរតែមានស្មារតីដឹងអំពីពួកអ្នកដែលមានបញ្ហាក្នុងការកំណត់ពីរបៀបដែលពួកគេគួរស្រឡាញ់ ។ ប្រសិនបើមានយុវជនមួយចំនួនបែបនោះជាសមាជិករបស់ក្លុំម នោះអ្នកដឹកនាំត្រូវដាក់អាទិភាពក្នុងបញ្ជីរបស់គាត់ ដោយផ្តល់ការយកចិត្តទុកដាក់លើពួកអ្នកដែលត្រូវការការបីបាច់ជាបន្ទាន់ ។ ហើយគាត់ និង សមាជិកក្លុំមដទៃទៀតត្រូវចាប់ផ្តើមសួរសុខទុក្ខពួកគេដោយបង្កើតមិត្តភាព និង ទំនាក់ទំនងជាមួយនឹងក្លុំម ក្នុងរបៀបមួយដែលនាំពួកគេត្រឡប់មកមានមិត្តភាពវិញ ។

ក្លុំមបព្វជិតមានកាតព្វកិច្ច និង ការទទួលខុសត្រូវក្នុងការ « ព្រមាន ពន្យល់ ទូន្មាន និង បង្រៀន ហើយអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ » (គ. និង ស. ២០:៥៩) ។ ការបម្រើក្នុងក្លុំមបព្វជិតភាពគឺចាំបាច់ដល់ការអភិវឌ្ឍន៍របស់យើងនៅលើផែនដីនេះ ។ ហេតុដូច្នោះហើយ សមាជិកក្លុំមទាំងអស់គួរតែពិចារណាពីកាតព្វកិច្ចទាំងនេះទុកជាផ្នែកនៃកាតព្វកិច្ចនៃការបម្រើរបស់ពួកគេ នៅក្នុងនគររបស់ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ ។

យើងទាំងអស់គ្នាដឹងថា យើងប្រឈមនឹងឧបសគ្គទាំងឡាយក្នុងជីវិតសាកល្បងរបស់យើង ។ លើកលែងតែយើងមាននូវការគាំទ្រដើម្បីជួយយើងឆ្លងកាត់ជីវិតនេះ បើមិនដូច្នោះទេ យើងនឹងឃើញថា ខ្លួនយើងពុំមាននូវផែនការរឹងមាំ សេចក្តីណែនាំរឹងមាំ ឬ ផែនទីបង្ហាញផ្លូវ ដើម្បីដឹកនាំយើងនោះទេ ។ ក្លុំមដែលដំណើរការត្រឹមត្រូវ ជួយយើងបង្កើតផែនការ និង ផែនទីបង្ហាញផ្លូវដែលនឹងដឹកនាំយើងត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌វិញ ។

សូមមានអំណរគុណ

បិស្សពកាន់កូនសោបព្វជិតភាពទាំងឡាយ ដើម្បីធ្វើជាអធិបតីក្នុងវួដរបស់ពួកគាត់ រួមទាំងពួកយុវជននៃបព្វជិតភាពអើរ៉ុនផងដែរ ។ តាមពិត បិស្សពគឺជាប្រធាននៃក្លុំមសង្ឃក្នុងវួដរបស់គាត់ ។ គាត់ជួយដល់ពួកយុវជនឲ្យមានភាពសក្តិសម ដើម្បីទទួល និង ចម្រើនឡើងក្នុងបព្វជិតភាពអើរ៉ុន ហើយរៀបចំពួកគេដើម្បីទទួលបព្វជិតភាពមិលគីស្សាដែក ។ គាត់ជួយពួកគេឲ្យយល់ពីកាតព្វកិច្ច និង ពរជ័យទាំងឡាយដែលមានដល់ពួកអ្នកកាន់បព្វជិតភាព ។ គាត់ជួយពួកគេឲ្យរៀនលើកតម្កើងបព្វជិតភាព ដោយផ្តល់ការចាត់តាំងទាំងឡាយដល់ពួកគេដែលនឹងជួយពួកគេឲ្យបម្រើដល់អ្នកដទៃ ។

កូនសោទាំងឡាយដែលជារបស់បព្វជិតអើរ៉ុនរំឭកយើងថា យើងគប្បីមានអំណរគុណជានិច្ចសម្រាប់បព្វជិតភាពដែលបានស្តារឡើងវិញ ជាមួយនឹងអំណាច សិទ្ធិអំណាច និង ទំនួលខុសត្រូវទាំងឡាយរបស់វា ៖ « អំណាច និងសិទ្ធិអំណាចនៃរបស់តូចជាង ឬ បព្វជិតភាពអើរ៉ុន គឺត្រូវកាន់កូនសោទាំងឡាយនៃការងារបម្រើរបស់ពួកទេវតា ហើយដើម្បីចាត់ចែងការប្រព្រឹត្តខាងក្រៅទាំងឡាយនៃពាក្យខាងដំណឹងល្អ បុណ្យជ្រមុជទឹកខាងការប្រែចិត្ត សម្រាប់ការផ្តាច់បាបទាំងឡាយ យល់ព្រមតាមសេចក្តីសញ្ញា និង ព្រះបញ្ញត្តិទាំងឡាយ » (គ. និង ស. ១០៧:២០) ។

ខ្ញុំសូមអញ្ជើញពួកយុវជនឲ្យលើកតម្កើងដល់បព្វជិតភាពដែលពួកគេកាន់ និង ឲ្យរៀបចំខ្លួនដើម្បីបានតំណែងដែលខ្ពស់ជាងក្នុងបព្វជិតភាពអើរ៉ុន កាលដែលពួកគេរៀបចំខ្លួនដើម្បីទទួលបានពរជ័យបន្ថែមទៀតក្នុងការទទួលបព្វជិតភាពមិលគីស្សាដែក ដោយការបម្រើព្រះអម្ចាស់ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង និង ទីបំផុតរៀបការក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ពុំមានបុរសម្នែងស្លាប់ណាម្នាក់ដឹកនាំសាសនាចក្រនេះឡើយ ។ វាគឺជាសាសនាចក្ររបស់ព្រះអង្គសង្គ្រោះ ហើយទ្រង់ដឹកនាំវាតាមរយៈបព្វជិតភាព ដែលទ្រង់ប្រគល់ដល់បុរសទាំងឡាយនៅលើផែនដី ដើម្បីពួកគេអាចធ្វើជាភ្នាក់ងាររបស់ទ្រង់នៅក្នុងការដឹកនាំសាសនាចក្ររបស់ទ្រង់ និង ក្នុងការធ្វើពិធីការបរិសុទ្ធដ៏ពិសិដ្ឋទាំងឡាយ ។ យើងគួរមានអំណរគុណខ្លាំងយ៉ាងណាទៅ ដែលព្រះអម្ចាស់បានស្តារឡើងវិញនូវសាសនាចក្រ និងបព្វជិតភាពរបស់ទ្រង់ដល់ផែនដីនេះ ។ ■

ការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពី

ភាពជាសិស្ស

នៅក្នុងដំណើររឿងរបស់លូកាអំពីការធ្វើដំណើរចុងក្រោយរបស់ព្រះយេស៊ូវគ្រីស្ទទៅកាន់ក្រុងយេរូសាឡិម យើងឃើញថា ព្រះអង្គសង្គ្រោះប្រទានដល់យើងនូវគំរូដ៏ច្បាស់លាស់មួយអំពីរបៀបដើម្បីធ្វើតាមទ្រង់ ។

ដោយ ខេស៊ី ដាប់ប៊ីលយូ អូលសិន
ថ្នាក់សិក្ខាសាលា និង វិទ្យាស្ថាន

ត្រឹមតែបួនខែមុនពេលការសុគតរបស់ព្រះអង្គសង្គ្រោះ « កាលជិតដល់កំណត់ដែលទ្រង់ត្រូវឡើងទៅស្ថានសួគ៌ នោះទ្រង់តម្រង់ព្រះភក្ត្រ [យ៉ាងម៉ឺងម៉ាត់] យាងឆ្ពោះត្រង់ទៅឯក្រុងយេរូសាឡិមតែម្តង » (លូកា ៩:៥១) ។[1] នៅប៉ុន្មានសប្តាហ៍មុននោះ ព្រះយេស៊ូវគ្រីស្ទបានរៀបចំពួកសិស្សរបស់ទ្រង់ដោយព្រះទ័យទុកដាក់ សម្រាប់ភាពលំបាក និង ព្រឹត្តិការណ៍ខាងវិញ្ញាណដែលគិតមិនដល់ទាំងឡាយ ដែលនឹងមាននៅខាងមុខ ។

ឧទាហរណ៍ ភ្លាមៗបន្ទាប់ពីពេត្រុសបានថ្លែងបន្ទាល់អំពីទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទនៅឯខែសារ៉ៀ ភីលីពី នោះព្រះអង្គសង្គ្រោះបានមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់អំពីការសុគតរបស់ទ្រង់ដែលនឹងមកដល់ និង ការមានព្រះជន្មរស់ឡើងវិញជាលើកដំបូង ដោយទ្រង់បានមានបន្ទូលក្នុងន័យយ៉ាងច្បាស់ពិតប្រាកដ (សូមមើល ម៉ាថាយ ១៦:១៣–២១; ម៉ាកុស ៨:២៧–៣១; លូកា ៩:១៨–២២) ។[2] ព្រះយេស៊ូវក៏បាននាំពេត្រុស យ៉ាកុប និង យ៉ូហាន ទៅជាមួយនឹងទ្រង់ « ក៏នាំឡើងទៅលើភ្នំខ្ពស់ » ជាកន្លែងដែលទ្រង់ « បានផ្លាស់ប្រែនៅមុខអ្នកទាំងនោះ » (ម៉ាថាយ ១៧:១–២) ។ នៅទីនោះ ព្រះអង្គសង្គ្រោះ ម៉ូសេ និង អេលីយ៉ា បានប្រគល់កូនសោបព្វជិតភាពដល់ពេត្រុស យ៉ាកុប និង យ៉ូហាន ។ ម៉ូសេ និង អេលីយ៉ា ក៏បានផ្តល់ការលួងលោម និង ការគាំទ្រដល់ព្រះយេស៊ូវផងដែរ ពេលដែលពួកលោកបានមានប្រសាសន៍ថា « ដែលលេចមកក្នុងសិរីល្អ ទូលពីដំណើរទ្រង់សុគត ដែលត្រូវសម្រេចនៅក្រុងយេរូសាឡិម » (លូកា ៩:៣១) ។[3] អែលឌើរ ដេម អឺ ថាល់មេហ្គ (ឆ្នាំ ១៨៦២–១៩៣៣) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសំដៅដល់បទពិសោធន៍នៅលើភ្នំនេះថាជា « ការចាប់ផ្តើមនៃទីបញ្ចប់ » របស់ការបម្រើក្នុងភាពរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ។[4]

ព្រឹត្តិការណ៍ទាំងនេះបង្ហាញថា ពេលព្រះយេស៊ូវគ្រីស្ទ « តម្រង់ព្រះភក្ត្រយាងឆ្ពោះត្រង់ទៅឯក្រុងយេរូសាឡិមតែម្តង » នោះទ្រង់បានត្រាស់ដឹងយ៉ាងច្បាស់ថា ទ្រង់កំពុងចាប់ផ្តើមដំណើរមួយដែលនឹងបញ្ចប់ព្រះជន្មរបស់ទ្រង់ ។ គម្ពីរលូកា ដែលផ្តល់នូវព័ត៌មានពិស្តារបំផុតទាក់ទងនឹងការធ្វើដំណើរនេះ ចែងថា ពេលដែលព្រះអង្គសង្គ្រោះ « យាងកាត់អស់ទាំងក្រុង អស់ទាំងភូមិ ទាំងបង្រៀនបណ្តើរ ហើយចេះតែតម្រង់ឆ្ពោះទៅឯក្រុងយេរូសាឡិម » (លូកា ១៣:២២) នោះពួកសិស្សមួយក្រុម — មានទាំងបុរស និង ស្ត្រី — បានធ្វើដំណើរជាមួយទ្រង់ (លូកា ១១:២៧) ។[5] ខណៈកំពុងដើរជាមួយគ្នា នោះព្រះយេស៊ូវបានបង្រៀនពួកអ្នកដើរតាមទ្រង់ អំពីតម្រូវការនៃភាពជា

សិស្ស ។ កាលដែលយើងសិក្សាពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងបរិបទនៃការធ្វើដំណើរនេះ នោះយើងអាចបង្កើននូវការដឹងគុណកាន់តែខ្លាំងឡើងអំពីរបៀបដែលទ្រង់បានពង្រឹងការណែនាំរបស់ទ្រង់អំពីភាពជាសិស្ស ជាមួយនឹងអំណាចនៃគំរូរបស់ទ្រង់ផ្ទាល់ ។

ការឆ្លើយតបបីចំពោះការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទដែលឲ្យ « ចូរមកតាមខ្ញុំ »

មិនយូរប៉ុន្មាន មុនពេលព្រះអង្គសង្គ្រោះបានចាប់ផ្ដើមការធ្វើដំណើរចុងក្រោយរបស់ទ្រង់ទៅកាន់ក្រុងយេរូសាឡិម នោះទ្រង់បានប្រកាសថា ៖ « បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់ថ្ងៃ ហើយមកតាមខ្ញុំចុះ » (លូកា ៩:២៣) ។ ក្រោយមក ពេលព្រះយេស៊ូវ និង ពួកសិស្សរបស់ទ្រង់បានធ្វើដំណើរឆ្ពោះទៅក្រុងយេរូសាឡិម « នោះមានម្នាក់ទូលទ្រង់ថា ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ ទោះបើទ្រង់យាងទៅក្នុងទីណាក៏ដោយ » (លូកា ៩:៥៧) ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលតបថា « កូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ » (លូកា ៩:៥៨) ប្រហែលជាសំដៅថា « ជីវិតគឺមិនមានភាពសុខស្រួលទេសម្រាប់ទ្រង់ » ដូចអែលឌើរ ជេហ្វ្រី អ័រ ហូឡិន បានប្រតិបត្តិតាម ហើយថ្លែងថា « ជាញឹកញាប់ វានឹងដូច្នោះ » សម្រាប់ពួកអ្នកដែលជ្រើសរើសដើរតាមទ្រង់ ។[6]

បន្ទាប់មក ព្រះអម្ចាស់ « មានបន្ទូលទៅម្នាក់ទៀតថា ចូរមកតាមខ្ញុំ » (លូកា ៩:៥៩) ប៉ុន្តែបុរសនោះបានស្នើសុំទៅកប់ខ្មោចឪពុកគាត់សិន ។ ព្រះយេស៊ូវបានមានបន្ទូលតបថា ៖ « ទុកឲ្យពួកមនុស្សស្លាប់កប់ខ្មោចពួកគេចុះ ឯអ្នក ចូរទៅផ្សាយដំណឹងពីនគរព្រះវិញ » (លូកា ៩:៦០) ។[7] ព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះពុំបានមានន័យថា វាជាការខុសឆ្គងដែលទួញសោកចំពោះការបាត់បង់មនុស្សជាទីស្រឡាញ់នោះទេ (សូមមើល គ. និង ស. ៤២:៤៥) ។ ប៉ុន្តែព្រះបន្ទូលនោះសង្កត់ន័យថា ភក្ដីភាពចំពោះព្រះអម្ចាស់គឺជាអាទិភាពខ្ពស់បំផុតរបស់សិស្សម្នាក់ ។

បុគ្គលទីបីបានទូលថា « ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ទៅដែរ តែសូមអនុញ្ញាតឲ្យទូលបង្គំទៅលាពួកផ្ទះទូលបង្គំសិន » (លូកា ៩:៦១) ។ ព្រះយេស៊ូវបានតបដោយការប្រៀបធៀបទៅនឹងអ្នកអូសនង្គ័ល ដែលការងារគឺតម្រូវឲ្យគាត់យកចិត្តទុកដាក់ទៅអ្វីដែលនៅខាងមុខ ជាងអ្វីដែលនៅពីក្រោយ (សូមមើល លូកា ៩:៦២) ។ មេរៀនសម្រាប់បុរសនេះគឺថា គ្រាន់តែធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ដែល « តម្រង់ព្រះភក្ត្រយាងឆ្ពោះត្រង់ទៅឯក្រុងយេរូសាឡិម » (លូកា ៩:៥១) ហើយមិនក្រឡេកមើលក្រោយឡើយ ។

ផ្លូវឆ្លងកាត់សាម៉ារី

ពេលដែលព្រះយេស៊ូវ និង ពួកសិស្សរបស់ទ្រង់បានឆ្លងកាត់សាម៉ារី នៅតាមផ្លូវទៅកាន់ក្រុងយេរូសាឡិម នោះមានពួកសាសន៍សាម៉ារីមួយចំនួន « មិនទទួលទ្រង់ទេ » (លូកា ៩:៥៣) — ទំនងជាពួកគេស្គាល់ថា ព្រះយេស៊ូវ និង ពួកសិស្សទ្រង់គឺជាពួកសាសន៍យូដា ។[8] ជាការឆ្លើយតបវិញ យ៉ាកុប និង យ៉ូហាន បានសូមអនុញ្ញាតហៅភ្លើងឲ្យធ្លាក់មកពីលើមេឃមកបញ្ឆេះពួកគេ (សូមមើល លូកា ៩:៥២–៥៤) ។ ដោយឃើញភាពឆេវឆាវបែបនេះ ព្រះអង្គសង្គ្រោះបានបង្ហាញឲ្យឃើញពីសេចក្ដីអត់ធ្មត់ និង ស៊ូទ្រាំ ខណៈដែលទ្រង់ទូន្មានដល់ពួកសិស្សរបស់ទ្រង់ឲ្យធ្វើដូចគ្នាដែរ (សូមមើល លូកា ៩:៥៥–៥៦) ។

មិនយូរប៉ុន្មានក្រោយពីនោះ ព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ពីការប្រៀបធៀបនៃសាសន៍សាម៉ារីមួយ (សូមមើល លូកា ១០:២៥–៣៧) ។ បន្ថែមលើការធ្វើឲ្យស្ដាប់ទៅនឹងសំណួររបស់អ្នកប្រាជ្ញច្បាប់ដែលមិនទៀងត្រង់ម្នាក់ នោះការប្រៀបធៀបនេះអាចបានរំឭកដល់ពួកសិស្សរបស់ព្រះអង្គសង្គ្រោះថា ពុំមានការលើកលែងទេចំពោះបទបញ្ញត្តិទាំងឡាយដែលថា « ត្រូវ . . . ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯងដែរ » (លូកា ១០:២៧; សូមមើលផងដែរ ខ ២៥–២៩) ។

ដូចជាសាសន៍សាម៉ារីដ៏ល្អដែរ ព្រះយេស៊ូវបានបម្រើដល់គ្រប់ព្រលឹងដែលមានរបួសដែលទ្រង់បានជួប ។

ជាងនោះទៅទៀត ពួកសិស្សរបស់ព្រះអង្គសង្គ្រោះអាចបានដឹងពីភាពស្រដៀងគ្នារវាងទង្វើរបស់សាសន៍សាម៉ារីដ៏ល្អ និង ទង្វើទាំងឡាយរបស់ព្រះយេស៊ូវ ។ សេចក្ដីស្រឡាញ់ដែលសាសន៍សាម៉ារីដ៏ល្អបានធ្វើដល់សាសន៍យូដាម្នាក់នោះបានបង្ហាញពីសេចក្ដីសប្បុរសដែលព្រះយេស៊ូវទើបតែបានបង្ហាញចំពោះពួកសាសន៍សាម៉ារីដែលជាសត្រូវនោះ ។ នៅក្នុងសប្ដាហ៍ដែលនឹងចូលមកដល់នោះដែរ ពួកសិស្សរបស់ព្រះអង្គសង្គ្រោះនឹងបានឃើញព្រះយេស៊ូវជួបនឹងព្រលឹងដែលមានរបួសជាច្រើននាក់នៅតាមផ្លូវទៅកាន់ក្រុងយេរូសាឡិម (សូមមើល លូកា ១៣:១០–១៧; ១៤:១–៦; ១៧:១១–១៩; ១៩:១–១០) ។ ដូចជាសាសន៍សាម៉ារីដ៏ល្អ ដែលបានឈប់នៅតាមផ្លូវដែលមានចោរប្លន់ដ៏គ្រោះថ្នាក់មួយ ហើយបានសង្គ្រោះដល់មនុស្សម្នាក់ទៀតមុនខ្លួនគាត់ នោះព្រះយេស៊ូវនឹងបម្រើដល់ពួកព្រលឹងដែលមានរបួសដែលទ្រង់បានជួបទាំងនោះ ដោយពុំបានគិតអំពីខ្លួនអង្គទ្រង់ឡើយ សូម្បីតែទ្រង់ជិតនឹងសុគតហើយក៏ដោយ ។

ព្រះអង្គសង្គ្រោះបង្រៀនដល់ម៉ារា និង ម៉ាថា

អំឡុងការធ្វើដំណើររបស់ទ្រង់ទៅកាន់ក្រុងយេរូសាឡិម ព្រះយេស៊ូវបានឈប់នៅផ្ទះម៉ាថា (សូមមើល លូកា ១០:៣៨) ។ ខណៈម៉ាថា « មានការរវល់

ជាច្រើន » (លូកា ១០:៤០) នោះប្អូនស្រីរបស់នាងគឺម៉ារា « បានអង្គុយស្តាប់ព្រះបន្ទូលនៅទៀបព្រះបាទព្រះអម្ចាស់ » (ខ ៣៩) ។ ការទទួលភ្ញៀវគឺសំខាន់ខ្លាំងណាស់ក្នុងសង្គមពួកសាសន៍យូដា ហើយវាហាក់បីដូចជាម៉ាថា កំពុងតែព្យាយាមបំពេញការរំពឹងខាងវប្បធម៌យ៉ាងឧស្សាហ៍ ក្នុងនាមនាងជាម្ចាស់ផ្ទះ ។[៩]

ថ្វីបើម៉ាថាបានបង្ហាញនូវភក្តីភាព និង សេចក្តីជំនឿយ៉ាងអស្ចារ្យចំពោះព្រះអង្គសង្គ្រោះតាមទម្រង់មួយផ្សេង (សូមមើល យ៉ូហាន ១១:១៩–២៩) ក៏នាងបានរអ៊ូរទាំថា « ព្រះអម្ចាស់អើយ តើទ្រង់មិនគិតឃើញថា ប្អូនខ្ញុំម្ចាស់ វាទុកខ្ញុំម្ចាស់ឲ្យខ្វល់ខ្វាយបម្រើតែម្នាក់ឯងទេឬអី សូមទ្រង់ប្រាប់ឲ្យវាមកជួយខ្ញុំម្ចាស់ផង » (លូកា ១០:៤០) ។ ដើម្បីជួយដល់សមាជិកសាសនាចក្រឲ្យរៀនពីមេរៀនសំខាន់មួយចេញពីរឿងនេះ អែលឌើរ ដាល្លិន អេក អូក នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានដកស្រង់សន្ទរកថានៃការប្រជុំធម្មនិដ្ឋានដែលថ្លែងដោយសាស្ត្រាចារ្យ ខេធើរីន ខូមែន ផែរី ថា ៖

« ព្រះអម្ចាស់ពុំបានចូលទៅក្នុងចង្រ្កាន ហើយប្រាប់ម៉ាថាឲ្យឈប់ចម្អិនម្ហូប ហើយមកស្តាប់ឡើយ ។ ជាក់ស្តែងទ្រង់សប្បាយព្រះទ័យទុកឲ្យនាងបម្រើទ្រង់តាមរបៀបដែលនាងចង់ រហូតទាល់តែនាងបានវិនិច្ឆ័យដល់ការបម្រើរបស់មនុស្សម្នាក់ផ្សេងទៀត ។ . . . *ភាពសំខាន់ផ្ទាល់ខ្លួន* របស់ម៉ាថា . . . បានបណ្តាលឲ្យមានការស្តីបន្ទោសពីព្រះអម្ចាស់ពុំមែនមកពីការរវល់ធ្វើម្ហូបរបស់នាងនោះទេ ។[90]

កំហុសចម្បងរបស់ម៉ាថានៅពេលនេះ ហាក់បីដូចជាការផ្តោតទៅលើខ្លួនឯង — សូម្បីពេលនាងកំពុងបម្រើអ្នកដទៃ ។ ព្រះអង្គសង្គ្រោះបានជួយម៉ាថាឲ្យយល់ថាវាមិនទាន់គ្រប់គ្រាន់ទេដែលគ្រាន់តែបម្រើព្រះអម្ចាស់ និង អ្នកនៅជុំវិញខ្លួននោះ ។ យើងត្រូវតែរៀនលះបង់ខ្លួនយើងក្នុងដំណើរការនៃការបម្រើ ហើយស្វែងរកព្រះឆន្ទៈរបស់ព្រះអម្ចាស់ដើម្បីដឹកនាំបំណងប្រាថ្នា និង កត្តាជំរុញ ក៏ដូចជាសកម្មភាពរបស់យើងផងដែរ (សូមមើល លូកា ៩:២៤; គ. និង ស. ១៣៧:៩) ។ ពួកសិស្សត្រូវតែយកឈ្នះនូវទំនោរក្នុងការគិតពីខ្លួនឯងមុន ហើយរៀនបម្រើដល់ព្រះវរបិតាសួគ៌ និង បុត្រាបុត្រីរបស់ទ្រង់ជាមួយនឹងភ្នែក « ស្មោះស្ម័គ្រទាំងស្រុងទៅចំពោះសិរីល្អ [របស់ទ្រង់] » (គ. និង ស. ៨៨:៦៧) ។ ក្រោយមកទៀត បន្ទាប់ពីការស្លាប់របស់ប្អូន

ប្រុសនាង ម៉ាថាបានបង្ហាញពីសេចក្តីជំនឿរបស់នាង ដោយបានទម្លាក់ចោលអ្វីៗទាំងអស់ ហើយបានចេញទៅជួបព្រះអង្គសង្គ្រោះ ពេលនាងបានឮថាទ្រង់យាងមក (សូមមើល យ៉ូហាន ១១:១៩–២០) ។

ព្រះអង្គសង្គ្រោះអធិប្បាយអំពីការតម្រូវនៃភាពជាសិស្ស

ក្រោយមកទៀត នៅក្នុងការធ្វើដំណើររបស់ព្រះអង្គសង្គ្រោះទៅកាន់ក្រុងយេរូសាឡិម មានបុរសម្នាក់បានស្នើថា « លោកគ្រូ សូមលោកប្រាប់បងខ្ញុំ ឲ្យគាត់ចែកមរតកមកខ្ញុំផង » (លូកា ១២:១៣) ។ ព្រះយេស៊ូវបានតបដោយប្រាប់ពីឫសគល់នៃបញ្ហារបស់បុរសនោះថា ៖ « ចូរប្រយ័ត្ន ហើយខំចៀសពីសេចក្តីលោភចេញ ដ្បិតជីវិតនៃមនុស្សមិនស្រេចនឹងបានទ្រព្យសម្បត្តិជាបរិបូរទេ » (លូកា ១២:១៥) ។ បន្ទាប់មក ទ្រង់បានប្រទានការប្រៀបធៀបពីអ្នកមានល្ងីល្ងើម្នាក់ (សូមមើល លូកា ១២:១៦–២១) ។

នៅក្នុងការប្រៀបធៀបនោះ មូលហេតុមួយដែលព្រះបានចាត់ទុកថាបុរសអ្នកមាននោះជាមនុស្សល្ងីល្ងើ គឺអាចមកពីភាពអាត្មានិយមរបស់បុរសនោះ ។ នៅក្នុង លូកា ១២:១៧–១៩ បុរសអ្នកមានប្រើសព្វនាម *ខ្ញុំ* និង *របស់ខ្ញុំ* ចំនួន ១១ ដង ដោយបានបង្ហាញពីកង្វល់ចំពោះខ្លួនឯង ។[99] បុរសនោះមិនត្រឹមតែត្រូវបានគ្រប់គ្រងដោយភាពអាត្មានិយមប៉ុណ្ណោះទេ តែគាត់ក៏មិនដឹងពីប្រភពនៃភាពមានបានរបស់គាត់ផងដែរ ។ គ្មានវិធីណាបានធ្វើឲ្យបុរសអ្នកមាននោះទទួលស្គាល់ ដូចដែលព្រះអង្គសង្គ្រោះបានទទួលស្គាល់ឡើយថា វាគឺជា « ស្រែចម្ការ » ដែល « បានកើតផលចម្រើនជាបរិបូរ » (លូកា ១២:១៦) ហើយគាត់ក៏មិនបានអរព្រះគុណដល់ព្រះអម្ចាស់ដែលបានបង្កើតផែនដីសម្រាប់គាត់ដាំដំណាំដែរ ។ នៅទីបំផុត បុរសនោះត្រូវបានផ្តន្ទាទោស មិនមែនដោយសារ ការអនុវត្តដ៏ឈ្លាសវៃក្នុងការទុកដាក់ស្បៀងខាងលោកិយនោះទេ ប៉ុន្តែដោយសារមិនបានរៀបចំខាងវិញ្ញាណសម្រាប់ពេលខាងមុខ ។ ដោយ « ទុកបម្រុងតែខ្លួនឯង តែឥតមានខាងឯព្រះ » (លូកា ១២:២១) នៅទីបំផុត បុរសនោះត្រូវបានដកហូតអស់ មិនត្រឹមតែទ្រព្យសម្បត្តិដែលគាត់មាននៅលើផែនដីប៉ុណ្ណោះទេ តែថែមទាំង « ទ្រព្យដែលមិនចេះអស់នៅឯស្ថានសួគ៌ » ទៀត (លូកា ១២:៣៣) ។ ជម្រើសរបស់គាត់នៅក្នុងជីវិត បន្សល់ទុកដល់គាត់នូវភាពលិចលង់នៅក្នុងភាពអស់កល្បជានិច្ច ។

ផ្ទុយស្រឡះពីអ្នកមានល្បីល្បើដែលពូនគរតែទ្រព្យសម្បត្តិខាងសម្ភារ មុនពេលនៃការស្លាប់ដោយមិនបានរំពឹងទុក នោះព្រះយេស៊ូវបានមានបំណងយាងឆ្ពោះទៅកាន់សេចក្ដីសុគតរបស់ទ្រង់ ដោយមិនរុញរានឹងថ្វាយដល់ព្រះនូវអ្វីៗទាំងអស់ដែលទ្រង់មាន — រួមទាំងព្រះជន្មទ្រង់ផ្ទាល់ និង ព្រះឆន្ទៈដ៏ពេញរង្វាល់របស់ទ្រង់ (សូមមើល លូកា ២២:៤២; ម៉ូសាយ ១៥:៧) ។ ទ្រង់បានប្រកាសថា « ខ្ញុំត្រូវទទួលបុណ្យជ្រមុជទឹកមួយសិន ហើយខ្ញុំត្រូវចង្អៀតចង្អល់យ៉ាងដូចម្ដេចទៅហ្ន៎ ទម្រាំបុណ្យនោះបានសម្រេច » (លូកា ១២:៥០) ។ ដោយសារទ្រង់បានទទួលបុណ្យជ្រមុជដោយទឹករួចហើយ នោះព្រះយេស៊ូវចង់សំដៅដល់ដង្វាយធួនរបស់ទ្រង់ ។ មិនយូរទៀតទេ ទ្រង់នឹងយាងចុះទៅក្រោមអ្វីៗទាំងអស់ ហើយព្រះកាយរបស់ទ្រង់នឹងត្រូវស្រោចស្រប់ដោយព្រះលោហិត និង ញើស កាលដែលទ្រង់រងទុក្ខសម្រាប់អំពើបាបរបស់យើង ហើយទទួលនូវការឈឺចាប់ និង សេចក្ដីវេទនារបស់យើង ។[១២]

ដូចជាម៉ារា និង ម៉ាថា ដែរ យើងត្រូវតែរៀនដើម្បីលះបង់ខ្លួនយើងទៅក្នុងដំណើរការនៃការបម្រើព្រះអម្ចាស់ និង ធ្វើតាមព្រះឆន្ទៈរបស់ទ្រង់ ។

ក្រោយមក នៅពេលដែលពួកផារិស៊ីបានព្រមានព្រះយេស៊ូវថា ស្ដេចហេរ៉ូឌអាន់ទីផាស នឹងព្យាយាមធ្វើគតទ្រង់ នោះព្រះអង្គសង្គ្រោះគ្រាន់តែបានបញ្ជាក់ថា ទ្រង់នឹងបន្តចាប់យកគ្រប់ឱកាសដែលទ្រង់មានដើម្បីបង្រៀន ប្រទានពរ និង ព្យាបាលអ្នកដទៃ (សូមមើល លូកា ១៣:៣១–៣៣) ។ ទ្រង់ចំណាយពេលប៉ុន្មានថ្ងៃចុងក្រោយនៃជីវិតរមែងស្លាប់របស់ទ្រង់ — ដូចជាថ្ងៃទាំងឡាយរបស់ទ្រង់ពីមុនមកដែរ — ក្នុងការបម្រើអ្នកដទៃ ។

ខណៈដែលខិតកាន់តែជិតដល់ក្រុងយេរូសាឡិម នោះព្រះយេស៊ូវបានណែនាំពួកសិស្សរបស់ទ្រង់ឲ្យរាប់ចំនួនពួកសិស្ស — ដើម្បីឲ្យពួកគេគិតជាមុនឲ្យបានដិតដល់មុននឹងសម្រេចចិត្តដើរតាមទ្រង់ (សូមមើល លូកា ១៤:២៥–២៨) ។ ទ្រង់មិនបានព្យាយាមបំផ្លើស្ថានភាពលំបាកដែលពួកគេអាចនឹងជួបប្រទះនៅខាងមុខនោះទេ បើសិនពួកគេបន្តធ្វើជាសិស្សទ្រង់នោះ ។ ផ្ទុយទៅវិញ ទ្រង់បានប្រកាសយ៉ាងម៉ឺងម៉ាត់ថា ៖ « អស់អ្នកណាក្នុងចំណោមពួកអ្នករាល់គ្នាដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់ នោះធ្វើជាសិស្សខ្ញុំមិនបានទេ » (លូកា ១៤:៣៣) ។ ប៉ុន្តែ ព្រះអង្គសង្គ្រោះក៏បានសន្យាផងដែរថា ពេលដែលយើងបំភ្លេចខ្លួនយើងនៅលើមាគ៌ានៃភាពជាសិស្ស នោះយើងនឹងទទួលបានមកវិញ ច្រើនជាងនេះទៅទៀត (សូមមើល លូកា ៩:២៤) ។ ពរជ័យដែលទ្រង់បានសន្យាដល់សិស្សរបស់ទ្រង់ រួមមាន « សេចក្ដីសុខសាន្ត នៅលោកិយនេះ និង ជីវិតដ៏នៅអស់កល្បជានិច្ច នៅបរលោកនាយ » (គ និង ស ៥៩:២៣) ។

ទោះបីយើងពុំបានមានឱកាសដើរជាមួយនឹងព្រះយេស៊ូវគ្រីស្ទទៅក្រុងយេរូសាឡិម តែយើងអាចបង្ហាញពីឆន្ទៈរបស់យើងក្នុងការធ្វើតាមការធ្វើដំណើរនោះនៅក្នុងជីវិតយើងផ្ទាល់ ។ ការចងចាំពីព្រះឆន្ទៈផ្ទាល់របស់ព្រះអង្គសង្គ្រោះដើម្បីលះបង់ និង បម្រើឲ្យស្របទៅនឹងព្រះទ័យរបស់ព្រះវរបិតាសួគ៌អាចផ្ដល់កម្លាំងដល់យើងដើម្បី « ទៅ ហើយ . . . ប្រព្រឹត្តបែបយ៉ាងដូច្នោះដែរ » (លូកា ១០:៣៧) ។ ■

កំណត់ចំណាំ

១. សូមមើល A. B. Bruce, *The Training of the Twelve* (ឆ្នាំ ១៩៧១) ទំព័រ ២៤០ ។
២. សេចក្ដីយោងដែលបានថ្លែងសំដៅដល់ការរងទុក្ខ និង ការសុគតរបស់ព្រះអង្គសង្គ្រោះ តាំងពីការកើតមានពីមុនមកនៅក្នុងការបម្រើរបស់ទ្រង់ដែលរួមមាន ម៉ាថាយ ៩:១៥; ១៦:៤; យ៉ូហាន ២:១៩; ៣:១៤ ។
៣. សូមមើល James E. Talmage, *Jesus the Christ,* 3rd ed. (ឆ្នាំ ១៩៣៦) ទំព័រ ៣៧៣ ។
៤. James E. Talmage, *Jesus the Christ,* ទំព័រ ៣៧៣ ។
៥. ផ្ទុយពី ម៉ាកុស និង ម៉ាថាយ ដែលគ្រាន់តែមានការលើកឡើងត្រួសៗអំពីការយាងចេញពីស្រុកកាលីឡេ ជាចុងក្រោយបង្អស់នៅក្នុងជីវិតរមែងស្លាប់ និង ការធ្វើដំណើររបស់ទ្រង់ទៅកាន់ក្រុងយេរូសាឡិម (សូមមើល ម៉ាថាយ ១៩:១–២; ម៉ាកុស ១០:១) នោះ លូកា បានផ្ដោតយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការធ្វើដំណើររបស់ទ្រង់ (សូមមើល លូកា ៩:៥១–៥៣; ១៣:២២, ៣៤; ១៧:១១; ១៨:៣១; ១៩:១១) ។ នៅក្នុងមាតិកានៃដំណឹងល្អរបស់យ៉ូហានមានភាពខុសគ្នាយ៉ាងច្រើនគួរសមពីដំណឹងល្អសង្ខេបនៃ ម៉ាថាយ ម៉ាកុស និង លូកា ហើយពុំបានមានចែងពីការយាងចេញចុងក្រោយរបស់ព្រះអង្គសង្គ្រោះពីស្រុកកាលីឡេទៅក្រុងយេរូសាឡិមនោះទេ ។
៦. ជែហ្វ្រី អ័រ ហូឡិន "The Inconvenient Messiah," *Ensign,* ខែ កុម្ភៈ ឆ្នាំ ១៩៨៤ ទំព័រ ៦៨ ។
៧. ការគោរពដល់ឪពុកម្ដាយគឺសំខាន់ខ្លាំងណាស់នៅក្នុងវប្បធម៌ពួកសាសន៍យូដា រួមទាំងការទទួលខុសត្រូវក្នុងការផ្ដល់កិច្ចបញ្ចុះសពយ៉ាងត្រឹមត្រូវសម្រាប់ពួកគាត់ ។ បន្ទាប់ពីការរៀបចំសាកសពសម្រាប់បញ្ចុះ និង ដាក់ក្នុងផ្នូរ នោះសមាជិកក្រុមគ្រួសារត្រឡប់មកវិញក្នុងពេលមួយឆ្នាំក្រោយមក ដើម្បីរើសឆ្អឹងដាក់ក្នុងប្រអប់ថ្មមួយដែលហៅថាគំនរឆ្អឹង ដែលជាឆ្អឹងដែលនៅសេសសល់ក្នុងផ្នូរ ដោយចាត់ទុកថានោះជាការបញ្ចុះលើកទីពីរក្នុងចំណោមឆ្អឹងសេសសល់របស់សមាជិកគ្រួសារដែលស្លាប់ហើយផ្សេងទៀត ។ (សូមមើល Richard Neitzel Holzapfel, Eric D. Huntsman, and Thomas A. Wayment, *Jesus Christ and the World of the New Testament* [ឆ្នាំ ២០០៦] ទំព័រ ៧៨–៧៩) ។ នៅក្នុងករណីនេះ ប្រសិនបើសិស្សនោះនិយាយអំពីការបញ្ចុះលើកទីពីរ ជាជាងសេចក្ដីត្រូវការបន្ទាន់ក្នុងការថែទាំសាកសពឪពុកគាត់ដែលទើបស្លាប់ថ្មីៗ នោះសំណើររបស់គាត់បានបង្ហាញពីបំណងប្រាថ្នាក្នុងការផ្ដល់អាទិភាពដល់ទំនៀមទម្លាប់ខាងវប្បធម៌ ឲ្យខ្ពស់ជាងឱកាសតែមួយគត់ក្នុងការដើរទៅក្រុងយេរូសាឡិមជាមួយព្រះរាជបុត្រានៃព្រះ ហើយនិងត្រូវបានបង្រៀនពីទ្រង់ ។
៨. មាននូវសម្អប់យ៉ាងច្រើនរវាងពួកសាសន៍យូដា និង ពួកសាសន៍សាម៉ារីនៅក្នុងជំនាន់របស់ព្រះយេស៊ូវគ្រីស្ទ ។ ក្រុមទាំងពីរនេះចៀសវាងពីការប្រាស្រ័យទាក់ទងគ្នា ។ ក្នុងករណីនេះ ពួកសាសន៍សាម៉ារីបានបដិសេធព្រះយេស៊ូវ និង ពួកសិស្សរបស់ទ្រង់យ៉ាងជាក់ស្ដែង ដោយមិនផ្ដល់នូវទម្លាប់នៃការទទួលភ្ញៀវ ដូចជាមិនផ្ដល់ស្បៀងអាហារ និង ផ្ទះឲ្យស្នាក់ ។ (សូមមើល Richard Neitzel Holzapfel and Thomas A. Wayment, *Making Sense of the New Testament* [ឆ្នាំ ២០១០] ទំព័រ ១៤០ Ralph Gower, *The New Manners and Customs of Bible Times* [ឆ្នាំ ១៩៨៧] ទំព័រ ២៤១–៤២) ។
៩. សូមមើល Gower, *New Manners and Customs of Bible Times,* 244–45; Fred H. Wight, *Manners and Customs of Bible Lands* (ឆ្នាំ ១៩៥៣) ទំព័រ ៦៩–៧៧ ។
១០. នៅក្នុង Dallin H. Oaks, "'Judge Not' and Judging," *Ensign*, ខែ សីហា ឆ្នាំ ១៩៩៩ ទំព័រ ១២–១៣ ការសង្កត់ន័យត្រូវបានបន្ថែម ។
១១. សូមមើល Jay A. Parry and Donald W. Parry, *Understanding the Parables of Jesus Christ* (ឆ្នាំ ២០០៦) ទំព័រ ១២២ ។
១២. សូមមើល លូកា ២២:៤៤; អាលម៉ា ៧:១១–១៣; គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៨; ៨៨:៦ ។

រូបភាពពី *ព្រះគ្រីស្ទនៅក្នុងផ្ទះរបស់ម៉ាថា និង ម៉ារា* ដោយ ដេល (ប៊ូអេន) ប៊ើឡៀ © ដោយមានការអនុញ្ញាតពីគ្រឹះស្ថានប្រពៃណី រូបភាពអេឌីធ័រ/ប៊្រីដមែន

ដោយ អែលឌើរ ស្កត់ ឌី វែតធីង
នៃពួកចិតសិបនាក់

អ្នកនេសាទមនុស្ស

អ្នកទាំងអស់ណាដែលបានទទួលការហៅឲ្យដឹកនាំសាសនាចក្រ
គឺបានទទួលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះដើម្បីក្លាយជាអ្នកនេសាទមនុស្ស ។

ខណៈកំពុងបីបាច់ក្រុមគ្រួសារដ៏ក្មេងខ្ចីរបស់យើងនៅរដ្ឋ ហាវ៉ៃ នោះ ភរិយាខ្ញុំ និង ខ្ញុំបានមានអំណរគុណចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ល្អៗដែលបានជួយយើង ។ សមាជិកដ៏ជាទីស្រឡាញ់ទាំងនេះបានឱបក្រសោបយើង ហើយប្រព្រឹត្តនឹងយើងដូចជាក្រុមគ្រួសាររបស់គេដែរ ។ ក្នុងឱកាសមួយចំនួន ពួកបុរសៗនៅក្នុងវួដយកកូនប្រុសខ្ញុំទៅកាន់ដំណើរផ្សងព្រេងស្ទូចត្រីនៅលើសមុទ្រ ។ ដំណើរកម្សាន្តទាំងនេះ មិនប្រើទូកទេ ប៉ុន្តែមានវិធីសាស្ត្រស្ទូចត្រីពីបុរាណ ដែលបង្កើតឡើងដោយពួកសាសន៍ហាវ៉ៃពីជំនាន់មុន ។

ដោយប្រើវិធីសាស្ត្រមួយបែបនោះ អ្នកនេសាទដ៏ជំនាញម្នាក់នឹងបត់សំណាញ់ចុះឡើងជាស្រទាប់យ៉ាងប្រុងប្រយ័ត្នបំផុត ដែលសំណាញ់នោះមានដុំទម្ងន់ភ្ជាប់ទៅនឹងជុំវិញជើងសំណាញ់ ។ បន្ទាប់មកគាត់នឹងស្តាយសំណាញ់នោះយ៉ាងប្រុងប្រយ័ត្នទៅកាន់កន្លែងមួយនៅតាមបណ្តោយច្រាំងសមុទ្រដែលមានថ្មនៅខាងលើថ្កុកដែលមានទឹកថ្លា ។ ពេលគាត់ឃើញត្រីចូលក្នុងថ្កុកនោះ នៅពេលវេលាដែលត្រឹមត្រូវ និងជាមួយនឹងជំនាញយ៉ាងអស្ចារ្យ នោះគាត់នឹងបោះសំណាញ់ ដែលនឹងធ្វើឲ្យសំណាញ់នោះលាសន្ធឹងទាំងអស់ ហើយធ្លាក់ចុះទៅលើទឹកដែលនៅខាងក្រោមជារង្វង់មួយយ៉ាងធំ ហើយភ្លាមនោះវាលិចចូលទៅក្នុងទឹក ហើយសង្កត់យកត្រីដែលប្រមូលផ្តុំគ្នានោះ ។

ខណៈដែលជំនាញរបស់អ្នកនេសាទគួរឲ្យស៊ើចសរសើរ នោះគាត់នឹងជាមនុស្សទីមួយដែលប្រាប់អ្នកថា បើគ្មានសំណាញ់ល្អ ស្អាត ដែលបានប៉ះ និងបានជួសជុលទាំងស្រុងទេ នោះការខិតខំរបស់គាត់នឹងគ្មានប្រយោជន៍ឡើយ ។ អ្នកនេសាទដែលពោរពេញដោយបទពិសោធន៍ដឹងថា ជោគជ័យរបស់ពួកគាត់គឺទទួលបានដោយអាស្រ័យទៅលើភាពលេញលេញនៃសំណាញ់របស់ពួកគាត់ ហើយថា ការនេសាទដ៏មានប្រសិទ្ធិភាព និង បានផលច្រើនពុំអាចកើតមានទេទាល់តែសំណាញ់ត្រូវបានពិនិត្យពិចារណាឃើញថាល្អសិន ។

យើងឃើញពីការយល់ដឹងនៃគោលការណ៍នេះ នៅក្នុងចំណោមពួកសាវកដើម ដែលក្នុងនោះមានអ្នកនេសាទមួយចំនួនដែរ ។ យើងត្រូវបាននាំឲ្យស្គាល់ពួកអ្នកនេសាទទាំងនេះនៅជំពូកទាំងឡាយខាងដើមគម្ពីរម៉ាថាយ ម៉ាកុស និង លូកា ដែលពួកលោកកំពុងតែបង់ ជួសជុល និង លាងសម្អាតសំណាញ់របស់ពួកលោក ពេលដែលពួកលោកជួបនឹងអនាគតលោកគ្រូរបស់ពួកលោកដំបូង (សូមមើល ម៉ាថាយ ៤:១៨, ២១; ម៉ាកុស ១:១៦, ១៩; លូកា ៥:២) ។ បុរសទាំងនេះបានចិញ្ចឹមក្រុមគ្រួសាររបស់ពួកលោក និង ក្រុមគ្រួសារអ្នកផ្សេងទៀត ដោយការពុះពារាល់ថ្ងៃដើម្បីចាប់ត្រី ។ ជោគវាសនារបស់ពួកលោក និង ក្រុមគ្រួសារលោកបានពឹងផ្អែកទៅលើការរៀបចំ និង ជំនាញរបស់ពួកលោក និង ភាពល្អពេញលេញនៃសំណាញ់របស់ពួកលោក ។

ពេលព្រះយេស៊ូវបានអញ្ជើញពួកលោកឲ្យ « ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឲ្យជាអ្នកនេសាទមនុស្សវិញ » « គេក៏ទុកសំណាញ់ចោលទៅតាមទ្រង់ភ្លាម » « គេទុករបស់ទាំងអស់ចោល ហើយដើរតាមទ្រង់ទៅ » (ម៉ាថាយ ៤:១៩, ២០; លូកា ៥:១១; សូមមើលផងដែរ ម៉ាកុស ១:១៧–១៨) ។

ខ្ញុំបានគិតអំពីគំរូនេះជាច្រើនដង ពេលខ្ញុំបានពិចារណាថា ពួកអ្នកដែលដឹកនាំសាសនាចក្របានឆ្លើយតបជាមួយនឹងសេចក្តីជំនឿស្រដៀងគ្នានេះដែរដល់ការអញ្ជើញឲ្យ « មកតាមខ្ញុំ » ។ ដូចជាសាសនាចក្រកាលពីបុរាណដែរ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានដឹកនាំដោយពួកព្យាការី និង សាវក ដែលបានទុកចោលសំណាញ់ និង ទ្រព្យសម្បត្តិ

របស់ពួកលោកដែលបានមកដោយធ្វើការយ៉ាងលំបាក ហើយបានអភិវឌ្ឍជំនាញថ្មីៗដើម្បីបម្រើ និង ដើរតាមលោកគ្រូ ។

អ្នកដឹកនាំមនុស្ស

តើការក្លាយជា « អ្នកនេសាទមនុស្ស » មានន័យដូចម្តេច ? ក្នុងព្រះបន្ទូលដ៏សាមញ្ញនៃការអញ្ជើញរបស់ទ្រង់ទៅដល់ពួកសាវកពីបុរាណ ព្រះអង្គសង្គ្រោះបាននាំឲ្យស្គាល់នូវអ្វីដែលបានក្លាយជាទម្រង់នៃការបង្រៀនធម្មតា និង ដែលប្រកបដោយព្រះចេស្តា — គឺការបង្រៀនដោយការប្រៀបធៀបទាំងឡាយ ។ ទ្រង់បានដឹងថា ពួកអ្នកដែលត្រូវបានហៅឲ្យដើរតាមទ្រង់នឹងបានយល់ ត្រឹមកម្រិតមួយ នូវអ្វីដែលទ្រង់មានន័យដល់ពាក្យថា « អ្នកនេសាទមនុស្ស » ។

ប្រធាន ហារ៉ូលដ៍ ប៊ី លី (ឆ្នាំ ១៨៩៩–១៩៧៣) បានបង្រៀនថា « ការក្លាយជា ‹ អ្នកនេសាទមនុស្ស › គឺគ្រាន់តែជារបៀបម្យ៉ាងទៀតក្នុងការនិយាយថា ‹ អ្នកដឹកនាំមនុស្ស › ។ ដូច្នេះ នៅក្នុងភាសាសម័យនេះ យើងនឹងនិយាយថា ៖ ‹ បើអ្នកនឹងរក្សាបទបញ្ញត្តិទាំងឡាយរបស់យើង នោះយើងនឹងធ្វើឲ្យអ្នកក្លាយជាអ្នកដឹកនាំក្នុងចំណោមមនុស្សទាំងឡាយ › » ។[1]

អ្នកដឹកនាំមនុស្សគឺជាម្នាក់ដែលត្រូវបានហៅឲ្យជួយអ្នកដទៃក្លាយទៅជា « អ្នកដើរតាមដ៏ពិតនៃ . . . ព្រះយេស៊ូវគ្រីស្ទ » (ម៉ូរ៉ូណៃ ៧:៤៨) ។ *ក្បួនខ្នាត ភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* ប្រាប់ថា « ដើម្បីធ្វើដូចនេះបាន ដំបូង អ្នកដឹកនាំត្រូវព្យាយាមធ្វើជាពួកសិស្សស្មោះត្រង់របស់ព្រះអង្គសង្គ្រោះ ដោយរស់នៅតាមជារៀងរាល់ថ្ងៃ ដើម្បីពួកគាត់អាចត្រឡប់ទៅរស់នៅក្នុងវត្តមានរបស់ព្រះ ។ បន្ទាប់មក ពួកគាត់អាចជួយអ្នកដទៃឲ្យអភិវឌ្ឍទីបន្ទាល់រឹងមាំ និង ខិតទៅកាន់តែជិតព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ » ។[2]

> អ្នកទាំងអស់ណាដែលបានទទួលការហៅឲ្យដឹកនាំសាសនាចក្រ គឺបានទទួលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះដើម្បីក្លាយជាអ្នកនេសាទមនុស្ស ។

សំណាញ់ និង ក្រុមប្រឹក្សា

ពីកម្រិតខ្ពស់បំផុតនៃថ្នាក់ដឹកនាំក្នុងសាសនាចក្ររហូតដល់ក្រុមបព្វជិតភាពអើរ៉ុន និង គណៈប្រធានថ្នាក់យុវនារី នោះពួកអ្នកដឹកនាំត្រូវបានរៀបចំឡើងទៅជាក្រុមប្រឹក្សាទាំងឡាយ ។ ពួកអ្នកដឹកនាំត្រូវបានណែនាំឲ្យរៀបចំខាងវិញ្ញាណ ចូលរួមពេញលេញក្នុងក្រុមប្រឹក្សា បម្រើអ្នកដទៃ បង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និង គ្រប់គ្រងបព្វជិតភាព និង អង្គការជំនួយទាំងឡាយរបស់សាសនាចក្រ ។ ជាងនោះទៀត ពួកគាត់ត្រូវកសាងសាមគ្គីភាព និង ភាពចុះសម្រុងគ្នានៅក្នុងសាសនាចក្រ រៀបចំអ្នកផ្សេងទៀតឲ្យក្លាយជាអ្នកដឹកនាំ និង ជាគ្រូ ផ្ទេរការទទួលខុសត្រូវនានា និង ធានាឲ្យបាននូវទំនួលខុសត្រូវ ។[3]

ដូចជាពួកសាវកពីបុរាណដែលបានអនុវត្តការចេះដឹងរបស់ពួកលោកអំពីការនេសាទ ឲ្យក្លាយជាអ្នកនេសាទមនុស្ស នោះយើងអាចអនុវត្តនូវគោលការណ៍ទាំងឡាយដែលមាននៅក្នុងការប្រើប្រាស់សំណាញ់ចំពោះក្រុមប្រឹក្សានៃសាសនាចក្រផងដែរ ។ ដូចជាសំណាញ់មួយដែរ ក្រុមប្រឹក្សាទាំងនេះត្រូវបានបង្កើត និង រៀបចំឡើងឲ្យប្រមូលបុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌ — សមាជិកម្នាក់ៗនៃក្រុមប្រឹក្សាប្រៀបបានទៅនឹងខ្សែសំណាញ់ដែលសំខាន់បំផុត ។ ដូចជាសំណាញ់មួយដែរ វាមានប្រសិទ្ធិភាពបានលុះត្រាតែវាត្រូវបានជួលជុលយ៉ាងល្អ ក្រុមប្រឹក្សាទាំងឡាយចុះខ្សោយ ពេលដែលសមាជិកទាំងឡាយនៃក្រុមប្រឹក្សាពុំត្រូវបានបង្កើតឡើង មិនផ្តោតការយកចិត្តទុកដាក់ និង មិនដំណើរការដូចដែលពួកគេគួរធ្វើ ។

អ្នកដឹកនាំនៃក្រុមប្រឹក្សាត្រូវធ្វើតាមគំរូនៃពួកសាវកពីបុរាណដែលជាអ្នកនេសាទ ដោយការពិនិត្យ និង ជួសជុល « សំណាញ់ » ទាំងនេះជាទៀងទាត់ ។ អ្នកដឹកនាំក្រុមប្រឹក្សាធ្វើដូច្នោះ ដោយការផ្តល់នូវការហ្វឹកហ្វឺនជាទៀងទាត់ ដឹកនាំក្នុងការប្រជុំក្រុមប្រឹក្សា ផ្តល់យោបល់ត្រឹមត្រូវ និង ទាន់ពេលវេលាដល់សមាជិកក្រុមប្រឹក្សា និង ផ្តល់សេចក្តីស្រឡាញ់ ការលើកទឹកចិត្ត និង ការសរសើរ ។ ពុំមានអ្វីមកជំនួសកម្លាំងដ៏មានប្រសិទ្ធិភាព និង សមត្ថភាពនៃការប្រមូលផ្តុំនៃក្រុមប្រឹក្សាដែលដំណើរការត្រឹមត្រូវនោះទេ ។



ចូលរួមក្នុងជួរ

« អំឡុងពេលការបម្រើរបស់លោកចៅហ្វាយ ទ្រង់បានហៅពួកអ្នកនេសាទគ្រីនៅស្រុកកាលីឡេឲ្យបោះបង់ចោលសំណាញ់របស់ពួកគេ ហើយដើរតាមទ្រង់ ដោយប្រកាសថា ‹ ខ្ញុំនឹងតាំងអ្នកឲ្យជាអ្នកនេសាទមនុស្សវិញ › ។ សូមឲ្យយើងចូលរួមក្នុងនាមជាអ្នកនេសាទមុស និង ស្ត្រីទាំងឡាយ ដើម្បីយើងអាចផ្តល់នូវជំនួយអ្វីក៏ដោយដែលយើងអាចធ្វើបាន » ។

ប្រធាន ថូម៉ាស អេស ម៉ុនសុន “Our Responsibility to Rescue,” *លេអាហូណា,* ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ៤ ។

ក្រុមប្រឹក្សារួម

ប្រហែលក្រុមប្រឹក្សាដែលមានឱកាសដ៏ធំធេងបំផុតក្នុងការជះឥទ្ធិពលដល់សមាជិកសាសនាចក្រម្នាក់ៗ គឺក្រុមប្រឹក្សារួម ។ បុរស និង ស្ត្រីទាំងឡាយនៅក្នុងក្រុមប្រឹក្សានេះ គឺពិតជាត្រូវបានហៅឲ្យធ្វើជាអ្នកនេសាទមនុស្ស ដោយមានទំនួលខុសត្រូវក្នុងការដឹកនាំកិច្ចការនៃសេចក្តីសង្គ្រោះនៅក្នុងរួម ដូចដែលត្រូវបានដឹកនាំដោយប៊ីស្សព ។ ពួកគេរស់នៅ និង បម្រើនៅក្នុងរួមជារៀងៗខ្លួន ជាកន្លែងដែលពួកគេអាចស្គាល់ និង ប្រាស្រ័យទាក់ទងនឹងពួកអ្នកដែលពួកគេត្រូវបានហៅឲ្យដឹកនាំនោះ ។

« សមាជិកនៃក្រុមប្រឹក្សារួមព្យាយាមជួយដល់បុគ្គលម្នាក់ឲ្យស្ថាបនាទីបន្ទាល់ ទទួលពិធីបរិសុទ្ធនៃការសង្គ្រោះ រក្សាសេចក្តីសញ្ញាទាំងឡាយ ហើយប្រែក្លាយជាអ្នកដើរតាមដែលបានតែងតាំងរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ូរ៉ូណៃ ៦:៤–៥) ។ សមាជិកនៃក្រុមប្រឹក្សារួមទាំងអស់មានការទទួលខុសត្រូវជាទូទៅមួយចំពោះសុខុមាលភាពរបស់សមាជិករួម » ។[4]

សមាជិកនៃក្រុមប្រឹក្សារួមមានតួនាទីយ៉ាងសំខាន់នៅក្នុងការពន្លឿនកិច្ចការនៃសេចក្តីសង្គ្រោះ ។ ពេលដែលក្រុមប្រឹក្សារួមពុំដំណើរការដូចដែលការគួរ នោះកិច្ចការនឹងដើរយឺត ។ សមត្ថភាពនៃការប្រមូលផ្តុំរបស់ « សំណាញ់ » នឹងចុះខ្សោយ ហើយកិច្ចប្រឹងប្រែងរបស់ក្រុមប្រឹក្សានឹងនាំមកនូវលទ្ធផលដែលមានកម្រិត ។ ប៉ុន្តែ ពេលក្រុមប្រឹក្សារួមត្រូវបានបង្កើតឡើង ហើយយកចិត្តទុកដាក់លើការពង្រឹងបុគ្គល និង ក្រុមគ្រួសារទាំងឡាយ នោះលទ្ធផលអាចជាការភ្ញាក់ផ្អើល ។

ខ្ញុំស្គាល់ច្បាស់ពីរួមមួយដែលជួបការលំបាកក្នុងការមានក្រុមប្រឹក្សារួមដ៏មានប្រសិទ្ធិភាពមួយ ។ វាពិបាកសម្រាប់ប៊ីស្សព ក្នុងការទទួលយកការណែនាំដែលមានក្នុង *ក្បួនខ្នាតភាគ ២* ដោយសារគាត់មានភាពងាយស្រួលនឹងរបៀបរបស់គាត់ ហើយចូលចិត្តរបៀបចាស់របស់គាត់ ។ ទោះជាយ៉ាងណា ក្រោយពីការប្រឹក្សា និង ការហ្វឹកហ្វឺនយ៉ាងច្រើនពីសំណាក់ប្រធានស្តេកដែលពោរពេញដោយក្តីស្រឡាញ់ម្នាក់ នោះប៊ីស្សពបានបន្ទន់ចិត្តរបស់គាត់ បានប្រែចិត្ត ហើយបានចាប់ផ្តើមដោយស្មោះអស់ពីចិត្តដើម្បីបង្កើតក្រុមប្រឹក្សារួមឡើងដូចដែលបានណែនាំ ។ គាត់បានមើលវីដេអូបំពាក់បំប៉នដែលមានលើគេហទំព័រ LDS.org គាត់បានអានផ្នែកទី ៤ និង ៥ នៃ *ក្បួនខ្នាតភាគ ២* ហើយគាត់បានអនុវត្តនូវអ្វីដែលគាត់បានរៀន ។

សមាជិកនៃក្រុមប្រឹក្សារួមបានទទួលយកការផ្លាស់ប្តូរនេះយ៉ាងឆាប់រហ័ស ហើយវិញ្ញាណនៃសេចក្តីស្រឡាញ់ និង សាមគ្គីភាពបានសណ្ឋិតលើពួកគេ កាលដែលពួកគេបានផ្តោតលើការពង្រឹងបុគ្គល និង ក្រុមគ្រួសារទាំងឡាយ ។ នៅក្នុងគ្រប់ការប្រជុំ ពួកគេបាននិយាយយ៉ាងច្រើនអំពីសាសនាគន់ការី អ្នកប្រែចិត្តជឿថ្មី សមាជិកមិនសូវសកម្ម និង សមាជិកដែលត្រូវការជំនួយ ។ ដួងចិត្តរបស់ពួកគេបានចាប់ផ្តើមមានសេចក្តីសប្បុរសចំពោះបងប្អូនប្រុសស្រីទាំងនេះ ហើយអព្ភូតហេតុបានចាប់ផ្តើមកើតឡើង ។

ប៊ីស្សពបានប្រាប់ថា ស្ទើរតែភ្លាមៗក្រោយពីការផ្លាស់ប្តូរទាំងនេះត្រូវបានធ្វើឡើងទាក់ទងនឹងក្រុមប្រឹក្សារួម នោះមានសមាជិកដែលមិនសូវសកម្មពីមុនៗដែលយើងមិនបានស្គាល់ បានចាប់ផ្តើមមកព្រះវិហារ ។ សមាជិកទាំងនេះបាននិយាយថា ពួកគេបានមានអារម្មណ៍ភ្លាមៗថាត្រូវត្រឡប់មកព្រះវិហារវិញ ។ ពួកគេបាននិយាយថា ពួកគេបានទទួលចំណាប់អារម្មណ៍យ៉ាងច្បាស់ថា ពួកគេត្រូវប្រាស្រ័យទាក់ទងនឹងពួកបរិសុទ្ធឡើងវិញ ។ ពួកគេបានដឹងថា ពួកគេនឹងទទួលសេចក្តីស្រឡាញ់ ហើយថា ពួកគេត្រូវការការគាំទ្រដែលសមាជិកផ្តល់ឲ្យ ។

ប៊ីស្សពបានចែកចាយជាមួយខ្ញុំថា គាត់ប្រាកដណាស់ថា ព្រះវរបិតាបានរង់ចាំឲ្យគាត់ធ្វើតាមដំបូន្មានដែលគាត់បានទទួល ហើយបង្កើតក្រុមប្រឹក្សារួមដូចដែលបានណែនាំ មុននឹងទ្រង់អាចដាក់បំណងប្រាថ្នាចូលទៅក្នុងដួងចិត្ត និង គំនិតរបស់ពួកសមាជិកដែលមិនសូវសកម្មទាំងនេះ ឲ្យត្រឡប់មកសកម្មក្នុងព្រះវិហារវិញ ។ ប៊ីស្សពបានដឹងថា គាត់ត្រូវការបង្កើតនូវបរិយាកាសនៃក្តីស្រឡាញ់ និង ចញ្ចឹមបីបាច់ ដែលសមាជិកទាំងនេះត្រូវការ មុននឹងព្រះវិញ្ញាណនឹងដឹកនាំពួកគេឲ្យត្រឡប់មកវិញ ។ ពាក្យសម្តីរបស់គាត់រំឭកខ្ញុំអំពីបទពិសោធន៍របស់ពេត្រុសជាអ្នកនេសាទ ៖

« [ព្រះយេស៊ូវ] យាងចុះទូកមួយនោះ ជាទូករបស់ស៊ីម៉ូន ក៏សូមឲ្យគាត់ចេញទូកពីដីបន្តិចទៅ ។ រួចទ្រង់គង់បង្រៀនដល់បណ្តាមនុស្សពីក្នុងទូកវិញ ។

« លុះឈប់អធិប្បាយហើយ នោះទ្រង់មានបន្ទូលទៅស៊ីម៉ូនថា ឲ្យចេញទូកទៅឯកន្លែងទឹកជ្រៅទម្លាក់អួនចាប់ត្រីចុះ ។

« ស៊ីម៉ូនទូលឆ្លើយថា លោកគ្រូអើយ យប់មិញ យើងខ្ញុំបានខំដឹកអួនទាល់តែភ្លឺ គ្មានបានអ្វីសោះ តែខ្ញុំនឹងទម្លាក់អួនតាមពាក្យលោកមើល ។

« កាលទម្លាក់ទៅ នោះក៏ជាប់បានត្រីសន្ធឹកដល់ម្ល៉េះបានជាអួនចាប់តាំងធ្លាយ » (លូកា ៥:៣–៦) ។

ពេលយើងស្តាប់ និង ធ្វើតាមដំបូន្មានដែលត្រូវបានផ្តល់ដល់យើងដោយពួកព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈសម័យទំនើប — « អ្នកនេសាទមនុស្ស » ដ៏ពិត — ហើយពេលយើងពិនិត្យ និង ជួសជុលសំណាញ់របស់យើងខណៈកំពុងបម្រើ នោះសមត្ថភាពរបស់យើងក្នុងការពន្លឿនកិច្ចការនៃសេចក្តីសង្គ្រោះ នឹងកើនឡើងយ៉ាងខ្លាំង ហើយយើងនឹងក្លាយជាឧបករណ៍នៅក្នុងព្រះហស្តនៃព្រះវរបិតាសួគ៌ដើម្បីប្រមូលបុត្រាបុត្រីរបស់ទ្រង់ ។ ■

កំណត់ចំណាំ

១. ហារ៉ូល ប៊ី លី នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៦០ ទំព័រ ១៥ ។

២. *ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* (ឆ្នាំ ២០១០) ចំណុច ៣.១ ។

៣. សូមមើល *ក្បួនខ្នាតភាគ ២* ចំណុច ៣.២.១–៥; ៣.៣.២–៤ ។

៤. *ក្បួនខ្នាតភាគ ២* ចំណុច ៤.៤ ។

ផ្លែប៉ែសដែលផ្ទុះរបស់ខ្ញុំ

ខ្ញុំបានគិតថា ខ្ញុំគឺជាម្តាយដ៏ល្អឥតខ្ចោះម្នាក់ . . . រហូតទាល់តែដល់ពេលខ្ញុំមានកូន ។

សម្រាប់ខ្ញុំ ភាពជាម្តាយគឺជាភ្លើងរបស់ជាងសំរង ។ ភាពទន់ខ្សោយរបស់ខ្ញុំហាក់លេចចេញមក នៅពេលដែលខ្ញុំថប់អារម្មណ៍ មិនបានគេងគ្រប់គ្រាន់ ព្រួយបារម្ភ ឬ អន់ចិត្ត ។ ពិតណាស់ ពរជ័យនៃភាពជាម្តាយទូទាត់សងវិញចំពោះគ្រាទាំងនោះ ប៉ុន្តែខ្ញុំបានឃើញថា ខ្ញុំមានចិត្តឆេវឆាវ ។ វាគួរឲ្យអាម៉ាស់ណាស់ដែលត្រូវសារភាព ប៉ុន្តែខ្ញុំធ្លាប់ស្រែក ឬ គប់របស់របរដើម្បីទាញយកចំណាប់អារម្មណ៍របស់កូនៗខ្ញុំ ។

ខ្ញុំតាំងចិត្តជាច្រើនដងណាស់ដើម្បីកុំឲ្យចិត្តឆេវឆាវ ប៉ុន្តែខ្ញុំនៅតែមានចិត្តឆេវឆាវនៅពេលខ្ញុំថប់អារម្មណ៍ ។ ព្រះវរបិតាសួគ៌បានដឹងថា ខ្ញុំត្រូវការអ្វីមួយដែលអស្ចារ្យក្រៃលែងដើម្បីជួយខ្ញុំ ។

នៅល្ងាចមួយ បន្ទាប់ពីធ្វើដំណាប់ផ្លែប៉ែសអស់ពេញមួយថ្ងៃ ខ្ញុំបានដាក់ចំហុយដំណាប់ប៉ុន្មានកែវចុងក្រោយ ហើយសម្រេចចិត្តទៅគេងសម្រាកមួយភ្លែត ។ ខ្ញុំមានភាពប្រាកដថា ខ្ញុំនឹងភ្ញាក់ទាន់ពេលដើម្បីយកកែវទាំងនោះចេញពីឆ្នាំងចំហុយ ។

ខ្ញុំមិនបានភ្ញាក់ទេ ។

ឃ្វីន ជាស្វាមីខ្ញុំ និង ខ្ញុំត្រូវបានដាស់ឲ្យភ្ញាក់ឡើង ដោយសារសំឡេងនៃកែវដែលផ្ទុះ ។ ខ្ញុំបានរត់ចូលទៅក្នុងផ្ទះបាយ ហើយបានឃើញអំបែងកែវខ្ចាត់ខ្ចាយ និង ផ្លែប៉ែសស្អិតៗប្រឡាក់ពេញផ្ទះបាយ ។ ជាក់ស្តែង ទឹកក្នុងឆ្នាំងចំហុយនោះរឹងហួតអស់ ហើយកម្តៅ និង សម្ពាធកើនខ្លាំងឡើង គម្របឆ្នាំងបានខ្ចាតប៉ើងឡើង ហើយកែវក្រាំមួយក្នុងចំណោមក្រាំពីរត្រូវផ្ទុះ ។

ខ្ញុំបាននិយាយថា « ខ្ញុំគិតថា ខ្ញុំនឹងសម្អាតវានៅពេលព្រឹក » ។

ជាគំនិតមិនល្អសោះ ។

ដល់ពេលព្រឹក ផ្លែប៉ែសដែលខ្ចាត់ខ្ចាយដ៏ស្មោគគ្រោកនោះបានកកឹង អំបែងកែវនៅជាប់ពេញផ្ទះបាយ និង កន្លែងញុំាអាហារ ។ កម្ទេចតូចៗរបស់កែវផ្លែប៉ែសដែលខ្ចាតខ្ចាយនោះ ថែមទាំងខ្ចាតទៅលើប្រដាប់ប្រដាប្រើប្រាស់ដែលនៅលើតុ និង ខ្ចាតចូលទៅក្នុងគ្រប់ជ្រុងជ្រោយ គ្រប់រន្ធតូចៗ រួមទាំងពីក្រោយទូរទឹកកកទៀតផង ។

ត្រូវចំណាយពេលបួនប្រាំម៉ោងក្នុងការសម្អាតវា ។ ខ្ញុំត្រូវជ្រលក់ក្រដាសឲ្យសើមហើយដាក់នៅលើអំបែងកែវដែលកកនោះ ហើយព្យាយាមកោសជូតវាដោយប្រយ័ត្នកុំឲ្យវាមុតដៃខ្ញុំ ។

ពេលខ្ញុំធ្វើការសម្អាត នោះមានសំឡេងដែលខ្ញុំស្គាល់បានខ្សឹបប្រាប់ខ្ញុំថា ៖ « ម៉ារី ពេលអារម្មណ៍អ្នកផ្ទុះឡើង គឺវាដូចជាកែវទាំងនេះអញ្ចឹង អ្នកមិនអាចជួសជុលវាដោយងាយស្រួលនោះទេ ។ អ្នកមិនអាចមើលឃើញពីកន្លែង និង របៀបដែលកំហឹងរបស់អ្នកធ្វើឲ្យកូនៗអ្នក និង អ្នកដទៃទៀតឈឺចាប់នោះទេ ។ ដូចជាភាពរាយប៉ាយនេះដែរ ភាពឈឺចាប់នោះកកឹងយ៉ាងឆាប់ ហើយវាឈឺខ្លាំងណាស់ » ។

ភ្លាមនោះ ខ្ញុំបានយល់ថាការសម្អាតនោះអាចជានិមិត្តរូបអំពីជីវិតខ្ញុំ ។ មេរៀននោះជាមេរៀនដ៏ពោរពេញដោយចេស្តា ។ ដូចជាកំហឹងរបស់ខ្ញុំដែរ ការសម្អាតមិនមែនធ្វើតែមួយភ្លែតហើយនោះទេ ។ ប៉ុន្មានសប្តាហ៍ក្រោយមក ខ្ញុំនៅ

ខ្ញុំបានរត់ចូលទៅក្នុងផ្ទះបាយ ហើយបានឃើញអំបែងកែវខ្ចាត់ខ្ចាយ និង ដំណាប់ផ្លែប៉ែសស្អិតៗរាយប៉ាយពេញផ្ទះបាយ ។

តើយើងបានធ្វើការណ៍ដ៏ត្រឹមត្រូវឬទេ ?

ខ្ញុំគឺជាអ្នកសារព័ត៌មានដ៏ល្បីម្នាក់ ដែលបាននិពន្ធសម្រាប់ទស្សនាវដ្តី និង កាសែតល្អៗមួយចំនួននៅរដ្ឋធានី លីម៉ា ប្រទេស ពេរូ ប៉ុន្តែនិថីនៃជីវិតខ្ញុំ — ឆ្ងាយពីព្រះ — បានធ្វើទារុណកម្មខ្ញុំកាន់តែខ្លាំងឡើងៗជារៀងរាល់ថ្ងៃ ។ ដោយសារតែបែបនេះ ខ្ញុំបានទទួលការងារមួយដោយធ្វើជាអ្នកអានកំណែសម្រាប់ទស្សនាវដ្តីមួយនៅក្នុងស្រុក វិនថានីឡា ដែលនៅឆ្ងាយពីផ្ទះខ្ញុំ ។ ខ្ញុំបានព្យាយាមយ៉ាងខ្លាំងដើម្បីស្វែងរកការបៀបមួយ ដើម្បីនៅឲ្យឆ្ងាយពីក្រុមមិត្តភក្តិរបស់ខ្ញុំ ។ នៅវិនថានីឡា ខ្ញុំបានដឹងនៅក្នុងដួងចិត្តខ្ញុំថា ជីវិតខ្ញុំនឹងផ្លាស់ប្តូរ ។

ពេលខ្លះ ខ្ញុំបានទៅព្រះវិហារជាមួយ ម៉ារៀ គ្រីស្ទីណា ជាមិត្តស្រីខ្ញុំ ពេលដែលអ្នកផ្សព្វផ្សាយសាសនារឹងក្បាលដ៏ល្អពីរនាក់បានលួងលោមឲ្យខ្ញុំសួរដល់ព្រះវរបិតាសួគ៌នៅក្នុងការអធិស្ឋាន ថាបើសាសនាចក្រគឺជាសាសនាចក្រពិត ។ ខ្ញុំបានធ្វើដូច្នោះ ហើយអ្វីដែលខ្ញុំបានមានបទពិសោធន៍គឺពុំអាចពិពណ៌នាបានឡើយ ។ ខ្ញុំពុំដែលទទួលអារម្មណ៍ពីព្រះវិញ្ញាណខ្លាំងដូចជានៅថ្ងៃដែលមិនអាចបំភ្លេចបាននោះឡើយ ។

ដោយបានរៀបការ និង ទទួលបុណ្យជ្រមុជទឹកមិនយូរប៉ុន្មានក្រោយពីនោះ នោះម៉ារៀ គ្រីស្ទីណា និង ខ្ញុំបានជួលបន្ទប់ដ៏តូច និង មិនស្រួលរស់នៅនៅវិនថានីឡា ។ ដោយសារតែខ្ញុំខំធ្វើការ នោះខ្ញុំបានឡើងតំណែងពីអ្នកអានកំណែ ទៅជាអ្នកបោះពុម្ពផ្សាយប្រចាំទស្សនាវដ្តី និង កាសែតរបស់ក្រុមហ៊ុននោះ ។ ខ្ញុំពុំដែលធ្លាប់ធ្វើជាអ្នកបោះពុម្ពផ្សាយពីមុនមកទេ ហើយខ្ញុំសប្បាយចិត្តនឹងមុខតំណែងថ្មីនោះ ។ ទោះបីដូច្នោះក្តី អ្វីៗចាប់ផ្តើមប្រែប្រួល ពេលដែលការបោះពុម្ពរបស់យើងចាប់ផ្តើមបន្ទាបបន្ថោកដល់ស្តង់ដារ និង គោលការណ៍ដែលអសីលធម៌ ។ ការផ្លាស់ប្តូរនេះ ត្រូវបានបញ្ជាដោយនាយករបស់យើង ដែលផ្ទុយពីគោលការណ៍ និង តម្លៃនៃសាសនាចក្រ ។

ខ្ញុំតែងតែចង់ធ្វើជាអ្នកបោះពុម្ពផ្សាយ ប៉ុន្តែស្ថានភាពនេះធ្វើឲ្យខ្ញុំមិនស្រួលក្នុងចិត្តសោះ ។ បីស្បាតរបស់យើងបានផ្តល់យោបល់ថា បើយើងធ្វើអ្វីៗដែលសព្វព្រះទ័យដល់ព្រះវរបិតាសួគ៌យើង នោះទ្រង់នឹងប្រទានពរយើង ។ បន្ទាប់ពីភរិយាខ្ញុំ និង ខ្ញុំបានគិតហើយគិតទៀត ហើយបានអធិស្ឋានអំពីវា យើងទទួលការបំផុសថា ខ្ញុំគួរតែឈប់ពីការងារខ្ញុំ ។

ពីរបីថ្ងៃក្រោយមក ខ្ញុំចាប់ផ្តើមមានការថប់អារម្មណ៍ ហើយឆ្ងល់ថា តើខ្ញុំបានធ្វើរឿងត្រឹមត្រូវដែរឬទេ ។ បន្ទាប់ពីការសុំលាលែងពីការងារ ខ្ញុំបានដាក់ពាក្យកែការងារទៅក្រុមហ៊ុនមួយចំនួន ប៉ុន្តែពុំបានឮអ្វីឡើយ ។ ម៉ារៀ គ្រីស្ទីណា បានផ្តល់យោបល់ថា យើងអធិស្ឋានម្តងទៀត ហើយយើងបានធ្វើដូច្នោះ ។ យើងបានអធិស្ឋានថា អ្វីៗនឹងប្រសើរឡើង ហើយថាយើងនឹងមិនបាត់បង់សេចក្តីជំនឿទេ ទោះជាមានវិក័យប័ត្រច្រើនដែលយើងត្រូវបង់ក៏ដោយ ។

ពីរបីម៉ោងក្រោយមក ភរិយាខ្ញុំបានលើកទឹកចិត្តខ្ញុំឲ្យទូរស័ព្ទទៅក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំងនោះ ។ ដោយមិនគួរឲ្យជឿ ខ្ញុំបានទូរស័ព្ទទៅ ។ ខ្ញុំបានស្រឡាំងកាំង ពេលមន្ត្រីនៅទីនោះបាននិយាយថា គាត់រៀបនឹងទូរស័ព្ទមកខ្ញុំ ។ គាត់ចង់ដឹងថាបើខ្ញុំអាចចាប់ផ្តើមធ្វើការថ្ងៃស្អែក !

ពួកយើងបានយំដោយសេចក្តីអំណរ ។ ព្រះវរបិតាសួគ៌យើងបានឆ្លើយតបការអធិស្ឋានរបស់យើង ។

យើងត្រូវតែចាកចេញពីវួដ និង មិត្តភក្តិល្អៗរបស់យើងជាច្រើនសម្រាប់ការងារថ្មីរបស់ខ្ញុំ ប៉ុន្តែយើងបានចាកចេញជាមួយនឹងទីបន្ទាល់ដែលកាន់តែរឹងមាំ ។ ឥឡូវនេះ ខ្ញុំមានការងារដ៏គួរឲ្យគោរព និង មានប្រាក់ខែល្អ ហើយយើងរស់នៅក្នុងកន្លែងល្អមួយ ។ លើសអស់អ្វីៗទាំងអស់ យើងត្រូវបានប្រទានពរជាមួយនឹងភាពប្រាកដប្រជាថា ពេលយើងធ្វើអ្វីៗដែលសព្វព្រះទ័យព្រះ នោះយើងទទួលបានពរជ័យរបស់ទ្រង់ ។ ■

ខាឡូស ចាវៀ លេអន យូហ្គាតេ រដ្ឋធានី លីម៉ា ប្រទេស ពេរូ

តែយើញមានដុំផ្លែប៉ែសកកជាប់នឹងអំបែងកែវខ្លះៗ ។

ខ្ញុំអធិស្ឋានថា ថ្ងៃមួយការអត់ធ្មត់របស់ខ្ញុំនឹងក្លាយជាកម្លាំងដ៏អស្ចារ្យ ដូចជាភាពទន់ខ្សោយដែរ ។ សម្រាប់ពេលនេះ ខ្ញុំមានអំណរគុណដែលដង្វាយធួនរបស់ព្រះអម្ចាស់កំពុងជួយខ្ញុំឲ្យគ្រប់គ្រងអារម្មណ៍របស់ខ្ញុំបានកាន់តែប្រសើរ ដើម្បីខ្ញុំអាចការពារកុំឲ្យអ្នកដែលខ្ញុំស្រឡាញ់ត្រូវទទួលរងនូវភាពរាយប៉ាយដែលបណ្តាលមកពីការផ្ទុះកំហឹងរបស់ខ្ញុំ ។ ■

ម៉ារី ប៊ីសឹងហ្គ័រ រដ្ឋ យូថាហ៍ ស.រ.អា

ខ្ញុំស្រឡាញ់អ្នក

កាលដែលសន្និសីទហ្សូនបេសកកម្មរបស់ខ្ញុំជិតមកដល់ នោះខ្ញុំបានឈរនៅខាងក្រៅដោយគិតថា « តើខ្ញុំកំពុងធ្វើអ្វីនៅក្នុងប្រទេសគេនេះ ? តើខ្ញុំនឹងធ្វើអ្វីៗទាំងអស់ដែលគេរំពឹងពីខ្ញុំដោយរបៀបណាទៅ ? »

ខ្ញុំបានមកដល់ទីក្រុង សីសីលី ប្រទេស អ៊ីតាលី ជាងមួយសប្តាហ៍ ប៉ុន្តែខ្ញុំបានមានអារម្មណ៍បាក់ទឹកចិត្តបាត់ទៅហើយ ។ ពេលវេលារបស់ខ្ញុំនៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកផ្សព្វផ្សាយសាសនាហាក់បីដូចជាសុបិនមួយដ៏អស្ចារ្យ ប៉ុន្តែ ដោយសារភាពមិនពេញលេញរបស់ខ្ញុំ ឥឡូវនេះខ្ញុំបានមានអារម្មណ៍ថា ខ្ញុំដូចជានៅក្នុងសុបិនដ៏អាក្រក់មួយ ។

ខ្ញុំបានអធិស្ឋានថា « ព្រះវរបិតាជាទីស្រឡាញ់អើយ កូនចង់ក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យ ។ ឥឡូវនេះ ដោយកូននៅទីនេះ នោះកូនដឹងថា កូនពុំមានភាពបិនប្រសប់ ជំនាញ ឬ ភាពឈ្លាសវៃ ដើម្បីសម្រេចបាននូវអ្វីដែលកូនត្រូវបានបញ្ជូនឲ្យមកធ្វើនោះទេ ។ កូនបានគិតថា កូនចេះភាសានេះ ប៉ុន្តែអ្នកគ្រប់គ្នានិយាយលឿនៗណាស់ ហើយពាក្យណាក៏ដោយដែលកូនព្យាយាមបញ្ចេញសម្លេងចេញទៅ គឺត្រូវបានធ្វើឲ្យប្រទាក់នឹងអណ្តាតកូន ។ កូនគិតថា ដៃគូរបស់កូនមិនចូលចិត្តកូនទេ ។ ប្រធានបេសកកម្មរបស់កូននិយាយភាសាអង់គ្លេសបានតែបន្តិចបន្តួច ។ កូនគ្មាននរណានឹងនិយាយជាមួយទេ ។ សូមជួយកូនផង » ។

ខ្ញុំបានដឹងថា ខ្ញុំត្រូវត្រឡប់ចូលខាងក្នុងវិញ ប៉ុន្តែខ្ញុំបាននៅបង្អែបង្អង់នៅតាមផ្លូវពីរបីនាទីទៀត ។ រំពេចនោះ មាននរណាម្នាក់ទាញខ្នងអាវធំខ្ញុំពីរបីដង ។ ខ្ញុំបានបែរខ្នង ហើយបានឃើញក្មេងស្រីតូចដ៏ស្រស់ស្អាតម្នាក់ ហើយខ្ញុំបានលុតជង្គង់ចុះយឺតៗទៅក្បែរនាងនៅលើផ្លូវគ្រួសនោះ ។ នាងបានដាក់ដៃនាងជុំវិញកខ្ញុំ ហើយខ្សឹបទៅត្រចៀកខ្ញុំថា “Ti voglio bene” ។

« តើប្អូននិយាយថាម៉េច ? » ខ្ញុំបានសួរជាភាសាអង់គ្លេស ដោយដឹងយ៉ាងច្បាស់ថា នាងពុំយល់នោះទេ ។

នាងបានសម្លឹងទៅស្លាកឈ្មោះខ្ញុំ ។ “Sorella Domenici,” នាងបានអាន “ti voglio bene” ។

ខ្ញុំស្គាល់ពីអត្ថន័យនៃឃ្លានោះ ។ វាជាឃ្លាដំបូងមួយដែលយើងបានរៀនក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។ វាជាឃ្លាមួយដែលអាចនិយាយដោយផ្ទាល់ទៅកាន់ព្រលឹង ។ វាមានន័យថា « ខ្ញុំស្រឡាញ់អ្នក » ។

ពាក្យទាំងនោះគឺពិតជាពាក្យដែលខ្ញុំត្រូវការឮនៅពេលនោះតែម្តង ។ ព្រះអង្គសង្គ្រោះបានបញ្ជូនសារទូតដ៏ពិសេសម្នាក់ឲ្យបញ្ជូនសារនោះដល់ខ្ញុំ ។ ខ្ញុំបាននាំក្មេងស្រីនោះចូលទៅក្នុងអគារ ។

ខ្ញុំបានគិតថា « នាងប្រាកដជាកូនរបស់សមាជិក » ។ ខ្ញុំបានដើរដោយប្រុងប្រយ័ត្នកាត់ក្រុមអ្នកផ្សព្វផ្សាយសាសនា ដោយសង្ឃឹមថាម្តាយនាងនឹងឃើញនាង ។

ពេលខ្ញុំរកឃើញដៃគូខ្ញុំ ខ្ញុំបានសួរថា « តើស៊ីស្ទើរធ្លាប់បានឃើញក្មេងស្រីតូចនេះពីមុនមកទេ ? »

គាត់បានឆ្លើយតប ដោយងឿងឆ្ងល់ « ក្មេងស្រីតូចអីគេ ? »

ខ្ញុំបានក្រឡេកមើលទៅចំហៀងខ្ញុំ ។ ក្មេងស្រីតូចនោះបានទៅបាត់ហើយ ។

ខ្ញុំបានឈរនៅទ្វារអគារ ហើយសម្លឹងចុះឡើងទៅផ្លូវខ្សាច់នោះ ។ ខណៈដែលខ្ញុំពិចារណា នោះសម្លេងខ្សឹប ដែលខ្ញុំមិនត្រឹមតែបានឮប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបន្ទរចូលទៅក្នុងព្រលឹងខ្ញុំថា ៖ “Sorella Domenici, ti voglio bene” ។

ខ្ញុំពុំបានដឹងថា ក្មេងស្រីតូចនោះជានរណាទេ ប៉ុន្តែខ្ញុំបានដឹងថា ព្រះអង្គសង្គ្រោះទ្រង់ស្រឡាញ់ខ្ញុំ ។ ■

ណាថាលី ធី ហ្វ្រីសត្លេរ យូថាហ៍ ស.ប.អា

ខ្ញុំបានបែរខ្នង ហើយបានឃើញក្មេងស្រីតូចដ៏ស្រស់ស្អាតម្នាក់ ហើយខ្ញុំបានលុតជង្គង់ចុះយឺតៗទៅក្បែរនាងនៅលើផ្លូវគ្រួសនោះ ។

ពេលរសៀលថ្ងៃស្អែកនោះ ខ្ញុំបានទទួលការបំផុសឲ្យយកម្ហូបដែលខ្ញុំបានចម្អិនសម្រាប់អាហារពេលល្ងាចទៅជូនបងស្រី ម៉ារហ្គិន និង ស្វាមីគាត់ សម្រាប់ខួបអាពាហ៍ពិពាហ៍របស់ពួកគាត់ ។

តើអាហាររបស់ខ្ញុំសាមញ្ញពេកឬ ?

អស់រយៈពេលពីរឆ្នាំ ខ្ញុំបានបង្រៀនសូរសុខទុក្ខអ្នកជិតខាង និង ជាមិត្តខ្ញុំម្នាក់ ឈ្មោះបងស្រី ម៉ារហ្គិន ។ គាត់មានអាយុច្រើនជាងខ្ញុំច្រើន ដូច្នេះ ខ្ញុំបានរៀនពីគាត់ និង ពីជីវិតគាត់យ៉ាងច្រើន ដូចដែលគាត់បានរៀនពីសារលិខិតបង្រៀនសូរសុខទុក្ខរបស់ខ្ញុំដែរ ។

ពេលដែលខ្ញុំជាគ្រូបង្រៀនសូរសុខទុក្ខរបស់គាត់ បងស្រី ម៉ារហ្គិន ត្រូវបានរកឃើញថាមានជំងឺមហារីក ។ ខ្ញុំមានភាពអស្ចារ្យចំពោះការស៊ូទ្រាំដ៏ក្លាហានរបស់គាត់ទៅនឹងការព្យាបាលខាងវេជ្ជសាស្ត្ររបស់គាត់ ហើយគាត់តែងតែមានស្នាមញញឹមស្នើរតែគ្រប់ពេល ។

អំឡុងពេលនៃការសូរសុខទុក្ខមួយរបស់ខ្ញុំ គាត់បានលើកឡើងថា ថ្ងៃស្អែកនោះគឺជាថ្ងៃខួបអាពាហ៍ពិពាហ៍របស់គាត់ ។ មិនយូរប៉ុន្មាន ការសន្ទនារបស់យើងបាននាំទៅរឿងផ្សេង ហើយការសូរសុខទុក្ខរបស់យើងក៏បានបញ្ចប់ ។

ពេលរសៀលថ្ងៃស្អែកនោះ ខ្ញុំបានទទួលការបំផុសឲ្យយកម្ហូបដែលខ្ញុំបានចម្អិនសម្រាប់អាហារពេលល្ងាចទៅជូនបងស្រី ម៉ារហ្គិន និង ស្វាមីគាត់សម្រាប់ខួបអាពាហ៍ពិពាហ៍របស់ពួកគាត់ ។ ពីដំបូង ខ្ញុំបានព្រងើយកន្តើយនឹងការបំផុសនោះ ដោយសារខ្ញុំគ្រាន់តែធ្វើម្ហូបធម្មតាៗប៉ុណ្ណោះ ។ ពិតណាស់ ម្ហូបធម្មតាបែបនេះវានឹងមិនសមនឹងឱកាសដ៏ពិសេសបែបនេះទេ ។

ប៉ុន្តែ ការបំផុសនោះមិនចាកចេញពីខ្ញុំទេ ។ ខ្ញុំបានទូរស័ព្ទទៅស្វាមីខ្ញុំដែលនៅកន្លែងធ្វើការ ដោយសង្ឃឹមថា គាត់នឹងយល់ស្របថា វាមិនមែនជាគំនិតល្អទេ ។ ផ្ទុយទៅវិញ គាត់បានលើកទឹកចិត្តខ្ញុំឲ្យទូរស័ព្ទទៅបងស្រី ម៉ារហ្គិន ហើយប្រាប់គាត់ថាខ្ញុំនឹងយកអាហារពេលល្ងាចទៅជូនគាត់ ។

ដោយខ្មាស់អៀននឹងម្ហូបដ៏សាមញ្ញរបស់ខ្ញុំ ហើយអ្វីដែលខ្ញុំគិតនោះគឺជាការសន្មត់ខាងខ្ញុំខ្លួនឯងផងនោះ បានរារាំងខ្ញុំមិនឲ្យទូរស័ព្ទទៅមិត្តរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចបោះបង់ចោលអារម្មណ៍ដែលថា ខ្ញុំត្រូវចែកចាយអាហារពេលល្ងាចរបស់ខ្ញុំនោះឡើយ ។ ដូច្នេះ ខ្ញុំបានចាប់ម្ហូបដាក់ចាន ហើយដើរឆ្លងផ្លូវទៅទាំងភ័យ ។

ពេលខ្ញុំចូលក្នុងទីធ្លារបស់ពួកគាត់ ខ្ញុំបានឃើញបងប្រុស និង បងស្រី ម៉ារហ្គិន កំពុងចូលក្នុងឡានរបស់ពួកគាត់ ។ ខ្ញុំបានប្រាប់ថា ខ្ញុំបានយកអាហារពេលល្ងាចមកសម្រាប់ខួបអាពាហ៍ពិពាហ៍របស់ពួកគាត់ ហើយសង្ឃឹមថា ពួកគាត់មិនប្រកាន់ទេ ។

ស្នាមញញឹមពព្រាយបានលេចឡើងនៅលើផ្ទៃមុខរបស់បងស្រី ម៉ារហ្គិន ។ គាត់បានពន្យល់ថា ពួកគាត់បានសម្រេចចិត្តទៅអបអរខួបអាពាហ៍ពិពាហ៍របស់ពួកគាត់នៅឯភោជនីយដ្ឋានក្នុងតំបន់មួយ ព្រោះមហារីករបស់គាត់ធ្វើឲ្យគាត់អស់កម្លាំងខ្លាំង មិនអាចចម្អិនម្ហូប ឬ ទៅកន្លែងណាទៀតបានទេ ។ មើលទៅគាត់ហាក់រសាយចិត្តដែលអាចញ៉ាំអាហារពេលល្ងាចនៅផ្ទះ ។

ខ្ញុំមានអារម្មណ៍រសាយចិត្ត និង សប្បាយរីករាយពេលពួកគាត់បានទទួលយកអាហារដ៏សាមញ្ញរបស់ខ្ញុំ ។

មិនបានពីរខែក្រោយមក ពេលបងស្រី ម៉ារហ្គិន បានបញ្ចប់ការព្យាបាលមហារីករបស់គាត់ ស្វាមីជាទីស្រឡាញ់របស់គាត់បានទទួលមរណៈភាពទៅដោយសារជំងឺឈឺភ្លាមៗមួយ ។ ខួបអាពាហ៍ពិពាហ៍របស់ពួកគាត់គឺទើបតែប៉ុន្មានសប្តាហ៍មុនថ្ងៃចុងក្រោយរបស់ពួកគាត់ប៉ុណ្ណោះ ។

ខ្ញុំបានរៀនយ៉ាងច្រើនពីពេលនោះ អំពីការធ្វើតាមសំឡេងដ៏តូចរហៀងរបស់ព្រះវិញ្ញាណ នៅក្នុងការបម្រើដល់អ្នកដទៃ ។ ការបម្រើដែលយើងត្រូវបានស្នើ — ឬ ត្រូវបានបំផុស — ឲ្យធ្វើ អាចមិនមានភាពងាយស្រួល ឬ សាមញ្ញពេកនៅក្នុងក្រសែភ្នែកយើង ប៉ុន្តែ ប្រហែលវាជាអ្វីដែលត្រូវការនោះឯង ។ បទពិសោធន៍នេះ បានផ្តល់ភាពក្លាហានដល់ខ្ញុំ ដើម្បីបម្រើក្នុងគ្រប់លទ្ធភាពដែលព្រះអម្ចាស់ត្រូវការខ្ញុំ ហើយវាបង្កើនសេចក្តីជំនឿរបស់ខ្ញុំដើម្បីធ្វើ « កិច្ចការនៃពួកទេវតា » (« ដោយជាស្ត្រីក្នុងសិយ៉ូន » *ទំនុកតម្កើង*, លេខ ១៥៦) ។ ■

ធេនីហ្វើ ឃ្លីងហូនស្ទីត រដ្ឋ យូថាហ៍ ស.ប.អ

ការទុកចិត្តលើ ការអះអាងទាំងឡាយ របស់ព្រះអម្ចាស់

យើងអាចនឹងមិនតែងតែត្រូវបានដោះលែងចេញពីការសាកល្បងរបស់យើងនោះទេ ប៉ុន្តែពេលយើងស្វែងរកការអះអាងទាំងឡាយរបស់ព្រះអម្ចាស់ នោះយើងអាចដឹងថាអ្វីៗទាំងអស់នឹងបានស្រួល សូម្បីតែនៅក្នុងគ្រាសាកល្បងទាំងឡាយ ។

ដោយ មិនឌី អែន ឡាំតែ
ទស្សនាវដ្តីសាសនាចក្រ

ខ្ញុំបានអង្គុយនៅក្នុងបន្ទប់សេឡេស្ទាលនៃព្រះវិហារបរិសុទ្ធ សញ្ជឹងគិតពីទិសដៅនៃជីវិតខ្ញុំ — គឺពិតជាចេញពីផ្លូវដែលខ្ញុំបានដាក់ផែនការ ។ ដូចជាមជ្ឈិមវ័យវ័យក្មេងជាច្រើនទៀតដែរ អ្វីដែលខ្ញុំឮក្នុងគំនិតខ្ញុំគឺការព្រួយបារម្ភរបស់ខ្ញុំ ៖ តើខ្ញុំអាចធ្វើឲ្យមានតុល្យភាពរវាងពិន្ទុល្អក្នុងថ្នាក់ និង មានជីវិតមួយល្អខាងសង្គមយ៉ាងដូចម្តេចទៅ ? តើខ្ញុំគួរតែឈប់ពីការងាររបស់ខ្ញុំ ? ស្វែងរកការងាមួយផ្សេងទៀត ? តើខ្ញុំអាចសន្សំលុយយ៉ាងណាទៅ បើខ្ញុំអត់មានលុយផង ? ហេតុអ្វីខ្ញុំមិនទាន់រៀបការ ? បញ្ជីនៃការគិតនោះចេះតែបន្តដោយការព្រួយបារម្ភ ។ ខ្ញុំបានទៅព្រះវិហារបរិសុទ្ធដើម្បីស្វែងរកការលួងលោម ដោយអធិស្ឋានដើម្បីបានការអះអាងថា ជីវិតរបស់ខ្ញុំគឺស្ថិតក្នុងព្រះហស្តព្រះវរបិតាសួគ៌ ។ « តើអ្វីៗគ្រប់យ៉ាងនឹងបានរៀបរយនៅក្នុងជីវិតខ្ញុំឬទេ ? » ខ្ញុំបានសួរ ។ ចម្លើយបានចូលមកក្នុងគំនិតខ្ញុំយ៉ាងរហ័ស និង ប្រាកដប្រជាថា ៖ « *អ្វីៗទាំងអស់ នឹងបាន* ស្រួល » ។

ក្នុងគ្រានោះ ខ្ញុំបានយល់ថា ទោះបីជាជីវិតរបស់ខ្ញុំពុំបានដូចជាអ្វីដែលខ្ញុំបានដាក់ផែនការ ក៏វាកំពុងតែស្របទៅតាមផែនការ *របស់ទ្រង់* ហើយទ្រង់ជាអ្នកគ្រប់គ្រង ។ ការអះអាងដ៏ផ្អែមល្ហែមនោះដែលថា ទ្រង់ស្គាល់ និង ថែរក្សាខ្ញុំ សូម្បីបើទ្រង់មិនតែងតែដកយកចេញនូវការសាកល្បងរបស់ខ្ញុំក៏ដោយ ក៏ទ្រង់បានបីត្រកងខ្ញុំឆ្លងកាត់ការលំបាកទាំងឡាយដែរ ។ ពេលយើងបានយល់ ស្វែងរក និង រង់ចាំដើម្បីបានការអះអាងទាំងនេះ នោះយើងអាចដឹងថា ព្រះអម្ចាស់គាំទ្រយើងឆ្លងកាត់បន្ទុកដែលត្រូវបានដាក់លើយើង ។

ការអះអាងជាជាងការដោះលែង

ច្បាស់ណាស់ ការដោះលែងភ្លាមៗចេញពីការសាកល្បងរបស់យើងមិនមែនតែងតែជាចម្លើយរបស់ព្រះអម្ចាស់ចំពោះការអង្វររបស់យើងនោះទេ ។ ផ្ទុយពីនោះ ទ្រង់អាចនឹងប្រទានពរយើងជាមួយនឹងការអះអាងទាំងឡាយដែលមានតម្លៃឥតគណនាតាមរយៈវិវរណៈផ្ទាល់ខ្លួន — ជាការអះអាងដែលថាទ្រង់ដឹកនាំជីវិតយើង ហើយទ្រង់នឹងដោះលែងយើងចេញពីការសាកល្បងរបស់យើង ។ ការអះអាងទាំងនេះអាចនឹងមិនដោះលែងយើងចេញពីការសាកល្បងរបស់យើងនោះទេ ប៉ុន្តែប្រហែលនឹងផ្តល់ដល់យើងនូវកម្លាំងដែលយើងត្រូវការដើម្បីដោះលែងខ្លួនយើង សូម្បីបើការដោះលែងនោះគ្រាន់តែជាការលួងលោមពីព្រះវិញ្ញាណបរិសុទ្ធក៏ដោយ ។ ជាញឹកញាប់ ខ្ញុំបានកត់សម្គាល់គំរូជាច្រើននៅក្នុងព្រះគម្ពីរ ពីរបៀបដែលព្រះអម្ចាស់បានបញ្ជូនការអះអាងមកមុនការដោះលែង ។

ខណៈដែលហេលេមិនកំពុងដឹកនាំកងពលកំលោះទាំង ២០៦០ នាក់ និង កងទ័ពសាសន៍នីហ្វៃផ្សេងទៀតរបស់លោក ពួកគេបានទទួលការអះអាងពីព្រះអម្ចាស់ ។ បន្ទាប់ពីការរង់ចាំអស់ជាច្រើនខែដើម្បីទទួលបានស្បៀង និង កងទ័ពជំនួយបន្ថែម នោះពួកគេស្ថិតក្នុងដំណាក់កាលនៃការអត់ឃ្លានយ៉ាងខ្លាំង ពេលដែលស្បៀងអាហារមកដល់ជាមួយនឹងពលទ័ពមួយក្រុមតូច ។ ដោយខ្លាចថាពលទ័ពបន្ថែមដ៏តិចតួចនេះមិនគ្រប់គ្រាន់ នោះនៅទីបំផុតពួកគេបានបែរទៅរកព្រះអម្ចាស់ ហើយ « បានខិតខំអស់ពីដួងចិត្តនៅក្នុងការអធិស្ឋានដល់ព្រះ សូមឲ្យទ្រង់ចម្រើនកម្លាំងដល់ [ពួកគេ] » ។ បន្ទាប់ពីពួកគេអធិស្ឋាន

ហើយ ហេលេមិនបានរៀបរាប់ថា « ព្រះអម្ចាស់ជាព្រះរបស់យើង ទ្រង់បានយាងមកជួបយើង ដោយនូវការអះអាងទាំងឡាយថា ទ្រង់នឹងដោះលែងពួកយើងឲ្យរួច មែនហើយ ដរាបដល់ទ្រង់មានព្រះបន្ទូលនូវសេចក្តីសុខសាន្តដល់ព្រលឹងពួកយើង ហើយបានប្រទានដល់យើងនូវសេចក្តីជំនឿដ៏ធំ ហើយបានធ្វើឲ្យយើងមានសេចក្តីសង្ឃឹមដល់ការដោះលែងពួកយើងក្នុងទ្រង់ » (អាលម៉ា ៥៨:១០–១១) ។ ការអះអាងទាំងនេះបានផ្តល់ដល់ហេលេមិន និង កងពលរបស់លោកនូវកម្លាំងដើម្បីមានសេចក្តីខ្ជាប់ខ្ជួន និង យកជ័យជំនះលើសត្រូវរបស់ពួកគេ ។

យ៉ូសែប ស្ម៊ីធ ក៏បានទទួលការអះអាងមួយផងដែរពីព្រះអម្ចាស់ ពេលជាប់នៅក្នុងគុកលីប៊ើធី ។ កាលដែលលោកបានអធិស្ឋានដោយក្តៀវក្លា នោះលោកត្រូវបានប្រាប់ថា ៖

« បុត្រយើងអើយ ចូរមានសេចក្តីសុខសាន្តដល់ព្រលឹងបុត្រចុះ សេចក្តីទំនាស់ និងសេចក្តីលំបាករបស់អ្នកនោះគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ

« ហើយខណៈនោះ បើសិនជាអ្នកស៊ូទ្រាំការណ៍នោះដោយហ្មត់ចត់ នោះព្រះទ្រង់នឹងតម្កើងអ្នកឡើងនៅស្ថានខ្ពស់ » (គ. និង ស. ១២១:៧–៨) ។

ការអះអាងនេះបានផ្តល់ដល់យ៉ូសែបនូវសេចក្តីក្លាហាន និង កម្លាំងចិត្តដើម្បីបន្តស៊ូទ្រាំចំពោះការលំបាកទាំងឡាយដែលស្ទើរតែយកឈ្នះលើលោកនោះ ។

ក្នុងគំរូទាំងនេះ និង ជាច្រើនផ្សេងទៀត (ជាឧទាហរណ៍ សូមមើល ម៉ូសាយ ២៤:៨–១៦) ព្រះអម្ចាស់ពុំគ្រាន់តែដោះលែងពួកអ្នកស្មោះត្រង់ចេញពីការសោកល្បងរបស់ពួកគេភ្លាមនោះទេ ។ ប៉ុន្តែ ទ្រង់បានយាងមកជួបពួកគេជាមួយនឹង *ការអះអាង* ថា ទ្រង់ *នឹង* ដោះលែងពួកគេនៅក្នុងពេលវេលារបស់ទ្រង់ ។ ដោយខ្ចីពាក្យសម្តីពីអែលឌើរ រីឆាដ ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់ នោះការអះអាងទាំងនេះគឺដូចជា « សំណុំនៃពន្លឺព្រះអាទិត្យខាងវិញ្ញាណ » ដែលព្រះវរបិតាសួគ៌ដាក់នៅតាមផ្លូវរបស់យើង « ដើម្បីបំភ្លឺផ្លូវ [របស់យើង] » ។[9] ជួនកាលការអះអាងនោះគឺជាអ្វីៗទាំងអស់ដែលយើងត្រូវការ ដើម្បីខំព្យាយាមឆ្លងកាត់ការសោកល្បងរបស់យើង ដោយដឹងថា នឹងមានការដោះលែងនៅទីបំផុត ។

ការអះអាងនៃអំណាចរបស់ទ្រង់

« យើងទាំងអស់គ្នាត្រូវតែប្រឈមនឹងភាពមិនអនុគ្រោះ ។ . . . ខណៈដែលយើងត្រូវតែរង់ចាំដោយទុក្ខព្រួយដើម្បីបានការរំដោះដែលបានសន្យារបស់ព្រះអង្គសង្គ្រោះ វានឹងលួងលោមយើងចា ទ្រង់ត្រាស់ដឹង ចេញពីបទពិសោធន៍ ពីរបៀបព្យាបាល និង ជួយយើង ។ ព្រះគម្ពីរមរមនផ្តល់ដល់យើងនូវការអះអាងជាក់លាក់មួយអំពីអំណាចដើម្បីលួងលោមរបស់ទ្រង់ ។ ហើយសេចក្តីជំនឿនៅក្នុងអំណាចនោះ នឹងផ្តល់ដល់យើងនូវការអត់ធ្មត់ កាលដែលយើងអធិស្ឋាន និង ខិតខំ ហើយរង់ចាំជំនួយ ។

ប្រធាន ហិនរ៍ ប៊ី អារ៉ិង ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ "Adversity," *លីអាហូណា,* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ២៤ ។

ស្វែងរកការអះអាង

ជីវិតគឺលំបាក ។ មានពេលវេលាទាំងឡាយពេលដែលយើងសង្ស័យ ពេលដែលយើងខ្វះទំនុកចិត្តលើខ្លួនយើង និង លើសមត្ថភាពរបស់យើងក្នុងការយកជ័យជំនះលើមាសត្រូវ ពេលយើងបាត់បង់សេចក្តីសង្ឃឹម ។ ជាញឹកញាប់ វាអាចមានអារម្មណ៍ដូចជាការសោកល្បងរបស់យើងមិនចេះចប់សោះ ។ ហើយទោះបីការអះអាងមួយចំនួនបានមកដោយពុំមានការខិតខំលើផ្នែករបស់អ្នកក្តី ក៏ភាគច្រើនយើងត្រូវការស្វែងរកការអះអាងទាំងនោះដែលប្រាប់យើងថា នឹងមានការលើកលែងចេញពីការសោកល្បងរបស់យើង ។

ជាញឹកញាប់ ការអះអាងទាំងឡាយរបស់ព្រះអម្ចាស់បានមកតាមរយៈសំឡេងនៃពួកអ្នកបម្រើរបស់ទ្រង់ ៖ អ្នកដឹកនាំតាមតំបន់ គ្រូថ្នាក់សិក្ខាសាលា និង គ្រូសាលាថ្ងៃអាទិត្យ និង ជាពិសេសគឺពួកព្យាការី និង សាវករបស់ទ្រង់ ។ ខារ៉ូល អេហ្វ ម៉ាក់ខន់ឃី ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានយុវនារីទូទៅ បានរំឭកយើងថា « នៅក្នុងពាក្យសម្តីរបស់ពួកអ្នកដឹកនាំ យើងឮសំឡេងនៃព្រះអម្ចាស់ ហើយយើងទទួលអារម្មណ៍ពីសេចក្តីស្រឡាញ់នៃព្រះអង្គសង្គ្រោះ » ។[10]

ការអះអាងទាំងនេះក៏មកតាមសំឡេងនៃព្រះវិញ្ញាណបរិសុទ្ធផងដែរ ពេលដែលយើងទូលទៅព្រះវរបិតាដោយស្មោះអស់ពីចិត្តតាមរយៈការអធិស្ឋានដ៏ក្តៀវក្លា ពេលយើងអាន និង ពិចារណាព្រះគម្ពីរ ពេលយើងចូលរួមក្នុងព្រះវិហារបរិសុទ្ធ ពេលយើងបម្រើអ្នកដទៃ និង ព្យាយាមធ្វើអ្វីដែលត្រឹមត្រូវ ។ និយាយឲ្យខ្លីទៅ ការអះអាងរបស់ព្រះអម្ចាស់មក នៅពេលយើង « រកទ្រង់អស់ពីចិត្ត [របស់យើង] ហើយអស់ពីព្រលឹង [របស់យើង] » (ចោទិយកថា ៤:២៩) និង គោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

ហេលេមិន និង ពលទ័ពរបស់លោកបានទទួលការអះអាងមួយ បន្ទាប់ពីមានការអធិស្ឋានដោយស្មោះអស់ពីចិត្តជាច្រើន យ៉ូសែប ស្ម៊ីធ បានទទួលការអះអាងមួយបន្ទាប់ពីបានអធិស្ឋាន និង សញ្ជឹងគិត ។ ក្នុងស្ថានភាពទាំងពីរ ព្រះអម្ចាស់បានសាកល្បងការអត់ធ្មត់ និង សេចក្តីជំនឿរបស់ពួកគេ ពីមុនផ្តល់ការអះអាងមួយ — ជាការរំឭកដ៏ល្អមួយថា អំឡុងពេលនៃការសោកល្បងទាំងឡាយ យើងគប្បីតោងជាប់នឹងសេចក្តីជំនឿរបស់យើង ហើយអនុវត្តការអត់ធ្មត់ ។

ការរង់ចាំការអះអាង

ដូចនឹងការសោកល្បងនៃការអត់ធ្មត់ផ្សេងទៀតដែរ ការអះអាងរបស់ព្រះអម្ចាស់អាចនឹងមិនបានមកតាមរបៀប និង ពេលដែលយើងរំពឹងចង់បាននោះទេ ។ យើងអាចត្រូវការអធិស្ឋានដើម្បីមាន « ភ្នែកសម្រាប់មើល » (អេសេគាល ១២:២) ព្រះហស្តនៃព្រះអម្ចាស់



និង ការអះអាងរបស់ទ្រង់នៅក្នុងជីវិតយើង ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងក្តារ៉ែមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍អំពីរបៀបដែលសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់អាចរួមបញ្ចូលទាំងការអះអាងទាំងនេះ ហើយលោកបានមានប្រសាសន៍ទៀតថា ការអះអាងទាំងនេះ « ពុំកើតឡើងព្រៀវៗ ឬ គ្រាន់តែដោយចៃដន្យនោះទេ ។ ភាពស្មោះត្រង់ និង ការគោរពប្រតិបត្តិ ជួយយើងឲ្យទទួលបាននូវអំណោយទានដ៏សំខាន់ទាំងនេះ ហើយជាញឹកញាប់ ពេលវេលារបស់ព្រះអម្ចាស់នឹងជួយយើងឲ្យស្គាល់អំណោយទានទាំងនោះ » ។[៣]

ជាញឹកញាប់ ការរង់ចាំដើម្បីបានការដោះលែង ឬ ការអះអាងមួយអំពីការដោះលែង ត្រូវការនូវភាពអត់ធ្មត់ច្រើនជាងដែលយើងគិតថាយើងមាន ។ យើងអាចនឹងត្រូវតែប្រឈមនឹងការសាកល្បងដ៏ធ្ងន់ធ្ងរ ពីមុនទទួលបានការធានាណាមួយនោះ ។ ដូចដែល អែលឌើរ ស្គត បានពន្យល់ថា « សំណុំនៃពន្លឺព្រះអាទិត្យខាងវិញ្ញាណ » ដែលព្រះអម្ចាស់ប្រទាន « ជាញឹកញាប់បានមក បន្ទាប់ពីការសាកល្បងបានក្លាយជាការសាកល្បងដ៏ធំមហិមាបំផុត ជាភស្តុតាងនៃសេចក្តីអាណិតស្រឡាញ់របស់ព្រះវរបិតាដែលគ្រាស់ដឹងពីអ្វីៗគ្រប់យ៉ាង ។ ការសាកល្បងទាំងនោះតម្រង់ផ្លូវទៅកាន់សុភមង្គលដែលកាន់តែមហិមា ទៅកាន់ការយល់ដឹងកាន់តែច្រើន និង ពង្រឹងការប្តេជ្ញាចិត្ត [របស់យើង] ឲ្យទទួលយក និង គោរពប្រតិបត្តិដល់ព្រះឆន្ទៈរបស់ទ្រង់ » ។[៤] ពេលយើងបន្តស្មោះត្រង់ និង គោរពប្រតិបត្តិឆ្លងកាត់ការសាកល្បងរបស់យើង នោះការអះអាងរបស់ព្រះអម្ចាស់នឹងមកដើម្បីជួយយើងឲ្យបន្តធ្វើដូច្នោះ ។

ការអះអាងដ៏ធំបំផុតរបស់យើង

នៅទីបំផុត មិនថាយើងបានទទួលការអះអាងច្រើនប៉ុណ្ណាដែលថា ព្រះវរបិតាសួគ៌ទ្រង់គ្រាស់ដឹងពីយើង និង ស្ថានភាពរបស់យើងនោះទេ វានឹងមិនគ្រប់គ្រាន់ដើម្បីជួយយើងឲ្យស៊ូទ្រាំដល់ទីបំផុតឡើយ បើយើងមិនមានសេចក្តីជំនឿ និង សេចក្តីសង្ឃឹមក្នុងព្រះយេស៊ូវគ្រីស្ទនោះ ។ តាមរយៈដង្វាយធួនរបស់ទ្រង់ យើងអាចមានសេចក្តីសង្ឃឹមទាំងស្រុងថា យើងនឹងត្រូវបានដោះលែងឲ្យរួចពីការសាកល្បងទាំងអស់របស់យើងនៅថ្ងៃមួយ ។ យើងក៏អាចដឹងផងដែរថា ព្រះអង្គសង្គ្រោះរបស់យើងទ្រង់គង់នៅទីនោះ យល់ចិត្តយើងឥតចន្លោះ ដ្បិតទ្រង់ « បានយាងចុះក្រោមគ្រប់ទាំងអស់ ដោយហេតុនោះទើបទ្រង់យល់គ្រប់ទាំងអស់ » (គ. និង ស. ៨៨:៦) ។ ទ្រង់យល់ពីការសាកល្បង និង ទុក្ខព្រួយរបស់យើង ព្រោះទ្រង់ « រងការឈឺចាប់ និង ទុក្ខវេទនា និង ការល្បួងគ្រប់បែបយ៉ាង . . . ដើម្បីទ្រង់អាចដឹង . . . តើត្រូវជួយរាស្ត្រទ្រង់បែបណា តាមជំងឺរបស់គេ » (អាលម៉ា ៧:១១–១២) ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្តារ៉ែមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា ៖ « អ្វីដែលជាការអះអាងដ៏មហិមាបំផុតនៅក្នុងផែនការរបស់ព្រះគឺថា ព្រះបានសន្យាថានឹងប្រទានព្រះអង្គសង្គ្រោះមួយអង្គ ជាព្រះអង្គប្រោសលោះដែលតាមរយៈសេចក្តីជំនឿរបស់យើងនៅក្នុងទ្រង់ នោះទ្រង់នឹងលើកយើងឡើងដោយជោគជ័យឈ្នះទៅលើការសាកល្បង និង ការលំបាកទាំងនោះ ។ . . . វាជាការដឹងគុណចំពោះក្តីស្រឡាញ់ដ៏ទេវភាពនេះតែមួយគត់ ដែលនឹងធ្វើឲ្យការរងទុក្ខតិចតួចរបស់យើង ដំបូង អាចទ្រាំទ្របាន រួចហើយអាចយល់ និង ចុងក្រោយអាចសង្គ្រោះបាន » ។[៥] ការរៀនអំពីទ្រង់ និង ដង្វាយធួនរបស់ទ្រង់ គឺជាការអះអាងមួយអំពីវាផ្ទាល់ ។

« សំណុំនៃពន្លឺព្រះអាទិត្យខាងវិញ្ញាណ . . . ជាញឹកញាប់បានមក បន្ទាប់ពីការសាកល្បងបានក្លាយជាការសាកល្បងដ៏ធំមហិមាបំផុត ជាភស្តុតាងនៃសេចក្តីអាណិតស្រឡាញ់របស់ព្រះវរបិតាដែលគ្រាស់ដឹងពីអ្វីៗគ្រប់យ៉ាង ។ ការសាកល្បងទាំងនោះតម្រង់ផ្លូវទៅកាន់សុភមង្គលដែលកាន់តែមហិមា ។

អ្វីៗទាំងអស់នឹងបានស្រួល

ពេលយើងយល់ តាមស្វែងរក និង រង់ចាំដើម្បីបានការអះអាងពីព្រះអម្ចាស់ នោះការអះអាងទាំងនោះនឹងមកពិតមែន ។ យើងគប្បីចងចាំគ្រាដែលមិនអាចកាត់ថ្លៃបានទាំងនោះ សរសេរវាទុក និង គិតអំពីវាជាញឹកញាប់ ។ សំខាន់បំផុត យើងត្រូវទុកចិត្តលើការអះអាងទាំងនោះ ហើយជឿ ដូចជា ហេលេមិន និង ពួកពលទំពារបស់លោក និង ព្យាការីយ៉ូសែប ជឿដែរ ថាព្រះអម្ចាស់នឹងបំពេញការសន្យាដែលទ្រង់បានសន្យាដល់យើង ។ ទ្រង់រំឭកយើងអំពីការសន្យាទាំងនោះតាមរយៈការអះអាងទាំងឡាយរបស់ទ្រង់ ហើយទោះបីជាការអះអាងទាំងនោះអាចនឹងពុំធ្វើឲ្យការសាកល្បងរបស់យើងចប់ទៅមែន ក៏យើងអាចដឹងថា ព្រះវរបិតាសួគ៌ទ្រង់គង់នៅទីនោះជាមួយយើង ដើម្បីគាំទ្រ និង ទ្រទ្រង់យើងឲ្យឆ្លងកាត់អ្វីៗគ្រប់យ៉ាង ។

បន្ទាប់ពីបទពិសោធន៍របស់ខ្ញុំនៅក្នុងព្រះវិហារបរិសុទ្ធនៅថ្ងៃនោះ ការសាកល្បងរបស់ខ្ញុំមិនបានមានតិចជាងមុនទេ ។ ខ្ញុំពុំបានពិន្ទុល្អភ្លាមៗ ឬ មានលុយច្រើនជាងមុន ឬ មានការណាត់ជួបជាគូច្រើននោះទេ ។ ប៉ុន្តែ អ្វីដែលខ្ញុំមាន គឺការអះអាងដ៏ស្រទន់ថា ទោះខ្ញុំមានការសាកល្បងក្តី ក៏ខ្ញុំមិនអីដែរ ពីព្រោះព្រះអម្ចាស់នៅតែមានព្រះបំណងរក្សាការសន្យារបស់ទ្រង់ដែលថានឹងដោះលែងខ្ញុំ ។ ជាមួយនឹងការអះអាងនោះ ខ្ញុំដឹងថា អ្វីៗទាំងអស់ *នឹងបាន* ស្រួល ។ ■

កំណត់ចំណាំ

១. រីឆាដ ជី. ស្គត “Trust in the Lord,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ១៧ ។
២. ខារ៉ុល អេហ្ម ម៉ាក់ខន់ឃី “Live according to the Words of the Prophets,” *លីអាហូណា,* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៧៧ ។
៣. ដេវីឌ អេ បែដណា “The Tender Mercies of the Lord,” *លីអាហូណា,* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ១០០ ។
៤. រីឆាដ ជី. ស្គត “Trust in the Lord,” ទំព័រ ១៧ ។
៥. ជែហ្វ្រី អ័រ ហូឡិន “Like a Broken Vessel,” *លីអាហូណា,* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៨០ ។

គ្មានការប្តូរតំបន់ទេ

ដោយ ឡេណា សឺនយ៉ៅ ឆូ

ខ្ញុំបានចាកចេញពីផ្ទះរបស់ខ្ញុំនៅភូមិនេនត្សេ ប្រទេស តៃវ៉ាន់ ដើម្បីទៅបម្រើបេសកកម្ម ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនៅ ប៉ែកខាងជើងរដ្ឋ កាលីហ្វញ៉ា ក្នុងឆ្នាំ ២០០៥ ។ តំបន់ដែលដៃគូខ្ញុំ និង ខ្ញុំត្រូវបានចាត់ឲ្យបម្រើនោះ ជាតំបន់តូចល្មមដែលក្នុងរយៈពេលបួនខែកន្លះ យើងបានគោះទ្វារនៅគ្រប់ផ្លូវទាំងអស់ដែល នៅក្នុងតំបន់ក្រុងនោះ ។ កិច្ចការផ្សព្វផ្សាយ មានការលំបាក ហើយជាញឹកញាប់មនុស្ស ស្រែកឲ្យយើង ។ យើងមានសាសនាគន់ការី ពីរបីនាក់ ។ ចំពោះខ្ញុំ កិច្ចការហាក់ដូចជាពុំទៅ មុខសោះ ។ បន្ទាប់ពីនៅទីនោះជិតបួនខែ ខ្ញុំចង់ ចាកចេញរួចទៅហើយ ។ ខ្ញុំជឿថា ខ្ញុំនឹងត្រូវប្តូរ តំបន់ ។

យប់ថ្ងៃអាទិត្យ ខ្ញុំបានរង់ចាំទទួលទូរស័ព្ទ រហូតដល់ប្រធានហ្សូនរបស់ខ្ញុំបានទូរស័ព្ទមក ។ ពេលគាត់បានប្រាប់ថា ខ្ញុំត្រូវចាត់ឲ្យនៅក្នុងតំបន់ ដដែលជ្រាំមួយសប្តាហ៍ទៀត ខ្ញុំមិនអាចជឿត្រចៀក របស់ខ្ញុំទេ ។ ខ្ញុំបានគិតថា ពិតជាមានកំហុសអ្វី មួយហើយ !

សប្តាហ៍បន្ទាប់នោះខ្ញុំពុំបានធ្វើអ្វីជាប្រយោជន៍ សោះឡើយ ហើយប្រហែលជាដៃគូខ្ញុំក៏ដូច្នោះដែរ ព្រមទាំងមនុស្សដែលនៅក្រោមការដឹកនាំ របស់យើងផងដែរ ។ ខ្ញុំបដិសេធនឹងជឿថា នេះគឺ ជាការសម្រេចចិត្តដ៏ត្រឹមត្រូវ ។ ទោះយ៉ាងណា ខ្ញុំ នៅតែញញឹមពព្រាយពេលយើងជួប ឬ និយាយ ជាមួយមនុស្សផ្សេងៗ ប៉ុន្តែកប់ជ្រៅនៅក្នុងចិត្ត ខ្ញុំ មិនសប្បាយចិត្តទេ ។ ដោយការអួតអាងរបស់ខ្ញុំ ខ្ញុំបន្តប្រាប់ខ្លួនឯងថា ខ្ញុំមិនបាននៅកន្លែងដែល ខ្ញុំសមនឹងនៅទេ ។ ខ្ញុំនៅតែសង្ឃឹមថា ប្រធាន បេសកកម្មរបស់ខ្ញុំនឹងទូរស័ព្ទ ហើយប្រាប់ខ្ញុំថា ខ្ញុំត្រូវប្តូរទៅតំបន់ផ្សេង ។

ប្រធានបេសកកម្មរបស់ខ្ញុំច្បាស់ជាបានធ្វើកំហុសមួយហើយ — តើខ្ញុំអាចរៀនអ្វីពីការនៅក្នុងតំបន់នេះកាន់តែយូរនោះ ?

រូបភាពថត ដោយ GRACETHANG/ISTOCK/THINKSTOCK;
រូបភាពនៃ វ៉ាលីសដាក់សម្លៀកបំពាក់ ដោយ MONTICELLO/ISTOCK/THINKSTOCK

របៀបដែលការអះអាងឡើងវិញបានមក

នៅព្រឹកថ្ងៃអាទិត្យបន្ទាប់ ពេលខ្ញុំកំពុងរៀបចំខ្លួនទាំងទើសទាល់ ដើម្បីទៅព្រះវិហារ នោះទូរស័ព្ទបានរោទ៍ឡើង ។ គឺប្រធានបេសកកម្ម ។ គាត់សួរសុខទុក្ខខ្ញុំដូចសព្វដង ដោយសំឡេងដ៏ស្មោះត្រង់ នោះគាត់បានមានប្រសាសន៍ថា « ស៊ីស្ទើរ ឆូ កាលពីម្សិលមិញនៅពេលអាហារថ្ងៃត្រង់ ខ្ញុំបានគិតអំពីស៊ីស្ទើរ ហើយមានអារម្មណ៍ថាខ្ញុំត្រូវទូរស័ព្ទទៅស៊ីស្ទើរ ដើម្បីប្រាប់ឲ្យស៊ីស្ទើរដឹងថា ស៊ីស្ទើរនៅក្នុងតំបន់ដ៏ត្រឹមត្រូវហើយ ។ ស៊ីស្ទើរកំពុងនៅកន្លែងដែលស៊ីស្ទើរសមនឹងនៅ » ។ ខ្ញុំបានចាប់ផ្ដើមយំពេលខ្ញុំបានឮពាក្យសម្ដីរបស់គាត់ ។

ខ្ញុំបានអរគុណគាត់ ហើយបានដាក់ទូរស័ព្ទចុះ ។ ពេលខ្ញុំចាប់ផ្ដើមយំ អារម្មណ៍ដ៏ថ្លាដូចគ្រីស្ទាល់បានចូលមកក្នុងដួងចិត្តរបស់ខ្ញុំយ៉ាងខ្លាំងថា *មាន* កិច្ចការដែលមិនទាន់ធ្វើចប់កំពុងរង់ចាំខ្ញុំនៅក្នុងតំបន់នេះ ។ ខ្ញុំក៏បានដឹងផងដែរថា ព្រះវរបិតាសួគ៌របស់ខ្ញុំទ្រង់ត្រាស់ដឹងពីគំនិត និងការថប់បារម្ភរបស់ខ្ញុំ ។ ទ្រង់យល់ពីភាពទន់ខ្សោយរបស់ខ្ញុំ ហើយទ្រង់បានបញ្ជូនអ្នកបម្រើរបស់ទ្រង់ឲ្យមកធ្វើការអះអាងឡើងវិញដល់ខ្ញុំ ។

បន្ទាប់ពីនិយាយតាមទូរស័ព្ទហើយ ខ្ញុំចាប់ផ្ដើមទទួលស្គាល់ពីកន្លែងដែលខ្ញុំបម្រើ ហើយធ្វើការកាន់តែខ្លាំងជាងមុន ។ ខ្ញុំបានអធិស្ឋានសូមកម្លាំងជារៀងរាល់ថ្ងៃ សូមឲ្យមើលឃើញកាន់តែច្បាស់ពីរបៀបដែលខ្ញុំអាចធ្វើនូវអ្វីដែលព្រះអម្ចាស់រំពឹងចង់ឲ្យខ្ញុំធ្វើ ។ អស់ពេញប្រាំសប្ដាហ៍បន្ទាប់នោះ ដៃគូខ្ញុំ និង ខ្ញុំបានឃើញអព្ភូតហេតុជាច្រើន កាលដែលយើងបានអនុវត្តសេចក្ដីជំនឿគ្រប់គ្រាន់ដើម្បីខិតខំធ្វើការ ។ សាសនាគន់ការីដែលបានរៀបចំយ៉ាងល្អម្នាក់ បានប្ដូរមកនៅក្នុងតំបន់យើង ហើយបានទទួលបុណ្យជ្រមុជទឹកមុនពេលខ្ញុំប្ដូរតំបន់ ។

យើងក៏ត្រូវបានអញ្ជើញឲ្យចូលក្នុងផ្ទះដែលពីមុនមកគេមិនស្វាគមន៍យើង ។ យើងបានជួបមនុស្សថ្មីៗជាច្រើន ដែលកំពុងជួបការពិបាក ហើយយើងមានពរជ័យដែលបានចែកចាយពាក្យល្អលោមរបស់ព្រះជាមួយពួកគេ ។ ទោះបីមនុស្សមួយចំនួនពុំបានជ្រើសរើសទទួលបុណ្យជ្រមុជទឹកនៅពេលនោះក្ដី ក៏ខ្ញុំនឹងមិនដែលភ្លេចពីទឹកមុខដ៏ចែងចាំងរបស់ពួកគេ ឬ ពីរបៀបដែលព្រះវិញ្ញាណ និង សេចក្ដីស្រឡាញ់នៃព្រះបានធ្វើឲ្យរំជួលដល់ដួងចិត្តរបស់ពួកគេ — និង ដួងចិត្តខ្ញុំ ។

អ្វីដែលខ្ញុំបានរៀន

ខ្ញុំបានរៀនថា ព្រះអម្ចាស់ពិតជាត្រាស់ដឹងពីយើងម្នាក់ៗ ទ្រង់មិនបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនារបស់ទ្រង់ទៅកន្លែងនានាដោយពុំមានហេតុផលនោះទេ ។ ខ្ញុំបានរៀនថា ពេលយើងត្រូវបានចាត់ឲ្យទៅតំបន់មួយ ព្រះអម្ចាស់មានព្រះទ័យចង់ប្រើប្រាស់យើងនៅទីនោះ ជាឧបករណ៍ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ ។ ពេលយើងដាក់ខ្លួនយើងនៅក្នុងព្រះហស្តទ្រង់ នោះអព្ភូតហេតុកើតមានឡើង ហើយដួងចិត្តនឹងទន់ សូម្បីពេលយើងមិនឃើញថាវាអាចកើតឡើងដោយរបៀបណាក៏ដោយ ។

ជាពិសេស ខ្ញុំបានរៀនថា ប្រធានបេសកកម្មរបស់ខ្ញុំ ក៏ដូចជាអ្នកដឹកនាំសាសនាចក្រផ្សេងៗទៀត គឺពិតជាត្រូវបានហៅពីព្រះដើម្បីធ្វើជាអ្នកបម្រើរបស់ទ្រង់ ។ ព្រះអម្ចាស់ធ្វើឲ្យអ្នកដឹកនាំរបស់យើងសក្ដិសមនឹងទទួលវិវរណៈ និង ការបំផុសគំនិត ដែលយើងត្រូវការសម្រាប់សុខុមាលភាពនៃព្រលឹងយើង ។

ខ្ញុំមានអំណរគុណជារៀងរហូត សម្រាប់បទពិសោធន៍ទាំងឡាយដែលខ្ញុំទទួលបាន ដែលជាលទ្ធផលនៃ ការដែល *មិន* បានប្ដូរតំបន់ ។ ■

អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។

ដោយប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

ការរស់នៅ *ក្នុង* ពិភពលោក *ដែលពោរពេញដោយការផ្លាស់ប្ដូរ*

ប្រសិនបើជីវិត និង ការផ្លាស់ប្ដូរដ៏លឿនរបស់វា និង ការថប់អារម្មណ៍ជាច្រើនធ្វើឲ្យពិបាកសម្រាប់អ្នកក្នុងការមានអារម្មណ៍អរសប្បាយ នោះប្រហែលឥឡូវនេះជាពេលដ៏ល្អដើម្បីផ្ដោតឡើងវិញលើអ្វីដែលសំខាន់បំផុត ។

តើអ្នកធ្លាប់នៅក្នុងយន្តហោះ ហើយជួបបទពិសោធន៍ខ្យល់គួចដែរឬទេ ? បុព្វហេតុដ៏ធម្មតាបំផុតមួយនៃខ្យល់គួច គឺជាការផ្លាស់ប្ដូរភ្លាមៗនៃចលនាកម្លាំងខ្យល់ ដែលបណ្ដាលឲ្យយន្តហោះគ្រវែងចុះឡើង រង្គោះរង្គើ និង រលាក់ ។ ទោះបីជាយន្តហោះត្រូវបានផលិតឡើងដើម្បីតទល់នឹងកម្លាំងខ្យល់គួចដ៏ខ្លាំងជាងខ្យល់ដែលអ្នកជួបប្រទះនៅក្នុងការជិះធម្មតាក្ដី ក៏វានៅតែធ្វើឲ្យអ្នកដំណើរភ័យដូចគ្នា ។

តើអ្នកស្មានថា អ្នកបើកយន្តហោះធ្វើដូចម្ដេចពេលជួបនឹងខ្យល់គួចនោះ ? កូនសិស្សដែលរៀនបើកយន្តហោះម្នាក់ប្រហែលជាគិតថា ការបន្ថែមល្បឿនគឺជាវិធីសាស្ត្រមួយយ៉ាងល្អ ពីព្រោះវានឹងជួយពួកគេឲ្យឆ្លងកាត់ខ្យល់គួចនោះបានកាន់តែលឿន ។ ប៉ុន្តែការធ្វើដូច្នោះប្រហែលជាខុសហើយ ។ អ្នកបើកយន្តហោះដែលមានវិជ្ជាជីវៈច្បាស់លាស់យល់ថា មានកម្រិតល្បឿនដ៏ល្អបំផុតមួយដើម្បីឆ្លងកាត់ខ្យល់គួច ដែលបង្រួមឥទ្ធិពលអវិជ្ជមាននៃខ្យល់គួចនោះ ។ ហើយស្ទើរតែគ្រប់ពេលគឺត្រូវបន្ថយល្បឿនវិញ ។ គោលការណ៍នេះអនុវត្តដូចគ្នាទៅនឹងកន្លែងផ្លូវរលាក់ដែលយើងត្រូវបន្ថយល្បឿន ។

ដូច្នេះ ដំបូន្មានដ៏ល្អមួយគឺថា ត្រូវបន្ថយល្បឿនបន្តិច ហើយត្រូវរក្សាលំនឹង ហើយយកចិត្តទុកដាក់តែទៅអ្វីដែលចាំបាច់ នៅពេលដែលជួបប្រទះនឹងគ្រោះអកុសល ។

ល្បឿននៃជីវិតសម័យទំនើប

លក្ខណៈមួយនៃជីវិតទាន់សម័យហាក់បីដូចជាយើងកំពុងធ្វើចលនាកាន់តែលឿនទៅមុខ ទោះជាស្ថិតនៅក្នុងភាពចលាចល ឬ ឧបសគ្គយ៉ាងណាក្ដី ។

សូមនិយាយត្រង់ វាស្រួលណាស់ក្នុងការជាប់រវល់ ។ យើងទាំងអស់គ្នាអាចគិតពីការធ្វើបញ្ជីកិច្ចការយ៉ាងវែង ដែលប៉ះពាល់ដល់កាលវិភាគរបស់យើង ។ មនុស្សមួយចំនួនប្រហែលជាគិតថា



រូបថតយន្តហោះ © 06 PHOTO/DOLLAR PHOTO CLUB



ទំនាក់ទំនងជាមួយព្រះ

ខ្លួនគេមានតម្លៃគឺអាស្រ័យលើបញ្ជីកិច្ចការដែលពួកគេត្រូវធ្វើមានប្រវែងវែង ។

អ្នកឆ្លាតវៃទប់ទល់នឹងការល្បួង ដើម្បីជាប់ទាក់ទិនក្នុងជីវិតសែនរវល់ប្រញាប់ប្រញាល់ប្រចាំថ្ងៃ ។ ពួកគេធ្វើតាមដំបូន្មាននេះថា « មានអ្វីច្រើនក្នុងជីវិតជាងភាពតក់ក្រហល់ » ។[1] សរុបសេចក្តីមក គឺគេយកចិត្តទុកដាក់ទៅលើបញ្ហាអ្វីដែលសំខាន់ជាងគេ ។

អែលឌើរ ដាល្លិន អេក អ៊ុក នៃក្លុំមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « យើងត្រូវតែលះបង់ការដែលល្អ ដើម្បីជ្រើសរើសអ្វីដែលប្រសើរជាង ឬ ប្រសើរលើសគេ ពីព្រោះការណ៍ទាំងនោះអភិវឌ្ឍជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងពង្រឹងក្រុមគ្រួសាររបស់យើង » ។[2]

ការស្រាវជ្រាវរកការណ៍ដែលល្អបំផុតនោះគឺតែងតែដឹកនាំទៅរកគោលការណ៍គ្រឹះនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ — គឺជាសេចក្តីពិតដ៏សាមញ្ញ និង អស្ចារ្យ ដែលត្រូវបានបើកសម្តែងមកកាន់យើងដោយព្រះវរបិតាសួគ៌អស់កល្ប ដែលយកព្រះទ័យទុកដាក់ និង មានការចេះដឹងទាំងអស់ ។

តើខ្ញុំអាចរៀនពីអ្វីដែលសំខាន់បំផុតបានតាមរបៀបណា ?

ខ្ញុំគិតថា យើងទាំងអស់គ្នាភាគច្រើនមានសភាវគតិយល់ពីសារៈសំខាន់នៃគោលការណ៍គ្រឹះ ។ គ្រាន់តែពេលខ្លះ យើងត្រូវបានរំខានដោយកិច្ចការជាច្រើនដែលហាក់ដូចជាមានការទាក់ទាញជាង ។

ឯកសារដែលចោះពុម្ព ប្រភពព័ត៌មានផ្សេងៗទៀត ឧបករណ៍អេឡិចត្រូនិច និង គ្រឿងម៉ាស៊ីនផ្សេងៗ — ទាំងអស់នេះវាជាជំនួយ ប្រសិនបើប្រើដោយត្រឹមត្រូវ — ប៉ុន្តែវាអាចប្រែក្លាយជាខូចទំនាក់ទំនង ឬ ធ្វើឲ្យមនុស្សឯកោក៏បានដែរ ។

ក៏ប៉ុន្តែនៅក្នុងចំណោមសំឡេង និង ជម្រើសច្រើនក្រៃលែង បុរសនៃស្រុកកាលីឡេដ៏រាបសាបានក្រោកឈរឡើង លាតព្រះហស្តរបស់ទ្រង់ ។ សារលិខិតដ៏សាមញ្ញរបស់ទ្រង់គឺថា ៖ « ចូរមកតាមខ្ញុំចុះ » (លូកា ១៨:២២) ។ ហើយទ្រង់ពុំបានមានព្រះបន្ទូលដោយប្រើប្រដាប់បំពងសម្លេងនោះទេ ប៉ុន្តែគឺដោយសំឡេងតូចរហៀងៗ (សូមមើល ពង្សាវតារក្សត្រ ទី១ ១៩:១២) ។ វាជាការងាយណាស់សម្រាប់សារលិខិតគ្រឹះនៃដំណឹងល្អ ក្នុងការបាត់បង់នៅកណ្តាលទឹកជំនន់នៃព័ត៌មានដែលវាយប៉ះត្រូវយើងពីគ្រប់ផ្នែក ។

ព្រះគម្ពីរដ៏បរិសុទ្ធ និង ពាក្យសម្តីរបស់ព្យាការីដែលនៅរស់ បានសង្កត់ធ្ងន់ទៅលើគោលការណ៍ និង គោលលទ្ធិនៃដំណឹងល្អដែលជាមូលដ្ឋានគ្រឹះ ។ មូលហេតុដែលយើងត្រឡប់ទៅរកគោលការណ៍គ្រឹះទាំងនេះ គឺត្រឡប់ទៅរកគោលការណ៍ដ៏បរិសុទ្ធ ពីព្រោះវាជាផ្លូវចូលទៅរកសេចក្តីពិតនៃអត្ថន័យដ៏ជ្រាលជ្រៅ ។

មូលដ្ឋានគ្រឹះ ៖ ទំនាក់ទំនងដ៏សំខាន់ទាំងបួន

នៅពេលយើងងាកទៅរកព្រះវរបិតាសួគ៌ និង ស្វែងរកប្រាជ្ញារបស់ទ្រង់ស្តីអំពីការណ៍ដែលចាំបាច់បំផុត យើងរៀនម្តងហើយម្តងទៀតអំពីសារៈសំខាន់នៃទំនាក់ទំនងដ៏សំខាន់ទាំងបួន ៖ ជាមួយព្រះរបស់យើង ជាមួយគ្រួសាររបស់យើង ជាមួយមនុស្សជាតិរបស់យើង និង ជាមួយខ្លួនឯង ។ នៅពេលយើងវាយតម្លៃជីវិតរបស់យើងដោយមានឆន្ទៈ យើងនឹងឃើញកន្លែងណាដែលយើងរសាត់អណ្តែតចេញពីផ្លូវដែលប្រសើរលើសលប់ ។ កែវភ្នែកនៃការយល់របស់យើងនឹងបើកឡើង ហើយយើងនឹងដឹងពីអ្វីដែលត្រូវធ្វើ ដើម្បីធ្វើឲ្យបេះដូងយើងបានបរិសុទ្ធ និង យកចិត្តទុកដាក់លើជីវិតរបស់យើងម្តងទៀត ។

ទីមួយ ទំនាក់ទំនងរបស់យើង ជាមួយព្រះ គឺពិសិដ្ឋ និង សំខាន់បំផុត ។ យើងគឺជាបុត្រខាងវិញ្ញាណរបស់ទ្រង់ ។ ទ្រង់គឺជាព្រះវរបិតារបស់យើង ។ ទ្រង់សព្វព្រះទ័យឲ្យយើងមានសុភមង្គល ។ នៅពេលយើងស្វែងរកទ្រង់ រៀនពីបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ នៅពេលយើងបើកដួងចិត្តទទួលឥទ្ធិពលពីព្រះវិញ្ញាណបរិសុទ្ធ នោះជីវិតយើងនឹងកាន់តែមានលំនឹង និង សុវត្ថិភាព ។ យើងនឹងទទួលបទពិសោធន៍នៃភាពសុខសាន្ត សេចក្តីអំណរ និង ជោគជ័យដ៏អស្ចារ្យ នៅពេលយើងធ្វើអ្វីដែលប្រសើរបំផុត ដើម្បីរស់នៅតាមផែនការដ៏អស់កល្បជានិច្ចរបស់ព្រះ ហើយរក្សាព្រះបញ្ញត្តិរបស់ទ្រង់ ។

យើងអភិវឌ្ឍទំនាក់ទំនងជាមួយព្រះវរបិតាសួគ៌ តាមរយៈការរៀនសូត្រអំពីទ្រង់ សន្ទនាជាមួយទ្រង់ ដោយប្រែចិត្តពីអំពើបាបរបស់យើង និង ដើរតាមព្រះយេស៊ូវគ្រីស្ទដោយសកម្ម ដ្បិត « បើមិនមកតាម [ព្រះគ្រីស្ទ] នោះគ្មានអ្នកណាអាចទៅឯព្រះវរបិតាបានឡើយ » (យ៉ូហាន ១៤:៦) ។ ដើម្បីពង្រឹងទំនាក់ទំនងរបស់យើងជាមួយព្រះ យើងត្រូវការពេលវេលាដ៏មានអត្ថន័យជាមួយ

ទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់យើង

ទ្រង់ដោយឡែកតែឯង ។ ការយកចិត្តទុកដាក់ដោយស្ងាត់ៗលើការអធិស្ឋានផ្ទាល់ខ្លួន និង ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ តែងតែប្រឹងប្រែងឲ្យមានភាពសក្តិសមនៃបណ្ណចូលព្រះវិហារបរិសុទ្ធបច្ចុប្បន្នជានិច្ច — នេះហើយគឺជាការវិនិយោគដ៏ឆ្លាតវៃចំពោះពេលវេលារបស់យើង និង ការខិតខំរបស់យើង ដើម្បីខិតចូលកាន់តែជិតព្រះវរបិតាសួគ៌ ។ ចូរស្តាប់តាមការអញ្ជើញរបស់ទំនុកដំកើងថា « ចូរបង្អង់សិន ឲ្យបានដឹងថាអញជាព្រះ » (ទំនុកដំកើង ៤៦:១០) ។

ទំនាក់ទំនងសំខាន់ ទីពីរ គឺទំនាក់ទំនង ជាមួយក្រុមគ្រួសារយើង ។ ពីព្រោះ « គ្មានជោគជ័យណាអាចតបស្នងនឹងបរាជ័យនៅក្នុងផ្ទះបានឡើយ »[៣] នោះ យើងត្រូវតែផ្តល់អាទិភាពដល់ក្រុមគ្រួសារយើង ។ យើងកសាងគ្រួសារដោយមានទំនាក់ទំនងស្រឡាញ់ និង ជ្រាលជ្រៅ តាមរយៈការធ្វើការសាមញ្ញជាមួយគ្នា ដូចជាការបរិភោគអាហារពេលល្ងាចជាគ្រួសារ រាត្រីជួបជុំគ្រួសារ និង លេងល្បែងរីករាយជាមួយគ្នា ។ នៅក្នុងទំនាក់ទំនងគ្រួសារ *សេចក្តីស្រឡាញ់* ត្រូវប្រែកបអក្សរថា *ព-រ-ល-រ-ល-ា* គឺពេលវេលា ។ ការឆ្លៀតពេលដើម្បីគ្នានឹងគ្នាទៅវិញទៅមកគឺជាគន្លឹះសម្រាប់ភាពសុខដុមនៅក្នុងគេហដ្ឋាន ។ យើងនិយាយជាមួយគ្នាប្រសើរជាងគ្រាន់តែនិយាយអំពីគ្នាទៅវិញទៅមក ។ យើងរៀនពីគ្នាទៅវិញទៅមក និង អបអរចំពោះភាពខុសគ្នារបស់យើង ក៏ដូចជាភាពដូចគ្នារបស់យើងផងដែរ ។ យើងកសាងចំណងដ៏ទេវភាពជាមួយគ្នា នៅពេលយើងចូលទៅរកព្រះជាមួយគ្នា តាមរយៈការអធិស្ឋានជាគ្រួសារ ការសិក្សាដំណឹងល្អ និង ការថ្វាយបង្គំនៅថ្ងៃអាទិត្យ ។

ទំនាក់ទំនងជាមួយបងប្អូនរបស់យើង

ទំនាក់ទំនងសំខាន់ ទីបី ដែលយើងមាន គឺទំនាក់ទំនង ជាមួយមនុស្សជាតិ ។ យើងកសាងទំនាក់ទំនងនេះម្នាក់ម្តងៗ — តាមរយៈការយល់ដឹងពីសេចក្តីត្រូវការរបស់អ្នកដទៃ បម្រើគេ និង ផ្តល់ពេលវេលា និង ទេពកោសល្យរបស់យើង ។ ខ្ញុំមានការកោតសរសើរចំពោះបងស្រីម្នាក់ដែលមានបន្ទុកដោយសារបញ្ហាជរា និង ជំងឺ ប៉ុន្តែគាត់បានសម្រេចចិត្តថា ទោះបីគាត់មិនអាចធ្វើអ្វីបានច្រើនក្តី គាត់នៅតែស្តាប់បាន ។ ដូច្នេះ រាល់សប្តាហ៍គាត់រកមនុស្សដែលហាក់បីដូចជាមានបញ្ហា ឬ បាក់ទឹកចិត្ត ហើយគាត់ចំណាយពេលជាមួយពួកគេ ស្តាប់រឿងរ៉ាវរបស់ពួកគេ ។ វាជាពរជ័យខ្លាំងណាស់នៅក្នុងជីវិតមនុស្សជាច្រើនដោយសារគាត់ ។

ទំនាក់ទំនងសំខាន់ ទីបួន គឺទំនាក់ទំនង ជាមួយខ្លួនឯង ។ វាហាក់បីដូចជាប្លែកក្នុងការគិតពីការមានទំនាក់ទំនងជាមួយខ្លួនឯង ប៉ុន្តែយើងពិតជាមាន ។ មនុស្សមួយចំនួនមិនសូវជាមានភាពស្រុះស្រួលជាមួយខ្លួនឯងប៉ុន្មានទេ ។ ពួកគេរិះគន់ និង មានភាពល្ងីល្ងើជូរចត់ជាមួយនឹងខ្លួនឯងពេញមួយថ្ងៃ រហូតដល់គេចាប់ផ្តើមស្អប់ខ្លួនឯង ។ ខ្ញុំសូមផ្តល់យោបល់ថា សូមកាត់បន្ថយភាពប្រញាប់ប្រញាល់ ហើយឆ្លៀតពេលបន្តិចបន្តួចបន្ថែមដើម្បីរៀនស្គាល់ខ្លួនអ្នកឲ្យបានកាន់តែប្រសើរ ។ សូមដើរគយគន់ធម្មជាតិ មើលព្រះអាទិត្យរះ រីករាយជាមួយនឹងស្នាព្រហស្តនៃការបង្កបង្កើតរបស់ព្រះ ពិចារណាសេចក្តីពិតនៃដំណឹងល្អដែលបានស្តារឡើងវិញ និង ស្វែងរកថាតើវាមានអត្ថន័យចំពោះអ្នកផ្ទាល់យ៉ាងដូចម្តេច ។ សូមរៀនមើលខ្លួនអ្នកដូចព្រះវរបិតាសួគ៌មើលអ្នក — គឺជាបុត្រី ឬ បុត្រាដ៏មានតម្លៃជាមួយនឹងសក្តានុពលភាពដ៏ទេវភាព ។

កម្លាំងនៅក្នុងភាពសាមញ្ញ

ភាពរឹងមាំបានមក មិនមែនតាមរយៈសកម្មភាពដ៏រីករាក់ទេ ប៉ុន្តែតាមរយៈការចាក់គ្រឹះដ៏រឹងមាំនៃសេចក្តីពិត និង ពន្លឺ ។ វាបានមកពីការដាក់ការយកចិត្តទុកដាក់ និង ការខិតខំរបស់យើងទៅលើមូលដ្ឋាននៃដំណឹងល្អដែលបានស្តារឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ ។ វាបានមកពីការផ្តោតយកចិត្តទុកដាក់ទៅលើអ្វីៗដ៏ទេវភាពដែលមានសារៈសំខាន់បំផុត ។

សូមយើងធ្វើឲ្យជីវិតយើងមានភាពសាមញ្ញបន្តិច ។ ចូរយើងធ្វើការផ្លាស់ប្តូរដែលចាំបាច់ដើម្បីយកចិត្តទុកដាក់លើជីវិតរបស់យើងសារជាថ្មី ទៅលើភាពស្រស់ស្អាតយ៉ាងវិសេសនៃផ្លូវនៃភាពជាសិស្សជាពួកគ្រីស្ទានដ៏រាបទាបសាមញ្ញ — ជាផ្លូវដែលតែងតែដឹកនាំឆ្ពោះទៅជីវិតមានន័យ សេចក្តីរីករាយ និង សេចក្តីសុខសាន្ត ។ ■

ចេញមកពីសុន្ទរកថា ដែលបានផ្តល់នៅក្នុងសន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១០ ។

ទំនាក់ទំនងជាមួយខ្លួនយើង

កំណត់ចំណាំ

១. Mahatma Gandhi, in Larry Chang, *Wisdom for the Soul* (ឆ្នាំ ២០០៦) ទំព័រ ៣៥៦ ។

២. ដាល្លិន អេក អូក “Good, Better, Best,” *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ១០៧ ។

៣. J. E. McCulloch, *Home: The Savior of Civilization* (ឆ្នាំ ១៩២៤) ទំព័រ ៤២; សូមមើលផងដែរ Conference Report, ខែ មេសា ឆ្នាំ ១៩៣៥ ទំព័រ ១១៦ ។

ទីកន្លែងរបស់យើង

សំណួរសម្ភាសន៍ដែលមិនបានរំពឹងទុក

បន្ទាប់ពីបេសកកម្មរបស់ខ្ញុំ ខ្ញុំបានមានការលំបាកក្នុងការស្វែងរកការងារធ្វើ ។ នៅទីបំផុត ខ្ញុំបានទទួលការសម្ភាសន៍មួយ ។ មុខតំណែងនោះគឺជាឱកាសដ៏អស្ចារ្យមួយ ប៉ុន្តែខ្ញុំបានព្រួយបារម្ភថាខ្ញុំពុំមានជំនាញគ្រប់គ្រាន់ ។ ដល់វេនខ្ញុំត្រូវសម្ភាសន៍ ហើយខ្ញុំបានអង្គុយទាំងភ័យនៅមុខអ្នកគ្រប់គ្រង ។ ពេលខ្ញុំក្រឡេកទៅតុរបស់គាត់ ខ្ញុំបានឃើញក្រដាសសំណួរដែលគាត់នឹងសួរដល់បេក្ខជន ។ បេះដូងខ្ញុំលោតក្តុកក្តាក់ៗ ។ សំណួរទាំងនោះប្រើនូវពាក្យពិបាកៗ ។

អ្នកគ្រប់គ្រងបានរកឃើញប្រវត្តិរូបរបស់ខ្ញុំ ហើយបានចាប់ផ្តើមសួរអំពីបទពិសោធន៍ការងាររបស់ខ្ញុំ ។ ពេលគាត់អានថា « អ្នកផ្សព្វផ្សាយសាសនាពេញម៉ោង » គាត់បានសួរបើខ្ញុំអាចប្រាប់គាត់ពីអ្វីដែលខ្ញុំបានបង្រៀននៅក្នុងបេសកកម្ម ។

ខ្ញុំបាននិយាយជាមួយគាត់អំពីពួកព្យាការីផែនការនៃសេចក្តីសង្គ្រោះ និង ក្រុមគ្រួសារដ៏អស់កល្បជានិច្ច ។ គាត់ញញឹម ហើយនិយាយថា « ខ្ញុំចង់ឲ្យប្អូនមកជួបក្រុមគ្រួសារខ្ញុំ » ។

ជាថ្មីម្តងទៀត គាត់បានទាញយកក្រដាសដែលមានសំណួរសម្រាប់សម្ភាសន៍ ។ អារម្មណ៍ភ័យខ្លាចរបស់ខ្ញុំបានត្រឡប់មកវិញ ។ គាត់បានសួរថា « តើប្អូនមានកន្លែងស្នាក់នៅនៅទីក្រុងម៉ានីលនេះទេ ? » គាត់មិនបានរងចាំចម្លើយរបស់ខ្ញុំនោះទេ ហើយបាននិយាយថា « មែនហើយ ប្អូនត្រូវការរកកន្លែងស្នាក់នៅ ។ ប្អូននឹងត្រូវចាប់ផ្តើមការងារនៅថ្ងៃស្អែក » ។

វាជាអព្ភូតហេតុមួយ ។ ខ្ញុំមិនដែលភ្លេចទេពីរបៀបដែលការបម្រើបេសកកម្មបានជួយខ្ញុំនៅក្នុងការសម្ភាសន៍ការងាររបស់ខ្ញុំ ។ ■

អាលវិន អេ ប្រទេស ហ្វីលីពីន

សេចក្តីសុខសាន្តនៅក្នុងសេចក្តីបៀតបៀន

ខ្ញុំតម្រង់ខ្លួនឡើងនៅលើកៅអីខ្ញុំ ពេលខ្ញុំបានឮប្រធានបទរបស់អ្នកឡើងនិយាយបន្ទាប់ ៖ មូលហេតុដែលសាសនាចក្រមរមនគឺជាសាសនាចក្រខុសឆ្គង និង មូលហេតុដែលពួកមរមនជាអ្នកស្អប់ខ្ពើមដ៏លាក់ពុត ។ ក្នុងអំឡុងនៃសន្ទរកថានោះ ខ្ញុំបានមានអារម្មណ៍ថា ថ្ពាល់ខ្ញុំឡើងក្រហម ហើយតក់ស្លុត និង ការក្បាត់ ធ្វើឲ្យដួងចិត្តខ្ញុំឈឺចាប់ ។ តើមិត្តភក្តិរបស់ខ្ញុំ ដែលដឹងថាខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយហើយនោះ បែរជាជ្រើសរើសនិយាយមួលបង្កាច់នៅនឹងមុខសិស្សក្នុងថ្នាក់អង់គ្លេសទាំងមូលរបស់ខ្ញុំបានដោយរបៀបណា ?

បន្ទាប់ពីកណ្តឹងបានរោទ៍បញ្ចប់ថ្នាក់ អ្នកនិយាយ និង មិត្តភក្តិមួយចំនួនផ្សេងទៀតបានមករកខ្ញុំ ។ ដោយវិញ្ញាណកំពុងឆេះសន្ធោរសន្ធៅនៅក្នុងខ្លួន ខ្ញុំ ខ្ញុំបានប្រាប់ពួកគេថា អ្វីដែលពួកគេបាននិយាយគឺមិនពិត ហើយថាសមាជិកសាសនាចក្រពុំស្អប់មនុស្សដែលពុំរស់នៅតាមជំនឿរបស់យើងនោះទេ ។ តបតត្រឡប់មកវិញ ពួកគេបានបាញ់មកវិញជាមួយនឹងសេចក្តីថ្លែង និង ការចោទប្រកាន់ខុសឆ្គងទាំងឡាយ ។ ខ្ញុំបានមានអារម្មណ៍ឯកោ ។ ខ្ញុំបានគិតថា « តើវាយុត្តិធម៌យ៉ាងដូចម្តេចទៅ នៅពេលដែលខ្ញុំរស់នៅតាមអ្វីដែលខ្ញុំដឹងថាពិត តែខ្ញុំបែរជាត្រូវបៀតបៀនទៅវិញ ? »

ពេលខ្ញុំត្រឡប់ពីសាលាមកដល់ផ្ទះវិញនៅថ្ងៃនោះ ខ្ញុំបានឃើញអ៊ីមែលមួយពីលោកយាយខ្ញុំ ។ ក្នុងអ៊ីមែលនោះ គាត់បានប្រាប់ខ្ញុំឲ្យមើលម៉ាថាយ ៥:១១–១៤ ។ ខ្ញុំបានអានវាទាំងទឹកភ្នែក ៖ « អ្នករាល់គ្នាមានពរក្នុងកាលដែលគេជេរប្រមាថ ហើយនិយាយបង្ខូសគ្រប់ទាំងសេចក្តីអាក្រក់ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ ។ ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នាបែបដូច្នេះដែរ ។ . . . អ្នករាល់គ្នាជាពន្លឺនៃលោកិយ ។ ឯទីក្រុងណាដែលនៅលើភ្នំ នោះលាក់មិនកំចាំងទេ » ។

ព្រះវិញ្ញាណបរិសុទ្ធបានបំពេញក្នុងដួងចិត្តខ្ញុំ ពេលខ្ញុំអានពាក្យទាំងនោះ ។ ខ្ញុំដឹងថាការបៀតបៀននឹងពង្រឹងសក្ខីភាពរបស់យើង ហើយខ្ញុំដឹងថា ពរជ័យទាំងឡាយនៅក្នុងស្ថានសួគ៌នឹងសក្តិសមនឹងតម្លៃនៃការឈឺចាប់ដែលយើងឆ្លងកាត់នៅលើផែនដីនេះ ។ ព្រះអង្គសង្គ្រោះបានធ្វើឲ្យមានឡើងចំពោះយើង ដើម្បីស្វែងរកសេចក្តីសុខសាន្តនៅពេលយើងកំពុងត្រូវគេបៀតបៀន ដោយសាររស់នៅតាមដំណឹងល្អរបស់ទ្រង់ ហើយខ្ញុំពិតជាមានសេចក្តីអំណរគុណចំពោះការណ៍នោះ ។ ■

បេកា អេហ្វ រដ្ឋ ម៉ុនតាណា ស.រ.អា



ផែនការរត់គេចដោយតន្ត្រីរបស់ខ្ញុំ

ខណៈកំពុងជិះឡានក្រុងក្នុងដំណើរកម្មសិក្សាសាលា ខ្ញុំបានអង្គុយនៅពីមុខក្មេងស្រីម្នាក់ដែលចេះតែនិយាយ និង កំប្លែងដោយប្រើពាក្យមិនសមរម្យ ដែលធ្វើឲ្យខ្ញុំមិនស្រួលក្នុងចិត្ត ។ គ្រូៗរបស់ខ្ញុំ និង សិស្សដទៃទៀតបានប្រាប់នាងឲ្យឈប់ ប៉ុន្តែនាងនៅតែនិយាយបែបនោះ ។ ខ្ញុំមិនដឹងត្រូវធ្វើយ៉ាងណា ដូច្នេះខ្ញុំបានសម្រេចចិត្តទាញយកម៉ាស៊ីន MP3 របស់ខ្ញុំ ហើយស្តាប់បទចម្រៀងដែលខ្ញុំចូលចិត្ត ។

ខ្ញុំបានបើកវាឲ្យលេងឆ្លាស់បទ ហើយបទដំបូងគេមួយគឺជាបទដែលមកពី youth.lds.org/music ។ ខ្ញុំហៀបនឹងចុចឲ្យរំលងបទនោះទៅហើយ ពេលដែលមានអ្វីមួយនៅខាងក្នុងចិត្តបានប្រាប់ខ្ញុំថា ខ្ញុំគួរតែស្តាប់បទនោះ ។ ខ្ញុំបានបន្តស្តាប់បទចម្រៀងដែលពោរពេញដោយការបំផុសគំនិតអស់រយៈពេល ២០ នាទីបន្ទាប់ទៀត ។ ពាក្យពេចន៍ក្នុងបទចម្រៀងទាំងនោះបានលើកទឹកចិត្តខ្ញុំឲ្យតោងជាប់ ហើយរំឭកខ្ញុំថា ខ្ញុំជាបុត្រីជាទីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ។

ក្រោយមកនៅក្នុងសប្តាហ៍នោះ សាលារបស់ខ្ញុំរៀបចំការរាំកម្សាន្តមួយ ។ ថ្វីបើពួកគេបានប្រើបទកំណែថ្មីដែលមានពាក្យពេចន៍ល្អៗដែលមានទំនុកភ្លេងរបស់បទចម្រៀងល្បីក៏ដោយ ក៏ពួកសិស្សៗនៅថ្នាក់ខ្ញុំបានចាប់ផ្តើមស្រែកបន្ទរនូវពាក្យពេចន៍មិនល្អដែលគេដកចេញពីបទចម្រៀងមួយ ។

ជាថ្មីម្តងទៀត ខ្ញុំមានអារម្មណ៍មិនស្រួលក្នុងចិត្តទេ ។ គ្រូៗអង្គុយនៅជិតនោះ តែហាក់ដូចជាមិនចាប់អារម្មណ៍ទេ ។ ខ្ញុំបានក្រឡេកទៅកដៃខ្ញុំ ។ ខ្ញុំបានឃើញខ្សែដៃរបស់ខ្ញុំដែលបានមកពីសន្និសីទយុវវ័យដែលថា « ចូរអ្នករាល់គ្នាឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ (គ. និង ស. ៨៧:៨) » ។

ខ្ញុំបានដឹងថា កន្លែងដែលខ្ញុំកំពុងឈរពុំមែនជាទីបរិសុទ្ធទេ ដូច្នេះខ្ញុំបានចាកចេញទាល់តែដល់បទថ្មី ។

ខ្ញុំដឹងថា តន្ត្រីអាចមានឥទ្ធិពលដ៏ជ្រាលជ្រៅនៅក្នុងជីវិតយើង ។ ខ្ញុំដឹងថា ការស្តាប់តន្ត្រីដែលពោរពេញដោយការបំផុសគំនិតនៅក្នុងម៉ាស៊ីន MP3 របស់ខ្ញុំកាលពីពីរថ្ងៃមុន បានជួយផ្តល់ដល់ខ្ញុំនូវភាពក្លាហានដែលខ្ញុំត្រូវការដើម្បីចាកចេញពីការរាំនោះ ។ បទពិសោធន៍ទាំងនេះបានជួយខ្ញុំឲ្យខិតកាន់តែជិតព្រះវរបិតាសួគ៌ ។ ■

អេឡិចហ្សា ប៊ី ប្រទេស ហូឡង់

រូបភាពលំអរដោយ ថែន ស៊ីម៉ិនស៊ិន

ការចែកចាយ ដំណឹងល្អ ដូចជា យ៉ូហាន បាទីស្ទ

អ្នកអាចជួយរៀបចំមនុស្សសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ដូចជា យ៉ូហាន បាទីស្ទ បានធ្វើសម្រាប់ការយាងមកជាលើកទីមួយរបស់ព្រះអង្គសង្គ្រោះដែរ ។

ដោយ រ៉ាយមិន ខា
ទស្សនាវដ្ដីសាសនាចក្រ

អ្នកដែលមិនដូចយ៉ូហាន បាទីស្ទ គឺអ្នកនឹងមិនបម្រើបេសកកម្មនៅក្នុង « ទីរហោស្ថានស្រុកយូដា » នោះទេ (ម៉ាថាយ ៣:១) ។ សំលៀកបំពាក់របស់អ្នកមិនត្រូវបានធ្វើឡើងពី « រោមអូដ្ឋ » នោះទេ (ម៉ាថាយ ៣:៤) ។ អ្នកនឹងមិនបរិភោគ « កណ្ដូប និង ទឹកឃ្មុំព្រៃ » នោះទេ (ម៉ាថាយ ៣:៤) ។ ប៉ុន្តែគោលបំណងរបស់អ្នកក្នុងការចែកចាយដំណឹងល្អ គឺដូចគ្នានឹងយ៉ូហាន បាទីស្ទ ដែរ ៖ អ្នករៀបចំមនុស្សសម្រាប់ការយាងមករបស់ព្រះយេស៊ូវ ដោយការប្រកាសថា « ចូរឲ្យប្រែចិត្តចុះ ដ្បិតនគរស្ថានសួគ៌ជិតដល់ហើយ » (ម៉ាថាយ ៣:២) ។

បេសកកម្មរបស់យ៉ូហាន បាទីស្ទ គឺច្បាស់លាស់ ៖ « មកមុនព្រះមេស៊ី ដើម្បីរៀបចំផ្លូវថ្វាយព្រះអម្ចាស់ » (នីហ្វៃទី១ ១០:៧) ។ ប៉ុន្តែបេសកកម្មរបស់លោកគឺមិនងាយស្រួលទេ ។ ព្យាការីពីមុនលោកគឺ ម៉ាឡាគី គឺជាង ៤០០ ឆ្នាំពីមុននោះ ។ « ដោយពុំមានព្យាការី នោះប្រជាជននៅក្នុងដែនដីបានចាប់ផ្តើមបែងចែកទៅជាក្រុមទាំងឡាយ ដោយក្រុមនីមួយៗប្រកាសថាមានសិទ្ធិបកស្រាយព្រះគម្ពីរ និង ដឹកនាំប្រជាជន ។ ការយល់ដឹងដ៏ពិតអំពីព្រះយេហូវ៉ា ត្រូវថមថយក្នុងចំណោមក្រុមទាំងនេះ » ។[1]

ថ្វីបើមានឧបសគ្គនៅក្នុងជំនាន់របស់យ៉ូហានក្តី ដ៏ពួកបណ្ដាជនបានចូលទៅក្នុងទីរហោស្ថានដើម្បីស្តាប់លោកផ្សាយ ហើយលោកបានជ្រមុជទឹកឲ្យមនុស្សជាច្រើន ។ អនាគតសាវកពីនាក់ គឺយ៉ូហាន ជាទីស្រឡាញ់ និង អនទ្រេ បានស្គាល់ព្រះយេស៊ូវតាមរយៈយ៉ូហាន (សូមមើល យ៉ូហាន ១:៤០) ។

ការចែកចាយដំណឹងល្អនៅសព្វថ្ងៃនេះក៏មានឧបសគ្គដែរ ។ ជីវិតនៅសម័យទំនើបនេះមាននូវការរំខានជាច្រើន ។ ទស្សនវិជ្ជាខាងលោកិយដឹកនាំមនុស្សឲ្យវង្វេង ។ មនុស្សកាន់តែច្រើនឡើងៗ មិនបានរស់នៅតាមបទដ្ឋានខាងសីលធម៌ឲ្យបានខ្ពស់នោះទេ ។ មនុស្សខ្លះពុំបានឃើញពីសេចក្តីត្រូវការខាងសាសនានោះទេ ។

ក្នុងកាលៈទេសៈទាំងនេះ តើអ្នកអាចមានភាពជោគជ័យក្នុងការចែកចាយដំណឹងល្អដូចជា យ៉ូហាន បាទីស្ទ បានដោយរបៀបណាទៅ ? នេះជាមេរៀនមួយចំនួនចេញពីជីវិតរបស់លោកដែលអាចជួយបាន ។

យ៉ូហានបានដឹងថាបេសកកម្មរបស់លោកជាអ្វី ។ លោកបានដឹងថា លោកត្រូវបានហៅឲ្យជួយមនុស្សមករកព្រះគ្រីស្ទ (សូមមើល លូកា ១:១៦) ។ ពេលលោកបានឃើញព្រះអង្គសង្គ្រោះ យ៉ូហានបានថ្លែងទីបន្ទាល់ថា « នុះន កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក » (យ៉ូហាន ១:២៩) ។ ជាជាងការលើកទឹកចិត្តប្រជាជនឲ្យដើរតាមលោក នោះយ៉ូហានបានជួយពួកគេឲ្យក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ យ៉ូហានបានមានប្រសាសន៍ពីព្រះអង្គសង្គ្រោះថា « ព្រះអង្គនោះបានចម្រើនឡើង ហើយខ្ញុំត្រូវថយវិញចុះ » (យ៉ូហាន ៣:៣០) ។

យ៉ូហានបានបង្រៀនគោលការណ៍មូលដ្ឋាននៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ លោកបានបង្រៀនប្រជាជនអំពីសេចក្តីយុត្តិធម៌ សេចក្តីមេត្តាករុណា ភាពស្មោះត្រង់ សីលធម៌ ការតមអាហារ ការអធិស្ឋាន ការប្រែចិត្ត និង ការសារភាពអំពើ

យ៉ូហាន បាទីស្ទ កំពុងផ្សាយក្នុងទីរហោស្ថាន ដោយ រ៉ូប៊ឺត ធី បារ៉េត

បាប បុណ្យជ្រមុជទឹកដោយពន្លិច ដំណើររស់ឡើងវិញ និង ការជំនុំជម្រះ (សូមមើល ម៉ាថាយ ៣; លូកា ៣) ។ ការបង្រៀនរបស់លោកអាចត្រូវបានពិពណ៌នាថាដូចការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ៖ « គេនឹកប្លែកក្នុងចិត្តពីសេចក្តីបង្រៀនរបស់ទ្រង់ ដ្បិតទ្រង់បង្រៀនដូចជាមានអំណាច មិនដូចពួកអាចារ្យទេ » (ម៉ាកុស ១:២២) ។

យ៉ូហានបានរស់នៅខុសពីមនុស្សលោក ។ ព្រះយេស៊ូវបានបង្ហាញពីភាពខុសគ្នារវាងយ៉ូហាន និង គ្រូបង្រៀនខាងលោកិយថា ៖ យ៉ូហានមិនមែនជា « មនុស្សស្លៀកពាក់អាវទន់ភ្លន់ . . . ស្លៀកពាក់ល្អប្រសើរ . . . នៅក្នុងដំណាក់ស្តេចទេ » (លូកា ៧:២៥) ។ លោកមិនធឹក « ស្រាទំពាំងបាយជូរ ឬ គ្រឿងស្រវឹងទេ » (លូកា ១:១៥) ។ យ៉ូហានមាន « សំឡេងនៃមនុស្សម្នាក់កំពុងតែស្រែកនៅទីរហោស្ថានថា ឲ្យរៀបចំផ្លូវទទួលព្រះអម្ចាស់ » (ម៉ាកុស ១:៣) ។ ដោយសារលោកបានបង្រៀនដោយព្រះចេស្តានៃព្រះ នោះប្រជាជនបានទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយបានប្រែចិត្តជឿ ។

យ៉ូហានបានមានការលះបង់ខ្ពស់ណាស់ ។ អ្នកប្រាជ្ញម្នាក់បានសង្ខេបពីគុណសម្បត្តិរបស់យ៉ូហានថា ៖ « គោលបំណងតែមួយឥតល្អៀងរបស់លោក ការលះបង់ទាំងស្រុងចំពោះការហៅបម្រើដ៏ពិសេសរបស់លោក និង ភក្តីភាពដ៏ពេញលេញរបស់លោកចំពោះព្រះរាជបុត្រានៃព្រះ ។ លក្ខណៈទាំងនេះរួមជាមួយនឹងសិទ្ធិអំណាចបព្វជិតភាពដ៏ទេវភាពរបស់លោក បុគ្គលិកលក្ខណៈដែលមិនចេះភ័យខ្លាចរបស់លោក និង សេចក្តីសុចរិតផ្ទាល់ខ្លួនរបស់លោក ធ្វើឲ្យលោកក្លាយជាតួអង្គដ៏ស្វារ្យបំផុតមួយក្នុងចំណោមតួអង្គទាំងអស់ក្នុងព្រះគម្ពីរ » ។[២]

ពេលអ្នកសិក្សាពីជីវិតរបស់យ៉ូហាន បាទីស្ទ អ្នកឃើញថា លោកគឺលើសពីគ្រាន់តែជាមនុស្សម្នាក់ដែលមានពរជ័យពិសេសនៃការដែលបានធ្វើបុណ្យជ្រមុជទឹកឲ្យព្រះយេស៊ូវគ្រីស្ទទៅទៀត ។ អ្នកឃើញថា ជីវិត និង បេសកកម្មរបស់លោកគឺអំពីការរៀបចំមនុស្សសម្រាប់ការយាងមករបស់ព្រះអង្គសង្គ្រោះ គឺដូចជាបេសកកម្មរបស់អ្នកដែរ ។ ■

កំណត់ចំណាំ

1. S. Kent Brown និង Richard Neitzel Holzapfel, "The Lost 500 Years: From Malachi to John the Baptist," *លីអាហូណា*, ខែ ធ្នូ ឆ្នាំ ២០១៤ ទំព័រ ៣០ ។
2. Robert J. Matthews, "John the Baptist: A Burning and a Shining Light," *Ensign,* ខែ កញ្ញា ឆ្នាំ ១៩៧២ ទំព័រ ៧៩ ។

ហេតុអ្វីអ្នកនៅលើផែនដីនៅពេលនេះ ?

« អ្នក និង ខ្ញុំនឹងបានរីករាយនៅពេលនៃការយាងមករបស់ទ្រង់ ហើយអរព្រះគុណដល់ព្រះអម្ចាស់ដែលទ្រង់បានបញ្ជូនយើងមកលើផែនដីនៅពេលនេះ ដើម្បីបំពេញកណ្តឹកិច្ចដ៏ពិសិដ្ឋរបស់យើង ក្នុងការជួយរៀបចំពិភពលោកសម្រាប់ការវិលត្រឡប់មកវិញរបស់ទ្រង់ » ។

អែលឌើរ នែល អិល អាន់ឌើរសិន
នៃក្រុមនៃពួកសាវកដប់ពីរនាក់
"Preparing the World for the Second Coming," *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៥២ ។

ប៉ុន្តែ ចុះបើ . . . ?

សំណួរអំពីការបម្រើបេសកកម្ម

ពេលដែលពេលវេលាដើម្បីបម្រើបេសកកម្មកាន់តែខិតជិតមកដល់ នោះអ្នកអាចនឹងសួរខ្លួនឯងថា « តើខ្ញុំពិតជាអាចធ្វើវាបានមែនឬ ? » មែនហើយ អ្នកអាច ! វាអាចមិនមែនជាការងាយស្រួលទេ ប៉ុន្តែអ្នកនឹងមិនដែលសោកស្តាយឡើយ ។

ការរៀបចំខ្លួនដើម្បីបម្រើបេសកកម្មអាចជាការគួរឲ្យភ័យខ្លាច ។ មានអ្វីៗជាច្រើនដែលអ្នកអាចនឹងព្រួយបារម្ភ—លុយកាក់ ចំណេះដឹង ភាពខ្មាស់អៀន—ប៉ុន្តែមិនថាកង្វល់នោះជាអ្វីទេ អ្នកអាចរកឃើញការអះអាង និង ភាពក្លាហានដែលអ្នកត្រូវការ ។ ទាំងនេះគឺជាសំណួរ និង ចម្លើយមួយចំនួនដែលត្រូវបានសួរឆ្លើយជាញឹកញាប់ ដើម្បីជួយអ្នកយកឈ្នះលើភាពភ័យខ្លាចរបស់អ្នក និង ដើម្បីស្វែងរកសេចក្តីជំនឿដើម្បីឈានឆ្ពោះទៅមុខ ។

ចុះបើខ្ញុំមិនចេះព្រះគម្ពីរ និង ដំណឹងល្អគ្រប់គ្រាន់ ?

ការរៀបចំបេសកកម្មពិតជាគប្បីត្រូវរួមបញ្ចូលទាំងការរៀនអំពីដំណឹងល្អ ប៉ុន្តែអ្នកមិនចាំបាច់ត្រូវចេះអ្វីៗគ្រប់យ៉ាងមុនពេលអ្នកទៅបម្រើនោះទេ ។ ឧទាហរណ៍ ពេលនៅជាក្មេងប្រុសម្នាក់ អែលឌើរ នែល អិល អាន់ឌើរសិន នៃក្លឹមនៃពួកសាវកដប់ពីរនាក់ លោកបានព្រួយបារម្ភថា លោកពុំបានរៀបចំខ្លួនដើម្បីបម្រើបេសកកម្ម ។ លោកបានមានប្រសាសន៍ថា « ខ្ញុំចាំពីការអធិស្ឋានថា ‹ ព្រះវរបិតាសួគ៌អើយ តើខ្ញុំអាចបម្រើបេសកកម្មមួយបានដោយរបៀបណាទៅ បើខ្ញុំ ចេះតែបន្តិចបន្តួចហ្នឹង ? › ខ្ញុំបានជឿទៅលើសាសនាចក្រ ប៉ុន្តែខ្ញុំ មានអារម្មណ៍ថា ចំណេះដឹងខាងវិញ្ញាណរបស់ខ្ញុំ គឺមានកម្រិតតិចតួចណាស់ ។ នៅពេលខ្ញុំបានអធិស្ឋាន ខ្ញុំទទួលបានអារម្មណ៍ថា ៖ ‹ អ្នកពុំចេះដឹងអ្វីៗទាំងអស់នោះទេ ប៉ុន្តែអ្នកដឹងល្មមគ្រប់គ្រាន់ហើយ ! › »[1]

ចំណេះដឹងអំពីដំណឹងល្អនឹងបានមក ពេលអ្នកធ្វើកិច្ចការដោយស្មោះត្រង់ ដើម្បីរៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អ និង សិក្សាព្រះគម្ពីរ ហើយអ្នកនឹងមិនឯកោទេ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំអ្នក ហើយអ្នកនឹងមានដៃគូ អ្នកដឹកនាំអ្នកផ្សព្វផ្សាយសាសនា និង ប្រធានបេសកកម្មរបស់អ្នកដើម្បីជួយអ្នកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់អ្នក ។ សូមចងចាំពីអ្វីដែល អែលឌើរ ដៃវ្រ៊ី អ័រ ហូឡិន នៃក្លឹមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « ទំហំនៃសេចក្តីជំនឿរបស់អ្នក ឬ កម្រិតនៃចំណេះដឹងរបស់អ្នកមិនមែនជាបញ្ហានោះទេ—វាគឺជាសេចក្តីសុចរិតដែលអ្នកបង្ហាញទៅកាន់សេចក្តីជំនឿដែលអ្នកមាន និង សេចក្តីពិតដែលអ្នកបានដឹងរួចស្រេចហើយ » ។[2]

ចុះបើ ខ្ញុំមិនប្រាកដថាបើខ្ញុំមានទីបន្ទាល់មួយឬអត់នោះ ?

ការទទួលបានទីបន្ទាល់គឺជាផ្នែកមួយដ៏សំខាន់ក្រៃលែងក្នុងការរៀបចំខ្លួនសម្រាប់បេសកកម្ម ។ អ្នកអាចនឹងមានអារម្មណ៍ថា ទីបន្ទាល់របស់អ្នកខ្សោយ ប៉ុន្តែវានឹងលូតលាស់ឡើង ពេលដែលអ្នកខំប្រឹងប្រែងដោយស្មោះត្រង់ដើម្បីស្ថាបនាវាឡើង ។ គ្រាន់តែចងចាំថា ៖

- *សូមស្វែងរកពេលវេលាដ៏ស្ងប់ស្ងាត់ទាំងឡាយដើម្បីសិក្សា និង អធិស្ឋាន ។* អ្នកត្រូវការពេលវេលាដែលអ្នកអាចទទួលអារម្មណ៍នៃការបំផុសពីព្រះវិញ្ញាណ ។
- *សូមរស់នៅតាមដំណឹងល្អ ។* សូមមើល យ៉ូហាន ៧:១៧ ដើម្បីរកមើលពីមូលហេតុដែលការណ៍នេះនឹងជួយឲ្យទីបន្ទាល់របស់អ្នកលូតលាស់ ។
- *សូមបង្កើតវាឡើងបន្តិចម្តងៗ ។* « ដំណើរខាងវិញ្ញាណ [របស់អ្នក] គឺជាដំណើរការអស់មួយជីវិត ។ យើងពុំដឹងអ្វីៗទាំងអស់ចាប់តាំងពីដំបូង ឬ សូម្បីតែនៅតាមផ្លូវធ្វើដំណើរ ។ ការប្រែចិត្តជឿរបស់យើងមកមួយជំហានម្តងៗ » ។[3]

សូមចងចាំផងដែរថា ទីបន្ទាល់របស់អ្នកអាចនឹងរឹងមាំជាងដែលអ្នកគិត ។ អែលឌើរ ហូឡិន បានចែកចាយរឿងនេះថា ៖ « ក្នុងពេលថ្មីៗនេះ ក្មេងប្រុសអាយុ ១៤ ឆ្នាំម្នាក់ បាននិយាយមកកាន់ខ្ញុំដោយស្នាក់ស្ងើរបន្តិចថា ‹ បងប្រុស ហូឡិន ខ្ញុំមិន



ទាន់អាចនិយាយបានទេថា ខ្ញុំដឹងថាសាសនាចក្រនេះពិត ប៉ុន្តែខ្ញុំជឿថាវាពិត › ។ ខ្ញុំបានឱបក្មេងនោះយ៉ាងណែន ។ ខ្ញុំបានប្រាប់ . . . ថា *ការជឿ* គឺជាពាក្យដ៏មានតម្លៃ លើសពីនេះទៀត វាគឺជាទង្វើដ៏មានតម្លៃ ហើយថាគាត់មិនត្រូវសុំទោសសម្រាប់ ‹ ការគ្រាន់តែជឿប៉ុណ្ណោះនោះឡើយ › ។ ខ្ញុំបានប្រាប់គាត់ថា ព្រះគ្រីស្ទទ្រង់ផ្ទាល់បានមានព្រះបន្ទូលថា ‹ កុំខ្លាចអី ឲ្យគ្រាន់តែជឿប៉ុណ្ណោះ › ។ . . . ខ្ញុំបានប្រាប់ក្មេងប្រុសនេះថា ការជឿគឺតែងតែជាជំហានទីមួយឆ្ពោះទៅកាន់ការជឿស៊ប់ ។ . . . ហើយខ្ញុំបានប្រាប់គាត់ថា ខ្ញុំមានមោទនភាពចំពោះគាត់សម្រាប់ភាពស្មោះត្រង់នៃការស្វែងរករបស់គាត់ » ។[៩]

ចុះបើខ្ញុំមិនមានអារម្មណ៍ថាខ្ញុំសក្តិសម ?

ប្រសិនបើមានអ្វីខុសឆ្គងនៅក្នុងជីវិតអ្នក អ្នកអាចដោះស្រាយវាបាន ។ ប៊ីស្សព ឬ ប្រធានសាខារបស់អ្នកនឹងជួយអ្នកឲ្យដឹងពីអ្វីដែលអ្នកត្រូវធ្វើ ដើម្បីឲ្យបានស្អាតស្អំតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ អែលឌើរ រីឆាដ ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « ខ្ញុំសូមទទូចដល់អ្នកថា អ្នកមិនអធិស្ឋានដើម្បីដឹងថាបើអ្នកគួរទៅ [បេសកកម្ម] ឬអត់ទេ ប៉ុន្តែសូមសួរដល់ព្រះអម្ចាស់ដើម្បីដឹកនាំអ្នកឲ្យធ្វើអ្វីដែល

យុវនារី ៖ ការសម្រេចចិត្តដើម្បីបម្រើបេសកកម្ម

ក្នុងនាមជាយុវនារីម្នាក់ អ្នកមិនមានកាតព្វកិច្ចដើម្បីបម្រើទេ ប៉ុន្តែអ្នកពិតជាមានឱកាស ។ ពេលអ្នកធ្វើការសម្រេចចិត្តថាបម្រើ ឬ អត់ អ្នកអាចនឹងមានសំណួរមួយចំនួនដូចជា ៖

- តើបេសកកម្មត្រឹមត្រូវសម្រាប់ខ្ញុំទេ ? តើខ្ញុំនឹងដឹងដោយរបៀបណា ?
- តើខ្ញុំគួរតែរៀបចំនៅថ្ងៃនេះសម្រាប់បេសកកម្មពេញម៉ោងមួយទេ ?
- តើមានហេតុផលអ្វីខ្លះដែលខ្ញុំគួរតែពិចារណាក្នុងការបម្រើបេសកកម្ម ?
- តើខ្ញុំនឹងធ្វើជាអ្នកផ្សព្វផ្សាយដ៏ល្អ ឬ អត់ ?

សូមស្វែងរកចម្លើយ និង ការណែនាំនៅក្នុងអត្ថបទ “Young Women and the Mission Decision,” *លីអាហូណា* ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៣២-៣៥ ។

ចាំបាច់ដើម្បីឲ្យក្លាយជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងដ៏សក្តិសម និង ពោរពេញដោយចេស្តា » ។[៥]

រេបេកា អេស ពីប្រទេស រុស្សី ចែកចាយបទពិសោធន៍របស់នាងថា ៖ « ទោះបីខ្ញុំបានប្រែចិត្តហើយក្តី ក៏កំហុស និង ការឈឺចាប់បានធ្វើឲ្យខ្ញុំគិតថា ខ្ញុំពុំអាចបម្រើបេសកកម្មបានទេ ដោយសារកំហុសរបស់ខ្ញុំវាធំធេងពេក ។ ទោះជាយ៉ាងណា បិស្សព និង ប្រធានស្តេករបស់ខ្ញុំបានជួយខ្ញុំឲ្យដឹងថា អំណាចនៃការព្យាបាលនៃដង្វាយធួនគឺនៅក្នុងជីវិតខ្ញុំ ។ ខ្ញុំមានអំណរគុណយ៉ាងខ្លាំងសម្រាប់ការប្រែចិត្ត ។ ការមានភាពសក្តិសមគឺជាអ្វីៗគ្រប់យ៉ាងនៅក្នុងបេសកកម្ម ។ អ្នកពុំអាចបង្រៀនដោយព្រះវិញ្ញាណទេ បើអ្នកមិនមានភាពសក្តិសមនោះ (សូមមើល គ. និង ស. ៤២:១៤) ។ អ្នកត្រូវតែមានសេចក្តីសុខសាន្តក្នុងដួងចិត្តអ្នក ដើម្បីបម្រើឲ្យអស់ពីចិត្តអ្នក ។ វាធ្វើឲ្យមានការផ្លាស់ប្តូរទាំងអស់ » ។

តើខ្ញុំអាចចាកចេញពីក្រុមគ្រួសារ និងមិត្តភក្តិខ្ញុំដោយរបៀបណាទៅ ?

វាពិបាកដែលត្រូវចាកចេញពីមនុស្សជាទីស្រឡាញ់ទាំងឡាយ ជាពិសេសដោយដឹងថា អ្វីៗវានឹងខុសប្លែកពេលអ្នកត្រឡប់មកវិញ—សម្រាប់មិត្តភក្តិអ្នក ក្រុមគ្រួសារអ្នក និង ជាពិសេសខ្លួនអ្នក ។ អ្នកអាចនឹងព្រួយបារម្ភអំពីរបៀបដែលក្រុមគ្រួសារអ្នកចាត់ចែងហិរញ្ញវត្ថុដោយគ្មានអ្នក ឬ របៀបដែលពួកគេនឹងប្រតិកម្មចំពោះបេសកកម្មអ្នក ។ ប៉ុន្តែព្រះអម្ចាស់នឹងថែរក្សាពួកអ្នកទាំងឡាយដែលអ្នកស្រឡាញ់ និង ប្រទានពរដល់ពួកគេសម្រាប់ការបម្រើរបស់អ្នក (សូមមើល គ. និង ស. ១០០:១) ។ ថ្វីបើអ្នកនឹងនឹកពួកគេ តែព្រះអម្ចាស់ត្រូវការអ្នកដើម្បីជួយក្រុមគ្រួសារផ្សេងទៀតឲ្យស្វែងរកសុភមង្គលក្នុងដំណឹងល្អ ។ សូមជឿថា ព្រះវរបិតាសួគ៌មានព្រះទ័យចង់បានអ្វីដែលល្អបំផុតសម្រាប់អ្នក និង ក្រុមគ្រួសារអ្នក ហើយសូមចាំថា « សេចក្តីជំនឿគឺទុកចិត្តថា ព្រះអម្ចាស់មានអ្វីៗដ៏អស្ចារ្យនៅក្នុងឃ្លាំងសម្រាប់យើងម្នាក់ៗ » ។[៦] ព្រះអម្ចាស់មានពរជ័យដ៏អស្ចារ្យដែលនៅរង់ចាំអ្នក និង ក្រុមគ្រួសារអ្នក ពេលអ្នកស្វែងរកសេចក្តីជំនឿដើម្បីឆ្ពោះទៅមុខ ។

ចុះបើខ្ញុំគិតថា ខ្ញុំពុំអាចបង់ប្រាក់សម្រាប់បេសកកម្មបាន ?

តម្លៃសម្រាប់ចេញបេសកកម្មអាចមើលទៅហាក់ដូចជាការលះបង់ដ៏ធំមួយ ប៉ុន្តែព្រះអម្ចាស់ត្រាស់ដឹងពីអ្វីដែលទ្រង់ចង់ឲ្យអ្នកធ្វើ ។ ប្រធាន ប៊ែនជ័ឃេ ផាកគឺ ជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ខ្ញុំនិយាយទៅកាន់យុវជននោះ ដែលមិនដឹងសោះថាគាត់អាចបង់សម្រាប់បេសកកម្មមួយយ៉ាងណា ។ ខ្ញុំក៏មិនដឹងដែរ ។ ប៉ុន្តែខ្ញុំដឹងការណ៍នេះថា ៖ បើអ្នកមានសេចក្តីជំនឿ ហើយប្តេជ្ញាចិត្តថា អ្នកនឹងទៅ នោះនឹងមានមធ្យោបាយមួយ » ។[៧]

ឡូរេន ស៊ី ពីប្រទេស អង់គ្លេស បានមានបទពិសោធន៍នេះ ៖ « ខ្ញុំទើបតែចាប់ផ្តើមបំពេញក្រដាសបេសកកម្មរបស់ខ្ញុំ កាលដែលធនាគាររបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្ញុំមានបំណុលយ៉ាងច្រើនដោយប្រើប័ណ្ណឥណទាន ។ ប៊ីស្សពរបស់ខ្ញុំ និង ខ្ញុំបានរៀបចំផែនការថវិកាថាចំនួនប៉ុន្មានដែលខ្ញុំត្រូវបង់ទៅបំណុលរបស់ខ្ញុំ បេសកកម្មរបស់ខ្ញុំ ដង្វាយមួយភាគក្នុងដប់ និង ចំណាយផ្សេងៗរបស់ខ្ញុំ ។ វាត្រូវការការលះបង់ច្រើនណាស់ ហើយខ្ញុំបានគិតថា ខ្ញុំនឹងមិនអាចសម្រេចគោលដៅរបស់ខ្ញុំបានទេ ។ ទោះយ៉ាងណា ខ្ញុំបានបង់ដង្វាយមួយភាគក្នុងដប់របស់ខ្ញុំយ៉ាងស្មោះត្រង់ ហើយព្រះអម្ចាស់បានយាងចូលមកជួយ ។ អំណោយពីអ្នកដែលមិនស្គាល់ម្នាក់បានផ្តល់លុយដែលខ្ញុំត្រូវការដើម្បីសងបំណុលរបស់ខ្ញុំ និង បំពេញគោលដៅបេសកកម្មរបស់ខ្ញុំ » ។

ចុះបើខ្ញុំអៀនមិនហ៊ាននិយាយទៅមនុស្ស ?

ការគិតអំពីការចំណាយពេលពេញមួយថ្ងៃ ជារៀងរាល់ថ្ងៃក្នុងការនិយាយទៅកាន់មនុស្សដែលអ្នកមិនស្គាល់ អាចជាការលំបាក ។ សេម អិល ពីរដ្ឋកាលីហ្វ័ញ៉ា សហរដ្ឋអាមេរិក បានថា ៖ « ចំពោះមនុស្សម្នាក់ដែលមិនទាំងបើកទ្វារឲ្យខ្ញុំផងនោះ គំនិតនៃការគោះទ្វាររបស់មនុស្សដែលមិនស្គាល់គ្នាសោះ ដើម្បីនិយាយអំពីដំណឹងល្អ ហាក់បីដូចជាហួសពីព្រំដែនដែលអាចទៅរួច ។

« នៅឯសន្និសីទយុវវ័យស្តេកមួយ យើងត្រូវបានសុំឲ្យចេញទៅជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ហើយផ្សព្វផ្សាយដំណឹងល្អ ។ ទៅជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនាពិតៗ ? ទៅជួបមនុស្សពិតៗ ? ខ្ញុំភ័យ ប៉ុន្តែខ្ញុំបានចងចាំពីបទគម្ពីរមួយ ៖ ‹ ដ្បិតអញនេះគឺយេហូវ៉ាជាព្រះនៃឯង អញនឹងកាន់ដៃស្តាំឯង ដោយពោលនឹងឯងថា កុំឲ្យភ័យខ្លាចឡើយ អញនឹងជួយឯង › (អេសាយ ៤១:១៣) ។ ខ្ញុំបានអធិស្ឋានសុំជំនួយ ហើយថ្វីបើខ្ញុំនៅឆោតល្ងង់នៅឡើយ ក៏ខ្ញុំបានទទួលអារម្មណ៍ថាមានអំណាចតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយបានចែកជូនព្រះគម្ពីរមរមនពីរច្បាប់ទៀតផង » ។

ចុះបើវាបង្អាក់ដល់ការអប់រំ ឬការងាររបស់ខ្ញុំ ?

អ្នកអាចនឹងគិតថា ការយកពេលវេលាទៅបម្រើបេសកកម្ម ពេលដែលអ្នកកំពុងរៀបចំទៅមហាវិទ្យាល័យ ឬ មានការងារមួយ គឺជាការប្រថុយប្រថានដែលអនាគតរបស់អ្នក ប៉ុន្តែការពិតទៅវាផ្ទុយពីនោះវិញ ។ ព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកជោគជ័យ ហើយទ្រង់នឹងជួយអ្នក ។ ពុំមានអ្វីដែលអ្នកលះបង់នឹងមានតម្លៃជាងការបម្រើបេសកកម្មរបស់អ្នកនោះទេ ។

មនុស្សវ័យក្មេងជាច្រើនបានធ្វើការសម្រេចចិត្តស្រដៀងគ្នានេះ ។ វិល្លៀម អេច ពីប្រទេស អូស្ត្រាលី បានលះបង់អាជីពបាល់ឱបដ៏ជោគជ័យ ដោយមិនបានដឹងថាបើគាត់នឹងមានឱកាសលេងទៀតឬអត់ពេលគាត់ប្រឡប់មកពីបេសកកម្មវិញ (សូមមើល “Time-Out for a Mission,” *លីអាហូណា* ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ៥–៥២) ។ យ៉ូសែប ប៊ី ពីប្រទេស ហ្វីលីពីន បានដើរទៅក្នុងការិយាល័យរបស់លេខាធិការមហាវិទ្យាល័យ រៀបចំនឹងលះបង់ឱកាសអប់រំដែលមានតែមួយក្នុងជីវិត (សូមមើល “For a Burnt Offering,” *លីអាហូណា* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៤០–៤២) ។ មិនថាអ្វីដែលអ្នកសង្ឃឹមចង់បានបន្ទាប់ពីបេសកកម្មរបស់អ្នកនឹងកើតឡើងឬអត់នោះទេ គ្មានឱកាសណានឹងមានតម្លៃជាងការបម្រើរបស់អ្នកជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នោះឡើយ ។

គ្មានការស្តាយក្រោយ

ព្រះវរបិតាសួគ៌មានព្រះទ័យចង់ឲ្យយើងរីករាយ ហើយទ្រង់នឹងមិនស្នើយើងឲ្យធ្វើអ្វីៗដែលនឹងមិនផ្តល់ពរជ័យ និង ជួយយើងនោះទេ ។ បើអ្នកធ្វើអ្វីៗដែលព្រះអម្ចាស់ស្នើឲ្យអ្នកធ្វើដោយស្មោះត្រង់ សូម្បីតែពេលវាពិបាក នោះអ្នកនឹងឃើញថា ពរជ័យទាំងឡាយដែលនឹងបានមកគឺល្អខ្លាំងជាងអ្វីៗដែលលោកិយផ្តល់ឲ្យទៅទៀត ។ អ្នកនឹងមិនដែលស្តាយក្រោយឡើយ ក្នុងការបម្រើបេសកកម្ម ។ ■

កំណត់ចំណាំ

១. នែល អិល អាន់ឌើរសិន “You Know Enough,” *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ១៣ ។
២. ដែហ្វ្រី អ័រ ហូឡិន “Lord, I Believe,” *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩៤ ។
៣. នែល អិល អាន់ឌើរសិន “You Know Enough,” ទំព័រ ១៣ ។
៤. ដែហ្វ្រី អ័រ ហូឡិន “Lord, I Believe,” ទំព័រ ៩៤–៩៥ ។
៥. រីឆាដ ជី ស្កត “Now Is the Time to Serve a Mission!” *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៦ ទំព័រ ៩០ ។
៦. ដែហ្វ្រី អ័រ ហូឡិន នៃ ក្លឹមនៃពួកសាវកដប់ពីរនាក់ “The Best Is Yet to Be” *លីអាហូណា* ខែ មករា ឆ្នាំ ២០១ ទំព័រ ២១ ។
៧. ប៊ីយង់ ឃេ ជាកគី “Come, All Ye Sons of God,” *Ensign,* ខែ សីហា ឆ្នាំ ១៩៨៣ ទំព័រ ៧១ ។

« មិត្តម្នាក់របស់ខ្ញុំចង់សាកល្បងអ្វីដែលមិនល្អ គ្រាន់តែម្តងប៉ុណ្ណោះ ដើម្បីនាងអាចយល់ពីរឿងនោះ ពេលមនុស្សនិយាយពីវា ។ តើខ្ញុំអាចជួយនាងយ៉ាងដូចម្តេច ដើម្បីឲ្យនាងយល់ថាវាមិនមែនជាគំនិតល្អទេ ? »

រឿងដ៏សំខាន់បំផុតមួយដែលអ្នកអាចធ្វើ គឺជួយមិត្តអ្នកឲ្យចងចាំពីមូលហេតុដែលយើងមានព្រះបញ្ញត្តិទាំងឡាយ ។ ព្រះវរបិតាសួគ៌ប្រទានដល់យើងនូវព្រះបញ្ញត្តិទាំងឡាយ ពីព្រោះទ្រង់ស្រឡាញ់យើង ហើយត្រាស់ដឹងថា ព្រះបញ្ញត្តិទាំងនោះនឹងជួយយើងឲ្យរីករាយ និងជួយយើងឲ្យក្លាយដូចជាទ្រង់ ។

នៅក្នុងគម្ពីរសញ្ញាថ្មី ព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលថា « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ » (យ៉ូហាន ១៤:១៥) ។ សូមជួយមិត្តរបស់អ្នកឲ្យដឹងថា ការជ្រើសរើសអ្វីដែលត្រូវបង្ហាញពីសេចក្តីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ និង ការដឹងគុណដល់ដង្វាយធួន និង ដំណឹងល្អរបស់ទ្រង់ ។

អ្នកអាចរំឭកនាងផងដែរថា ការធ្វើអ្វីដែលអាក្រក់ដឹកនាំទៅរកផលអាក្រក់ សូម្បីវាតែម្តងក៏ដោយ ។ យើងមិនអាចធ្វើអំពើបាប ហើយគេចផុតពីផលរបស់វានោះទេ ។ ការមិនគោរពដោយចេតនានូវព្រះបញ្ញត្តិទាំងឡាយ គឺដូចជាការឈានជើងចេញពីព្រះវរបិតាសួគ៌ ហើយទូលទ្រង់ថា ទ្រង់មិនសំខាន់ខ្លាំងដូចជាមិត្តភក្តិរបស់យើង ឬ មនុស្សដទៃទៀតឡើយ ។

ព្រះវរបិតាសួគ៌ស្រឡាញ់យើង ហើយទ្រង់នឹងប្រទានពរដល់យើងឲ្យមានការដឹកនាំពីព្រះវិញ្ញាណ ពេលយើងរក្សាព្រះបញ្ញត្តិរបស់ទ្រង់ ។ បើយើងគោរពប្រតិបត្តិ នោះព្រះវិញ្ញាណនឹងបង្រៀនយើងច្រើនជាងដែលយើងអាចរៀនដោយការដកពិសោធន៍ជាមួយនឹងអំពើបាប ។

យើងពុំត្រូវការការដកពិសោធន៍ទេ

ខ្ញុំនឹងបង្រៀនមិត្តរបស់អ្នកថា « អ្វីក៏ដោយដែលល្អចេញមកពីព្រះ ហើយអ្វីក៏ដោយដែលអាក្រក់ចេញមកពីអារក្ស » (អាលម៉ា ៥:៤០) ។ ខ្ញុំក៏នឹងពន្យល់ផងដែរថា ទង្វើគ្រប់យ៉ាងមានផលរបស់វា ហើយថាយើងមិនគប្បីធ្វើអ្វីៗដែលអាចធ្វើឲ្យអន្តរាយដល់យើងនោះទេ ។ យើងពុំចាំបាច់ដកពិសោធន៍ការណ៍អាក្រក់នោះទេ ។ មាននូវការណ៍អាក្រក់ច្រើនហួសហើយនៅជុំវិញខ្លួនយើង ហើយវាងាយស្រួលនឹងឃើញណាស់ថា មនុស្សជាច្រើនបានរស់នៅក្នុងទុក្ខវេទនា ពីព្រោះពួកគេពុំរក្សាព្រះបញ្ញត្តិទាំងឡាយទេ ។

វីនីស្ស អេស អាយុ ១៧ ឆ្នាំ ទីក្រុង សៅ ប៉ូឡូ ប្រទេសប្រេស៊ីល

ប្រាប់ពីរបៀបដើម្បីយកឈ្នះការល្បួង

សូមប្រាប់មិត្តរបស់អ្នកថា អ្វីដែលសំខាន់បំផុតនោះគឺការឈររបស់នាងចំពោះព្រះភ័ក្ត្រព្រះ ។ យើងមិនត្រូវលះបង់សេចក្តីសង្គ្រោះដ៏អស់កល្បជានិច្ចរបស់យើង ជាថ្នូរនឹងបទពិសោធន៍ខាងលោកិយនៅទេ ។ ហើយអ្នកនឹងកាន់តែជួយដល់មិត្តអ្នក ប្រសិនបើអ្នកអាចប្រាប់នាងអំពីរបៀបដែលអ្នកបានយកឈ្នះលើការល្បួង ។

អេមិលី ជី អាយុ ១៩ ឆ្នាំ ធីតូ រីកូ

យើងមានសក្តានុពលភាពដ៏ទេវភាព

អ្នកអាចពន្យល់ដោយរាបសាទៅកាន់មិត្តរបស់អ្នកថា ខណៈដែលជម្រើសអាក្រក់មួយអាចហាក់ដូចជាពុំមានអន្តរាយ នោះវាអាចនាំទៅកាន់អំពើបាបដែលកាន់តែធ្ងន់ធ្ងរ ។ អ្នកក៏អាចចែកចាយខគម្ពីរនេះ ៖ « ព្រះអម្ចាស់ពុំអាចទតមើលអំពើបាប សូម្បីតែបន្តិចបន្តួច » (គ. និង ស. ១:៣១) ។ សូមរំឭកមិត្តអ្នកថា សូម្បីតែបទពិសោធន៍នៃអំពើបាបតែមួយ អាចធ្វើឲ្យយើងពុំមានភាពបរិសុទ្ធដើម្បីស្តាប់សំឡេងនៃ

ការឆ្លើយតបទាំងឡាយមានគោលបំណងទុកជាជំនួយ និង ជាទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។

ព្រះវិញ្ញាណ ។ លើសអ្វីៗទាំងអស់ សូមឲ្យនាងដឹងថា អ្នកស្រឡាញ់នាង ហើយថាការជ្រើសរើសត្រូវ គឺជាផ្នែកនៃសក្តានុពលភាពដ៏ទេវភាពរបស់នាង ក្នុងនាមជាបុត្រីនៃព្រះ ។

អាឌ្រីអាណា អេហ្វ អាយុ ១៧ ឆ្នាំ រដ្ឋ អារីហ្សូណា ស.រ.អា

គ្រាន់តែម្តងនឹងឈឺចាប់

គ្រប់ការណ៍អាក្រក់ទាំងអស់ សូម្បីបើអ្នកធ្វើវាតែម្តង វានឹងធ្វើឲ្យអ្នកចេញឆ្ងាយពីព្រះវិញ្ញាណ ។ ប្រសិនបើព្រះវិញ្ញាណយាងចេញ វានឹងកាន់តែងាយស្រួលសម្រាប់សាតាំងដើម្បីល្បួងអ្នកឲ្យធ្វើការណ៍អាក្រក់កាន់តែច្រើនឡើងៗ ។ អ្នកនឹងត្រូវតែប្រែចិត្តពីអំពើបាបទាំងអស់របស់អ្នក មិនថាអ្នកធ្វើវាច្រើនដងប៉ុណ្ណាទេ ហើយការប្រែចិត្តពីអំពើបាបធ្ងន់ធ្ងរទាំងឡាយ អាចជាដំណើរការដ៏ឈឺរអង្វែង និង ឈឺចាប់ ។

អេមីលី អិល អាយុ ១៨ ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា

ចូររឹងមាំឡើង

សូមអះអាងសារជាថ្មីដល់នាងថា អ្នកស្រឡាញ់នាង ហើយចង់ជួយនាងឲ្យជ្រើសរើសត្រូវ ។ ខ្ញុំបានដឹងតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនថា យើងមិនចាំបាច់ជ្រើសជម្រើសដូចគ្នាទៅនឹងនរណាម្នាក់ ដើម្បីស្គាល់ពីគេនោះទេ ។ ពេលដែលយើងរស់នៅតាមដំណឹងល្អ នោះព្រះវិញ្ញាណនឹងជួយយើងឲ្យដឹងពីរបៀបដើម្បីស្គាល់មនុស្ស ។ សូមរំឭកមិត្តអ្នកថា នាងត្រូវបន្តរឹងមាំ ដើម្បីនាងអាចជួយអ្នកផ្សេងទៀតឲ្យគោរពព្រះបញ្ញត្តិទាំងឡាយផងដែរ ។ សូមអធិស្ឋានថា អ្នកនឹងអាចជួយ និងបម្រើដល់នាង ។

វ៉ានីណា ភី អាយុ ១៩ ឆ្នាំ ប៊ូណូស អ៊ែរីស ប្រទេសអាហ្សង់ទីន

អ្នកប្រហែលជានឹងមិនអាចបញ្ឈប់បាន ខ្ញុំនឹងប្រាប់មិត្តខ្ញុំថា កុំសូម្បីតែគិតអំពីវា ។ វាមិនមែនជាគំនិតល្អទេ ក្នុងការធ្វើអ្វីដែលអាក្រក់សូម្បីតែម្តង ពីព្រោះអ្នកប្រហែលជានឹងមិនអាចបញ្ឈប់វាបាន ពេលអ្នកបានចាប់ផ្តើមវាហើយ ។ ព្រះវរបិតាសួគ៌បានប្រទានព្រះបញ្ញត្តិដល់យើងដើម្បី ជួយយើងឲ្យមានសុវត្ថិភាព និង សេចក្តីរីករាយ ។

ដាក់ឡាស ប៊ី អាយុ ១៣ ឆ្នាំ រដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា

វាចាប់ផ្តើមពីតូចមុន

អែលឌើរ ដៃហ្វ្រី អ័រ ហូឡិន បានមានប្រសាសន៍ម្តងថា « ការធ្វើដំណើររាប់ពាន់គីឡូគឺចាប់ផ្តើមពីមួយជំហាន ដូច្នេះសូមប្រុងប្រយ័ត្នចំពោះការឈានជំហានរបស់អ្នក » (“Place No More for the Enemy of My Soul,” *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៤៥) ។ ខ្ញុំនឹងជួយមិត្តខ្ញុំឲ្យយល់ថា សាតាំងប្រើប្រាស់ការល្បួងតូចៗ ដើម្បីនាំយើងឲ្យចាប់ផ្តើមចុះទៅតាមផ្លូវអាក្រក់ ។ ពេលអ្នកសាកល្បងអ្វីដែលអាក្រក់ សូម្បីតែម្តងនោះអ្នកអនុញ្ញាតឲ្យសាតាំង និង អ្នកដើរតាមវាចាប់ផ្តើមល្បួងអ្នកឲ្យធ្វើវាម្តងហើយម្តងទៀត ។

សិមីឡូនី អេហ្វ អាយុ ១៨ រដ្ឋ យូថាហ៍ ស.រ.អា



ហេតុអ្វីមិនសាកល្បងវា ?

« ជាច្រើនឆ្នាំកន្លងមកហើយ កូនប្រុសម្នាក់របស់យើងបានសួរខ្ញុំថា ហេតុអ្វីវាមិនមែនជាគំនិតល្អដើម្បីសាកល្បងគ្រឿងស្រវឹង ឬ ថ្នាំជក់ ដើម្បីដឹងថាវាយ៉ាងម៉េច ។ . . . ខ្ញុំបានឆ្លើយតបថា បើគាត់ចង់សាកល្បង គាត់គួរតែទៅជង្រុកស្រូវ ហើយញាំជីអាចម៍សត្វបន្តិចទៅ ។ គាត់បានគ្រវែញខ្លួនទាំងខ្ពើមឆ្អើម ។ គាត់បានតបថា ‹ ឱ វាគួរឲ្យខ្ពើមណាស់ › ។

« ខ្ញុំបាននិយាយថា ‹ ប៉ាសប្បាយចិត្តណាស់ដែលកូនគិតដូច្នោះ ប៉ុន្តែហេតុអ្វីកូនមិនសាកវាទៅ ដើម្បីកូននឹងដឹងដោយខ្លួនកូន ? ពេលដែលកូនស្នើសុំសាកល្បងអ្វីមួយ ដែលកូនដឹងថាមិនល្អសម្រាប់កូន ហេតុអ្វីកូនមិនអនុវត្តគោលការណ៍នោះទៅអ្វីផ្សេងទៀតដែរទៅ ? › »

អែលឌើរ ដាល្លិន អេក អ្នក នៃក្រុមនៃពួកសាវកដប់ពីរនាក់ “Sin and Suffering,” *Tambuli*, ខែ មេសា ឆ្នាំ ១៩៩៤ ទំព័រ ៣២ ។

សំណួរនាពេលខាងមុខ

« ឪពុកម្តាយរបស់ខ្ញុំស្តីបន្ទោសការ ស្តាប់ចម្រៀងឮខ្លាំងៗ និង មើលកម្មវិធីទូរទស្សដែលមិនសមរម្យ ។ តើខ្ញុំអាចធ្វើអ្វីដើម្បីមានអារម្មណ៍ពីព្រះវិញ្ញាណនៅផ្ទះ ជាពិសេសនៅថ្ងៃអាទិត្យ ? »

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និងរូបថតច្បាស់មួយសន្លឹក ត្រឹម ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៥ នៅគេហទំព័រ liahona.lds.org តាមអ៊ីមែលទៅអាស័យដ្ឋាន liahona@ldschurch.org, ឬតាមសំបុត្រ (សូមមើលអាស័យដ្ឋាននៅទំព័រទី ៣) ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីមែល ឬ សំបុត្ររបស់អ្នក ៖ (១) នាមត្រកូលទាំងមូល (២) ថ្ងៃខែឆ្នាំកំណើត (៣) វួដ ឬ សាខា (៤) ស្តេក ឬ មណ្ឌល (៥) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានអាយុក្រោម ១៨ ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្តាយរបស់អ្នកជាលាយលក្ខណ៍អក្សរ (អ៊ីមែលអាចទទួលយកបាន) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

ល្បែងផ្គុំរូប ពេលសិក្សាព្រះគម្ពីរ

ដូចជាការដាក់ផ្គុំល្បែងផ្គុំរូបដែរ គ្រប់ពេលដែលអ្នកសិក្សាព្រះគម្ពីរ អ្នកទទួលបានគំហើញកាន់តែធំឡើងៗអំពីសេចក្តីពិតនៃព្រះ ។



ដោយ ខូឌី ហ៊្វីលីព

នៅក្នុងខែ កញ្ញា ឆ្នាំ ២០១១ ពួកនិសិត្សនៅសកលវិទ្យាល័យមួយនៅប្រទេសវៀតណាមបានទទួលកំណត់ត្រាពិភពលោកដោយបានដាក់ផ្គុំរូបដែលធំបំផុតលើពិភពលោក ។ មាននិសិត្ស ១,៦០០ នាក់ ចំណាយពេល ១៧ ម៉ោង ដើម្បីផ្គុំបំណែករូបភាព ៥៥១,២៣២ បញ្ចូលគ្នាជារូបមួយ ។

ពួកគេបានបង្កើតរូបផ្គុំមួយដែលមានទំហំ ១៥ ម ២៣ ម ដែលមានរូបភាពផ្កាឈូកដែលមានស្លឹកប្រាំមួយសន្លឹកជាតំណាងឲ្យប្រជាជន ភូមិសាស្រ្ត ប្រវត្តិសាស្រ្ត វប្បធម៌ ការអប់រំ និង សេដ្ឋកិច្ច ។ សូមគិតអំពីវា—បំណែករូបភាពច្រើនជាងកន្លះលានបំណែកចាក់ស្រេះដើម្បីបង្កើតជារូបភាពដ៏ធំមួយ ។ បំណែកនីមួយៗនៃរូបផ្គុំហាក់បីដូចជាមិនសំខាន់ និង មិនគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែរូបផ្គុំនោះនឹងមិនបញ្ចប់ឡើយបើបាត់តែបំណែកណាមួយនោះ ។

ព្រះគម្ពីរគឺដូចជារូបផ្គុំដែរ ៖ អ្នកកាន់តែដាក់បំណែករូបភាពចូលគ្នាច្រើនប៉ុណ្ណា នោះអ្នកឃើញសេចក្តីពិតនៃផែនការនៃព្រះកាន់តែច្បាស់ដែរ ។ ពេលដែលគំហើញរបស់អ្នកអំពីផែនការនោះលូតលាស់ឡើង អ្នកនឹងឃើញថាព្រះគម្ពីរគឺគួរឲ្យចាប់អារម្មណ៍ និង ទាក់ទងទៅនឹងជីវិតអ្នក ។

នេះគឺជាយោបល់សម្រាប់ការសិក្សាព្រះគម្ពីរមួយចំនួន ដើម្បីជួយអ្នកឲ្យឃើញរូបភាពធំ—និង ឃើញផ្នែកពិស្តារតូចៗ ។ ពេលដែលអ្នកដាក់បំណែកទាំងនេះបញ្ចូលគ្នា អ្នកនឹងឃើញសេចក្តីពិតដ៏អស្ចារ្យដែលរង់ចាំអ្នកនៅក្នុងព្រះគម្ពីរ ។

គោលលទ្ធិ ៖ បំណែកធំៗដែលបង្រៀនសេចក្តីពិតដ៏អស់កល្បជានិច្ច

ព្រះគម្ពីរបង្រៀនពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ « គ្រប់ទាំងបទគម្ពីរគឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និង ការបង្ហាត់ខាងឯសេចក្តីសុចរិត » (ធីម៉ូថេ ទី២ ៣:១៦) ។ ដោយសារយើងអាចត្រូវបានសង្គ្រោះតែតាមរយៈព្រះយេស៊ូវគ្រីស្ទ (សូមមើល យ៉ូហាន ១៤:៦) នោះយើងត្រូវការរៀនអំពីទ្រង់ និង គោលលទ្ធិរបស់ទ្រង់ ។ នោះហើយជាមូលហេតុដែលព្រះអម្ចាស់បានឲ្យយើង « ស្ទង់មើលគម្ពីរ . . . គឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ » (យ៉ូហាន ៥:៣៩) ។

មនុស្ស ៖ បំណែកដែលមានពណ៌ចំរុះដែលបង្រៀនមេរៀនទាំងឡាយ

មានមនុស្សរាប់រយនាក់នៅក្នុងព្រះគម្ពីរដែលយើងអាចអានអំពីពួកលោក ។ តើនរណាម្នាក់ក្នុងចំណោមពួកលោកដែលអ្នកមានការកោតសរសើរបំផុត ? ប្រហែលអ្នកសំឡឹងទៅអាំម៉ូនសម្រាប់ការគោរពប្រតិបត្តិដ៏អង់អាចក្លាហានរបស់លោកនៅក្នុងគ្រាដ៏គ្រោះថ្នាក់ ។ ឬ ប្រហែលអ្នកគិតអំពីយ៉ូប និង សេចក្តីជំនឿ និង សេចក្តីសុចរិតដ៏ឥតងាករេរបស់លោក ។

តើអ្នកធ្លាប់អានអំពីសត្វលាដែលនិយាយទៅកាន់ម្ចាស់វាទេ (សូមមើល ជនគណនា ២២) ? ឬស្តេចទុច្ចរិតដែលសុខចិត្តលះបង់នគររបស់ទ្រង់ដើម្បីបានការអត់ទោសដែរឬទេ (សូមមើល អាលម៉ា ២២) ? ឬ ស្ត្រីដែលត្រូវបានគេស្គាល់ពេញទាំងទីក្រុងរបស់នាងថាជាស្ត្រីដ៏មានគុណធម៌នោះ (សូមមើល នាងរស់ ១–៤) ?

ក៏មានមនុស្សនៅក្នុងព្រះគម្ពីរដែលមិនគួរឲ្យសរសើរផងដែរ ។ តើអ្នកអាចរៀនអ្វីពីពួកគេ និង ជម្រើសមិនល្អដែលពួកគេបានធ្វើការជ្រើសរើស ?

បំណែករូបផ្គុំ ដោយ ISTOCKPHOTO/THINKSTOCK; រចនារូបភាពដោយ ចាប៉ា ប៊ូប៊ី

សូមយកចិត្តទុកដាក់ទៅលើមនុស្សដែលអ្នកអាននៅក្នុងព្រះគម្ពីរ ហើយសួរខ្លួនឯងពីរបៀបដែលអ្នកអាចធ្វើតាមគំរូល្អៗរបស់ពួកគេ និង ចៀសវាងពីកំហុសរបស់ពួកគេ ។ បំណែករូបផ្គុំនៃជីវិតរបស់ពួកគេគឺជាបំណែកមួយចំនួនដែលគួរឲ្យចាប់អារម្មណ៍ និង ចំរុះពណ៌បំផុតក្នុងចំណោមបំណែកទាំងអស់ ។ បទពិសោធន៍របស់ពួកគេគឺជារបៀបដ៏គួរឲ្យចងចាំមួយ ដើម្បីរៀន និង ចងចាំគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។

និមិត្តរូប ៖ បំណែកបិទបាំងដែលលាតត្រដាង

ជួនកាលព្រះគម្ពីរប្រើប្រាស់និមិត្តរូបដើម្បីបង្រៀនគោលការណ៍ដំណឹងល្អទាំងឡាយ ។ អ្នកនឹងចាត់បង់បំណែកនៃរូបផ្គុំខ្លះៗហើយ បើអ្នកមើលមិនឃើញមេរៀននិមិត្តរូបនោះ ។ បន្ថែមលើថ្នាក់ទាំងឡាយនៅព្រះវិហារ និង ថ្នាក់សិក្ខាសាលា ជំនួយការសិក្សាទាំងឡាយដូចជា សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ឬ សៀវភៅណែនាំការសិក្សាថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថាន អាចជួយអ្នកឲ្យរកឃើញបំណែកដែលបាត់បង់ទាំងនោះ ។

ឧទាហរណ៍ រឿងមួយអំពីអ័ប្រាហាំ និង អ៊ីសាក (សូមមើល លោកុប្បត្តិ ២២) គឺជារឿងដ៏បំផុតគំនិត ប៉ុន្តែវាមានអត្ថន័យកាន់តែជ្រាលជ្រៅទៅទៀត ពេលអ្នករកឃើញថា វាគឺជានិមិត្តរូបអំពីការបូជារបស់ព្រះវរបិតាសួគ៌ និង អំពីការលះបង់ដ៏ធួនរបស់ព្រះអង្គសង្គ្រោះសម្រាប់យើង (សូមមើល យ៉ាកុប ៤:៥) ។

ព្រះមានព្រះបន្ទូលមកកាន់យើង

« នៅពេលយើងចង់និយាយទៅកាន់ព្រះ នោះយើងអធិស្ឋាន ។ ហើយនៅពេលយើងចង់ឲ្យទ្រង់មានបន្ទូលមកកាន់យើង នោះយើងសិក្សាស្រាវជ្រាវព្រះគម្ពីរទាំងឡាយ ដ្បិតព្រះបន្ទូលរបស់ទ្រង់បានមកតាមរយៈពួកព្យាការីរបស់ទ្រង់ ។ បន្ទាប់មកទ្រង់នឹងបង្រៀនដល់យើងនៅពេលយើងស្តាប់តាមការបំផុសគំនិតទាំងឡាយរបស់ព្រះវិញ្ញាណបរិសុទ្ធ » ។

អែលឌើរ រ៉ូប៊ឺត ឌី ហៃល នៃក្រុមនៃពួកសាវកដប់ពីរនាក់ « Holy Scriptures: The Power of God unto Our Salvation » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២៦–២៧ ។

ព្រះវិញ្ញាណបរិសុទ្ធ ៖ ការស្វែងរកបំណែកទាំងឡាយដែលភ្ជាប់គ្នា

បំណែករូបផ្គុំមួយចំនួនមើលទៅដូចជាអាចដាក់ផ្គុំជាមួយគ្នាបាន ប៉ុន្តែវាផ្គុំគ្នាមិនបានទេ ។ ព្រះវិញ្ញាណអាចជួយអ្នកឲ្យឃើញថា បំណែកណាមួយដែលពិតជាអាចដាក់ផ្គុំគ្នាបាន ។ ពេលអ្នកសុំជំនួយពីទ្រង់តាមរយៈការអធិស្ឋាន និង ការសញ្ជឹងគិត នោះព្រះវិញ្ញាណនឹងជួយអ្នកឲ្យឃើញពីរបៀបដែលខទាំងឡាយដែលអ្នកបានសិក្សាពីមុន ភ្ជាប់ទៅនឹងអ្វីដែលអ្នកកំពុងសិក្សាឥឡូវនេះ ក៏ដូចជាពីរបៀបដែលការបង្រៀនទាំងនោះភ្ជាប់ទៅនឹងជីវិតអ្នក ។ ជាក់ស្តែង អ្នកនឹងទទួលការបំផុសគំនិតពីព្រះបន្ទូលទាំងឡាយនៅក្នុងព្រះគម្ពីរ ប៉ុន្តែអ្នកក៏នឹងទទួលការបំផុសគំនិតពីព្រះវិញ្ញាណផងដែរ ពេលដែលអ្នកសញ្ជឹងគិតលើអ្វីដែលអ្នកអាន ។

ការអនុវត្ត ៖ ការដាក់បំណែកទាំងឡាយបញ្ចូលគ្នា

អ្នកនឹងមើលមិនឃើញថាវាជារូបភាពអ្វីនោះទេ បើអ្នកមិនផ្គុំបំណែកទាំងនោះចូលគ្នា ។ ស្រដៀងគ្នានេះដែរ គោលលទ្ធិ គោលការណ៍ និង ព្រះបញ្ញត្តិទាំងឡាយដែលអ្នករៀនចេញពីព្រះគម្ពីរនឹងមិនជួយអ្វីច្រើនដល់អ្នកនោះទេ លើកលែងតែអ្នករស់នៅតាមអ្វីដែលអ្នករៀន (សូមមើល យ៉ូហាន ៧:១៧) ។ ពេលដែលអ្នកព្យាយាមរាល់ថ្ងៃដើម្បីរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អដែលមានបង្រៀននៅក្នុងព្រះគម្ពីរ នោះសេចក្តីជំនឿ និងទីបន្ទាល់របស់អ្នកនឹងកាន់តែរឹងមាំឡើងៗ ហើយការសិក្សាព្រះគម្ពីរនឹងក្លាយទៅជាផ្នែកដ៏សំខាន់នៅក្នុងជីវិតអ្នក ។ ■

អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។

បងប្អូនស្រី ក្នុង ដំណឹងល្អ

ដោយសារខ្ញុំអាចមើលឃើញពរជ័យទាំងឡាយនៃដំណឹងល្អនៅក្នុងជីវិតខ្ញុំ នោះខ្ញុំចង់ចែកចាយវាជាមួយមិត្តខ្ញុំ ។

ដោយ ផៅឡា សារ៉ាហ៊ី ហើនដិនដេហ្ស ប្រូស

ខ្ញុំស្រឡាញ់មិត្តខ្ញុំ ឡូរីតា ដូចជាប្អូនស្រីម្នាក់អញ្ចឹង ។ យើងបានជួបគ្នានៅថ្នាក់ទីប្រាំមួយ ហើយយើងទាំងពីរនាក់នៅក្នុងក្រុមដើរព្យុះហយាត្រារបស់សាលា ។ នៅឆ្នាំសិក្សាបន្ទាប់ យើងកាន់តែជិតស្និតនឹងគ្នា ហើយបានចាប់ផ្តើមពឹងពាក់គ្នាទៅវិញទៅមក ។ នាងបានប្រាប់ខ្ញុំអំពីឧបសគ្គទាំងឡាយដែលនាងមាននៅផ្ទះ ព្រោះឪពុករបស់នាងមិនបាននៅទីនោះ ហើយម្តាយនាងពុំអាចផ្តល់ការយកចិត្តទុកដាក់ដែលនាងត្រូវការ ។ ខ្ញុំបានដឹងថា នាងមិនសប្បាយចិត្តដែលឪពុកម្តាយរបស់នាងពុំមែនជាផ្នែកដ៏ធំនៅក្នុងជីវិតនាង ។ នាងឯកា ប៉ុន្តែនាងមានខ្ញុំនៅជាមួយនាងជានិច្ច ។

ខ្ញុំមានពរជ័យដែលបានកើតមកនៅក្នុងផ្ទះមួយដែលមានដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ វាបាននាំមកក្នុងជីវិតខ្ញុំនូវសេចក្តីសុខសាន្តដែលមិត្តភក្តិខ្ញុំជាច្រើនពុំមាន ។ ដោយសារខ្ញុំអាចមើលឃើញពរជ័យទាំងឡាយដែលដំណឹងល្អបានផ្តល់ដល់ខ្ញុំ នោះខ្ញុំចង់ចែកចាយវាជាមួយឡូរីតា ។

ខ្ញុំបាននិយាយជាមួយនាងអំពីសាសនាចក្រ ហើយបានអញ្ជើញនាងឲ្យទៅការប្រជុំរួមយុវជនយុវនារីជាមួយខ្ញុំ ។ នាងបានទទួលការអញ្ជើញ ហើយបានចាប់ផ្តើមមកព្រះវិហារ និង សកម្មភាពរួមជាមួយខ្ញុំ និង ក្រុមគ្រួសារខ្ញុំ ។ ខ្ញុំបានណែនាំនាងទៅពួកអ្នកផ្សព្វផ្សាយសាសនា ដែលបានបង្រៀននាងអំពីដំណឹងល្អ ហើយបានអញ្ជើញនាងឲ្យទទួលបុណ្យជ្រមុជទឹក ។ នាងទទួលបានទីបន្ទាល់មួយ ហើយពេលនាងសុំម្តាយនាងថាបើនាងអាចទទួលបុណ្យជ្រមុជទឹកបានឬទេ នោះម្តាយនាងបានយល់ព្រម ។

បុណ្យជ្រមុជទឹករបស់នាងពិសេសខ្លាំងណាស់ ពីព្រោះនាងបានធ្វើសេចក្តីសញ្ញាជាមួយព្រះវរបិតាសួគ៌របស់យើង ដើម្បីចងចាំទ្រង់ និងរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ ខ្ញុំបានថ្លែងទីបន្ទាល់របស់ខ្ញុំទៅកាន់នាងនៅថ្ងៃនោះ ហើយបានប្រាប់នាងថា នាងស្ថិតនៅក្នុងកន្លែងដ៏ត្រឹមត្រូវ ហើយថាព្រះវរបិតាសួគ៌ទ្រង់មានមោទនភាពចំពោះនាងណាស់ ។ ខ្ញុំស្រឡាញ់ឡូរីតា ហើយខ្ញុំសប្បាយចិត្តណាស់ ដែលនាងជាមិត្តខ្ញុំ ហើយឥឡូវនេះជាបងប្អូនស្រីក្នុងដំណឹងល្អ ។ ខ្ញុំដឹងថា ជីវិតរបស់នាងនឹងបានរីករាយជាងមុន ព្រោះនាង និង អនាគតក្រុមគ្រួសារនាងនឹងបានរីករាយជាមួយនឹងពរជ័យនៃដំណឹងល្អ ។

ឡូរីតាបានប្រាប់ខ្ញុំថា នាងមានអំណរគុណ ដែលខ្ញុំបានសម្រេចចិត្តចែកចាយដំណឹងល្អជាមួយនាង ។ នាងនិយាយថា តាំងពីនាងចាប់ផ្តើមចូលរួមក្នុងសាសនាចក្រ ជីវិតរបស់នាងកាន់តែប្រសើរឡើង ហើយនាងមានអារម្មណ៍នៃសេចក្តីសុខសាន្ត ។ ខ្ញុំដឹងថា នេះជាការបញ្ជាក់សេចក្តីពិតពីព្រះវិញ្ញាណចំពោះនាង ។ នាងក៏និយាយផងដែរថា ថ្ងៃមួយនាងនឹងរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំមានសេចក្តីអំណរគុណចំពោះព្រះវរបិតាសួគ៌របស់ខ្ញុំ ព្រោះខ្ញុំបានរកឃើញមិត្តរបស់ខ្ញុំ និងពីព្រោះតែសេចក្តីអំណរដែលខ្ញុំមានពេលខ្ញុំចែកចាយអ្វីមួយដែលមានតម្លៃបំផុតសម្រាប់រូបខ្ញុំ ។ ■

អ្នកនិពន្ធរស់នៅក្នុងទីក្រុង ម៉ិកស៊ីកូ ប្រទេសម៉ិកស៊ីកូ ។

សាក្សីពិសេស

ដោយ អែលឌើរ អិល ថមភើរី

ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

សមាជិកកូរ៉ុមនៃពួកសាវកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។

តើខ្ញុំអាចទទួលការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធបានដោយរបៀបណា ?

សេះដ៏ល្អមួយក្បាលគ្រាន់តែត្រូវការការកន្ត្រាក់ថ្នមៗមួយពីអ្នកជិះប៉ុណ្ណោះ ដើម្បីធ្វើអ្វីដែលគាត់ចង់ឲ្យវាធ្វើ ។ ការកន្ត្រាក់ថ្នមៗនេះគឺដូចជាសំឡេងដ៏តូចរហៀង ។

យើងត្រូវតែរៀបចំខ្លួនផ្ទាល់ជាស្រេច ដើម្បីទទួលការកន្ត្រាក់ថ្នមៗនៃព្រះវិញ្ញាណបរិសុទ្ធ ។

បើយើងស្តាប់ដោយប្រុងប្រយ័ត្ន ដល់ការបំផុសគំនិតដ៏ទន់ភ្លន់នៃព្រះវិញ្ញាណបរិសុទ្ធ នោះការបំផុសទាំងនោះនឹងដឹកនាំយើងត្រឡប់ទៅព្រះវរបិតាដែលគង់នៅស្ថានសួគ៌វិញ ។

ដកស្រង់ចេញពី “Obedience through Our Faithfulness,” *លីអាហូណា ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ១០០–១០៣ ។*

ព្រះវិញ្ញាណបរិសុទ្ធ

(ដោយសាមញ្ញ)

ទំនុកច្រៀង និង ទំនុកភ្លេង
ដោយ ជេនី ភី ឡូយ



© 2015, 1989, 1977 ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង។
បទចម្រៀងនេះ អាចថតចម្លងយកមកប្រើប្រាស់ម្តងម្កាលនៅក្នុងសាសនាចក្រ និងក្នុងគេហដ្ឋាន ពុំមែនសម្រាប់ធ្វើអាជីវកម្មឡើយ ។
សេចក្តីប្រកាសនេះ ត្រូវតែភ្ជាប់ទៅនឹងច្បាប់ថតចម្លងនីមួយៗ ។

អ្នកគង្វាលល្អ

ដោយ អ៊ែរិន សាន់ឌឺសុន

ថ្ងៃមួយព្រះយេស៊ូវគ្រីស្ទបានប្រាប់រឿងមួយ (ឬ រឿងប្រៀបធៀប) អំពីអ្នកគង្វាលម្នាក់ ដែលស្រឡាញ់ចៀមរបស់គាត់ខ្លាំងណាស់ ដែលគាត់នឹងប្រគល់សូម្បីតែជីវិតគាត់ដើម្បីការពារពួកវា ។ យើងគឺដូចជាចៀមនៅក្នុងរឿងនោះដែរ ។ ហើយអ្នកគង្វាលគឺដូចជាព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។ ពេលខ្លះទ្រង់ត្រូវបានហៅថាជាអ្នកគង្វាលដ៏ល្អ ។

ព្រះយេស៊ូវបានបង្ហាញសេចក្ដីស្រឡាញ់របស់ទ្រង់ នៅពេលឪពុកម្ដាយមួយចំនួនបាននាំកូនៗរបស់ពួកគេមកមើលទ្រង់ ។ ទ្រង់មានព្រះបន្ទូលថា « **ទុកឲ្យ** កូនក្មេងមកឯខ្ញុំចុះ **កុំឃាត់វាឡើយ** ដ្បិតនគរព្រះមានសុទ្ធតែមនុស្ស ដូចវារាល់គ្នាដែរ » (លូកា ១៨:១៦) ។ បន្ទាប់មក ទ្រង់បាននាំពួកគេមកក្នុងរង្វង់ព្រះហស្តទ្រង់ ហើយប្រទានពរដល់ពួកគេ ។

សូមបិទភ្នែករបស់អ្នក ហើយស្រមៃថា ព្រះអង្គសង្គ្រោះកំពុងកាន់ដៃអ្នកនៅក្នុងព្រះហស្តទ្រង់ ហើយកំពុងប្រទានពរដល់អ្នក ។ អ្នកអាចទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ទ្រង់ ពេលអ្នករៀន ឬ គិតអំពីទ្រង់ ។ ព្រះវិញ្ញាណបរិសុទ្ធជួយអ្នកឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ពីអ្នកគង្វាលដ៏ល្អ គឺព្រះយេស៊ូវគ្រីស្ទ ។ ■

អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។

រៀនបន្ថែមទៀត

ទុកឲ្យ — អនុញ្ញាត

កុំឃាត់វាឡើយ — កុំបញ្ឈប់ពួកគេឡើយ

ការឡើងនិយាយក្នុងក្រុមគ្រួសារ

សូមអាន យ៉ូហាន ១០:១–៥, ១១–១៦ ។ បន្ទាប់មក សូមធ្វើបញ្ជីមួយអំពីរបៀបដែលព្រះយេស៊ូវគឺដូចជាអ្នកគង្វាល ហើយប្រាប់អំពីពេលវេលាទាំងឡាយដែលអ្នកមានអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។

ចម្រៀង ៖ "I Think When I Read That Sweet Story" (Children's Songbook, 56)

ខគម្ពីរ ៖ លូកា ១៨:១៥–១៧; យ៉ូហាន ១០:១–៥, ១១–១៦ ។

វីដេអូ ៖ "Suffer the Little Children to Come Unto Me" និង "Jesus Teaches that We Must Become as Little Children" (Biblevideos.org)

គំនូរព្រាងដោយ ប៉ូល ម៉ាន (ខាងឆ្វេង) និង រ៉ូប អិត (ខាងស្ដាំ)

អ្នកគង្វាលល្អ

សូមកាត់យករូបភាពនេះ ។ បត់វាធ្វើជាឆ្នៃតទៅតាមបន្ទាត់ពណ៌ស ។ បន្ទាប់មកបើកវាមកវិញ ហើយមើលវាពីខាងស្តាំ និង ពីខាងឆ្វេង ។ តើអ្នកមានអារម្មណ៍យ៉ាងណា ចំពោះសេចក្តីស្រឡាញ់របស់អ្នកគង្វាលដ៏ល្អរបស់យើង ?

ពណ៌មានពីព្រះគម្ពីរ

សូមរកមើលពាក្យ « ដំណឹងល្អ » នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ សម្រាប់តារាងមួយដែលប្រាប់អំពីព្រឹត្តិការណ៍ ឬ ការបង្រៀននីមួយ។ ។ មានតែគម្ពីរយ៉ូហានប៉ុណ្ណោះដែលប្រាប់អំពីអ្នកគង្វាលល្អ ។ គម្ពីរបី — ម៉ាថាយ ម៉ាកុស និង លូកា — ប្រាប់អំពីព្រះយេស៊ូវប្រទានពរដល់កូនក្មេង ។

ទំព័ររបស់យើង

ខ្ញុំមិនអាចរង់ចាំដល់ថ្ងៃដែលខ្ញុំនឹងទទួលបុណ្យជ្រមុជទឹកបានទេ ។ ឆ្នាំមុន ពេលខ្ញុំចូលដល់អាយុក្រាំមីឆ្នាំ ប៉ា ម៉ាក់ ក្រុមគ្រួសារ និង មិត្តភក្តិរបស់ខ្ញុំពីសាសនាចក្របានចូលរួមក្នុងពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ ។ វាជាបទពិសោធន៍ដ៏អស្ចារ្យណាស់សម្រាប់ខ្ញុំ ។ វាប្រៀបណាស់ដែលដឹងថា ស្ថានសួគ៌អបអរសាទរដល់ការសម្រេចចិត្តរបស់ខ្ញុំដើម្បីទទួលបុណ្យជ្រមុជទឹក និង ក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលយើងទទួលបុណ្យជ្រមុជទឹក យើងធ្វើសេចក្តីសញ្ញាមួយជាមួយព្រះវរបិតាសួគ៌។ ខ្ញុំដឹងថា ទ្រង់សព្វព្រះទ័យនឹងការសម្រេចចិត្តរបស់ខ្ញុំ ព្រោះវាជាការសម្រេចចិត្តដ៏ត្រឹមត្រូវ និង សុចរិត ។

ហ្សាប៉ៀ ហ្ស៊ី អាយុ ៨ ឆ្នាំ ប្រទេស ហុនឌូរ៉ាស

នេះគឺជាក្រុមគ្រួសារខ្ញុំនៅព្រះវិហារបរិសុទ្ធ ។

ហៃរ៉ូហ្សា ធី អាយុ ៨ ឆ្នាំ ប្រទេស ម៉ិកស៊ីកូ

ខ្ញុំបានគូរូបពលទ័ពហោះលេមិននៅលើអាវយឺតរបស់ខ្ញុំ ។ ខ្ញុំចង់ធ្វើជាមនុស្សស្មោះត្រង់ ក្លាហាន និង គោរពប្រតិបត្តិដល់ព្រះបញ្ញត្តិរបស់ព្រះ ដូចជាពួកគេដែរ !

ហ្ស៊ី យូអិន អាយុ ៦ ឆ្នាំ ប្រទេស តៃវ៉ាន់

យើងចូលចិត្ត ពេលប៉ា ម៉ាក់យើងនាំយើងទៅព្រះវិហារបរិសុទ្ធ ព្រោះវាជាកន្លែងដ៏ស្រស់ស្អាត ហើយយើងមានអារម្មណ៍កាន់តែខិតជិតព្រះ ពេលយើងនៅទីនោះ ។

នីហ្វៃ និង ច្រាយអិន ឺ អាយុ ៦ និង ៩ ឆ្នាំ ប្រទេស អេក្វាឌ័រ

អ្នកគង្វាលល្អ

យ៉ូហាន ១០:១–៥, ១១–១៦

សូមបិទទំព័រនេះ ទៅនឹងក្រដាសរឹង ឬក្រដាសកាតុង ។ បន្ទាប់មក សូមកាត់តួអង្គទាំងនេះ ហើយបិទរូបទាំងនេះទៅនឹងឈើការ៉េម ឬ ថង់ក្រដាស ។ ទុកនៅក្នុងស្រោមសំបុត្រជាមួយនឹងខយោងព្រះគម្ពីរដែលមានភ្ជាប់នៅខាងមុខ ។ ■





អ្នកអាចបោះពុម្ពច្បាប់ចម្លងជាច្រើនទៀតនៅ គេហទំព័រ liahona.lds.org ។

រចនារូបភាព ដោយ បេត ម វ៉ិតធើគើ

ថ្ងៃបុណ្យអនាគតឪពុក លើកទីមួយរបស់ស្ទីវិន

ដោយ ឃេលី ចច ភូសីល

ផ្អែកទៅលើដំណើររឿងពិត

ស្ទីវិនបានមូរក្រវ៉ាត់ករបស់គាត់ឡើងរហូតដល់ក្រោមចង្កា ពេលដែលកុមារផ្សេងទៀតនៅក្នុងថ្នាក់កុមារហាត់បទចម្រៀងថ្មី ។ ទេ គ្មានផ្លូវទេដែលគាត់នឹងច្រៀងបទនេះនោះ ។

ឪពុកក្នុងផ្ទះយើងដឹកនាំគ្រួសារយើង . . .

ស្ទីវិនបានមើលទៅក្រៅបង្អួច ហើយមើលទៅពិដាន ។ គាត់កម្រើកចុះឡើងរហូតនៅលើកៅអីគាត់ ដែលគាត់ស្ទើរតែដូចជាកំពុងរាំ ។ គាត់មិនអាចច្រៀងទេ សូម្បីតែគាត់ចង់ច្រៀងក៏ដោយ ។ មានអ្វីម៉្យាងយ៉ាងធំ និង ដែលធ្វើឲ្យគាត់អួលដើមក ។ កុមារផ្សេងទៀតក្នុងថ្នាក់កុមារចេះតែបន្តច្រៀងទៅមុខ រៀនពាក្យថ្មីៗមួយបន្ទាត់ម្ដងៗ ។

ដោយពន្លឺប្រាជ្ញាគ្រប់អ្វីដែលត្រូវ

ឪពុកខ្ញុំល្អចំពោះខ្ញុំ (“Fathers,” *Children’s Songbook*, ទំព័រ ២០៩) ។

ស្ទីវិនមានអារម្មណ៍ថាមានគេទះដៃគាត់តិចៗ ។ ម្ដាយគាត់ដែលបានមើលតាមទ្វារថ្នាក់កុមារដោយស្ងៀមស្ងាត់ បានទាញដៃគាត់ថ្នមៗ ។ នាងបាននាំគាត់ទៅផ្លូវដើរ ។ ពេលចេញឆ្ងាយពីមិត្តភក្តិរបស់គាត់ដែលនៅក្នុងថ្នាក់កុមារ ស្ទីវិនមិនអាចទប់ទឹកភ្នែកកុំឲ្យហូរបានឡើយ ។ ម្ដាយបានទាញគាត់មកឱបយ៉ាងណែន ។

ម្ដាយបាននិយាយថា « វាមិនអីទេដែលកូនមិនសប្បាយចិត្ត » ទាំងអង្អែលខ្នងគាត់ផង ។ « ម៉ាក់ដឹងថា ការឮ និង ច្រៀងបទនោះគឺពិបាកណាស់ » ។

ស្ទីវិនងក់ក្បាល បន្ទាប់មកជូតទឹកភ្នែក ។ « ខ្ញុំមិនចង់ច្រៀងនៅថ្ងៃបុណ្យឪពុកទេ ព្រោះខ្ញុំអត់មានប៉ាផង » ។ ភ្នែកស្ទីវិនឡើងក្រហម ហើយគាត់ខាំបបូរមាត់គាត់ ។ « ខ្ញុំមិនចង់ហៅគាត់ថា ប៉ាទៀតទេ ។ ខ្ញុំមិនបានឃើញគាត់ជាច្រើនឆ្នាំហើយ គាត់ក៏មិន *ចង់* ធ្វើជាប៉ារបស់ខ្ញុំដែរ » ។

ស្ទីវិនបានព្យាយាមយ៉ាងខ្លាំងដើម្បីកុំឲ្យយំ — ប៉ុន្តែ គាត់នៅតែអាចឮពួកគេកំពុងច្រៀង ។ បទចម្រៀងនោះបានធ្វើឲ្យគាត់ឈឺចាប់យ៉ាងខ្លាំងនៅក្នុងចិត្ត ។ គឺដូចជាពេលដែលឪពុកគាត់បានសរសេរសំបុត្រប្រាប់ថា គាត់ និង ភរិយាថ្មីរបស់គាត់បានសម្រេចចិត្តថាគាត់នឹងមិនជួបស្ទីវិន និង ប្អូនប្រុសរបស់ស្ទីវិនទៀតឡើយ ។

ម្ដាយបានទាញគាត់មកឱបម្ដងទៀត ហើយស្ទីវិនបានយំទៀតទាល់តែទឹកភ្នែកជោកអាវម្ដាយគាត់ ។ « ម៉ាក់នឹងនិយាយជាមួយប្រធានថ្នាក់កុមារ ។ កូនមិនបាច់ចាំច្រៀងទេ បើកូនមិនចង់ ។ ប៉ុន្តែ ម៉ាក់មានគំនិតមួយ » ។ ម្ដាយបានសំឡឹងទៅក្នុងភ្នែករបស់គាត់ ។ « ឆ្នាំនេះយើងនឹងមិនប្រារព្ធថ្ងៃបុណ្យឪពុកទេ — តែយើងនឹងប្រារព្ធថ្ងៃបុណ្យ អនាគត *ឪពុកវិញ* ! » នាងញញឹម ហើយគាត់សំឡឹងទៅវិញ ។

« ថាម៉េច ? ប្រារព្ធ *អីគេ?* »

« ថ្ងៃបុណ្យអនាគតឪពុក — យើងនឹងប្រារព្ធអបអរថា កូន និង ប្អូនប្រុសកូននឹងក្លាយជាឪពុកដ៏អស្ចារ្យនៅថ្ងៃមួយ ។ យើងនឹងមានអំណោយ ហើយនំខេក និង ភេសជ្ជៈដែលកូនចូលចិត្ត ! »

រចនារូបភាព ដោយ អាលីស្សា ធាលីទ

ម្តាយបានថើបថ្ពាសគាត់ ហើយព្យាយាមរៀបរយក្រវាត់កដៃលខ្ទេចខ្ទីរបស់គាត់ ។

« ស្ទីវិន កូននឹងក្លាយជាឪពុក *ដ៏អស្ចារ្យ* — ម៉ាក់អាចមើលដឹង ។ ព្រោះកូនកំពុងគិតរួចទៅហើយនូវអ្វីដែលកូននឹងធ្វើជាមួយកូនៗរបស់កូន ហើយដាក់ផែនការថាកូនចង់ក្លាយជាឪពុករបៀបណា » ។

ស្ទីវិនកាន់តែគិតអំពីរឿងនោះ គាត់កាន់តែមានស្នាមញញឹមកាន់តែធំ ។ គាត់បានឱបម្តាយគាត់ហើយបានចូលទៅក្នុងថ្នាក់កុមារវិញ ដោយមានអារម្មណ៍ល្អជាងមុនច្រើនណាស់ ។

ពីរសប្តាហ៍ក្រោយមក ស្ទីវិនបានឈរនៅមុខកញ្ចក់ រៀបរយបូអាវថ្មីដ៏ឡូយរបស់គាត់ ។ ម្តាយបានឲ្យវាទៅគាត់នៅព្រឹកនោះ សម្រាប់ថ្ងៃបុណ្យអនាគតឪពុកលើកដំបូងបំផុតរបស់គាត់ ! ស្ទីវិនបានយកព្រះគម្ពីររបស់គាត់ ហើយបានដើរទៅទ្វារខាងមុខដើម្បីទៅកាន់ព្រះវិហារ ។

គាត់ញញឹមដាក់ម្តាយគាត់ ។

« រីករាយថ្ងៃបុណ្យឪពុក ម៉ាក់ » ។

ម្តាយញញឹមពណ្តើយ ។ « រីករាយថ្ងៃបុណ្យអនាគតឪពុក ស្ទីវិន » ។ ■

អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ឃ្វីនស៍ឡិន ប្រទេស អូស្ត្រាលី ។



រៀបចំផែនការដោយមានគោលបំណង

« មិនថាអ្នកមានអាយុប៉ុន្មាន កាលៈទេសៈរបស់អ្នកយ៉ាងណាទេ ខ្ញុំសូមទូន្មានអ្នកឲ្យ **រៀបចំផែនការជីវិតរបស់អ្នកដោយមានគោលបំណង**» ។

ប្រធាន ថូម៉ាស អេស ម៉ុនសុន "Come, All Ye Sons of God," លីអាហូណា, ខែ ឧសភា ឆ្នាំ ២០១៣ ទំ។ ៦៧ ។

ទីបន្ទាល់ របស់ម៉ែ

ដោយ អាមេលា ហាមិន
ផ្អែកទៅលើដំណើររឿងពិត

« ព្រះវិញ្ញាណបរិសុទ្ធខ្សឹបជាសំឡេងរហៀង ។ ទ្រង់ថ្លែងពីព្រះអង្គ និង ព្រះគ្រីស្ទ ធ្វើឲ្យចិត្តយើងត្រេកអរ » (សៀវភៅចម្រៀងកុមារ *ទំព័រ ១០៥*) ។

ហួសពេលចូលគេងរបស់នាងហើយ តែម៉ែមិនទាន់ចូលគេងទៀត ។ នាងអង្គុយនៅលើតដ្ឋក្នុងបន្ទប់នាង កំពុងគិតអំពីអ្វីដែលបងស្រី ឌូវែលបានអាននៅក្នុងថ្នាក់កុមារ ៖ « ពេលវេលានឹងមកដល់ ពេលដែលគ្មានបុរស ឬ ស្ត្រីណាម្នាក់នឹងអាចឈរនៅលើពន្លឺដែលខ្ចីពីគេបានឡើយ » ។[9]

បងស្រី ឌូវែលបានពន្យល់ថា « ទីបន្ទាល់មួយគឺដូចជាពន្លឺដែលនៅខាងក្នុងខ្លួនយើង » ។ « ហើយយើងម្នាក់ៗត្រូវការពន្លឺនោះមួយសម្រាប់ខ្លួនយើងផ្ទាល់ ។ បន្ទាប់មកយើងអាចរឹងមាំពេលជីវិតជួបការលំបាក និង ពេលសាតាំងល្បួងយើង » ។

ម៉ែឱនក្បាលនាងទៅនឹងត្រែ ។ នាងបានគិតថា « ខ្ញុំចង់បានទីបន្ទាល់មួយដែលថា ដំណឹងល្អគឺពិត » ។ ប៉ុន្តែ តើអ្នកអាច *ទទួល* បានទីបន្ទាល់មួយដោយរបៀបណាឲ្យប្រាកដទៅ ? នាងបានដឹងថា ការអធិស្ឋានគឺជាផ្នែកមួយ ។

នាងសម្រេចថា « ខ្ញុំនឹងអធិស្ឋាន » ។ នាងអធិស្ឋាន ហើយមិនឈប់ឡើយ រហូតទាល់តែមានអ្វីមួយបានកើតឡើងដែលនឹងធ្វើឲ្យនាងដឹងថាសាសនាចក្រគឺពិត ។ នាងបានត្រៀមខ្លួនរួចជាស្រេចហើយដើម្បីអធិស្ឋានអស់ពេញមួយយប់ ប្រសិនបើនាងត្រូវតែធ្វើដូចនោះ ។

នាងបានលុតជង្គង់ចុះ ។ នាងអធិស្ឋានខ្សឹបៗថា « ព្រះវរបិតាសួគ៌ជាទីស្រឡាញ់អើយ កូនចង់ដឹងថាបើសាសនាចក្រពិតឬទេ ។ កូនចង់ដឹងនៅក្នុងចិត្តកូន » ។

ម៉ែបានរង់ចាំ ។ នាងពុំបានទទួលអារម្មណ៍អ្វីឡើយ លើកលែងតែអារម្មណ៍ទន់ភ្លន់ដែលនាងតែងតែទទួលពេលនាងអធិស្ឋាន ។ តើនាងបានធ្វើអ្វីខុសទៅ ? តើទីបន្ទាល់របស់នាងនៅឯណា ?

នាងបានលុតជង្គង់យ៉ាងយូរ ពេលដែលទ្វារបន្ទប់នាងរបើកបន្តិច ហើយឪពុកនាងបានចូលទៅ ។

គាត់បាននិយាយថា « ប៉ាបានឃើញពន្លឺតាមក្រោមទ្វារ » ។ « តើកូននៅមិនទាន់គេងដើម្បីអានសៀវភៅទៀតហើយមែនទេ ? » បន្ទាប់មកគាត់បានឃើញទឹកភ្នែកលើផ្ការ៉ាល់របស់ម៉ែ ។ គាត់បានលុតជង្គង់ចុះ ហើយឱបនាង ។ « មានរឿងអីកូន ? »

នាងស្ងៀមស្ងាត់មួយស្របក់ ។ បន្ទាប់មកនាងបានសួរថា « ប៉ា តើប៉ាបានទទួលទីបន្ទាល់មួយដោយរបៀបណាទៅ ? »

ឪពុកបានឱបនាងយ៉ាងណែន ។ « វាជាសំណួរដ៏ល្អមួយ ។ *ការចង់បាន* ទីបន្ទាល់មួយគឺជាជំហានទីមួយ » ។

ការអួលដើមករបស់ម៉ែ ហាក់ដូចជាបាត់ទៅវិញ ។

« ការទទួលបានទីបន្ទាល់មួយពុំតែងតែកើតឡើងជាមួយនឹងការអធិស្ឋានម្តងនោះទេ ។ ហើយសូម្បីតែនៅពេលកូនមានទីបន្ទាល់មួយហើយក្តី ក៏កូនត្រូវការបន្តពង្រឹងវាផងដែរ » ។

« ប៉ុន្តែ តើទីបន្ទាល់បានមកពីណាទៅ ? » ម៉ែបានសួរ ។

ឪពុកបាននិយាយថា « ទីបន្ទាល់មួយបានមកពីព្រះវិញ្ញាណបរិសុទ្ធ » ។ « តើកូនធ្លាប់មានអារម្មណ៍កក់ក្តៅ និង ល្អក្នុងអំឡុងពេលរាត្រីជួបជុំគ្រួសារ ឬ នៅព្រះវិហារទេ ? »

ម៉ែបានគិត ។ « ពេលប៉ាបានផ្តល់ពរជ័យពិសេសដល់កូន មុនពេលសាលាបើកបវេសនកាល កូនមានអារម្មណ៍ល្អ » ។ នាងបានគិតបន្ថែមទៀត ។ « ហើយកូនតែងតែមានអារម្មណ៍កក់ក្តៅនៅខាងក្នុង ពេលកូនឮប្រធានម៉ាសុន មានប្រសាសន៍នៅក្នុងសន្និសីទទូទៅ ។ ហើយពេលកូនធ្វើល្អចំពោះមិត្តភក្តិកូន ឬ ពេលកូនអានព្រះគម្ពីររបស់កូន កូនមានអារម្មណ៍ល្អនៅពេលនោះផងដែរ » ។

ឪពុកញញឹម ។ « អារម្មណ៍ទាំងនោះគឺជាព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលទៅកាន់កូន ។ ទ្រង់ប្រទានអារម្មណ៍ទាំងនោះដល់កូន ពេលកូនធ្វើអ្វីដែលត្រឹមត្រូវ ឬ ពេលកូនឮអ្វីដែលពិត » ។

ម៉ែបាននិយាយថា « ឥឡូវនេះកូនមានអារម្មណ៍កក់ក្តៅ និង សប្បាយចិត្ត » ។ « តើនេះគឺជាព្រះវិញ្ញាណបរិសុទ្ធមែនទេ ? »

ឪពុកបានឱបនាងម្តងទៀត ។ « បាទ ។ ទ្រង់កំពុងតែប្រាប់កូនថា អ្វីៗដែលយើងកំពុងតែនិយាយគឺពិត ។ ហើយ *នោះគឺជា* របៀបដែលកូនទទួលនូវទីបន្ទាល់មួយ » ។

ពេលម៉ែចូលគេងក្រោយពីនោះ នាងមិនបានគិតថា នាងមានទីបន្ទាល់ពេញលេញនៅឡើយទេ ប៉ុន្តែនាងបានមានអារម្មណ៍ដ៏ល្អ ដ៏កក់ក្តៅនោះ ដែលឪពុកនាងបានប្រាប់នាងថាពិត ។ នាងបានដឹងថា អារម្មណ៍គឺគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ ។

ម៉ែចូលទៅក្នុងភួយដ៏កក់ក្តៅរបស់នាង ហើយបិទភ្នែក ។ មុនពេលដែលនាងហៀបនឹងគេងលក់ នាងបានខ្សឹបថា « អរព្រះគុណព្រះវរបិតាសួគ៌ ដែលបានជួយកូនឲ្យមានទីបន្ទាល់មួយ ។ ហើយសូមអរព្រះគុណទ្រង់សម្រាប់ប៉ារបស់កូន » ។ ■

អ្នកនិពន្ធរស់នៅក្នុងរដ្ឋ មិសសួរី ស.រ.អា ។

កំណត់ចំណាំ

9. Orson F. Whitney, *Life of Heber C. Kimball* (ឆ្នាំ ១៩៦៧) ទំព័រ ៤៥០ ។

គេហដ្ឋានដែលដង្វាយមួយភាគក្នុងដប់ត្រូវបានស្ថាបនាឡើង

ដោយ ចានែល វិលាម

នេះគឺចាកឃ័ ។ ទាំងនេះគឺជាប្រាក់កាក់របស់ចាកឃ័ ដែលលាន់ឮសូរក្រឹងៗ ។ នេះគឺជាដង្វាយមួយភាគក្នុងដប់របស់ចាកឃ័ គឺ ១០ ភាគរយ ។

នេះគឺជាប៊ីស្សពដែលចាប់រលាក់ដៃរបស់ចាកឃ័ ពេលគាត់បានបង់ដង្វាយមួយភាគក្នុងដប់ គឺ ១០ ភាគរយរបស់គាត ។

នេះគឺជាព្យាការី ដែលពេញដោយការរីករាយ និង ដោយការអធិស្ឋាន ដែលបានមានប្រសាសន៍ថា « តោះយើងនាំគ្នាកសាងព្រះវិហារបរិសុទ្ធ » ជាមួយនឹងដង្វាយមួយភាគក្នុងដប់ដែលបានផ្ញើទៅពីប៊ីស្សព ដែលបានចាប់រលាក់ដៃរបស់ចាកឃ៍ ពេលគាត់បង់ដង្វាយមួយភាគក្នុងដប់ គឺ ១០ ភាគរយរបស់គាត់ ។

នេះគឺជាព្រះវិហារបរិសុទ្ធ ថែងចាំង និង ស ជាដំណាក់នៃព្រះអម្ចាស់ ដែលពេញដោយពន្លឺ ។

នេះគឺជាដំណាក់ដែលដង្វាយមួយភាគក្នុងដប់បានកសាង ព្រោះព្យាការីបានមានប្រសាសន៍ថា « តោះយើងនាំគ្នាកសាងព្រះវិហារបរិសុទ្ធ » ជាមួយនឹងដង្វាយមួយភាគក្នុងដប់ដែលបានផ្ញើទៅពីប៊ីស្សពដែលបានចាប់រលាក់ដៃរបស់ចាកឃ៍ ពេលគាត់បង់ដង្វាយមួយភាគក្នុងដប់ គឺ ១០ ភាគរយរបស់គាត់ ។

នេះគឺជាស្នាមញញឹមរបស់ចាកយ៍ ញញឹមយ៉ាងធំ និង ស្រស់ស្រាយ
ពេលគាត់ទៅព្រះវិហារបរិសុទ្ធ ដែលចែងចាំង និង ស ដើម្បីផ្សារភ្ជាប់
នឹងក្រុមគ្រួសាររបស់គាត់នៅក្នុងព្រះនេត្រនៃព្រះ ។ ■

អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។

តើដង្វាយមួយភាគក្នុងដប់របស់ចាកយ៍នៅឯណាខ្លះ ?

សូមជួយចាកយ៍ ស្វែងរកប្រាក់កាក់ដង្វាយមួយភាគក្នុងដប់ទាំងប្រាំបីរបស់គាត់ដែលឮសូរក្រឹងៗ !

លុះត្រាជួបទៀត

ដោយ ប្រធាន ប៊ យដ៏ កេ ផាកកឺ
ប្រធានកូរ៉ុម នៃពួកសាវកដប់ពីរនាក់

ទុកវាចោលមួយឡែកទៅ

ពិភពរបស់មិត្តខ្ញុំត្រូវខ្ទេចខ្ទាំអស់ ។ គាត់បានបាត់បង់ភរិយាគាត់ ។

បើសិនអ្នករងទុក្ខមកពីការព្រួយ ពីទុក្ខវេទនា ឬ ភាពខ្មាស់អៀន ឬ ការច្រណែន ឬ ការខកចិត្ត ឬ ការឃ្នានីស ពីការបន្ទោសខ្លួនឯង ឬ ការដោះសាខ្លួនឯង នោះសូមពិចារណាពីមេរៀននេះ ដែលបានបង្រៀនដល់ខ្ញុំជាច្រើនឆ្នាំកន្លងមកហើយ ដោយលោកអយ្យកោម្នាក់ ។ គាត់ជាបុរសដ៏បរិសុទ្ធខ្លាំងណាស់ ។ . . .

គាត់បានធំឡើងក្នុងសហគមន៍តូចមួយ ដោយមានបំណងប្រាថ្នាធ្វើអ្វីៗដោយខ្លួនឯង ។ គាត់មានការលំបាកក្នុងការទទួលបានការអប់រំមួយ ។

គាត់បានរៀបការនឹងស្ត្រីជាទីស្រឡាញ់របស់គាត់ ហើយអ្វីៗគឺល្អ ។ គាត់មានការងារល្អ ជាមួយនឹងអនាគតដ៏ភ្លឺស្វាង ។ ពួកគាត់ស្រឡាញ់គ្នាខ្លាំងណាស់ ហើយនាងកំពុងមានផ្ទៃពោះកូនដំបូងរបស់ពួកគាត់ ។

នៅយប់ដែលកូននោះត្រូវកើត នោះមានភាពស្មុគស្មាញច្រើនក្នុងការសម្រាលកូន ។ មានគ្រូពេទ្យតែម្នាក់គត់កំពុងនៅកន្លែងណាមួយនៅឯជាយក្រុង កំពុងថែទាំអ្នកជំងឺ ។ . . .

នៅទីបំផុត គេរកលោកគ្រូពេទ្យឃើញ ។ ដោយស្ថិតក្នុងភាពអាសន្ន នោះគាត់បានចាត់ចែងយ៉ាងឆាប់រហ័ស ហើយមិនយូរប៉ុន្មានអ្វីៗដ៏បានរៀបរយ ។ ទារកបានកើតមក ហើយភាពស្មុគស្មាញក្នុងការសម្រាលដែលមាននោះក៏បាត់ទៅ ។

ប៉ុន្មានថ្ងៃក្រោយមក ម្ដាយវ័យក្មេងនោះក៏បានស្លាប់ដោយសារឆ្លងរោគពីអ្នកជំងឺនៅផ្ទះផ្សេងទៀតដែលគ្រូពេទ្យបានព្យាបាលក្នុងយប់តែមួយនោះ ។

ពិភពរបស់ចនត្រូវខ្ទេចខ្ទាំអស់ ។ អ្វីៗមិនត្រឹមត្រូវទេនៅពេលនោះ អ្វីៗទាំងអស់គឺខុស ។ គាត់បានបាត់បង់ភរិយាគាត់ ។ គាត់ពុំមានរបៀបណាសោះដើម្បីថែទាំទាំងកូន និង ការងាររបស់គាត់ ។

ពេលវេលាចេះតែកន្លងទៅ ទុក្ខព្រួយរបស់គាត់កាន់តែធំឡើងៗ ។ គាត់និយាយថា « គ្រូពេទ្យនោះមិនសមនឹងត្រូវបានអនុញ្ញាតឲ្យព្យាបាលគេទេ » ។ « គាត់បាននាំមេរោគនោះមកដល់ភរិយាខ្ញុំ ។ បើគាត់បានប្រុងប្រយ័ត្ន នោះនាងនឹងនៅរស់ » ។

គាត់ស្ទើរតែមិនបានគិតពីអ្វីផ្សេងទៀតសោះ ហើយនៅក្នុងភាពល្វីងជូរចត់របស់គាត់ គាត់បានក្លាយជាមនុស្សគួរឲ្យខ្លាច ។ . . .

ថ្ងៃមួយមានគេគោះទ្វារគាត់ ។ ក្មេងស្រីតូចមួយបាននិយាយយ៉ាងសាមញ្ញថា « ប៉ាចង់ឲ្យលោកមកជួប ។ គាត់ចង់និយាយជាមួយលោក » ។

« ប៉ា » គឺជាប្រធានស្តេក ។ . . .

អ្នកគង្វាលខាងវិញ្ញាណនេះបានមើលថែហ្វូងចៀមរបស់គាត់ ហើយមានរឿងត្រូវនិយាយជាមួយចន ។

ដំបូន្មានមកពីអ្នកបម្រើដ៏ឆ្លាតវៃនោះ គឺសាមញ្ញ « ចន ទុកវាចោលមួយឡែកទៅ ។ គ្មានអ្វីដែលអ្នកធ្វើអាចនាំនាងឲ្យត្រឡប់មកវិញនោះទេ ។ អ្វីដែលអ្នកធ្វើគឺមានតែធ្វើឲ្យវាកាន់តែយ៉ាប់យ៉ឺនឡើងៗប៉ុណ្ណោះ ។ ចន ទុកវាចោលមួយឡែកទៅ » ។ . . .

គាត់មានការលំបាកក្នុងទុក្ខព្រួយ ដែលធ្វើឲ្យគាត់ពិបាកនឹងគ្រប់គ្រងអារម្មណ៍ខ្លួនឯង ។ ហើយនៅទីបំផុត គាត់បានប្ដេជ្ញាចិត្តថា មិនថាមានបញ្ហាអ្វីផ្សេងទៀតឡើយ គាត់គប្បីគោរពប្រតិបត្តិ ។

ការគោរពប្រតិបត្តិគឺជាឱសថខាងវិញ្ញាណដ៏មានអំណាច ។ វាស្ទើរតែជាថ្នាំដែលព្យាបាលគ្រប់ជំងឺទាំងអស់ ។

គាត់បានប្ដេជ្ញាចិត្តធ្វើតាមដំបូន្មានរបស់អ្នកដឹកនាំខាងវិញ្ញាណដ៏ឆ្លាតវៃនោះ ។ គាត់នឹងទុកវាចោលមួយឡែក ។

បន្ទាប់មកគាត់បានប្រាប់ខ្ញុំថា « . . . ទាល់តែខ្ញុំចាស់ ទើបខ្ញុំអាចបានជួបគ្រូពេទ្យស្រុកស្រែដ៏កំសត់នោះ—ធ្វើការហួសកម្រិត បានកម្រៃទាប រត់ទៅរត់មកទាំងអស់កម្លាំងពីអ្នកជំងឺម្នាក់ទៅអ្នកជំងឺម្នាក់ទៀត ដោយមានថ្នាំតែបន្តិចបន្តួច ពុំមានមន្ទីរពេទ្យមានឧបករណ៍តែបន្តិចបន្តួច ពុះពារសង្គ្រោះជីវិតទាំងឡាយ ហើយបានជោគជ័យភាគច្រើនបំផុត ។

« គាត់បានជួបនឹងគ្រាវិបត្តិមួយ ពេលមានជីវិតពីរកំពុងស្ថិតក្នុងគ្រោះថ្នាក់ដូចគ្នា ហើយបានចាត់ចែងធ្វើការភ្លាមៗមិនបង្អង់ ។

គាត់បាននិយាយដដែលៗថា « ខ្ញុំចាស់ហើយខ្ញុំទើបតែយល់ នៅទីបំផុត ! ខ្ញុំអាចនឹងបំផ្លាញជីវិតខ្ញុំ និង ជីវិតអ្នកផ្សេងៗទៀត » ។

គាត់បានលុតជង្គង់អរព្រះគុណដល់ព្រះអម្ចាស់ជាច្រើនដង ចំពោះអ្នកដឹកនាំខាងវិញ្ញាណដ៏ឆ្លាតវៃម្នាក់ ដែលបានផ្ដល់ដំបូន្មានយ៉ាងសាមញ្ញដល់គាត់ថា « ចន ទុកវាចោលមួយឡែកទៅ » ។ ■

ដកស្រង់ចេញពី “Balm of Gilead,” *Ensign*, *ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ ទំព័រ ១៧–១៨ ។*

ការយល់ដឹងជ្រៅជ្រះ

តើអាកប្បកិរិយាអ្វីទៅ ដែលសំខាន់នៅក្នុងជីវិត ?

«ជីវិតនេះគឺជាពេលវេលា សម្រាប់ឲ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ។ យើងគឺជាមនុស្សសប្បាយរីករាយ យើងពេញចិត្តការចេះលេងសើចសប្បាយជាមួយគ្នា ហើយឲ្យតម្លៃ ពេលវេលាដែលមិនបានព្រៀងទុកជាមួយមិត្តភក្តិ និងក្រុមគ្រួសារ។ ប៉ុន្តែយើងចាំបាច់ត្រូវទទួលស្គាល់ថា មានភាពប្រាកដប្រជា នៃគោលបំណងដែលត្រូវពង្រឹងវិធីសាស្ត្ររបស់យើង ចំពោះជីវិត និងជម្រើសទាំងអស់របស់យើង។

អែលឌើរ ឃ្វីនធិន អិល ឃុក នៃក្រុមនៃពួកសាវកដប់ពីរនាក់ « ជ្រើសរើស ដោយឆ្លាតវៃ » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៤៩។

មាននៅក្នុងច្បាប់នេះផងដែរ

សម្រាប់យុវមជ្ឈិមវ័យ

ការទុកចិត្តលើ ការអះអាងទាំងឡាយ របស់ព្រះអម្ចាស់

យើងមិនតែងតែត្រូវបានដោះលែងចេញពីការសាកល្បងរបស់យើងនោះឡើយ ប៉ុន្តែយើងអាចទទួលការអះអាងជានិច្ចថា ព្រះអម្ចាស់ទ្រង់គ្រាស់ដឹង ហើយមានព្រះទ័យជួយយើងឲ្យឆ្លងកាត់ការសាកល្បងទាំងនោះ ។



ទំព័រ ៤២

សម្រាប់យុវវ័យ

ទំព័រ ៥០

ប៉ុន្តែ ចុះបើ . . . ?

សំណួរអំពីការបម្រើបេសកកម្ម

ព្រួយបារម្ភថា អ្នកមិនដឹងល្មមគ្រប់គ្រាន់អំពីដំណឹងល្អឬ ? ថាទីបន្ទាល់របស់អ្នកមិនរឹងមាំគ្រប់គ្រាន់ឬ ? ថាអ្នកអៀនពេកឬ ? សូមស្វែងរកចម្លើយចំពោះសំណួរ និង កង្វល់ធម្មតា។ពីមុនបេសកកម្មនៅទីនេះ ។

សម្រាប់កុមារ

ទីបន្ទាល់របស់ម៉ែ

ម៉ែចង់មានទីបន្ទាល់ផ្ទាល់ខ្លួនអំពីដំណឹងល្អ ។ សូមរកមើលថានាងបានធ្វើដូចម្តេច !

ទំព័រ ៧៤

4 02125 66258 1
CAMBODIAN

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ